ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត




លេខ៤៧ ខែវិច្ឆិកា ឆ្នាំ២០០៣

ស្វែងរកការពិត

ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ៤៧ ខែវិច្ឆិកា ឆ្នាំ២០០៣

## មាតិកា

◆ សំបុត្រៈ ជួយប្រជាជនអ៊ីរ៉ាក់ឲ្យទទួលបានយុត្តិធម៌និងការចងចាំ.... ១

**ផ្នែកឯកសារ**

◆ ចម្លើយសារភាពរបស់ ផេង ស៊ិន់ ហៅ ជ័យ........................ ២

◆ របាយការណ៍ស្តីអំពីកិច្ចប្រជុំការងារ.................................... ៥

◆ ជីវទស្សន៍បដិវត្តន៍របស់សមមិត្ត ប៉ុន.................................... ៧

◆ បញ្ជីឈ្មោះជនរងគ្រោះនៅមន្ទីរ ស-២១.......................... ១២

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ ករណី ឡាយ ក្លឹង ហៅ ដុស........................................ ១៤

◆ ទីបញ្ចប់ខ្ញុំនៅក្នុងគុកព្រៃស............................................. ១៨

◆ ព្រះពុទ្ធសាសនាមិនសាបសូន្យ........................................ ២០

◆ បរាជ័យដោយការធ្វេសប្រហែស..................................... ២២

**ផ្នែកច្បាប់**

◆ សន្តិភាពនិងច្បាប់សង្គ្រាម............................................... ៣៧

**វេទិកាពិភាក្សាសាធារណៈ**

◆ តុលាការប្រជាជននៅប្រទេសរ៉្វាន់ដា.................................. ៥៣

**ទំព័រស្វែងរកគ្រួសារ**

◆ ខ្ញុំមិនចង់ជួប.............................................................. ៥៨





**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងពត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងពត៌មាន
លេខ ០២៩១ពម/៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និង សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នេរលេខនេះ:** យិន នាន, ព្រំ ផល្លា, លី សុខឃាង, ស៊ឹម សុរិយ៉ា, អៀ ម៉េងទ្រី, សូ ហ្វារីណា, ស៊ុន រ៉ាពីដ, ហ្សូរាល់ កាការីយ៉ា, ខូម ខែមប៊ែល
**អ្នកនិពន្ធនិងស្រាវជ្រាវៈ** លី សុផល, ផាត រចនា **ជំនួយការនិពន្ធនាយកៈ** សាន់ កល្យាណ **និពន្ធនាយករងៈ** សួ ប៊ុនស៊ូ **អ្នកបកប្រែៈ** អេង កុកថាយ
**និពន្ធនាយកទូទៅៈ** ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រៈ** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយៈ** មាស ប៊ុនថាន

**សំបុត្រៈ**

# ជួយប្រជាជនអ៊ីរ៉ាក់ឱ្យទទួលបានយុត្តិធម៌និងការចងចាំដូចប្រជាជនកម្ពុជា

នៅថ្ងៃទី៣០ ខែតុលា ខ្ញុំបានធ្វើដំណើរទៅកាន់ប្រទេសអ៊ីរ៉ាក់ ដើម្បីផ្តល់ការពិគ្រោះយោបល់អំពីការប្រមូលឯកសារនិងវត្ថុតាង ផ្សេងៗដែលនឹងមានសារប្រយោជន៍សម្រាប់ការដាក់ឲ្យមានការ ទទួលខុសត្រូវចំពោះបទឧក្រិដ្ឋប្រព្រឹត្តឡើងដោយរបប បាប់ទីស ដែលទើបតែត្រូវទម្លាក់ចេញពីតំណែង ។ ខ្ញុំមានអារម្មណ៍រំភើប រីករាយខ្លាំងណាស់ក្នុងនាមពលរដ្ឋមួយរូបមកពីប្រទេសដ៏តូចមួយ ដូចជាប្រទេសកម្ពុជាត្រូវបានអញ្ជើញមកជួបទពិសោធន៍បែប នេះ ។ ខ្ញុំបានអនុវត្តការងារចងក្រងឯកសារជាយូរមកហើយ គឺតាំង ពីឆ្នាំ១៩៩៥ ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាត្រូវបានបង្កើត ឡើងនៅក្នុងទីក្រុងភ្នំពេញ ។ កិច្ចខំប្រឹងប្រែងរបស់មជ្ឈមណ្ឌល ឯកសារកម្ពុជាដើម្បីស្វែងរកការពិតនៅក្នុងសម័យខ្មែរក្រហមនិង ការងារដ៏សែនពិបាករបស់យើងក្នុងការប្រមូលឯកសារនិងវត្ថុតាង ផ្សេងៗទទួលបានការចាប់អារម្មណ៍ពីមជ្ឈដ្ឋានអន្តរជាតិ ។ ការទទួល ស្គាល់នេះមានសារសំខាន់ណាស់ចំពោះយើងដែលជាពលរដ្ឋកម្ពុជា ហើយវាក៏មានសារប្រយោជន៍ដែរចំពោះមនុស្សជុំវិញពិភពលោក ដែលកំពុងធ្វើការដើម្បីធានាថាជនដែលទទួលខុសត្រូវចំពោះបទ ឧក្រិដ្ឋដ៏ឃោរឃៅត្រូវបាននាំយកទៅកាត់ទោស ។

នៅទីក្រុងបាដាត ខ្ញុំបានចំណាយពេលពេញមួយសប្តាហ៍ដើម្បី ផ្តល់យោបល់ទៅឲ្យឥស្សរជនជួរការនៃអាជ្ញាធរសម្ព័ន្ធមិត្តបណ្តោះ អាសន្ន តំណាងនៃក្រុមប្រឹក្សាគ្រប់គ្រងប្រទេសអ៊ីរ៉ាក់ អង្គការ ក្រៅរដ្ឋាភិបាល និងគណបក្សនយោបាយ ។ គោលដៅចម្បងរបស់ ខ្ញុំនៅទីនោះគឺស្វែងរកអង្គការក្រៅរដ្ឋាភិបាលនិងបុគ្គលមួយចំនួន ដែលកំពុងកាន់កាប់ឯកសារដែលអាចមានសារប្រយោជន៍ប្រើប្រាស់ ជាភស្តុតាងនៅក្នុងតុលាការពិសេសដែលគ្រោងនឹងបង្កើតសម្រាប់ ប្រទេសអ៊ីរ៉ាក់នៅក្នុងឆ្នាំ២០០៤ ។ ខ្ញុំបានសហការជាមួយអង្គការ ក្រៅរដ្ឋាភិបាលផ្សេងៗក្នុងប្រទេសអ៊ីរ៉ាក់ និងមេដឹកនាំគណបក្ស នយោបាយជាច្រើនរូប ដើម្បីស្វែងរកប្រភពនៃឯកសារទាក់ទិននឹង បទឧក្រិដ្ឋ ។ មានអង្គការក្រៅរដ្ឋាភិបាលមួយចំនួនតូចប៉ុណ្ណោះកំពុង ដំណើរការនៅក្នុងប្រទេសអ៊ីរ៉ាក់នាពេលបច្ចុប្បន្នដែលមានជំនាញ ក្នុងការប្រមូលនិងចងក្រងឯកសារទាក់ទងទៅនឹងការរំលោភសិទ្ធិ មនុស្សដ៏ធ្ងន់ធ្ងរ ។

ការបង្កើតប្រព័ន្ធចងក្រងឯកសារដ៏មានប្រសិទ្ធភាពនិង តម្លាភាពមួយ នឹងមានសារប្រយោជន៍ជាច្រើនយ៉ាងសម្រាប់សង្គម អ៊ីរ៉ាក់ៈ (ទីមួយ) ការចងក្រងឯកសារនឹងជាជំនួយដល់អាជ្ញាធរនៅ ក្នុងដំណើរការតុលាការពិសេសដែលបានគ្រោងទុកសម្រាប់ឆ្នាំ ២០០៤ខាងមុខនេះ និងក្នុងការធ្វើឲ្យមានការកាត់សេចក្តីដែល គោរពតាមបទដ្ឋានច្បាប់អន្តរជាតិ ។ (ទីពីរ) ការចងក្រងឯកសារនឹង ជំរុញឲ្យប្រជាជនអ៊ីរ៉ាក់ដែលជាជនរងគ្រោះចេញមុខតវ៉ារកយុត្តិធម៌ និងរួមចំណែកក្នុងដំណើរពិភាក្សាបែបប្រជាធិបតេយ្យថ្មី ។ (ទីបី) ការចងក្រងឯកសារដ៏ត្រឹមត្រូវនឹងក្លាយជាមូលដ្ឋានសម្រាប់សំណេរ ប្រវត្តិសាស្ត្រដ៏ក្បោះក្បាយនិងទូលំទូលាយ ។ ដូចដែលយើងបាន ឃើញនៅក្នុងប្រទេសកម្ពុជា សង្គមមួយដែលបានឆ្លងកាត់សង្គ្រាម រ៉ាំរ៉ៃមិនអាចគេចផុតពីស្រមោលនៃអតីតកាលរបស់ខ្លួនបានទេ លុះត្រាតែសង្គមនោះយល់ឲ្យបានច្បាស់អំពីមូលហេតុដែលបង្កឲ្យ មានភាពអន្ធកាល ។ តាមរយៈបទពិសោធន៍ការងារនៅក្នុងប្រទេស កម្ពុជា ខ្ញុំយល់ថា ការងារស្វែងរកការពិតនិងការទទួលខុសត្រូវអាច ក្លាយទៅជាបេសកកម្មស្នូលនៃការអភិវឌ្ឍន៍សង្គមស៊ីវិលនៃប្រទេស អ៊ីរ៉ាក់ ។

ខ្ញុំមានជំនឿយ៉ាងមុតមាំថា ប្រទេសអ៊ីរ៉ាក់មានធនធានមនុស្ស គ្រប់គ្រាន់ក្នុងការអនុវត្តន៍ដំណើរការចងក្រងឯកសារប្រកបដោយ ជោគជ័យ ទោះជាមានឧបសគ្គជាច្រើនក៏ដោយ ។ ខ្ញុំសង្ឃឹមថា បទ ពិសោធន៍របស់យើងនៅក្នុងប្រទេសកម្ពុជា រួមទាំងជោគជ័យនិង បរាជ័យផងនោះអាចផ្តល់ជាជំនួយមូលដ្ឋានសម្រាប់ជំរុញឲ្យប្រជាជន អ៊ីរ៉ាក់ចាប់ផ្តើមដំណើរការចងក្រងឯកសារដោយប្រសិទ្ធភាព ។ ខ្ញុំ រង់ចាំជួយប្រជាជនអ៊ីរ៉ាក់ជានិច្ច ដើម្បីសម្រេចឲ្យបាននូវយុត្តិធម៌ និងការចងចាំ ដូចដែលខ្ញុំបាននិងកំពុងជួយប្រជាជនកម្ពុជាដែរ ។

យើងត្រូវចងចាំថា ២៤ឆ្នាំក្រោយការដួលរលំនៃរបបកម្ពុជា ប្រជាធិបតេយ្យ កម្ពុជាពុំទាន់សម្រេចបាននូវការបង្កើតតុលាការដ៏ គួរឲ្យទុកចិត្តមួយដើម្បីកាត់ទោសអតីតមេដឹកនាំខ្មែរក្រហមនៅ ឡើយទេ ។ នៅពេលដែលយើងជួបទពិសោធន៍របស់យើងទៅឲ្យ ប្រទេសដទៃ យើងត្រូវសួរខ្លួនឯងថា ហេតុអ្វីបានជាតុលាការខ្មែរ ក្រហមមិនទាន់ត្រូវបានបង្កើត ហើយយើងត្រូវបន្តជំរុញឲ្យមេដឹកនាំ កម្ពុជាបង្កើតតុលាការនេះដោយមិនពន្យារពេលបន្តទៀត ។ ការ បង្កើតតុលាការខ្មែរក្រហមគួរតែជាអាទិភាពរបស់គណបក្ស នយោបាយទាំងបីដែលកំពុងតែពិភាក្សាអំពីការបង្កើតរដ្ឋាភិបាលថ្មី សម្រាប់កម្ពុជា ។

**ឆាំង យុ**

*(អត្ថបទសង្ខេបចេញពីចម្លើយសារភាព)*

# ចម្លើយសារភាពរបស់ ផេង ស៊ីន ហៅ ជ័យ

ផេង ស៊ីន មានឈ្មោះបដិវត្តន៍ ជ័យ ជាអតីតប្រធានពាណិជ្ជកម្មភូមិភាគកណ្តាលនៃកម្ពុជាប្រជាធិបតេយ្យ ។ ជ័យ ត្រូវអង្គការចាប់ខ្លួននៅថ្ងៃទី៣ ខែតុលា ឆ្នាំ១៩៧៧ ពីបទរួមគំនិតធ្វើវិទ្ធង្សនាប្រឆាំងនឹងបដិវត្តន៍ ។ បន្ទាប់ពីត្រូវឃុំឃាំង និងសួរចម្លើយនៅមន្ទីរ ស-២១ អស់រយៈពេល៥ខែ ជ័យ ត្រូវអង្គការកម្ទេចនៅថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៧៧ ក្នុងអាយុ ២៦ឆ្នាំ ។

ជ័យ មានស្រុកកំណើតនៅភូមិបឹងស្នាយ សង្កាត់សំបូរមាស ស្រុកកំពង់សៀម ខេត្តកំពង់ចាម ។ ជ័យ ជាកូនច្បងក្នុងចំណោមបងប្អូន៩នាក់ ឪពុកឈ្មោះ ផេង សេង ម្តាយឈ្មោះ ញ៉ែប អ៊ិន ។

កាលពីអាយុ៧ឆ្នាំ ជ័យ ចូលរៀននៅសាលាទួលថ្ម ក្រុងកំពង់ចាម ។ ឆ្នាំ១៩៦៨ ជ័យ ប្រឡងចូលរៀនថ្នាក់ទី៦នៅវិទ្យាល័យក្រុងកំពង់ចាម បានពីរឆ្នាំគឺឆ្នាំ១៩៧០ក៏ឈប់រៀន ។ កាលរៀននៅវិទ្យាល័យកំពង់ចាម ជ័យ បានស្គាល់ឈ្មោះ លាន និង សួន និស្សិតសាលាបច្ចេកទេសកំពង់ចាម ដែលមកស្នាក់នៅក្នុងភូមិរបស់ ជ័យ ជាយូរមកហើយ ។ អ្នកទាំងបីតែងតែដើរទៅរៀនជាមួយគ្នា ។ មុនដំបូង លាន និង សួន អប់រំ ជ័យ អំពីបដិវត្តន៍ បន្ទាប់មកក៏យកសៀវភៅរូបភាពរបស់អាមេរិកាំងស្តីអំពីសង្គមសេរីមកឲ្យ ជ័យ មើល និងបានអប់រំ ជ័យ អំពីភាពខុសគ្នារវាងរបបសេរីនិងរបបកុម្មុយនិស្ត ។ ការអប់រំនេះបានប្រព្រឹត្តទៅជារឿយៗរហូតដល់ខែ១២ ឆ្នាំ១៩៦៨ លាន និង សួន បាននាំ ជ័យ ចូលសេអ៊ីអាដោយមានឈ្មោះ ម៉ៅ សារឿន សាស្ត្រាចារ្យនៅវិទ្យាល័យកំពង់ចាម ជាអ្នកទទួលស្គាល់ ។ ក្នុងពិធីនោះក៏មានបញ្ចូលមនុស្សបីនាក់ជាសមាជិក សេ.អ៊ី.អា ដែរគឺ ជ័យ, ទា ហាក់ម៉េង និង អ៊ឹង ម៉េង ។ បន្ទាប់ពីក្លាយជាសមាជិកសេអ៊ីអា ជ័យ បានទទួលការចាត់តាំងឲ្យធ្វើជាប្រធានយុវជនក្នុងថ្នាក់ ដើម្បីងាយស្រួលឃោសនានិងកសាងកម្លាំង សេ.អ៊ី.អា ។ ជ័យ រួមជាមួយឈ្មោះ អេង ម៉េងលី និង ហាក់ យូស្រេង ដែលជាសិស្សរួមថ្នាក់ បានដឹកនាំបាតុកម្មប្រឆាំងខ្មែរក្រហមនៅមុខសាលាខេត្តកំពង់ចាម ។ ក្រោយពីនេះបានប្រមូលគ្រាក់ដែលបាចដោយក្រុមចម្រើនយកមកដុតចោល និងបានរាយការណ៍ឲ្យ លាន និង សួន ទៅប្តឹងប៉ូលិសឲ្យមកចាប់អ្នកធ្វើសកម្មភាពបាចគ្រាក់យកទៅដាក់គុកទៀត ។

មុនរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ លាន និង សួន បានចេញទៅធ្វើការនៅកំពង់សៀម ហើយបានផ្តាំផ្ញើឲ្យ ជ័យ ទៅជួបឈ្មោះ តាប៉ាល់ ប្រធានភូមិអណ្តូងពោធិ ដើម្បីឲ្យ តាប៉ាល់ ជូនទៅជួប សួស លេខាឃុំទ្រាន ។ ជ័យ និងកម្លាំងដែលខ្លួនកសាងបានពីរនាក់គឺឈ្មោះ ខា និង អុល ត្រូវបាន សួស ចាត់តាំងឲ្យបំផុសប្រជាជននៅភូមិប្រទៀង ភូមិទ្រាន និងភូមិត្រពាំងអំពិល រត់ទៅតំបន់ខ្មាំងអស់ចំនួន៣០គ្រួសារ ។ ខែ៣ ឆ្នាំ១៩៧១ ជ័យ មកធ្វើជាកងទ័ពស្រុកជាមួយនឹង សួន ចំណែក ខា និង អុល ធ្វើការជាមួយ សួស ហើយស្លាប់ក្នុងសមរភូមិនៅឆ្នាំ១៩៧២ ។

នៅខែ៥ ឆ្នាំ១៩៧១ អង្គការចាត់តាំងកងទ័ពតំបន់ ។ លាន និង សួន បានខទ្ទេសនាម ជ័យ ឲ្យធ្វើការជាមួយឈ្មោះ បេង ប្រធាននយោបាយកងវរសេនាតូចសមរភូមិ២៩០ ខេត្តកំពង់ចាម ។ បន្ទាប់ពីនោះ សួន ផ្លាស់ទៅធ្វើការនៅស្រុកកំពង់សៀម ត្រូវខ្មាំងលួចបាញ់ស្លាប់ ចំណែក លាន ក៏ត្រូវខ្មាំងលួចគប់គ្រាប់បែកចូលអង្គប្រជុំស្លាប់ដែរ ។ ខែកុម្ភៈ ឆ្នាំ១៩៧២ ជ័យ ធ្វើការជាមួយ បេង នៅក្នុងអង្គភាពទ័ពចល័តភូមិភាគ៣០៥ ។ ពេលវាយក្រុងកំពង់ធំនៅក្តីសែន ជ័យ បានបញ្ជាឲ្យកូនទាហានដកថយចោលខ្សែត្រៀម បណ្តាលឲ្យទាហានខ្មាំងព័ទ្ធកម្ទេចកម្លាំងបដិវត្តន៍អស់មួយកងតូច ។ ជាមួយនឹងសកម្មភាពខាងលើ ជ័យ នៅតែបន្តកសាងបានកម្លាំងថ្មីៗជាច្រើនទៀត ។

ម្តងហើយម្តងទៀត ជ័យ បានសរសេរនៅក្នុងចម្លើយសារភាពថា សកម្មភាពក្បត់របស់ខ្លួនដែលមិនអាចអត់ឪនបានគឺ

បំផុសយុទ្ធជនឲ្យរត់ទៅផ្ទះ រត់ចោលសមរភូមិ បើកផ្លូវឲ្យទាហានខ្មាំង វាយបុកដាច់ខ្សែត្រៀម ផ្តល់ព័ត៌មានឲ្យយន្តហោះមកទម្លាក់គ្រាប់បែកដាក់ជំរំយោធា ឲ្យកម្លាំងរបស់ខ្លួនចាក់ថ្នាំសម្លាប់យុទ្ធជនដែលឈឺនិងរបួស ចាត់កម្លាំងឲ្យដាក់គ្រាប់បែកក្នុងមន្ទីរពេទ្យ ពន្យារពេលអនុវត្តផែនការរបស់បក្ស ផ្តល់ព័ត៌មានមិនច្បាស់ដល់អង្គភាពធ្វើឲ្យមានការលំបាកក្នុងការវាយលុក បាញ់បំផ្លាញគ្រាប់កាំភ្លើងធំនិងកាំភ្លើងបាញ់យន្តហោះអស់ជាច្រើន ។

នៅខែ៥ ឆ្នាំ១៩៧៣ ជ័យ បានផ្លាស់ទៅមន្ទីរសេនាធិការភូមិភាគ ។ នៅចុងឆ្នាំ១៩៧៣ មុនពេលដកទ័ពទៅវាយនៅផ្លូវជាតិលេខ៥ ម្តុំទុជ្ជនិងកំពង់ហ្លួង ជ័យ បានទៅជួបនឹង បេង នៅភ្នំស្រីភ្នំប្រុស ។ បេង បានខទ្ទេសនាម ជ័យ ឲ្យធ្វើការជាមួយឈ្មោះ ជិត, ហ៊ាន និង សំបូរ ចំណែកខ្លួនគាត់ផ្លាស់ទៅធ្វើការនៅសមរភូមិកំពង់ធំ ។

ខែ៧ ឆ្នាំ១៩៧៤ ជ័យ ផ្លាស់ទៅខេត្តសៀមរាបឧត្តរមានជ័យ ជាមួយឈ្មោះ ជិត ។ ជិត បានខទ្ទេសនាម ជ័យ ឲ្យស្គាល់ឈ្មោះ ហោះ និង ខ្លូន ប្រធានវរសេនាតូចនៅខេត្តសៀមរាប ។ បន្ទាប់ពីទទួលជ័យជំនះទូទាំងប្រទេស ហោះ ផ្លាស់ទៅប្រចាំការនៅខេត្តកំពង់ធំ, ខ្លូន ទៅប្រចាំការនៅខេត្តកំពង់ចាម, ជិត មកធ្វើជាប្រធានពេទ្យភូមិភាគនៅខេត្តកំពង់ចាម, ជ័យ ក៏ផ្លាស់មកខេត្តកំពង់ចាមដែរ ។

នៅខែ៧ ឆ្នាំ១៩៧៥ ខ្លូន បានដឹកនាំអង្គប្រជុំមួយនិយាយអំពីផែនការកែប្រែសង្គមនេះឲ្យទៅជារបបឯកជនវិញ ព្រោះរស់ក្នុងរបបសមូហភាពលំបាកណាស់ គ្មានផ្សារ គ្មានលុយ គ្មានស្រាផឹក ។ ដូច្នេះផែនការគឺនាំគ្នាបំផុសការស៊ីផឹកនិងលេងបៀឲ្យបានច្រើនកន្លែង និងយកភាពយន្តរបស់ខ្មាំងមកបញ្ចាំងរាល់ៗយប់នៅរោងមហោស្រពខេត្តកំពង់ចាម ។

នៅខែ៤ ឆ្នាំ១៩៧៦ មុនថ្ងៃបុណ្យឯករាជ្យជាតិ ១៧ មេសា ខ្លូន បានដឹកនាំការប្រជុំមួយនៅមន្ទីររបស់ឈ្មោះ រាប នៅភ្នំប្រុសភ្នំស្រី ដើម្បីរៀបចំផែនការធ្វើរដ្ឋប្រហារដណ្តើមយកក្រុងកំពង់ចាម ។ ផែនការនេះមិនទាន់អនុវត្តភ្លាមទេ ដោយសារឈ្មោះ សី មិននៅ ម្យ៉ាងទៀតកម្លាំងក៏មិនទាន់ជុំគ្រប់គ្នា ប៉ុន្តែខ្លូន បានផ្តល់យោបល់ដល់កម្លាំងទាំងអស់ឲ្យធ្វើសកម្មភាពអុកឡុកតាមផ្ទះ ឃ្លាំងទំនិញ មន្ទីរពេទ្យ និងមន្ទីរភូមិភាគ ឲ្យចលាចលនៅក្នុងភូមិភាគ ។

នៅខែ៨ ឆ្នាំ១៩៧៦ ខ្លូន បានដឹកនាំការប្រជុំមួយទៀតនៅភូមិព្រែកដើមចាន់ រៀបចំផែនការធ្វើរដ្ឋប្រហារក្នុងឱកាសបុណ្យខួបបក្សថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៧៦ នេះ ។ ផែនការគឺរង់ចាំឲ្យខាងភ្នំពេញផ្ទុះអាវុធមុន បន្ទាប់មកខាងកំពង់ចាមវាយដណ្តើមយកអាវុធនិងសម្ភារៈទាំងអស់សម្រាប់វាយយកភូមិភាគកណ្តាលទាំងមូល ។ បន្ទាប់ពីអង្គប្រជុំនេះ ទាំងអស់គ្នារង់ចាំទទួលបញ្ជាពីឈ្មោះ ខ្លូន ប៉ុន្តែផែនការត្រូវបរាជ័យដោយសារបក្សចាប់ខ្លួនឈ្មោះ ហោះ, វើន, ខ្លូន និងបក្ខពួកដទៃទៀតជាបន្តបន្ទាប់ ។

នៅខែ១២ឆ្នាំ១៩៧៦ សី បានប្រមូលកម្លាំងដែលនៅសេសសល់ទៅប្រជុំនៅក្រុងកំពង់ចាម ប្រាប់ឲ្យសំងំសិន ការពារកម្លាំងរង់ចាំសភាពការណ៍ថ្មីទៀត ប៉ុន្តែនៅតែបន្តការអុកឡុកនៅពេលយប់ដដែល ។ នៅថ្ងៃទី៣០ ខែមករា ឆ្នាំ១៩៧៧ សី ដាក់ផែនការធ្វើរដ្ឋប្រហារវាយបក្សក្នុងរវាងពីថ្ងៃទី២០ដល់ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៧៧នេះ ឲ្យខាងតែបានដាច់ខាត ព្រោះបើទុកកាន់តែយូរ កម្លាំងកាន់តែរលោះដោយសារបក្សចាប់ខ្លួន ។ ផែនការគឺវាយក្រុងកំពង់ចាមមុនដើម្បីដណ្តើមអាវុធនិងគ្រាប់រំសេវ ។ បន្ទាប់មកគឺវាយយកក្រុងកំពង់ធំ ដើម្បីភ្ជាប់ជាមួយសៀមតាមខេត្តព្រះវិហារដោយ សី បានចាត់តាំង វើង ឲ្យទៅភ្ជាប់សភាពការណ៍នៅខាងសៀមរាបជាស្រេច ។

វើង បានទៅសៀមរាបតាមការចាត់តាំងរបស់ សី ប៉ុន្តែ វើង មិនទាន់ត្រឡប់មកវិញផង បក្សបានចាប់ខ្លួនមេៗមួយចំនួនទៀតជាបន្តបន្ទាប់ ហើយដល់ខែ៣ខែ៤ក៏ស្រាវជ្រាវចាប់ជាខ្សែសង្វាក់រហូតដល់មូលដ្ឋានសហករណ៍ ។ ដូច្នេះផែនការត្រូវបរាជ័យទាំងស្រុង ។

ថ្ងៃទី២៩ ខែ៤ ឆ្នាំ១៩៧៧ ជ័យ បានជួបប្រជុំជាមួយ សី, រាប និង លី ។ សី បាននិយាយថា "ឥឡូវនេះអង្គការលែងទុកចិត្តយើងហើយ មិនយូរមិនឆាប់គង់តែអង្គការចាប់យើងទៀតមិនខាន ។ ដូច្នេះបើមុននឹងស្លាប់ យើងត្រូវបំផ្លាញកម្លាំងបដិវត្តន៍ស្អីមួយឲ្យបាន" ។ ដោយសារភូមិភាគឧត្តរត្រូវបាន

អង្គការបញ្ចូលបន្ថែមខេត្តសៀមរាបនិងឧត្តរមានជ័យទៀត ដូច្នេះ សី បានរៀបផែនការទាក់ទងជាមួយ សៀមក្នុងករណីដែលរដ្ឋប្រហារត្រូវបរាជ័យ យើងនឹងនាំកម្លាំងរត់ទៅខាងដីសៀម ។ សី, រាប និង លី មាននាទីទៅរៀបចំកម្លាំងនៅខាងខេត្តសៀមរាប ។

ខែ៦ ឆ្នាំ១៩៧៧ អង្គការបានកាត់ខេត្តសៀមរាបចេញ ដូច្នេះភូមិភាគកណ្តាលនៅសល់តែខេត្តកំពង់ចាមនិងកំពង់ធំប៉ុណ្ណោះ ។ សី, រាប និង លី ត្រូវត្រឡប់មកពីសៀមរាបវិញ ។ សី បានបើកអង្គប្រជុំម្តងទៀត ដោយសារផែនការត្រូវទទួលបរាជ័យកាន់តែធ្ងន់ធ្ងរ ។ សី បានលើកឡើងថា ពេលនេះបើធ្វើក៏ស្លាប់ មិនធ្វើក៏ស្លាប់ ដូច្នេះមុននឹងស្លាប់ត្រូវតែបំផ្លាញឃ្លាំងគ្រាប់នៅកំពង់ចាមឲ្យបាន ។ ទាំងអស់គ្នាឯកភាពឲ្យ លី និង រាប ជាអ្នកធ្វើសកម្មភាពបំផ្លាញឃ្លាំងគ្រាប់ ។

នៅដើមខែ៨ ឆ្នាំ១៩៧៧ អង្គការផ្លាស់ សី ចេញពីលេខាកងពល មកធ្វើប្រធានកសិកម្មភូមិភាគវិញ ។ សី បានហៅកម្លាំងទាំងអស់ទៅជួបហើយនិយាយថា «ឥឡូវ...អង្គការលែងទុកចិត្តខ្ញុំហើយ ស្អែកឬខានស្អែកនេះប្រហែលអង្គការចាប់ខ្ញុំហើយ ។ ...បើអង្គការចាប់ខ្ញុំ សូមរាបដឹកនាំផែនការនេះដោយទៅទាក់ទងជាមួយ បងចន នៅតំបន់៤៣ ។» សី ត្រូវអង្គការចាប់ខ្លួននៅក្នុងខែ៨នេះ ។ បន្ទាប់ពី សី ត្រូវចាប់ខ្លួន រាប, លី, ជ័យ, សោ, ចន, និង បឿន ក៏បន្តផែនការដាក់គ្រាប់បែកបំផ្លាញឃ្លាំងគ្រាប់នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ១៩៧៧ ។ ជ័យ បានចូលរួមប្រជុំរៀបចំផែនការនេះនៅថ្ងៃទី៩ ខែកញ្ញា ប៉ុន្តែមិនបានចូលរួមអនុវត្តទេ ដោយត្រូវអង្គការចាត់ឲ្យទៅទទួលភ្ញៀវបរទេសដែលមកធ្វើទស្សនកិច្ចនៅភូមិភាគកណ្តាល លុះដល់ល្ងាចថ្ងៃទី១៧ត្រឡប់មកវិញចំពេលគ្រាប់ផ្ទុះតែម្តង ។ គ្រាប់ទី១ផ្ទុះនៅវេលាម៉ោង៤ល្ងាច កន្លះម៉ោងក្រោយមកផ្ទុះគ្រាប់ទីពីរ ។ ក្រោយពីមានព្រឹត្តិការណ៍ផ្ទុះគ្រាប់បែកភ្លាម បក្សមានវិធានការស្រាវជ្រាវនិងឃាត់ខ្លួនអ្នកធ្វើសកម្មភាពជាខ្សែសង្វាក់ ហើយដល់ថ្ងៃទី៣ ខែតុលា ឆ្នាំ១៩៧៧ ជ័យ ត្រូវចាប់ខ្លួនបញ្ជូនមកភ្នំពេញឃុំឃាំងនៅមន្ទីរស-២១ ។

នៅក្នុងមន្ទីរ ស-២១ ជ័យ ត្រូវសួរចម្លើយបួនលើក ។ លើកទីមួយសួរដោយឈ្មោះ អឿន នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩៧៧ ។ ជ័យ បានរាយការណ៍ថា មនុស្ស៥៥នាក់បានចូលរួមសកម្មភាពក្បត់ជាមួយខ្លួន ។ ក្នុងចំណោមឈ្មោះទាំងនោះមួយចំនួនធំគឺស្លាប់និងចាប់អស់ហើយ ក្រៅពីនោះគឺក្តាប់មិនបាន ។

សួរចម្លើយលើកទីពីរនៅថ្ងៃទី១៤ ខែ១០ ឆ្នាំ១៩៧៧ គ្រាន់តែជាការបញ្ជាក់បន្ថែមអំពីសកម្មភាពរបស់ សោ ដែលប៉ុនប៉ងមិនបានសម្រេចក្នុងការសម្លាប់ សមមិត្តអាន លេខាតំបន់៤៤ ។ សួរចម្លើយលើកទីបីនៅថ្ងៃទី១៨ ខែតុលា ។ លើកនេះបញ្ជីឈ្មោះមនុស្សកើនដល់៦១នាក់ ។ លើកចុងក្រោយពីថ្ងៃទី២៩ដល់ថ្ងៃទី៣១ ខែតុលា សួរដោយ ទុយ និង ឈិន ។ ចម្លើយសារភាពលើកនេះមានលក្ខណៈលម្អិតខ្លាំងជាងមុន ។

យោងតាមបញ្ជីឈ្មោះអ្នកទោសដែលត្រូវកម្ទេចនៅមន្ទីរ ស-២១ ដេង ស៊ីន់ ហៅ ជ័យ ត្រូវអង្គការកម្ទេចនៅថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៧៨ ។

**សាន់ កល្យាណ**

## ពាក្យស្លោកខ្មែរក្រហម

- ធ្វើបដិវត្តន៍មិនមែនអញ្ជើញភ្ញៀវទៅពិសាបាយទេ មិនមែនសរសេរអត្ថបទទេ មិនមែនប៉ាក់ផ្កាទេ មិនមែនត្រូវអប់រំទន់ទេ មិនត្រូវព្រងើយកន្តើយសុភាពរាបសាទេ មិនត្រូវខ្លាចខ្លាំងទេ បដិវត្តន៍គឺជាកំហឹងវណ្ណៈមួយវាយរំលំវណ្ណៈមួយ។
- ចំពោះមនុស្សយើងម្នាក់ៗ ប្រសិនបើខ្មាំងមិនប្រឆាំងទេនោះគឺមិនល្អដែរ ច្បាស់ជាត្រូវយើងនឹងខ្មាំងវិញ បើខ្មាំងប្រឆាំងវិញជាការល្អ បញ្ជាក់ថា "យើងនិងខ្មាំងអាចចែកព្រំដែនគ្នាច្បាស់លាស់" ហើយបើសត្រូវប្រឆាំងយើងកាន់តែខ្លាំងឡើងៗនោះយើងរឹតតែរលុះរលាយឡើង បញ្ជាក់ថាយើងមិនតែចែកព្រំដែនច្បាស់ ថែមទាំងបញ្ជាក់ថា ការងារយើងបានទទួលផលល្អ។
- យើងសង្ឃឹមចង់បានជំនួញបរទេសដែរ តែយើងត្រូវពឹងផ្អែកខ្លួនយើង ផ្អែកលើសេចក្តីព្យាយាមរបស់ខ្លួន ពឹងផ្អែកលើកម្លាំងកសាងរបស់ធ័ពនិងប្រជាជន។

*(សៀវភៅកំណត់ហេតុរបស់សមមិត្ត ញ៉ុក សារិន)*

*ទីស្តីការគណៈរដ្ឋមន្ត្រី*
*លេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល*
*រាជរដ្ឋាភិបាលកម្ពុជា*
*ថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៣*

# របាយការណ៍

## ស្តីពីកិច្ចប្រជុំការងារបច្ចេកទេសជាមួយបណ្តាអគ្គទូត ក្នុងការរៀបចំដំណើរការអង្គជំនុំជម្រះវិសាមញ្ញដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម

ខ្ញុំមានកិត្តិយសសូមជម្រាបជូនឯកឧត្តមមេត្តាជ្រាបអំពីរបាយការណ៍ស្តីពីកិច្ចប្រជុំការងារបច្ចេកទេសជាមួយបណ្តាអគ្គទូតក្នុងការបង្កើតដំណើរការអង្គជំនុំជម្រះវិសាមញ្ញដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម ដែលបានប្រារព្ធធ្វើឡើងកាលពីថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៣ ។ កិច្ចប្រជុំនេះបានដំណើរការនៅម៉ោង៣ៈ០០រសៀល ក្រោមអធិបតីភាពឯកឧត្តម ឳម យ៉ិនទៀង អនុប្រធានក្រុមការងាររាជរដ្ឋាភិបាល និងជាប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ។ កិច្ចប្រជុំនេះមានការចូលរួមពីបណ្តាអគ្គទូតនានាប្រចាំនៅកម្ពុជាចំនួន២៦នាក់ និងស្ថានបេសកកម្មប្រចាំនៅទីក្រុងបាងកកចំនួន១នាក់ តំណាងអង្គការយូអិនឌីភីចំនួន២នាក់ តំណាងអង្គការ UNCOHCHR ចំនួន១នាក់ និងភ្ញៀវពិសេសចំនួន៤នាក់ ។ របៀបវារៈនៃអង្គប្រជុំមានដូចតទៅ ÷

- សេចក្តីផ្តើមដោយឯកឧត្តម ឳម យ៉ិនទៀង អំពីកិច្ចប្រជុំ
- ការបង្ហាញជូននូវលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល និងអំពីការិយាល័យរដ្ឋបាលដែលនឹងត្រូវបង្កើតឡើង ដោយឯកឧត្តម ស៊ាន វិសុទ្ធ លេខាធិការប្រតិបត្តិ
- គម្រោងច្បាប់អំពីអង្គជំនុំជំរះសាមញ្ញ ដោយឯកឧត្តម ក្រាញ់ តូនី លេខាធិការច្បាប់
- គម្រោងរៀបចំឯកសារនិងពត៌មាន ដោយបណ្ឌិត ហេឡែន ហ្សារីស ទីប្រឹក្សានៃក្រុមការងាររាជរដ្ឋាភិបាល
- គំរោងថវិកានិងជម្រើសអំពីទីតាំងសម្រាប់អង្គជំនុំជម្រះវិសាមញ្ញ ដោយឯកឧត្តម ងី តាយី អនុរដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- សំណួរនិងចម្លើយ
- ការបង្ហាញនូវការរួមចំណែកជាសក្តានុពលសម្រាប់អង្គជំនុំជម្រះវិសាមញ្ញដោយប្រទេសផ្តល់ជំនួយ
- ជំហានបន្ទាប់ រួមទាំងការរៀបចំទទួលដំណើរទស្សនកិច្ចគណៈប្រតិភូរបស់ អ.ស.ប

### ១) សេចក្តីផ្តើម (ដោយឯកឧត្តម ឳម យ៉ិនទៀង)

ឯកឧត្តម ឳម យ៉ិនទៀង បានលើកឡើងនូវការឯកភាពពីសម្តេចនាយករដ្ឋមន្ត្រីឲ្យមានកិច្ចប្រជុំថ្នាក់បច្ចេកទេស ដើម្បីជម្រាបជូនអំពីការងារដែលភាគីកម្ពុជាបានធ្វើ កំពុងធ្វើ ហើយនឹងធ្វើការចរចាគ្នារវាងរាជរដ្ឋាភិបាលកម្ពុជានិងអ.ស.បអស់រយៈពេល៤ឆ្នាំ ដែលសម្រេចបានជាកិច្ចព្រមព្រៀងគ្នា និងត្រូវបានចុះហត្ថលេខាដោយឯកឧត្តម សុខ អាន តំណាងរាជរដ្ឋាភិបាលកម្ពុជា និងឯកឧត្តម ហេន កូរែល តំណាងអ.ស.បនៅសាលចតុមុខ រាជធានីភ្នំពេញ នាថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៣ និងការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ដើម្បីធ្វើយ៉ាងណាឲ្យកិច្ចព្រមព្រៀងនេះចូលជាធរមានឲ្យបានឆាប់ ហើយឈានទៅដល់ការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ។

### ២) ការបង្ហាញជូននូវលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល និងអំពីការិយាល័យរដ្ឋបាលដែលនឹងត្រូវបង្កើតឡើង (ដោយឯកឧត្តម ស៊ាន វិសុទ្ធ)

ឯកឧត្តមបានបង្ហាញជូននូវសមាជិកក្រុមការងារនិងអ្នកចូលរួមស្ម័គ្រចិត្តទាំងអស់លើការងារអង្គជំនុំជម្រះវិសាមញ្ញនេះជូនបណ្តាអគ្គទូត ។ បន្ទាប់មកទៀត បាននិយាយអំពីជំនួយរបស់ចក្រភពអង់គ្លេសនិងស៊ុយអែដ សម្រាប់ការចំណាយទៅលើក្រុមការងារនិងសម្ភារការិយាល័យ ។ បន្ទាប់មកទៀតឯកឧត្តមបានបង្ហាញនូវពង្រាងនិងរចនាសម្ព័ន្ធសម្រាប់ការិយាល័យរដ្ឋបាល ភ័ស្តុភារ និងតម្រូវការក្នុងការបណ្តុះបណ្តាលធនធាន

មនុស្សសម្រាប់អង្គជំនុំជម្រះវិសាមញ្ញនេះ ។

**៣) គម្រោងច្បាប់អំពីអង្គជំនុំជម្រះវិសាមញ្ញ (ដោយឯកឧត្តម ក្រាញ់ តូនី)**

ឯកឧត្តមបានពន្យល់អំពីទិដ្ឋភាពច្បាប់ តម្រូវការនូវអង្គចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី និងបុគ្គលិកបម្រើការងារនូវផ្នែកបច្ចេកទេសសម្រាប់តុលាការថ្នាក់ដំបូងនិងកំពូលដែលមានតួនាទីជាតុលាការខេត្តរណ៍ ហើយក៏បានត្រៀមនូវអង្គចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជីបម្រុង ។ ឯកឧត្តមក៏បានបង្ហាញនូវតម្រូវការក្នុងការបណ្តុះបណ្តាលបុគ្គលិកដោយរៀបចំជាមួយសាលាភូមិន្ទអង្គចៅក្រម ។

**៤) គម្រោងរៀបចំឯកសារនិងពត៌មាន (ដោយបណ្ឌិត ហេឡែន ហ្ចារីស)**

លោកស្រីបណ្ឌិត ហេឡែន ហ្វារីស បានបង្ហាញនូវគេហទំព័រដែលក្រុមការងារបានសម្រេចបាន ដើម្បីផ្សព្វផ្សាយនូវពត៌មានដែលទាក់ទងទៅនឹងតុលាការវិសាមញ្ញនេះជាភាសាខ្មែរនិងអង់គ្លេស ។ ការរៀបចំឯកសារច្បាប់ និងកិច្ចព្រមព្រៀងចំនួន២៩ដែលទាក់ទងនឹងច្បាប់កម្ពុជានិងអន្តរជាតិ ការបកប្រែឯកសារជាភាសាខ្មែរ អង់គ្លេស និងបារាំង និងផ្ញើឯកសារទាំងអស់ដាក់ទៅក្នុងគេហទំព័រនិងស៊ីឌីសម្រាប់សាធារណជន ។

ក្រុមការងារក៏បានរៀបចំនូវពង្រាងសម្រាប់ចម្លើយតបនឹងសំណួរដែលតែងលើកឡើងជាញឹកញាប់(FAQ) ។ ចំពោះប្រភពនៃឯកសារនោះវិញគឺបានប្រមូលពីប្រព័ន្ធច្បាប់នៅកម្ពុជានិងពីវិទ្យាស្ថានអន្តរជាតិដែលពាក់ព័ន្ធដូចជាតុលាការឧក្រិដ្ឋកម្មសង្គ្រាមនៅប្រទេសយូហ្គោស្លាវីនិងវ៉ាន់ដាជាដើម ។

**៥) គម្រោងថវិកានិងជម្រើសអំពីទីតាំងសម្រាប់អង្គជំនុំជម្រះវិសាមញ្ញ (ដោយឯកឧត្តមបណ្ឌិត ង៉ី តាយី)**

ឯកឧត្តមបណ្ឌិត ង៉ី តាយី បានបង្ហាញនូវពង្រាងហិរញ្ញវត្ថុសម្រាប់អង្គជំនុំជម្រះវិសាមញ្ញនេះ ដោយមានតារាងសង្ខេបលើចំណាយក្នុងរយៈពេលបីឆ្នាំ ។ ឯកឧត្តមក៏បានលើកឡើងអំពីទីតាំងសម្រាប់ធ្វើជាតុលាការ ការិយាល័យ ដូចជាសាលសន្និសីទចតុមុខ ការជួសជុលអគារដែលមានស្រាប់ ឬក៏សាលសន្និសីទមេគង្គនៅជ្រោយចង្វា អគាររបស់គណៈកម្មាធិការទន្លេមេគង្គ និងជាចុងក្រោយនូវថវិកាជាបន្ទាន់សម្រាប់ក្រុមការងារដាន់ខ្ពស់បម្រើនូវការងារនេះ ។

**៦) សំណួរនិងចម្លើយ**

បន្ទាប់ពីការពន្យល់និងបង្ហាញរួចមក អង្គប្រជុំបានឈានដល់នូវសំណួរនិងចម្លើយលើបញ្ហាការងារនេះពីបណ្តាអង្គទូតនានាដូចតទៅ ÷

**៧) ការចូលរួមចំណែករបស់ម្ចាស់ជំនួយលើតុលាការវិសាមញ្ញ**

ស្ថានទូតអូស្ត្រាលីបានបញ្ជាក់ថាបានផ្តល់ជំនួយជាទឹកប្រាក់ចំនួនមួយលានប្រាំសែនដុល្លារអូស្ត្រាលី (ប្រហែលមួយលានដុល្លារសហរដ្ឋអាមេរិក) សម្រាប់អង្គជំនុំជម្រះវិសាមញ្ញ រីឯចំណែកខាងតំណាងស្ថានទូតជប៉ុនវិញបាននិយាយថា ខ្លួនមិនអាចផ្តល់ពត៌មានដោយត្រូវរង់ចាំចម្លើយពីក្រសួងការបរទេសរបស់គេក្នុងការផ្តល់ជំនួយ និងជាចុងក្រោយឯកអគ្គរាជទូតអង់គ្លេសបានមានប្រសាសន៍ថានឹងចូលរួមចំណែកផ្តល់វិភាគទានដល់ដំណើរការនេះនិងបណ្តុះបណ្តាលដល់បុគ្គលិក ។

**៨) ជំហានបន្ទាប់ រួមទាំងការរៀបចំទទួលនូវដំណើរទស្សនកិច្ចគណៈប្រតិភូរបស់អ.ស.ប**

ចំណែករបៀបវារៈចុងក្រោយនេះ ឯកឧត្តម ឌិម យិនទៀង បានមានប្រសាសន៍ជម្រាបជូនបណ្តាអង្គទូតថា កាលពីថ្ងៃទី០៨ ខែតុលានេះ ខាងអ.ស.បបានផ្ញើលិខិតស្តីពីការធ្វើដំណើរមកដល់របស់គណៈប្រតិភូអ.ស.បក្នុងអំឡុងថ្ងៃទី១០ដល់១៥ ខែវិច្ឆិកា ក្រោយមករយៈពេលមួយអាទិត្យ ត្រូវនឹងថ្ងៃទី១៥ ខែតុលា ខាងអ.ស.បបានផ្ញើលិខិតម្តងទៀតដោយជម្រាបថា មិនបានមកកម្ពុជាទេ ដោយហេតុថាខ្វះថវិកា ។

ជាទីបញ្ចប់ ឯកឧត្តម ឌិម យិនទៀង បានធ្វើសេចក្តីសន្និដ្ឋាននិងសង្ខេបនូវកិច្ចប្រជុំក្នុងរយៈពេលជាង២ម៉ោងនេះ ហើយបានជូនពរនិងថ្លែងអំណរគុណដល់បណ្តាអង្គទូត តំណាងយូអិនឌីភី ដែលបានមកចូលរួមក្នុងកិច្ចប្រជុំនេះ ។

កិច្ចប្រជុំបានបញ្ចប់នៅម៉ោង៥និង៣០នាទីល្ងាច ហើយប្រព្រឹត្តទៅក្រោមបរិយាកាសរីករាយនិងស្និទ្ធស្នាលបំផុត ។

**អ្នកធ្វើរបាយការណ៍**

**ស៊ុន រ៉ាពីជ**

# ជីវទស្សន៍បដិវត្តន៍របស់សមមិត្ត ប៉ុន

## ឆ្លងថ្ងៃ ៧ ធ្នូ ១៩៧៦

### ក) ខ្លឹមសារសតិអារម្មណ៍

I. អំពីបដិវត្តន៍សង្គមនិយមគ្រប់ផ្នែក

មុនរៀន យើងខ្ញុំយល់តាមការអប់រំរបស់បក្សជាបន្តបន្ទាប់ថា បច្ចុប្បន្នគឺធ្វើបដិវត្តន៍សង្គមនិយមនិងកសាងសង្គមនិយម ។ តែការជ្រួតជ្រាបជាជំហររបស់យើងខ្ញុំ យើងខ្ញុំសូមលើកឡើងដើម្បីរាយការណ៍ដូចតទៅ ÷

១) ជាគុណសម្បត្តិ

◆ អាកប្បកិរិយាមិនវាយឫកពា មិនប្រកាន់ឫកពាជាមួយមិត្តផងគ្នា រួសរាយរាក់ទាក់ក៏មានមូលដ្ឋានដែរ ។

◆ គោរពការចាត់តាំងរបស់បក្សបានជាបន្តបន្ទាប់ ហើយការអនុវត្តភារកិច្ចបានពុំមានស្មុគស្មាញអ្វីនាំឲ្យស្ទះការងារ នាំឲ្យបក្សពិបាកចិត្តចំពោះខ្លួនទេ ។

២) ជាគុណវិបត្តិ

◆ កម្មសិទ្ធិអំណាចៈ ការជួយយោបល់របស់មហាជនក៏បានរកហេតុផលវែកញែក ធ្វើឲ្យគេញញើតក្នុងការជួយយោបល់ទៀត ។ ដូចនេះទៅថ្ងៃក្រោយអាចឯកោពីមហាជនបាន ពីព្រោះមហាជនគេលែងជួយយោបល់ទៀត ។ ជាពាក្យសម្ដីធំតូច កំបុតកំបុយ ប្រកែកប្រណាំងជាមួយមិត្តដទៃ ជាមួយថ្នាក់លើក៏មាន ។ ការធុញទ្រាន់ ធុញទ្រាន់ជាមួយអ្នកថ្នមគ្រួសារ និងបញ្ហាផ្សេងៗក៏មាន ហើយស្ដែងចេញជាទឹកមុខ សម្ដី អាកប្បកិរិយា ធ្វើឲ្យប៉ះពាល់សាមគ្គីភាពខ្លះដែរ ព្រោះថ្នាក់លើឬមិត្តដទៃពុំយល់មូលហេតុ ដោយយើងខ្ញុំផ្ទាល់ដឹងអក់មិននិយាយ មិនហ៊ានទិតៀនកសាង ខ្លាចអីចេះអីចុះ ។

បាតុភាពសួរ កែវ មាស ពុំចេញ បន្ទោសថ្នាក់លើក៏ធ្វើឲ្យភ្លេចកសាងអត្តនោម័តិផ្ទាល់ខ្លួនដែរ ។

◆ កម្មសិទ្ធិសម្ភារៈ ដូចដូរនាឡិកា ស្លាបប៉ាកកា ចុះឡើងក៏ប៉ះពាល់ដល់សាមគ្គីភាពឯកភាពដែរ ។

II. អំពីទំនាស់វណ្ណៈនិងដោះស្រាយទំនាស់វណ្ណៈក្នុងសង្គមកម្ពុជាបច្ចុប្បន្ន

១) ជាគុណសម្បត្តិ

◆ តាមភារកិច្ចប្រចាំថ្ងៃផង តាមការណែនាំរបស់ថ្នាក់លើជាប្រចាំថ្ងៃផង យើងខ្ញុំបានក្ដាប់ជាប់និងបែងចែកខ្មាំងនិងមិត្តបានច្បាស់លាស់មួយកម្រិត បានចាប់អារម្មណ៍រាយការណ៍ពាក្យចចាមអារ៉ាមរបស់ខ្មាំងក្នុងអង្គការសួរ ។

◆ ស្គាល់គ្រោះអាសន្ននៃពួកក្បត់ផ្ទៃក្នុងមួយកម្រិត ។

២) ជាគុណវិបត្តិ

◆ កន្លងមក យើងខ្ញុំចាប់អារម្មណ៍ស្រាលចំពោះស្រទាប់ដួរបដិវត្តន៍ដែលមានអំណាច ហើយបើស្រទាប់នេះមានកម្មសិទ្ធិឯកជនក្រាស់នោះ នឹងនាំបដិវត្តន៍ទៅជាសេរីក្បត់ប្រជាជនវិញ ។

◆ បាតុភាពដែលស្ដែងចេញចំពោះយើងខ្ញុំគឺជំហររួចខ្លួន ឧទាហរណ៍គិតគូរតែបំពេញភារកិច្ចផ្ទាល់ខ្លួន ឃើញការខ្វះខាតរបស់ផ្នែកដទៃក៏ពុំចាប់អារម្មណ៍ជួយមតិដែរ ។ ជំហរទិតៀនស៊័យទិតៀនក្នុងជីវភាពក៏ពុំស៊ីជម្រៅ លំៗក្នុងជំហរសន្តិភាព ។ ជំហររៀនសូត្រផ្ទាល់ខ្លួននិងផ្សព្វផ្សាយមាគ៌ាបដិវត្តន៍សង្គមនិយមក៏រយឹករយាកពុំខ្នះខ្នែង ដូចនេះក៏ស្ដែងចេញជំហរទទួលខុសត្រូវចំពោះភារកិច្ចពុំទាន់ខ្ពស់ ធ្វើមួយរួចខ្លួន ។ល ។

◆ បាតុភាពមិនតស៊ូកសាងផ្ទៃក្នុងឲ្យម៉ត់ចត់ ខ្លាចថ្នាក់លើឬមិត្តដទៃថាខ្លួនចាក់រុកឬអីចេះអីចុះ ក៏ជំហរតស៊ូកម្ចាត់កម្មសិទ្ធិមិនទាន់រឹងប៉ឹងដែរ ។

◆ បាតុភាពដោះស្រាយទំនាស់ធ្ងន់តែខាងវិធានការចាត់តាំងដោយចង់ឆាប់ ចង់រហ័ស ពុំឈរលើតស៊ូយូរអង្វែង តឹងតែងនិងស៊ិតស្មាញទេ ។ ឧទាហរណ៍ៈ ខ្មាំងឆ្លៀយដាក់មនុស្សមួយចំនួននៅក្នុងអង្គភាពសួរមាន អាសារ៉ាត ជាដើម ក៏ពុំបានគិតគូរដល់បញ្ហានយោបាយ ថ្វីបើមិនចេញស្ដីតែក៏ចង់ឆាប់ៗដែរ ។

III. អំពីរដ្ឋអំណាចនិងអំពីផ្ដាច់ការវណ្ណៈអធនរបស់បក្ស

១) ជាគុណសម្បត្តិ

◆ ជាការជ្រួតជ្រាបរបស់យើងខ្ញុំកន្លងមក គឺក្តាប់ជាប់ជំហរសម្រិតសម្រាំងអន្តភាពចំពោះសមាសភាពខ្មាំង សមាសភាពសេរី ឧទាហរណ៍ការរាយការណ៍អំពីពួក សារ៉ាត, ទ្រី, អៀង ។ ពីមុនមកក៏ធ្លាប់បានធ្វើដែរ ។

◆ ការគិតគូរអំពីវណ្ណៈមូលដ្ឋានក្នុងការចាត់តាំងផ្សេងៗក៏បានគិតគូរច្រើនដែរ ។

៣) គុណវិបត្តិ

◆ ការខ្វះខាតសំខាន់របស់យើងខ្ញុំគឺការកសាងជំហររបស់ខ្លួនឲ្យមានធាតុវណ្ណៈអធនរបស់បក្ស ។ កន្លងមក ចាប់អារម្មណ៍ស្រាលក្នុងបញ្ហានេះ ដោយគិតគូរតែការងារសន្តិបាលធ្ងន់ ដូចនេះក៏ពង្រីកកម្មសិទ្ធិឯកជន ស្តែងចេញជាបាតុភាពមិនអធនផ្សេងៗ ។

◆ ការតស៊ូកសាងផ្ទៃក្នុងក៏ខ្វះខាត មិនទាន់ជ្រួតជ្រាបអំពីការការពាររដ្ឋអំណាចនិងផ្តាច់ការវណ្ណៈអធនរបស់បក្សនៅឡើយ ។

ដូចនេះ បើប្រកាន់ជំហរបែបនេះយើងខ្ញុំច្បាស់ជាធ្លាក់ខ្លួនឯងកោពីបក្សពីមហាជនមិនខាន ។

IV. អំពីការតស៊ូវណ្ណៈរវាងកម្មសិទ្ធិឯកជនរបស់វណ្ណៈផ្សេងៗប្រឆាំងនឹងកម្មសិទ្ធិសមូហភាពរបស់វណ្ណៈអធន

◆ កន្លងមកជាមូលដ្ឋាន ចំពោះយើងខ្ញុំ កម្មសិទ្ធិសមូហភាពតែងឈ្នះកម្មសិទ្ធិឯកជនដែរ ។ ឧទាហរណ៍ខ្លះៗគឺការណែនាំរបស់ថ្នាក់លើច្រើនប្រកែកចុះឡើង តែការធ្វើនៅតែធ្វើ ហើយធ្វើដោយយកចិត្តទុកដាក់ ។ ការអន់ចិត្តជាមួយថ្នាក់លើទម្លាក់ទូរស័ព្ទក៏ឆាប់មកដោះស្រាយ ។ ការប្រើអំណាចលើមហាជនក៏បាននឹកឃើញហើយកម្ចាត់បានជារយៈកាលៗដែរ ។

◆ ការតស៊ូកម្ចាត់កម្មសិទ្ធិសម្ភារក៏ខំរំងាប់ការលោភលន់ចង់បានរបស់ល្អៗបានដែរ ។

៣) គុណវិបត្តិ

◆ ពុំទាន់ជ្រួតជ្រាបអំពីបច្ច័យអាក្រក់នៃកម្មសិទ្ធិឯកជន ។ ដូចនេះក៏បណ្តែតបណ្តោយក្នុងការកសាងខ្លួននិងការកសាងផ្ទៃក្នុងបក្សតាមវិធានការនយោបាយសតិអារម្មណ៍ចាត់តាំង ។

បច្ច័យអាក្រក់សម្រាប់យើងខ្ញុំកន្លងមកគឺកសាងមហាជនទាំងសមត្ថភាពនយោបាយទាំងសមត្ថភាពបច្ចេកទេសពុំលឿនទាន់សំណូមពររបស់បក្ស ដូចនេះក៏រត់ការងារម្នាក់ឯងពុំអស់ ហើយក៏ខ្លួនផ្ទាល់វិលវល់ខ្វក់ខ្វល់តែនឹងការងារបច្ចេកទេស ។ ដល់យ៉ាងនេះ ពេលមហាជនធ្វើមិនទាន់ក៏ស្តែងចេញជាអាជ្ញាបន្ទំ ជំរុញ ។ល ។

◆ បច្ច័យអាក្រក់ម្យ៉ាងទៀតដែលបណ្តាលមកពីដំអក់មិនដោះស្រាយនូវបាតុភាពទំនាស់កន្លងមក ក៏ធ្វើឲ្យសាមគ្គីភាពឯកភាពនៅមិនទាន់រឹងប៉ឹងដែរ ។ ជាមួយថ្នាក់លើក៏មិនយល់អំពីបាតុភាពកំបុតកំបុយរបស់ខ្លួនយើងខ្ញុំ មហាជនក៏ខ្លាចរអាចំពោះយើងខ្ញុំ ។

◆ បច្ច័យអាក្រក់ម្យ៉ាងទៀតដែលបណ្តាលមកពីមិនជ្រួតជ្រាបការតស៊ូកសាង ពិសេសចំពោះថ្នាក់លើដែលបានកសាងតស៊ូមតិក៏ភ័យខ្លួនឯងខ្លាចអឺចេះខ្លាចអឺចុះ ។ នេះក៏បណ្តាលឲ្យខ្លួនឃានទៅខ្លាចសមូហភាព មិនទុកចិត្តសមូហភាព ឃ្លាតពីសមូហភាពដែរ ។

V. រំពុកឡើងវិញអំពីសម្ភារនិយមបដិច្ចសមុប្បាទ

១) ជាគុណសម្បត្តិ

◆ កន្លងមកជាទស្សនៈ យើងខ្ញុំក្តាប់ជាប់អំពីច្បាប់ទាំង៤នៃសម្ភារនិយមបដិច្ចសមុប្បាទ ។

◆ ជំហរវិភាគទំនាស់ផ្ទៃក្នុងនិងទំនាស់ខ្មាំងស៊ីរូង និងចម្លើយខ្មាំងក៏មានមួយកម្រិតដែរ ។ ឧទាហរណ៍ ទំនាស់ក្នុងក្រុម II ពួកសារ៉ាត, ទ្រី, អៀង ដែលខ្មាំងឆ្លើយដាក់ ក៏បានរាយការណ៍ជូនថ្នាក់លើអំពីការសង្កេតកន្លងមក ។ល ។

៣) ជាគុណវិបត្តិ

◆ ការខ្វះខាតរបស់យើងខ្ញុំសំខាន់គឺមិនទាន់ម្ចាស់ការរឹងប៉ឹងក្នុងការវិភាគ ច្រើនបាក់បង្អៀងទៅម្ខាងៗ ពុំបានយកទំនាស់ម្ខាងៗមកថ្លឹងថ្លែងហើយវិភាគ ។ ទាន់តែមានប្រតិកម្មពីម្ខាងខ្លាំងទើបយកមកគិតគូរ ។ នេះចំពោះទំនាស់ផ្ទៃក្នុង ។ ដូចទំនាស់ក្នុងក្រុម II ។

◆ ចំពោះពួកបង្កប់ស៊ីរូងដែលយើងខ្ញុំបានជួបប្រទះ គឺពុំបានក្តាប់ប្រវត្តិរូបអន្តភាពឲ្យជាប់ដើម្បីលើកវិធានការទប់ទល់មុន ច្រើនបណ្តែតបណ្តោយទាល់តែមានបាតុភាពខ្លាំងទើបពិនិត្យ ។

◆ ចំពោះចម្លើយខ្មាំងក៏នៅវិភាគមួយជ្រុងៗ ឧទាហរណ៍

ខ្លាំងឆ្លើយដាក់នរណាគឺជឿមុនហើយបានស្រាវជ្រាវឯកសារពុំប្រកាន់ដំបហរវិភាគម៉ត់ចត់សិនសឹមជឿនោះទេ ។ ជួនកាលវិភាគបានម៉ត់ចត់ ការណែនាំរបស់អង្គការក៏ម៉ត់ចត់ ដល់អង្គការសម្រេចដូចបញ្ហា ចក្រី, សុផាន, សុជាតិ ក៏ព្រួយបារម្ភ នេះក៏មកពីដំបហរវិភាគនិងជឿអង្គការពុំទាន់នឹងនដែរ ។

◆ ក្រឹត្យក្រមអ្វីៗទាំងអស់សុទ្ធតែមានទំនាស់ ។ ក្រឹត្យក្រមនេះក៏យើងខ្ញុំពុំទាន់ជ្រួតជ្រាបដែរ ។ នៅគេចទំនាស់ ។ ដូចនេះក្នុងការគ្រប់គ្រងផ្ទៃក្នុងក៏ពុំបានត្រៀមទំនាស់ដែរ ដូចនេះឯងបានពុំមានវិធានការនយោបាយសតិអារម្មណ៍ម៉ត់ចត់ ។ ជាមួយថ្នាក់លើក៏ពុំត្រៀមទំនាស់ ។ បច្ច័យអាក្រក់ដល់ជួបទំនាស់ក៏ច្រើនខ្មៅដែរ ដល់ខ្មៅច្រើនគិតអំពីវិធានការចាត់តាំងចំពោះខាងក្រោយ និងច្រើនចង់រត់ចោលទំនាស់ពេលជួបទំនាស់ខាងលើបន្តិចបន្តួច ។ល ។

សរុបទាំងអស់មកវិញ យើងខ្ញុំសូមលើកមូលហេតុនៃបាតុភាពកម្មសិទ្ធិឯកជនរបស់យើងខ្ញុំកន្លងមកដូចតទៅ ÷

១) មូលហេតុសំខាន់គឺយើងខ្ញុំមើលធ្ងន់ការងារសន្តិបាលស្រាលការកសាងខ្លួននិងមហាជន ។ ខ្វះការរៀនសូត្រមាគ៌ាបដិវត្តន៍ផ្ទាល់ខ្លួន ហើយខ្វះទាំងការអប់រំមហាជនឲ្យជិតដល់ផង ។

២) ការធ្វើជីវភាពសមូហភាពក៏ពុំទាន់ស៊ីជម្រៅ នៅស៊ុមគ្រលុំប្រជុំដកពិសោធន៍ពុំទៀងទាត់ ។

៣) មូលហេតុមួយទៀតគឺយើងខ្ញុំទទួលឥទ្ធិពលនៃវណ្ណៈដើមរបស់យើងខ្ញុំជាអនុធនកណ្ដាលដែរ ដែលធ្វើអ្វីគិតតែមួយរូបខ្លួន ។

ទិសដោះស្រាយរបស់យើងខ្ញុំទៅថ្ងៃមុខដើម្បីបន្តធ្វើបដិវត្តន៍សង្គមនិយមនិងកសាងសង្គមនិយមគឺ ÷

១) ក្ដាប់ឲ្យជាប់ភារកិច្ចផ្ទៃក្នុងៈ ធ្វើការនយោបាយសតិអារម្មណ៍ជាសំខាន់ ដើម្បីកសាងខ្លួន កសាងមហាជន កសាងបក្សឲ្យបរិសុទ្ធភាពខាងជំបហរអធន ។

២) ប្រជុំជីវភាពឲ្យស៊ីជម្រៅ ដកពិសោធន៍ឲ្យទៀងទាត់ ។

៣) មើលឲ្យឃើញចំណុចខ្លាំងនិងចំណុចខ្សោយនៃប្រវត្តិរូបផ្ទាល់ខ្លួន ដើម្បីជំរុញចំណុចខ្លាំងកម្ចាត់ចំណុចខ្សោយ ។

## ខ) ខ្លឹមសារខាងនយោបាយ

I. ទស្សនៈសភាពការណ៍បដិវត្តន៍កម្ពុជាបច្ចុប្បន្ន

១) ជាគុណសម្បត្តិ

◆ តាមការណែនាំរបស់អង្គការជាប្រចាំថ្ងៃអំពីទស្សនៈវិភាគសភាពការណ៍ខ្លាំងក្នុងប្រទេសក្រៅប្រទេស យើងខ្ញុំក្ដាប់ជាប់ចំណុចខ្លាំង-ខ្សោយរបស់ខ្មាំងមួយកម្រិត ក្ដាប់ជាប់ចំណុចខ្លាំង-ខ្សោយនៃបដិវត្តន៍សង្គមនិយម និងសភាពការណ៍កសាងសង្គមនិយមមួយកម្រិតដែរ ។

◆ ឈរលើជំបហរដែលអង្គការបានបំពាក់បំប៉ននេះ កន្លងមកយើងខ្ញុំក៏បាននឹងនមួយកម្រិត ក្នុងការវិភាគសភាពការណ៍ក្នុងការបំពេញភារកិច្ចទទួលបានលទ្ធផល រកឃើញខ្សែក្បត់ធំមួយ (កែវ មាស, យ៉ា, ១២) មិនច្រឡូសច្រឡោសដូចជំនាន់ចក្រី, សុផាន, សុជាតិ ។

◆ ឈរលើជំបហរបំពាក់បំប៉ននេះដែរក៏ធ្វើឲ្យយើងខ្ញុំសុទិដ្ឋិនិយមជានិច្ចចំពោះជ័យជំនះធំៗរបស់បក្ស ក្នុងការកសាងនិងការពារប្រទេស ដូចនេះក៏ជះឥទ្ធិពលខ្លាំងក្លាដល់ការកសាងខ្លួនរបស់យើងខ្ញុំក្នុងការបន្តធ្វើបដិវត្តន៍សង្គមនិយមនិងកសាងសង្គមនិយមបច្ចុប្បន្ននេះ ។

២) គុណវិបត្តិ

◆ តែជាការខ្វះខាតរបស់យើងខ្ញុំក៏នៅមានអត្តនោម័តិច្រើនដែរក្នុងការវិភាគ ដូចជាឃើញតែបដិវត្តន៍យើងខ្លាំងជាងគេលើសកលលោក លឿនជាងគេ គំរូជាងគេលើសកលលោក អធនជាងគេលើសកលលោក ពុំអាចប្រែក្លាយទៅជាសេរីបានទេ ។ល ។ ភ្លេចគិតដល់ចំណុចខ្សោយនៃបដិវត្តន៍ខ្លួន ដូចនេះក៏ភ្លេចដល់ការកសាងខ្លួនកម្ចាត់កម្មសិទ្ធិឯកជនដែលមានជាប់ក្នុងខ្លួនដូចដែលយើងខ្ញុំរាយការណ៍ខាងលើរួចមកហើយ ។

◆ យល់ថាបដិវត្តន៍មួយដែលតស៊ូវណ្ណៈខ្លាំង-ចាត់តាំងរបបសមូហភាព មិនចាយលុយ ដកប្រជាជនពីទីក្រុង-ខ្មាំងបង្កប់ពុំអាចរស់នៅបានទេយូរប្រឆាប់គឺវាបែកមុខក្នុងមហាជន តែពុំបានត្រៀមជាយថាហេតុថាខ្មាំងខាងក្រៅអាចប្រថុយប្រថានថាខ្មាំងបង្កប់បើវារស់នៅបានយូរកាលណា វាបន្តកសាងកម្លាំងបានច្រើនកាលណោះ ហើយបើយើងធ្វេសប្រហែស វាវាយយើងបាន ។ ដូចនេះហើយបានជាជំបហរវាយសម្រុកបំពេញ

ភារកិច្ចរបស់យើងខ្ញុំនៅសេរី រយីករយាក មានទុកពេលទំនេរទុកពេលលេងសើចឥតប្រយោជន៍ ខ្វាំងសួរពុំអស់ចម្លើយ ។ល ។

◆ ការប្រមូលមិត្តលើសកលលោកកន្លងមកធ្លាប់រៀនដែរ តែក៏ពុំទាន់ជ្រួតជ្រាបឬគិតគូរទេ ។ នឹកតែម្យ៉ាងថាចង់ឲ្យសកលលោកកោតសរសើរ តែក៏ពុំបានគិតគូរបញ្ហានយោបាយបរទេសដែរ ។

◆ ការឆ្លៀតពេលចុះបង្កបង្កើនផលក៏ពុំសូវបានចុះធ្វើដែរ ។

៣) មូលហេតុ

◆ មូលហេតុដែលបណ្តាលឲ្យយើងខ្ញុំមានគុណវិបត្តិនេះគឺស្តែងចេញអំពីជំហរពុំរាបសាបដិវត្តន៍របស់យើងខ្ញុំនិងជំហរអត្តនោម័តិ ។ ឧទាហរណ៍ៈ មើលឃើញតែបដិវត្តន៍ខ្លួន ភ្លេចគិតកម្លាំងអន្តរជាតិ ។ ដូចនេះវាជះឥទ្ធិពលដល់ជំហរខ្លួន ដូចជាបាតុភូតអំណាចក្នុងការមើលឃើញតែខ្លួន ភ្លេចការរាបសារៀនសូត្រពីមហាជន ទទួលការកសាងពីមហាជនជុំវិញខ្លួន ។ ភ្លេចការរៀនសូត្រមាគ៌ា បដិវត្តន៍សង្គមនិយមនិងការកសាងសង្គមនិយម ។ល ។

៤) ទិសដោះស្រាយ

ក្រោយការរៀនសូត្រនេះ យើងខ្ញុំបានជ្រួតជ្រាបមួយកម្រិតសំខាន់ហើយ ដូចនេះយើងខ្ញុំបានប្តេជ្ញាកសាងសុភាពរាបសាបដិវត្តន៍ឲ្យបានជាជំហរ ដើម្បីបន្តធ្វើបដិវត្តន៍សង្គមនិយម កម្ចាត់កម្មសិទ្ធិឯកជន កសាងកម្មសិទ្ធិសមូហភាព ដោយដាក់ខ្លួនឲ្យទាបជូនសមូហភាព ជូនមហាជនជុំវិញតាមដាននិងកសាង ។ ឯខ្លួនវិញក៏ដាច់ខាតចូលប្រឡូកកសាងបក្ស កសាងអង្គភាពឲ្យល្អបរិសុទ្ធខាងជំហរអធនវិញដែរ ។

## ក) ខ្ទឹមសារខាងចាត់តាំង

១) ជាគុណសម្បត្តិ

កន្លងមកជាមូលដ្ឋាន យើងខ្ញុំបានកសាងពង្រឹងជំហរខ្លួនផ្ទាល់និងមហាជនបានមួយកម្រិត បំពេញភារកិច្ចបានជាទូទៅពុំដែលស្ទះការងារធំដុំទេ ។

កាលនៅគ្នាច្រើនក៏បានអប់រំរៀនសូត្រញឹកញាប់ជារួម ។ ក្រោយមកពេលគ្នាតិចក៏ច្រើនបានណែនាំជាបុគ្គល ៗ ដែរ ។

◆ បញ្ហាជ្រើសរើសនិងគ្រប់គ្រងកម្មាភិបាលក្នុងអង្គភាពក៏មិនដែលថ្លោះធ្លោយប៉ះចំខ្លាំងឬគ្រប់គ្រងសាមគ្គីភាពឯកភាពមិនបាននោះឡើយ ។

◆ បញ្ហាសម្រិតសម្រាំងសមាសភាពអន្តរាយក្នុងអង្គភាពដែលយើងខ្ញុំគ្រប់គ្រង យើងខ្ញុំក៏បានរាយការណ៍ជូនថ្នាក់លើជាបន្តបន្ទាប់ ហើយវិធានការទប់ទល់ជាជីវទស្សន៍តូចៗ ពេលមហាជនធ្វេសប្រហែសក៏មានដើម្បីតាមដានសម្រិតសម្រាំង ។

២) ជាគុណវិបត្តិ

◆ ការខ្វះខាតរបស់យើងខ្ញុំកន្លងមកសំខាន់គឺពុំបានយកចិត្តទុកដាក់លក្ខណៈ ១០"ខ" កសាងខ្លួននិងកម្មាភិបាល ។ ដូចនេះការខ្វះខាតរបស់យើងខ្ញុំដែលបានរាយការណ៍រួចមកហើយពិសេសលើកម្មសិទ្ធិឯកជនក៏បណ្តាលមកអំពីការមិនយកចិត្តទុកដាក់ចំពោះលក្ខណៈ ១០"ខ" នេះដែរ ។

◆ ការខ្វះខាតមួយទៀតគឺធ្ងន់ខាងចាត់តាំង ស្រាលខាងការអប់រំនយោបាយសតិអារម្មណ៍ ។ ឧទាហរណ៍រហ័សដកហូតពុំបានពិនិត្យតាមដានអប់រំកសាងឲ្យម៉ត់ចត់សិន ។ បច្ច័យអាក្រក់គឺធ្វើឲ្យអ្នកមានខ្លួនដទៃទៀតខ្វះរអៀសខ្លួនព្រួយបារម្ភ មិនកក់ក្តៅជាមួយអង្គការ ។

II. ពង្រឹងនិងពង្រីកការដឹកនាំរបស់បក្សក្នុងរយៈកាលថ្មីនៃបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយម

១) ជាគុណសម្បត្តិ

◆ កាលនៅទទួលគ្រប់គ្រងមុខសញ្ញាទី I នៃអង្គភាព២១ មានការងារច្រើន អង្គភាពរៀបចំថ្មីទំនាស់ក៏មាន ការណែនាំថ្នាក់លើក៏មានជាប់រាល់ថ្ងៃ ដូចនេះក៏បានប្រជុំដោះស្រាយប្រជុំដកពិសោធន៍លើកទិសការងារញឹកញាប់ទើបទាន់ពេលវេលាទាន់សំណូមពរបក្ស ។ ដូចនេះ ការធ្វើការងារតាមលក្ខណៈប្រជាធិបតេយ្យប្រមូលផ្តុំក៏មានមួយកម្រិត ។

២) ជាគុណវិបត្តិ

◆ រយៈកាលដែលអង្គភាពត្រូវរៀបចំសាថ្មីដើម្បីរក្សាលក្ខការណ៍ដោយចែកជាពួកៗ ភារកិច្ចរបស់យើងខ្ញុំគឺប្រធានពួក ដូចនេះការងារក៏តិច ពុំសូវមានបាតុភាពអី ការខ្វះខាតរបស់យើងខ្ញុំក៏អត្តនោម័តិ ខានប្រជុំដកពិសោធន៍ ជីវភាពក៏ពុំស៊ីជម្រៅ ដូចនេះកសាងសមត្ថភាពពួកក៏មិនជឿនលឿន ។ រត់ការងារ

ម្នាក់ឯងមិនអស់ក៏ស្វែងចេញអាជ្ញាជាមួយមហាជនខ្លះដែរ ។

◆ បាតុភាពសេរីផ្ទាល់ខ្លួនធ្វើការគ្មានផែនការ គ្មានកម្មវិធីច្បាស់លាស់ ដូចនេះរត់តាមការងារប្រចាំថ្ងៃការងារតិចតែដូចវវល់ជាប់ វិលវល់ភ្លេចទាំងការងារនយោបាយសតិអារម្មណ៍ ។

◆ ក្តាប់លក្ខការណ៍សមូហភាពដឹកនាំ បុគ្គលទទួលខុសត្រូវដោយឡែកនៅប្រហោងខ្លះពេលដែលសតិអារម្មណ៍កម្មសិទ្ធិអំណាចលោតកញ្រ្ជោលម្តងម្កាល ។ ឧទាហរណ៍បន្ទោសសភាពការណ៍ ។

៣) មូលហេតុ

◆ សរុបមូលហេតុនៃការមិនទាន់ជ្រួតជ្រាបខ្លឹមសារចាត់តាំងកន្លងមកនេះដែលច្រើនអំណាច គឺមកពីយើងខ្ញុំពុំបានគិតគូរអំពីការកសាងខ្លួន តស៊ូកម្ចាត់កម្មសិទ្ធិឯកជនដោយការរៀនសូត្រផ្ទាល់ ឬអប់រំមហាជនឲ្យបានម៉ត់ចត់ទៀងទាត់នោះឡើយ ។

◆ ការធ្វើជីវភាពក៏ពុំទាន់ស៊ីជម្រៅ ។

៤) សរុបទៅ ទិសដោះស្រាយរបស់យើងខ្ញុំគឺរៀនសូត្រផ្ទាល់និងអប់រំមហាជន ធ្វើជីវភាពឲ្យស៊ីជម្រៅនិងទៀងទាត់ប្រជុំដកពិសោធន៍ក្នុងពួកឲ្យទៀងទាត់ ដើម្បីលើកទិសការងារចែកភារកិច្ចជាសមូហភាព ហើយយកសមូហភាពជាបង្អែកដើម្បីតាមដានផ្ទាល់ខ្លួនផង ។

ឃ) សរុបរួម

១) គុណសម្បត្តិធំៗរបស់យើងខ្ញុំដែលដើរតួជាងគេគឺ ÷

◆ កសាងកម្មសិទ្ធិសមូហភាពបានជាមូលដ្ឋានក្នុងការរស់នៅស៊ីចុក ធ្វើការងារ គោរពការណែនាំរបស់ថ្នាក់លើបាន គ្រប់គ្រងសាមគ្គីភាពឯកភាពបាន ។

◆ បំពេញភារកិច្ចបាននឹងនមួយកម្រិត ពុំតក់ក្រហល់ពុំភ្លើតភ្លើនពេលជ័យជំនះ ។

◆ បានរួមក្នុងអង្គភាព២១រាយការណ៍សមាសភាពអន្តរាយខ្លាំងឆ្លើយដាក់ សមាសភាពសេរី ធ្វេសប្រហែសដើម្បីឲ្យអង្គការមានវិធានការផ្សេងៗ ពិសេសនៅមុខសញ្ញា I ។

២) គុណវិបត្តិធំៗរបស់យើងខ្ញុំដែលដើរតួជាងគេគឺ ÷

◆ កម្មសិទ្ធិឯកជនខាងអំណាច ។

◆ ពុំបានតស៊ូមតិឲ្យឯកភាពកាលនៅក្នុងគណៈអង្គភាពសួរ ។

◆ ខ្វះការរៀនសូត្រផ្ទាល់ រៀនសូត្រក្នុងមហាជន ប្រជុំជីវភាពមិនម៉ត់ចត់ ពុំទាន់ប្រជុំដកពិសោធន៍ដឹកនាំជាសមូហភាពត្រឹមត្រូវនៅក្នុងរយៈពេលចុងក្រោយ ។

◆ មើលធ្ងន់ការងារសន្តិបាលជាងការងារនយោបាយសតិអារម្មណ៍ ។

◆ មានជំហររួចខ្លួន ។

៣) មូលហេតុគុណវិបត្តិដែលដើរតួជាងគេកន្លងមកគឺ ÷

◆ ខ្វះការរៀនសូត្រមាគ៌ាបដិវត្តន៍សង្គមនិយមនិងការកសាងសង្គមនិយម ខ្វះដឹកនាំជាសមូហភាព ខ្វះជីវភាពម៉ត់ចត់ ។ល ។

◆ ទទួលឥទ្ធិពលនៃជំហររបស់វណ្ណភាពដើមរបស់យើងខ្ញុំជាអនុធន ឧទាហរណ៍ជំហររួចខ្លួនជាដើម ។

៤) ទិសដោះស្រាយរបស់យើងខ្ញុំគឺឆ្លៀតរៀនសូត្រខ្លួនឯងនិងផ្សព្វផ្សាយក្នុងមហាជន ធ្វើជីវភាពឲ្យម៉ត់ចត់និងទៀងទាត់ប្រជុំដកពិសោធន៍ដឹកនាំជាសមូហភាព ដើម្បីកសាងមហាជនក្នុងពួកឲ្យម្ចាស់ការ និងឲ្យមហាជនតាមដានកសាងខ្លួនវិញ ហើយខ្លួនយើងខ្ញុំនឹងប្តេជ្ញាដាក់ខ្លួនជូនសមូហភាពតាមដានកសាង ។

ខាងទស្សនៈគោលជំហរជាចំណុចខ្សោយរបស់យើងខ្ញុំគឺអំណាចនិងជំហររួចខ្លួន ឯចំណុចខ្លាំងរបស់យើងខ្ញុំគឺមានជំហរបែងចែកមិត្តសត្រូវច្បាស់លាស់ ស្មោះត្រង់ និងមានពិសោធន៍ក្នុងការងារសន្តិបាលមួយកម្រិត ។ ជាទិសថ្ងៃមុខយើងខ្ញុំនឹងជំរុញចំណុចខ្លាំង កម្ចាត់ចំណុចខ្សោយ ដោយចាត់តាំងមានវិធានការដូចខាងលើ ។

ថ្ងៃ ៣-១២-៧៦

## ស្តាប់ប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឲ្យមានកម្មវិធីអានអត្ថបទទស្សនាវដ្តីស្វែងរកការពិតដែលចាក់ផ្សាយរៀងរាល់ថ្ងៃពុធនិងព្រហស្បតិ៍ វេលាម៉ោង៣ះ៣០-៣ះ៤៥នាទីតាមរយៈវិទ្យុ១០២ MHz របស់មណ្ឌលពត៌មានស្ត្រីកម្ពុជា ។

**ផាត រចនា និង លី សុផល**

# បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរ ស-២១ (គុកទួលស្លែង)

រៀបចំនិងចងក្រងដោយៈ យិន នាន

(តពីលេខមុន)

| ល.រ | ឈ្មោះ | តួនាទី | កន្លែងយក | ថ្ងៃចូល | ថ្ងៃកម្ទេច |
|---|---|---|---|---|---|
| ១០០៩ | ឌី ប៊ុនឡុង ហៅ សាយ | យុទ្ធជន | រោងចក្រប្រេងកាត | ២៩-៧-៧៦ | ៥-១០-៧៦ |
| ១០១០ | ឈុន ច្រិច ហៅ វ៉ុម | យុទ្ធជន | ថាមពល | ១៨-៨-៧៦ | ៥-១០-៧៦ |
| ១០១១ | ដួន វួន ហៅ ជាតិ | អនុកងហារ | ថាមពល | ៣១-៨-៧៦ | ៥-១០-៧៦ |
| ១០១២ | ឈិត ឈត ហៅ មី | អនុក្រុម | ពាណិជ្ជកម្មកំពត | ២៥-៦-៧៥ | ៥-១០-៧៦ |
| ១០១៣ | ហ៊ិន ហាន | មេក្រុម | ពាណិជ្ជកម្ម | ១០-៧-៧៦ | ៥-១០-៧៦ |
| ១០១៤ | ក្លឹង ជិន | យុទ្ធជន | កងពល៥០២ | ១៩-៩-៧៦ | ៥-១០-៧៦ |
| ១០១៥ | កិច ហួយ (ស្រី) | ម្តាយ សុក ឃីម | រោងចក្រ ត-១០ | ៤-១០-៧៦ | ៥-១០-៧៦ |
| ១០១៦ | ស្រ៊ុន ហ៊ុន | កូន ព្រូ ស្រ៊ុន | រោងចក្រប្រេងកន្ទក់ | ៤-១០-៧៦ | ៥-១០-៧៦ |
| ១០១៧ | យុ មៀង ហៅ បួរ | យុទ្ធជន | មន្ទីរ ឈ-៤ | ២៨-៨-៧៦ | ៥-១០-៧៦ |
| ១០១៨ | សុក ផល្លី | អនុកងរយ | កងពល១៧០ | ១៧-៩-៧៦ | ៦-១០-៧៦ |
| ១០១៩ | កង ប៉ាង ហៅ សារ៉េន | អនុកងរយ | កងពល១៧០ | ១៧-៩-៧៦ | ៦-១០-៧៦ |
| ១០២០ | ចាន់ អួន ហៅ សុវ៉ាន | អនុកងរយ | កងពល១៧០ | ១៧-៩-៧៦ | ៦-១០-៧៦ |
| ១០២១ | យោគ សាំង | អនុកងរយ | កងពល១៧០ | ១៧-៩-៧៦ | ៦-១០-៧៦ |
| ១០២២ | សុក ពៅ | អនុកងរយ | កងពល១៧០ | ១៧-៩-៧៦ | ៦-១០-៧៦ |
| ១០២៣ | គី ហ៊ុន ហៅ សុផាត | អនុកងរយ | កងពល១៧០ | ១៧-៩-៧៦ | ៦-១០-៧៦ |
| ១០២៤ | ពោជ ហ៊ន់ ហៅ សោមសារឿន | មេក្រុម | កងពល១៧០ | ១៧-៩-៧៦ | ៦-១០-៧៦ |
| ១០២៥ | មៀច ចុន ហៅ សាម៉េត | កងរយ | កងពល១៧០ | ១៧-៩-៧៦ | ៦-១០-៧៦ |
| ១០២៦ | សូ សុន ហៅ ស្ទួត | កងរយ | កងពល១៧០ | ១៧-៩-៧៦ | ៦-១០-៧៦ |
| ១០២៧ | មាស ម៉ុន | កងរយ | កងពល១៧០ | ១៧-៩-៧៦ | ៦-១០-៧៦ |
| ១០២៨ | កែវ កាន ហៅ ចិត្ត | កងរយ | កងពល១៧០ | ១៧-៩-៧៦ | ៦-១០-៧៦ |
| ១០២៩ | ខឹម យ៉ាំ | ប្រធានកងរយ | កងពល១៧០ | ១៧-៩-៧៦ | ៦-១០-៧៦ |
| ១០៣០ | កែវ ឃុន ហៅ អឿន | អនុកងរយ | កងពល១៧០ | ១៧-៩-៧៦ | ៦-១០-៧៦ |
| ១០៣១ | អួម បាន ហៅ សុភួន | ប្រធានកងរយ | កងពល១៧០ | ១៩-៩-៧៦ | ៦-១០-៧៦ |
| ១០៣២ | ទិត ខ្មៅ ហៅ សាម៉ឺន | អនុកងរយ | កងពល១៧០ | ១៩-៩-៧៦ | ៦-១០-៧៦ |
| ១០៣៣ | ទោម ខ្មៅ | អនុកងរយ | កងពល១៧០ | ១៩-៩-៧៦ | ៦-១០-៧៦ |
| ១០៣៤ | គង់ សឿន | ប្រធានកងរយ | កងពល១៧០ | ១៩-៩-៧៦ | ៦-១០-៧៦ |
| ១០៣៥ | គង់ ណន | ប្រធានកងហារ | កងពល៥០២ | ១៩-៩-៧៦ | ៦-១០-៧៦ |
| ១០៣៦ | ឈុន សារុន | ប្រធានកងហារ | កងពល៥០២ | ១៩-៩-៧៦ | ៦-១០-៧៦ |
| ១០៣៧ | ដា ថន | ប្រធានពួក | កងពល៥០២ | ១៩-៩-៧៦ | ៦-១០-៧៦ |

| | | | | | |
|---|---|---|---|---|---|
| ១០៣៨ | ម៉ី រឿង ហៅ សុផល | កងហា | កងពល៥០២ | ១៩-៩-៧៦ | ៦-១០-៧៦ |
| ១០៣៩ | គុល ឌុន | ប្រធានក្រុម | កងពល៥០២ | ១៩-៩-៧៦ | ៦-១០-៧៦ |
| ១០៤០ | ជុំ រឿន ហៅ ចំរើន | ប្រធានកងហា | កងពល៥០២ | ២៤-៩-៧៦ | ៦-១០-៧៦ |
| ១០៤១ | ហេង ស្រេង | អនុក្រុម | កងពល៥០២ | ២៤-៩-៧៦ | ៦-១០-៧៦ |
| ១០៤២ | អ៊ូ សុន ហៅ សារុន | ប្រធានកងហា | កងពល៥០២ | ២៤-៩-៧៦ | ៦-១០-៧៦ |
| ១០៤៣ | នេត យឿន | ប្រធានក្រុម | កងពល៥០២ | ២៤-៩-៧៦ | ៦-១០-៧៦ |
| ១០៤៤ | ទឹម ដន | យុទ្ធជន | កងពល៥០២ | ២៤-៩-៧៦ | ៦-១០-៧៦ |
| ១០៤៥ | ដុក យៀន | មេក្រុម | កងពល៥០២ | ២៤-៩-៧៦ | ៦-១០-៧៦ |
| ១០៤៦ | មិន ស៊ីន | ប្រធានអនុសេនាធំ | កងពល៥០២ | ២៤-៩-៧៦ | ៦-១០-៧៦ |
| ១០៤៧ | អួន នឿន | មេក្រុម | កងពល៥០២ | ២៤-៩-៧៦ | ៦-១០-៧៦ |
| ១០៤៨ | ខៀវ សាយ ហៅ ភិន | កងវរយ | កងពល៥០២ | ១៧-៩-៧៦ | ៦-១០-៧៦ |
| ១០៤៩ | សូ ឯម ហៅ សំអាត (ស្រី) | អនុកងវរយ | កងពល៥០២ | ១៩-៩-៧៦ | ៦-១០-៧៦ |
| ១០៥០ | អន ផាត | យុទ្ធជន | កងពល១៧០ | ១៧-៩-៧៦ | ៧-១០-៧៦ |
| ១០៥១ | ខែក សៀន | សមាជិកកងវរយ | កងពល១៧០ | ១៧-៩-៧៦ | ៧-១០-៧៦ |
| ១០៥២ | នៅ ដុន | មេក្រុមកសិកម្ម | កងពល១៧០ | ១៧-៩-៧៦ | ៧-១០-៧៦ |
| ១០៥៣ | ធុច សុខខៃ ហៅ យ៉ែន | សេដ្ឋកិច្ច | កងពល១៧០ | ១៩-៩-៧៦ | ៧-១០-៧៦ |
| ១០៥៤ | ទឹម សុខុន | ប្រធានកងហា | កងពល៥០២ | ១៩-៩-៧៦ | ៧-១០-៧៦ |
| ១០៥៥ | សុក សៀត | បញ្ជាកងវរយ | កងពល៥០២ | ១៩-៩-៧៦ | ៧-១០-៧៦ |
| ១០៥៦ | គង់ ឆុំ ហៅ សារឿន | ប្រធានកងហា | កងពល៥០២ | ១៩-៩-៧៦ | ៧-១០-៧៦ |
| ១០៥៧ | ហៃ ហម | ប្រធានកងហា | កងពល៥០២ | ២៤-៩-៧៦ | ៧-១០-៧៦ |
| ១០៥៨ | ភ៉ា សារ៉េន | កងវរយ | កងពល៥០២ | ២៤-៩-៧៦ | ៧-១០-៧៦ |
| ១០៥៩ | វង់ សេន | អនុសេនាតូច | កងពល៥០២ | ២៤-៩-៧៦ | ៧-១០-៧៦ |
| ១០៦០ | វេន សារឿន | មេក្រុម | កងពល៥០២ | ២៤-៩-៧៦ | ៧-១០-៧៦ |
| ១០៦១ | ឃឹម សាបូរ | ប្រធានអនុសេនាតូច | កងពល៥០២ | ២៨-៩-៧៦ | ៧-១០-៧៦ |
| ១០៦២ | សូ ឈន | នីរសាកងវរយ | កងពល៥០២ | ២៨-៩-៧៦ | ៧-១០-៧៦ |
| ១០៦៣ | ភ៉ន់ សារ៉េន | ស្នងការកងវរយ | កងពល៥០២ | ២៨-៩-៧៦ | ៧-១០-៧៦ |
| ១០៦៤ | ហង់ អៀច ហៅ សារិទ្ធ | ស្នងការកងហា | កងពល៥០២ | ២៨-៩-៧៦ | ៧-១០-៧៦ |
| ១០៦៥ | ញ៉ឹក ជ្រា | ប្រធានកងហា | កងពល៥០២ | ២៨-៩-៧៦ | ៧-១០-៧៦ |
| ១០៦៦ | ហ៊ុន ហុង ហៅ ខុម | នីរសា | កងពល៥០២ | ២៨-៩-៧៦ | ៧-១០-៧៦ |
| ១០៦៧ | ប៉ែន យឿន ហៅ សុផល | ស្នងការកងវរយ | កងពល៥០២ | ២៨-៩-៧៦ | ៧-១០-៧៦ |
| ១០៦៨ | វង យ៉ូន | យុទ្ធជន | កងពល៥០២ | ២៨-៩-៧៦ | ៧-១០-៧៦ |
| ១០៦៩ | ម៉ុម យ៉ន់ | មេក្រុម | កងពល៥០២ | ២៨-៩-៧៦ | ៧-១០-៧៦ |
| ១០៧០ | ប៊ុន ស៊ីម | អនុក្រុម | កងពល៥០២ | ២៨-៩-៧៦ | ៧-១០-៧៦ |
| ១០៧១ | ថៃ ចើន ហៅ ធី | មេពួក | កងពល៥០២ | ២៨-៩-៧៦ | ៧-១០-៧៦ |

**(នៅមានត)**

# ឡាយ ក្លឹង ហៅ ដុស

ឡាយ ក្លឹង ហៅ ដុស ជាស្ត្រីម្នាក់ដែលខ្មែរក្រហមបានចាប់ខ្លួនពីខេត្តមណ្ឌលគិរីមកដាក់នៅគុកទួលស្លែងនៅឆ្នាំ១៩៧៧ ។ ស្របនឹងទំនោរនយោបាយនាពេលនោះ ដុស ត្រូវបានចោទប្រកាន់ថាឃុបឃិតជាមួយខ្សែបង្កប់វៀតណាម ។ តាមការស្រាវជ្រាវ ការចាប់ខ្លួននេះអាចបណ្តាលមកពីមូលហេតុពីរផ្សេងទៀត ។ ទីមួយ ទោះបីជាពេលត្រូវចាប់ខ្លួន ដុស ជាកម្មាភិបាលថ្នាក់ក្រោមក៏ដោយ ប៉ុន្តែគាត់មានប្រវត្តិរូបជាកូនរបស់រាជការសង្គមចាស់ ។ ទីពីរ គាត់ធ្វើការឃើតយ៉ាវដោយសារគាត់មានផ្ទៃពោះនិងនឹកប្តីដែលធ្វើទាហាននៅឆ្ងាយ ។

ឪពុករបស់ ដុស ត្រូវបានឧត្តមសេនីយ៍ម្នាក់នៃរបបសាធារណរដ្ឋខ្មែរដែលមកពីភ្នំពេញ បាញ់សម្លាប់ចោលនៅស្រុកកោះញែកនៅឆ្នាំ១៩៧០ ។ ប្រហែលដោយសារមូលហេតុនេះហើយបានជា ដុស ចូលបម្រើបដិវត្តន៍ខ្មែរក្រហមនៅឆ្នាំ១៩៧៣ ។ ទោះជាយ៉ាងណាក៏ដោយ ខ្មែរក្រហមមិនបានទុកចិត្ត ដុស ទេ ព្រោះគាត់ជាកូនរបស់អតីតមន្ត្រីរាជការពីរបបសង្គមរាស្ត្រនិយម ។ ដុស បានសរសេរនៅក្នុងចម្លើយរបស់គាត់ថាឪពុករបស់គាត់គឺជាទាហានដែលបានរំសាយរួចទៅហើយ ។ ប្អូនប្រុសរបស់ ដុស ដែលនៅរស់រហូតដល់បច្ចុប្បន្នបានប្រាប់យើងថា ឪពុករបស់គាត់ជាបាល័ដ្ឋស្រុក ។ រ៉ា អតីតអ្នកជិតខាងរបស់ ដុស កាលពីរបបខ្មែរក្រហមគិតថា ដុស ត្រូវចាប់ខ្លួនដោយសារតែគាត់មានផ្ទៃពោះ ធ្វើការឃើតយ៉ាវជាងធម្មតាហើយគាត់នឹកប្តីរបស់គាត់ខ្លាំងពេក ។


ឡាយ ហ៊ាញ

ឡាយ ហ៊ាញ ដែលជាប្អូនរបស់ដុស គិតថា ករណីរបស់ ដុស គឺជាករណីសងសឹក ។ ការបកស្រាយរបស់ ហ៊ាញ ស្របទៅនឹងសភាពការណ៍ទូទៅនៅស្រុកកោះញែកក្នុងឆ្នាំ១៩៧៧ ។ ប្តីរបស់ ដុស ឈ្មោះ ផៃ សុទ្ធ ជាជនជាតិឡាវ ។ នៅក្នុងឆ្នាំ១៩៧៧ ទាំងពីរនាក់ប្តីប្រពន្ធធ្វើការជិតគ្នា គឺម្នាក់នៅមន្ទីរ ក-១៦ និងម្នាក់ទៀតនៅមន្ទីរ ក-១១ ។ មុនពេល ដុស ត្រូវចាប់ខ្លួន ផៃ សុទ្ធ ដែលជាប្តី ត្រូវបញ្ជូនទៅឯព្រំដែនកម្ពុជា-វៀតណាម ។ នៅឯ ក-១៦ ឯណេះវិញ ដុស មានទំនាក់ទំនងជិតស្និទ្ធជាមួយឈ្មោះ បុប្ផា ដែលជាភរិយារបស់ឈ្មោះ ខាំភូន លេខាតំបន់១០៥ និងជាប្រធានមន្ទីរសេដ្ឋកិច្ចឬហៅមន្ទីរក-១៦ ។ ខ្មែរក្រហមបានចោទប្រកាន់ថា ខាំភូន ជាខ្សែវៀតណាម ដែលនាំឲ្យ ដុស ត្រូវចាប់បញ្ជូនមកគុកទួលស្លែង ។ គាត់ត្រូវចាប់ខ្លួននៅ ខែ៧ ឆ្នាំ១៩៧៧ ពីភ្នំក្រោលដែលជាមជ្ឈមណ្ឌលសេដ្ឋកិច្ចនយោបាយរបស់តំបន់ទាំងមូល ។

ដុស បានឆ្លើយសារភាពចំពោះមុខអ្នកសួរចម្លើយឈ្មោះ ប្រាក់ ខន ថា គាត់បានទាក់ទងជាមួយ បុប្ផា ប្រពន្ធរបស់ ខាំភូន ហើយនិងឈ្មោះ យ៉ុន នីសារបស់ ខាំភូន ក្នុងការឃុបឃិតជាមួយវៀតណាមដើម្បីផ្តួលរំលំអង្គការ ។ តាំងពីដើមឆ្នាំ១៩៧៣ ដុស បានបំផ្លាញក្នុងលក្ខណៈសម្ងាត់នូវបណ្តាទ្រព្យសម្បត្តិរបស់អង្គការ ហើយមានពេលមួយនោះគាត់បានខុសសីលធម៌ជាមួយអ្នកធ្វើការជាមួយគាត់ឈ្មោះ ស៊ី ។ នៅដើមឆ្នាំ១៩៧៧ ដុស, បុប្ផា, ខាំភូន និងអ្នកដទៃទៀត បានជួបគ្នានៅឯទំនប់ភូមិក ហើយបាននាំយកមាន់៥ក្បាល ជ្រូក១ក្បាលទៅទីនោះដើម្បីជប់លៀងស្វាគមន៍វៀតណាមឈ្មោះ ដឹក និង ថៃ ។ ខាំភូន ទទួលទង់មួយពីឈ្មោះ ដឹក ។ ទង់នោះមានផ្ទៃពណ៌ខៀវនិងស មានរូបអង្គរវត្តកំពូល៣ពណ៌លឿង ហើយនៅពីក្រោយនោះមានរូបតាចាស់ពុកមាត់វែងដែលតំណាងឲ្យបក្សពលករវៀតណាមនិងហូជីមិញ ។ នៅខែ៤ឆ្នាំ១៩៧៧ បុប្ផា និង ដុស បានជួបគ្នាម្តងទៀតនៅកន្លែងដដែល ហើយបានជួបនឹងអ្នកដែលទើបនឹងកសាងបានថ្មី ១នាក់ ។ ខែ៥ឆ្នាំ១៩៧៧ ក្រុមនេះបានជួបគ្នាទៀតរួមមានទាំង

ដុស, បុប្ផា, យ៉ុន, ហួរ, កង, ខាអេន, ប៉ាង, ប៊ុន និង ព្រឹម ។ ការជួបជុំគ្នានេះបានមូលមតិឡើងថា ការធ្វើអ្វីមួយនឹងមិនបានសម្រេចទេ ប្រសិនបើគ្មានវៀតណាមជួយ ព្រោះថាកន្លងមក អ្នកដៃដើងដែលធ្វើការជាមួយគ្នាមួយចំនួនត្រូវចាប់ខ្លួនរួចទៅហើយ ។ ការដកខ្លួនឬក៏សារភាពនឹងមានន័យថា បណ្តោយឲ្យគ្រួសារទាំងមូលត្រូវខ្មែរក្រហមសម្លាប់ ហើយត្រូវតែរត់ទៅវៀតណាម ប្រសិនបើវៀតណាមមិនមកជួយ ។ ចម្លើយសារភាពរបស់ ដុស សរសេរដោយ ប្រាក់ ខន (ប្រាក់ ខន ជាអ្នកសួរចម្លើយនៅមន្ទីរ ស-២១) ។ ចម្លើយសារភាពនេះមានចំនួន១៨ទំព័រ ចុះហត្ថលេខាដោយឈ្មោះ ដុស មានថ្ងៃខែនៅគ្រប់ទំព័រ ហើយមានស្នាមផ្តិតមេដៃរបស់ ដុស នៅទំព័រចុងក្រោយបំផុតផង ។ ថ្ងៃចុងក្រោយដែល ដុស ត្រូវសួរចម្លើយគឺថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៧៨ ។

បើយោងទៅតាមអ្នកជិតខាងនិងសាច់ញាតិថា តាមពិត ដុស គឺជាខ្មែរ ប៉ុន្តែគាត់បន្លំខ្លួនថាជាពួនប្រហែលជាចង់ឲ្យអ្នកសួរចម្លើយបន្ធូរបន្ថយការធ្វើទារុណកម្មហើយមើលទៅ ។ ទំព័រទី១នៃចម្លើយសារភាពគឺជាការរៀបរាប់បង្ហាញផ្លូវយើងទៅកាន់ភូមិកំណើតរបស់ ឡាយ ក្លឹង ហៅ ដុស គឺនៅឃុំស្រែសង្គម ស្រុកកោះញែក ខេត្តមណ្ឌលគិរី ។ នៅទីនោះ យើងបានជួបអ្នកជិតខាងនិងសាច់ញាតិរបស់ ដុស ។ ទាំងអស់គ្នាដឹងថា ដុស ត្រូវបានសម្លាប់ ប៉ុន្តែគ្មាននរណាម្នាក់ដឹងថាមកពីមូលហេតុអ្វី ហើយក៏មិនហ៊ានសួរដែរនៅជំនាន់នោះ ។ អ្នកទាំងអស់គ្នាក៏មិនដឹងថា ដុស ត្រូវបញ្ជូនមកគុកទួលស្លែងដែរ ។

នៅថ្ងៃទី២៨ ខែ១២ ឆ្នាំ១៩៩៩ យើងបានជួបជាមួយ ថែវ ម៉ៅ ដែលជាប្អូនថ្លៃរបស់ ដុស ។ ថែវ ម៉ៅ បាននិយាយថា៖

ខ្ញុំមានអាយុ៣៥ឆ្នាំ ជាជនជាតិខ្មែរ ។ ខ្ញុំកើតនៅភូមិកំពង់សឹង ឃុំកំពង់សឹង ស្រុកព្រះស្តេច ខេត្តព្រៃវែង ។ នៅក្នុងរបបប៉ុលពត ខ្ញុំនៅភូមិ៩ ឃុំស្រែសង្គម ស្រុកកោះញែក ខេត្តមណ្ឌលគិរី ។ ខ្ញុំរៀបការនៅឆ្នាំ១៩៧៩ ប្តីរបស់ខ្ញុំឈ្មោះ ស៊ឹម ស៊ិនគីល ។ ឪពុករបស់គាត់ឈ្មោះ ស៊ឹម ស៊ិនឡាយ ។ ឈ្មោះ ឡាយ ក្លឹង ហៅ ដុស គឺជាបងរបស់ប្តីខ្ញុំ ។ តាមពិតទៅ ដុស គឺជាខ្មែរ គាត់រៀបការជាមួយជនជាតិឡាវ ។ ខ្ញុំមិនដែលបានជួប ដុស ទេ ។ ខ្ញុំដឹងរឿង ដុស តាមរយៈប្តីរបស់ខ្ញុំ ។ យើងមិនដឹងហេតុអ្វីដែល ដុស ត្រូវសម្លាប់ទេ ។ បើតាមខ្ញុំដឹង នៅពេលនោះ ដុស មានផ្ទៃពោះផង ។ ដុស រស់នៅឃុំដីមាឌ ក្នុងឃុំណងឃីឡឹក ស្រុកកោះញែក មណ្ឌលគិរី ។ ដុស ធ្វើការនៅមន្ទីរ ក-១៦ ។ សព្វថ្ងៃបងប្អូនរបស់ប្តីខ្ញុំអត់រស់នៅភូមិនេះទៀតទេ គេរស់នៅ សែនមនោរម្យឯណោះ ។ បងប្អូនរបស់ ឡាយ ក្លឹង មានឈ្មោះ ប៊ុក, ហ៊ាញ, ម៉ៅ និង ពៅ ។ ឈ្មោះ ពៅ ត្រូវខ្មែរក្រហមសម្លាប់នឹងចម្រឹងដែក ។ អ្នកទាំងអស់នោះគឺជាកូនរបស់ពុក ស៊ឹម ស៊ិនឡាយ ។ ឥឡូវនេះគ្រួសាររបស់ខ្ញុំមានកូន៣នាក់ ។ យើងធ្វើស្រែហើយនិងលក់ដូរបន្តិចបន្តួច ។


សល់ រ៉ា

នៅថ្ងៃបន្ទាប់ គឺថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៩ ក្រុមស្រាវជ្រាវរបស់យើងបានជួបមនុស្សម្នាក់ទៀតឈ្មោះ សល់ រ៉ា ដោយចៃដន្យនៅតាមផ្លូវឆ្ពោះទៅត្រពាំងគៀន ដែលជាទីតាំងរណ្តៅសាកសពធំបំផុតនៅខេត្តមណ្ឌលគិរី ។ រ៉ា ជាជនជាតិពួន ភេទប្រុស អាយុ៥០ឆ្នាំ ។ គាត់ចេះនិយាយភាសាខ្មែរ ។ រ៉ា បានស្គាល់ ឡាយ ក្លឹង ហៅ ដុស ព្រោះគាត់ធ្វើការជិតមន្ទីររបស់ ដុស ។ រ៉ា មិនបានដឹងអំពីមូលហេតុដែល ដុស ត្រូវចាប់ខ្លួនទេ គាត់គិតថា មូលហេតុមកពី ដុស មានផ្ទៃពោះហើយនឹកប្តីច្រើនពេកមិនអាចធ្វើការងារបាន ។ រ៉ា ក៏មិនបានដឹងថា ដុស ត្រូវបញ្ជូនទៅគុកទួលស្លែងដែរ ។

តាមសម្តីរបស់ រ៉ា មានដូចតទៅ៖

ឡាយ ក្លឹង ហៅ ដុស សម្បុរខ្មៅ ទាប ប្តីឈ្មោះ ដៃ សុទ្ធ ទាបដែរប៉ុន្តែស ។ បងប្អូនរបស់ ដុស ឈ្មោះ ប៊ុក, ហ៊ាញ, គីល, និងម្នាក់ទៀតដែលឥឡូវរស់នៅទីរួមខេត្តមណ្ឌលគិរី ។ ឡាយក្លឹង ជាកូនស្រីរបស់សេហ្វម្នាក់ ។ គាត់រស់នៅជាមួយពួន ។ ម្តាយរបស់នាងស្លាប់ទៅហើយ ។ ដុស និងខ្ញុំធ្វើការជិតគ្នា ។ ខ្ញុំនៅមន្ទីរ ក-១១ ដុស នៅមន្ទីរសេដ្ឋកិច្ចហៅ ក-១៦ ។ ការងារប្រចាំថ្ងៃរបស់ ដុស គឺកិនស្រូវ បុកស្រូវ ដេរបាវដាក់ស្រូវ ។ ដុស មិនមែនជាសមាជិកបក្សអីទេ ។ ពេលដែល ដុស ត្រូវចាប់ខ្លួន

នោះគឺប្រហែលនៅក្នុងរដូវវស្សាឆ្នាំ១៩៧៧ ។ ខ្ញុំដឹងថា ដុស ត្រូវចាប់ខ្លួនពីព្រោះបាត់គាត់អត់ឃើញមកធ្វើការ ប៉ុន្តែខ្ញុំមិនហ៊ានសួរអ្នកណាទេ ។ ពេលនោះ ដុស មានផ្ទៃពោះ ។ ខ្ញុំដឹងថាម្តាយក្មេកខ្ញុំក៏ត្រូវចាប់ខ្លួនក្នុងពេលជាមួយគ្នានោះដែរ ។ ប្រហែលពីរបីថ្ងៃក្រោយមក ឈ្មោះ អ៊ី រ៉ែត ដែលជាអ្នកបើកឡានឲ្យមេតំបន់ បានខ្សឹបប្រាប់ខ្ញុំថា ដុស និងម្តាយក្មេករបស់ខ្ញុំត្រូវអង្គការសម្លាប់នៅឯត្រពាំងតឿនហើយ ។ ខ្ញុំដឹងរឿងនេះហើយមិនហ៊ាននិយាយអ្វីទេ ។ អស់រយៈពេលយូរណាស់ទម្រាំប្តីរបស់គាត់ដឹងអំពីការចាប់ខ្លួនប្រពន្ធ គឺរហូតដល់ខែ១២ ។ ប្តីរបស់គាត់មិនហ៊ាននិយាយអ្វីទេ ។ គ្មាននរណាហ៊ានសួរឬក៏និយាយអ្វីទាំងអស់ បើមិនអ៊ីចឹងទេត្រូវស្លាប់ទាំងគ្រួសារ ។ ខ្ញុំមិនយល់ពីរបបផ្តាច់ការនោះឡើយ ។ ដុស និងប្តីរបស់គាត់ រៀបការនៅក្នុងរបបប៉ុលពត ។ កាលពេលរៀបការនោះមានរហូតដល់១៥គូ ។ អ្នកផ្តួចផ្តើមរៀបការឲ្យគឺប្រធានតំបន់១០៥ ។ ខ្ញុំមិនបានចូលរួមទេ មានតែកម្មាភិបាលលើៗប៉ុណ្ណោះដែលបានចូលរួម ។ ដៃ សុខ គឺជាក្មួយរបស់ខ្ញុំ ។ គាត់គឺជាអ្នកលីសែងម៉ាស៊ីន ហើយក្រោយមកទៅធ្វើទ័ពនៅព្រំដែន ។ ខ្ញុំមិនដឹងច្បាស់ថា ដុស ត្រូវបញ្ជូនទៅណាដែរ ព្រោះមានឡានពីរ ។ តែក្នុងឡាននោះប្រាប់ខ្ញុំថាឡានមួយឈ្មោះឡានសេរីកា ឡានមួយទៀតមិនមែនឡានរុស្ស៊ីទេ គឺឡានហ្សីបគ្រួសី ។ អ្នកបើកឡាននោះឈ្មោះ ឆឺន សព្វថ្ងៃរស់នៅប៉ូស្រា ហើយអ្នកបើកឡានម្នាក់ទៀតឈ្មោះ អ៊ី រ៉ែត ។

តាមរយៈ ប៉ែ ម៉ៅ និង សល់ រ៉ា យើងបានជួបប្អូនរបស់ឡាយ ក្លីង ឈ្មោះ ឡាយ ហ៊ាញ នៅភូមិកណ្តាល ឃុំស្ពានមានជ័យ ស្រុកសែនមនោរម្យ ។ ហ៊ាញ គិតថា ដុស ត្រូវចាប់ខ្លួនមកពីខ្មែរក្រហមចង់សងសឹក ។ ហ៊ាញ បានរៀបរាប់ថា÷

បងស្រីរបស់ខ្ញុំកើតនៅឆ្នាំ១៩៥៨ ។ គាត់ឈប់រៀននៅថ្នាក់ទី៨ ។ នៅពាក់កណ្តាលឆ្នាំ១៩៧៣ គាត់ចូលខ្មែរក្រហមតាមរយៈមេភូមិម្នាក់ឈ្មោះ យ៉ន ។ បងស្រីរបស់ខ្ញុំធ្វើការខាងសេដ្ឋកិច្ចតំបន់១០៥ ។ ភារកិច្ចរបស់គាត់គឺដឹកជញ្ជូនស្រូវទៅដាក់នៅម៉ាស៊ីនកិនស្រូវ ។ គាត់ធ្វើការនេះរហូតដល់ឆ្នាំ១៩៧៧ ទើបត្រូវចាប់ខ្លួន ។ នៅឆ្នាំ១៩៧៦ គាត់រៀបការជាមួយអ្នកធ្វើការនៅមន្ទីរក-១១ ជាជនជាតិឡាវឈ្មោះ សុខ ។ នៅពេល


ក្រុមគ្រួសារជនជាតិភាគតិច

ដែលបងខ្ញុំមានផ្ទៃពោះ៥ខែ គាត់ត្រូវសន្តិសុខចាប់ខ្លួនបញ្ជូនទៅមន្ទីរភ្នំក្រោលដែលជាមន្ទីរសន្តិសុខតំបន់១០៥ ហើយមានមនុស្សផ្សេងៗទៀតក៏ត្រូវចាប់ខ្លួនបញ្ជូនទៅទីនោះដែរ ។ អ្នកគ្រប់គ្រងមន្ទីរសន្តិសុខភ្នំក្រោលនេះគឺចៅហ្វាយខេត្ត ឈ្មោះ ហម ក្រោយមកទៀតឈ្មោះ សារុន ។ ខ្ញុំមិនបានដឹងថាបងស្រីរបស់ខ្ញុំជាប់នៅភ្នំក្រោលយូរប៉ុន្មានទេ ។ គាត់ត្រូវយកចេញពីភ្នំក្រោលដោយឡានមិនដឹងថាបញ្ជូនទៅណាទៀត ។ ខ្ញុំរស់នៅប្រហែល២០គីឡូម៉ែត្រឆ្ងាយពីបងស្រីរបស់ខ្ញុំ ការងាររបស់ខ្ញុំគឺកសាងទំនប់ទឹកនិងធ្វើស្រែ ។ ខ្ញុំធ្លាប់ឃើញសន្តិសុខចាប់មនុស្សប៉ុន្តែមិនធ្លាប់ឃើញធ្វើទារុណកម្មទេ ។ ការចាប់ដែលខ្ញុំបានឃើញនោះដូចជាការខុសសីលធម៌និងវិន័យជាដើម ។ ឧទាហរណ៍ឈ្មោះ ប៉ាន់ ត្រូវចាប់ខ្លួនដោយសារខុសសីលធម៌ ហើយត្រូវបញ្ជូនមកមន្ទីរក-១១ ក្រោយមកត្រូវដោះលែង ។ អំពីរបបអាហារវិញគឺពុំគ្រប់គ្រាន់ទេ ។ នៅរដូវភ្លៀងធ្លាក់ ម្នាក់បានតែបបរមួយចានទេ ។ អ្នកណាលួចដកដំឡូងឬលួចបេះអ្វីត្រូវយកទៅទិតៀនកសាង ។ ខ្ញុំបានហូបគ្រប់គ្រាន់នៅរដូវប្រាំង ។ សម្លគឺស្លធ្នាំងធំម្ល៉ោះហើយអត់ឆ្ងាញ់ទេ ។ ពេលព្រឹកមានបបរ ពេលខ្លះទៀតមានពោតកំប៉ោរ ។ ជួនកាលមានបន្លែមក្នុងរវាង១០ថ្ងៃម្តង ។ ការហូបបាយរួមមានតាំងពីឆ្នាំ១៩៧៣ ។ ខ្ញុំបានដឹងរឿងបងស្រីរបស់ខ្ញុំតាមរយៈមិត្តភក្តិ ។ ខ្ញុំបានដឹងថា នៅក្នុងគុក អ្នកទោសត្រូវដាក់ខ្នោះ ហើយបត់ជើងដាក់បំពង់ឫស្សី ។ ខ្ញុំបានជួបបងថ្លៃរបស់ខ្ញុំឈ្មោះ សុទ្ធ នៅពេលដែលគាត់មកភូមិរបស់ខ្ញុំ ។ សុទ្ធបានហាមខ្ញុំមិនឲ្យនិយាយរឿងចាប់ខ្លួនបងស្រីខ្ញុំទេ ខ្លាចខ្មែរក្រហមចាប់ទាំងសាច់ញាតិទៀត ។ ក្រោយមក សុទ្ធ បានមកលេងម្តាយរបស់ខ្ញុំ ហើយប្រាប់គាត់អំពីបងស្រីរបស់ខ្ញុំ ។ បន្ទាប់ពីបងស្រីរបស់ខ្ញុំត្រូវចាប់ខ្លួន ខ្ញុំនិងម្តាយខ្ញុំត្រូវបង្ខំឲ្យធ្វើការងារធ្ងន់ៗជាងមុន ។

ខ្ញុំឮពាក្យខ្មែរក្រហមតាំងពីមុនឆ្នាំ១៩៧០ម៉្លេះ ។ ខ្ញុំមិនដឹងថាខ្មែរក្រហមប្រមូលកម្លាំងតាមរបៀបណាទេ ។ នៅឆ្នាំ១៩៧០ ខ្មែរក្រហមបានវាយយកឃុំស្រែសង្គម ប្រហែលជាពីព្រោះឃុំនេះសម្បូរព្រៃក្រាស់ៗ ។ ឈ្មោះ ហម ដែលជាចៅហ្វាយខេត្ត បានឃោសនាប្រជាជនឲ្យផ្តួលរំលំរបបសក្តិភូមិដើម្បីឲ្យកសិករក្លាយជាម្ចាស់ដី ហើយឈ្មោះ មី ជាអនុរបស់គាត់ ទទួលបន្ទុកខាងនយោបាយ ។ នៅពេលនោះប្រជាជនគាំទ្រខ្លាំងណាស់ ។ កាលនោះមានទាហានវៀតណាមខាងជើងច្រើនណាស់មកនៅមណ្ឌលគិរី ។ ខ្ញុំបានឃើញវៀតណាមដឹកស្រូវយកទៅហូបចុកផ្ទាល់ខ្លួន ។ ខ្ញុំឮថាមានមន្ទីរសម្ងាត់នៅក្នុងព្រៃ ។ ចាប់ពីឆ្នាំ១៩៧៣មក ខ្ញុំលែងឃើញទាហានវៀតណាមទៀត ខ្ញុំក៏មិនដឹងមូលហេតុអ្វីដែរ ។ ឪពុករបស់ខ្ញុំស្លាប់នៅឆ្នាំ១៩៧៣ ។ គាត់គឺជាបាល័ដ្ឋស្រុក ឬហៅថាចៅហ្វាយស្រុក ។ មានមេទាហានសក្តិ៥មកពីភ្នំពេញ បានហៅឪពុករបស់ខ្ញុំទៅជួបនៅឯវាលយន្តហោះស្រុកកោះញែក ។ កាលនោះទាហានទាំងអស់ត្រូវដកហូតអាវុធ ហើយវិលត្រឡប់ទៅស្រុកកំណើតធ្វើជាប្រជាជនស៊ីវិលវិញ ។ ក្រោយពីឪពុកខ្ញុំទៅជួបសក្តិ៥នោះមួយសន្ទុះស្រាប់តែឮស្នូរកាំភ្លើង ។ យើងបានជួលមនុស្សម្នាក់ឲ្យទៅរកគាត់ ហើយបានឃើញសាកសពគាត់ ។ ក្រុមគ្រួសាររបស់ខ្ញុំរត់ទៅពួនក្នុងព្រៃថ្ងៃស្អែកឡើងទើបនាំគ្នាវិលមកស្រែសង្គមវិញ ។ ពេលដែលឪពុករបស់ខ្ញុំស្លាប់ ម្តាយរបស់ខ្ញុំប្រាប់កូនៗឲ្យនៅស្ងៀមស្ងាត់ ។ កាលនោះ ដុស ក៏នៅជាមួយគ្នាដែរ ។ ម្តាយរបស់ខ្ញុំស្លាប់កាលពីឆ្នាំ១៩៨៣ដោយសារជំងឺ ចំណែក ដៃ សុទ្ធ សព្វថ្ងៃមានប្រពន្ធមួយទៀត ហើយរស់នៅឃុំរយ៉ ស្រុកកោះញែក ។

**សឹម សុរិយ៉ា**


## រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាននិងកំពុងសរសេរអត្ថបទ ឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជា តាមអាសយដ្ឋានខាងក្រោមៈ

ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

*Email: dccam@online.com.kh*

*Home page: www.dccam.org*

# ទីបញ្ចប់ខ្ញុំនៅក្នុងគុកព្រៃស

ថាច សៀក បានចាកចេញពីផ្ទះទៅចូលក្នុងជួរបដិវត្តន៍ខ្មែរក្រហមនៅឆ្នាំ១៩៧២ ។ ក្នុងនាមជាប្រធានកងធំទី១នៃកងប្រយុទ្ធនារីពិសេស ថាច សៀក ហៅ សាន បានឆ្លងកាត់សមរភូមិជាច្រើន ។ ក្រោយពីការបះបោរមិនបានសម្រេចនៅភូមិភាគឧត្តរនិងបូព៌ានៅក្នុងឆ្នាំ១៩៧៦ សៀក ត្រូវអង្គការចាប់ខ្លួនបញ្ជូនទៅមន្ទីរលត់ដំព្រៃសចាប់តាំងពីថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧៧ រហូតដល់ខែមករា ឆ្នាំ១៩៧៩ ។

សៀក មានស្រុកកំណើតនៅភូមិអន្លុងក្រហាយ ឃុំឈូក ស្រុកកំពង់ស្វាយ (បច្ចុប្បន្នស្រុកប្រាសាទសំបូរ) ខេត្តកំពង់ធំ ។ សៀក បានចូលបម្រើបដិវត្តន៍ខ្មែរក្រហមនៅឆ្នាំ១៩៧២ ដែលកាលនោះមានឈ្មោះថា រណសិរ្សរួបរួមជាតិកម្ពុជា តាមពាក្យឃោសនាថាតស៊ូដើម្បីនាំសម្តេចឪមកគ្រប់គ្រងប្រទេសវិញ ។ សៀក បានចូលរៀនមុខវិជ្ជាពេទ្យនៅតាមភូមិ និងធ្វើការនៅក្នុងកងផលិតដែលមានឈ្មោះថា ក្បាលដំរី អស់រយៈពេល២ឆ្នាំ ។ នៅឆ្នាំ១៩៧៤ សៀក ត្រូវបានជ្រើសរើសចូលក្នុងជួរកងទ័ពប្រយុទ្ធនារីពិសេសនៅខេត្តកំពង់ធំ ។ សៀក និយាយថា កងទ័ពប្រយុទ្ធនារីពិសេសនេះតែងតែចូលសមរភូមិប្រយុទ្ធនៅខេត្តសៀមរាប កំពង់ធំ និងភ្នំពេញ ។ អ្នកដឹកនាំកងនារីពិសេសឈ្មោះ ជុំ ជាអ្នកចាត់ចែងកម្លាំងនារីសម្រាប់ទៅប្រយុទ្ធ ។ ជាទូទៅនារី១០នាក់ត្រូវបានជ្រើសរើសចេញពីក្រុមនីមួយៗពេលចេញទៅប្រយុទ្ធម្តងៗ ។ សៀក ជាប្រធានកងធំទី១នៃកងនារីពិសេសខេត្តកំពង់ធំ ចំណុះឲ្យកងពលទី១ក្រោមការគ្រប់គ្រងរបស់ អឿន ដែលដឹកនាំការវាយលុកចូលទីក្រុងភ្នំពេញពីខាងព្រែកព្នៅនិងភ្នំប្រសិទ្ធិ ។ ក្រោយពេលកាន់កាប់ក្រុងភ្នំពេញទាំងស្រុង សៀក បញ្ជាក់ថា ប្រជាជននៅទីក្រុងភ្នំពេញត្រូវបានជម្លៀសចេញទាំងអស់ ។ កងពលទី១នៃភូមិភាគឧត្តរបានបោះទីតាំងនៅទួលគោក ជាកន្លែងដែល សៀក បានទទួលការបំពាក់បំប៉នខាងនយោបាយ ចំណែកឯកងពលទី២បោះទីតាំងនៅឫស្សីកែវ ។ មិនយូរប៉ុន្មាន សៀក ត្រូវអង្គការបញ្ជូនទៅធ្វើស្រែនៅបឹងបាយ៉ាបវិញ ។

សៀក បានអះអាងថា នៅចុងឆ្នាំ១៩៧៦ កុយ ធួន លេខាភូមិភាគឧត្តរ និង សោ ភឹម លេខាភូមិភាគបូព៌ា បានរៀបចំផែនការធ្វើរដ្ឋប្រហារដណ្តើមអំណាចពីបក្សកុម្មុយនិស្តកម្ពុជា ។ កម្លាំងកងពលទី១ និងទី២របស់ភូមិភាគឧត្តរឈរជើងនៅប៉ែកខាងជើងទីក្រុងភ្នំពេញ ចំណែកកម្លាំងខាងភូមិភាគបូព៌ាឈរជើងនៅប៉ែកខាងត្បូង ។ មិនទាន់ទាំងបានផ្ទុះអាវុធផង គម្រោងការក្បត់ក៏ត្រូវបែកការណ៍ ដែលនាំទៅដល់ការចាប់ខ្លួនប្រធានភូមិភាគទាំងពីរ ប្រធានកងពលទី១ អឿន និងប្រធានវរសេនាធំវរសេនាតូច រួមទាំង សៀក និង ប្តីរបស់គាត់ឈ្មោះ សំ វ៉ាត ជាអនុប្រធានវរសេនាតូច ។ សៀក ត្រូវចាប់ខ្លួននៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧៦ ក្នុងខណៈដែលគាត់កំពុងបំពេញការងារជាពេទ្យកងទ័ពនៅមន្ទីរពេទ្យព្រះអង្គឌួង ហើយបញ្ជូនទៅមន្ទីរលត់ដំនៅព្រៃស ចំណែកប្តីរបស់គាត់ត្រូវបញ្ជូនទៅគុកទួលស្លែង ។

នៅគុកព្រៃស សៀក និយាយថា ឌុច បានប្រកាសថា “ពួកមិត្តឯងត្រូវដឹងខ្លួន មិនមែនក្បត់តែមិត្តឯងក្នុងជួរកម្មាភិបាលនៅក្នុងក្រុងទេ សូម្បីតែឪពុកម្តាយមិត្តឯងនៅសមរភូមិក្រោយក៏ក្បត់ដែរ មួយភូមិភាគឧត្តរនិងភូមិភាគបូព៌ាគឺចូលយួនទាំងអស់” ។ សៀក ខិតខំធ្វើការងារគ្រប់បែបយ៉ាងដើម្បីលត់ដំខ្លួន ដូចជាត្បាញកន្ទេល កែលម្អភ្លឺស្រែ ប្រឡាយ ជាដើម ។ សៀក បន្តថា រៀងរាល់វេលាម៉ោងពីរទៀបភ្លឺ ខ្មែរក្រហមបានវាយជួងដើម្បីដាស់អ្នកទោសទាំងអស់ឲ្យក្រោកទៅធ្វើការងារ ។ អ្នកទោសម្នាក់ៗត្រូវតែមានការប្រុងប្រយ័ត្នជាទីបំផុតក្នុងការបំពេញការងារក្នុងករណីដែលធ្វេសប្រហែស ឧទាហរណ៍ច្រូតស្រូវមិនអស់ អង្គការនឹងបង្អត់របបបបរ ។ សៀក រៀបរាប់ទៀតថា រៀងរាល់៣ថ្ងៃម្តង អ្នកទោសណាដែលទៅវែកកណ្តាប់នៅពេលយប់នឹងបានទទួលអាហារបន្ថែមមុនពេលចូលដេក ចំណែកគាត់បាន

បដិសេធមិនទទួលរបបបន្ថែម ព្រោះគាត់មិនមានទម្លាប់ហូបអាហារពេលយប់ ។ សន្តិសុខបានតាមដានគាត់ដោយសារតែរឿងនេះ ។

សៀក បានបន្ថែមថា ជារៀងរាល់យប់ អ្នកទោសពី១០ទៅ២០នាក់ត្រូវបានបញ្ជូនចេញពីគុក ។ ដោយសារសៀក មានឈ្មោះហៅក្រៅថា សាន ទើបឈ្លបហៅឈ្មោះ ច្រឡំយកមនុស្សទៅសម្លាប់ចំនួនបីដង ព្រោះមានអ្នកទោសឈ្មោះ សាន ដល់ទៅបីនាក់ ប៉ុន្តែសំណាងល្អគាត់រួចខ្លួនរហូត ។ នៅចុងឆ្នាំ១៩៧៨ អ្នកទោសបានទទួលរបបបាយមួយថ្ងៃបីដង ព្រមទាំងមានបង្អែមផង ។ រយៈពេលពីរថ្ងៃគត់មុនពេលដែលវៀតណាមវាយចូលដល់ទីក្រុងភ្នំពេញ ឌុច បានប្រកាសនៅគុកព្រៃសថា "កន្ទុងមកមិនដឹងអ្នកណាខ្លាំង ចាប់មិត្តយើងមកសម្លាប់អស់មួយចំនួនធំដូច្នេះ ។ យួនវាយចូលមកទីក្រុងភ្នំពេញហើយយើងត្រូវតែភៀសខ្លួនទៅភ្នំឱរ៉ាល់" ។ មិនយូរប៉ុន្មានស្នូរកាំភ្លើងធំផ្ទោងចេញពីព្រលានយន្តហោះពោធិចិនតុងបានធ្លាក់ចូលក្នុងទីក្រុងភ្នំពេញតាំងពីម៉ោង៩ព្រឹកនៃថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ។ សៀក បានគេចខ្លួនជាមួយនឹងគ្នីគ្នាពីរបីនាក់ទៀត ហើយធ្វើដំណើរត្រឡប់មកស្រុកកំណើតវិញ ។

បច្ចុប្បន្ន សៀក មានអាយុ៥០ឆ្នាំ រស់នៅជាមួយប្តីក្រោយនិងកូន៤នាក់នៅភូមិកំពង់ឈើទាល ឃុំសំបូរ ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ ។ ប្តីក្រោយរបស់គាត់ឈ្មោះ ទុំ ស៊ីន មានមុខរបរជាកសិករ ។ រហូតមកដល់បច្ចុប្បន្ន សៀក នៅតែមិនអស់ចិត្តចំពោះការដែលគាត់ត្រូវជាប់ឃុំនៅគុកព្រៃសដោយគ្មានមូលហេតុ ។ សៀក និយាយទាំងទឹកមុខស្មើថា "នឹករឿងនៅព្រៃសខ្ញុំចង់ស្រក់ទឹកភ្នែក ។ ខ្ញុំខំធ្វើការបម្រើបដិវត្តន៍ ប៉ុន្តែនៅទីបំផុតខ្ញុំបែរជានៅក្នុងគុកព្រៃស ។ ជិតបីឆ្នាំនៅក្នុងគុកវាមិនមែនជារឿងងាយស្រួលនោះទេ" ។

**លី សុខឃាង**

# សេចក្តីជូនដំណឹងរបស់សមាគមអ្នកនិពន្ធខ្មែរ

សមាគមអ្នកនិពន្ធខ្មែរសូមជម្រាបដល់ប្រជាជនកម្ពុជាគ្រប់រូបថា សមាគមបានរៀបចំ **"វេទិកាថែរក្សាប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ"** ក្រោមកិច្ចសហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ។ វេទិកានេះមានគោលបំណងសំខាន់ៗដូចជា÷

- ◆ រួមជាចំណែកថែរក្សាប្រវត្តិសាស្ត្រទុកសម្រាប់កូនចៅជំនាន់ក្រោយឲ្យបានដឹងនិងសិក្សារៀនសូត្រ ។
- ◆ ជាវិធីមួយដើម្បីរំងាប់អារម្មណ៍ដោយយកហេតុការណ៍ សេចក្តីទុក្ខ ការខឹងគុំកួន មកតម្កល់ជាឯកសារប្រវត្តិសាស្ត្រដើម្បីបម្រើដល់ការស្រាវជ្រាវតទៅអនាគត ។
- ◆ ការចងចាំគឺជាសន្តិវិធីមួយក្នុងការទប់ស្កាត់មិនឲ្យអំពើប្រល័យពូជសាសន៍កើតឡើងជាថ្មីម្តងទៀតនៅក្នុងសង្គមមនុស្ស ។
- ◆ ជួយដល់ការស្វែងរកយុត្តិធម៌ជូនដល់ប្រជាជនកម្ពុជាដែលបានស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម និងជួយលើកកម្ពស់ការគោរពសិទ្ធិមនុស្សនៅកម្ពុជា ។

សមាគមអ្នកនិពន្ធខ្មែរសូមអំពាវនាវដល់ប្រជាជនកម្ពុជាចូលរួមសរសេរអត្ថបទទាំងឡាយអំពី÷ ១) រឿងរ៉ាវផ្ទាល់ខ្លួន ២) ព្រឹត្តិការណ៍ដែលលោកអ្នកធ្លាប់បានជួបប្រទះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និង ៣) ផ្តល់ដំណោះស្រាយចំពោះបញ្ហាប្រវត្តិសាស្ត្រនេះ ។ ប្រធានបទខាងលើនេះតម្រូវឲ្យលោកអ្នកសរសេរបែបប្រវត្តិសាស្ត្រចាប់ពី១០ទំព័រឡើងទៅ ។

សមាគមអ្នកនិពន្ធខ្មែរនិងមជ្ឈមណ្ឌលឯកសារកម្ពុជានឹងមានកិត្តិយសដោយចុះផ្សាយស្នាដៃរបស់លោកអ្នកនៅលើទំព័រទស្សនាវដ្តី "ស្វែងរកការពិត" ព្រមទាំងផ្តល់ថវិកាដល់ម្ចាស់អត្ថបទដែលនឹងត្រូវសរសេរបន្ថែមទៀតដើម្បីបោះពុម្ពជាសៀវភៅ ។ ការចូលរួមរបស់លោកអ្នកគឺជាការរួមចំណែកលើកស្ទួយតម្លៃនៃការសរសេរនិងចំណេះដឹង ។

សូមផ្ញើអត្ថបទរបស់លោកអ្នកមកសមាគមអ្នកនិពន្ធខ្មែរទីស្នាក់ការៈ វត្តបទុមវតី ភ្នំពេញ ឬទាក់ទងតាមទូរស័ព្ទលេខ ០១២ ៨៨៣ ០៧២ ចាប់ពីពេលផ្សាយដំណឹងនេះរហូតដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៤ ។

**យូ បូ**

**ប្រធានសមាគមអ្នកនិពន្ធខ្មែរ**

# ព្រះពុទ្ធសាសនាមិនសាបសូន្យ

មាត្រា២០ នៃរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យបានចែងថា “ប្រជាជនកម្ពុជាគ្រប់រូបមានសិទ្ធិជឿជំនឿឬសាសនាណាក៏បាន ហើយក៏មានសិទ្ធិមិនជឿជំនឿអ្វីឬក៏មិនជឿសាសនាណាក៏បាន ។ មិនអនុញ្ញាតឲ្យមានសាសនាប្រតិកិរិយាដែលបំផ្លិចបំផ្លាញកម្ពុជាប្រជាធិបតេយ្យនិងប្រជាជនកម្ពុជាដាច់ខាត ។”

ទោះជារដ្ឋធម្មនុញ្ញបានចែងយ៉ាងនេះក៏ដោយ ប៉ុន្តែគ្មានសាសនាណាមួយត្រូវបានខ្មែរក្រហមអនុញ្ញាតឲ្យប្រតិបត្តិឡើយ សូម្បីតែសាសនាព្រះពុទ្ធដែលប្រជាជនកម្ពុជាជាងប៉ែតសិបភាគរយគោរពប្រតិបត្តិនិងធ្លាប់ត្រូវទទួលស្គាល់ដោយរបបមុនៗថាជាសាសនារបស់រដ្ឋក៏ត្រូវហាមប្រាមដែរ ។ សាសនាទាំងអស់សុទ្ធតែត្រូវខ្មែរក្រហមចាត់ទុកថាជាសាសនាប្រតិកិរិយា ។ ព្រះសង្ឃដែលជាទីគោរពសក្ការៈរបស់ពុទ្ធបរិស័ទត្រូវចោទប្រកាន់ថាជាព្រូនរបស់សង្គម ហើយត្រូវបង្ខំឲ្យលាចាកសិក្ខាបទ និងធ្វើការងារពលកម្មដូចប្រជាជនទូទៅ ។ មិនតែប៉ុណ្ណោះ ព្រះសង្ឃត្រូវទទួលរងការធ្វើទារុណកម្មនិងសម្លាប់យ៉ាងព្រៃផ្សៃ ។ វត្តអារាមត្រូវបំផ្លិចបំផ្លាញ និងយកធ្វើជាកន្លែងឃុំឃាំងអ្នកទោស ជាឃ្លាំងស្រូវ ជាកន្លែងចិញ្ចឹមសត្វ ជាមូលដ្ឋានទ័ព ជាឃ្លាំងផ្ទុកគ្រាប់រំសេវ ។ល។ ពិធីបុណ្យចូលឆ្នាំថ្មី ពិធីបុណ្យភ្ជុំបិណ្ឌ ពិធីបុណ្យមាឃបូជា ឬពិសាខបូជា ពិធីបុណ្យសព ការសូត្រធម៌ ការថ្វាយបង្គំព្រះ និយាយរួមគឺគ្រប់សកម្មភាពតាមបែបព្រះពុទ្ធសាសនាត្រូវហាមប្រាមទាំងអស់ ។ ទោះបីជាយ៉ាងនេះក្តី ដោយសារជំនឿយ៉ាងមុតមាំចំពោះព្រះពុទ្ធសាសនា ព្រះសង្ឃនិងប្រជាជនមួយចំនួននៅតែបន្តប្រតិបត្តិព្រះពុទ្ធសាសនាដោយស្ងាត់កំបាំង ។

មេគណខេត្តបាត់ដំបងព្រះនាម អ៊ឹក មុត គង់នៅវត្តពោធិវាល ស្រុកបាត់ដំបង ដែលមានវាសនារួចផុតពីកណ្តាប់ដៃខ្មែរក្រហម បានមានសង្ឃដីកាថា÷ ព្រះសង្ឃនៅក្នុងខេត្តបាត់ដំបងត្រូវខ្មែរក្រហមជម្លៀសចេញពីវត្តព្រមពេលគ្នានឹងការជម្លៀសប្រជាជនចេញពីផ្ទះសម្បែងដែរ ។ ខ្មែរក្រហមបានបង្ខំឲ្យព្រះសង្ឃទៅធ្វើស្រែនិងធ្វើការងារផ្សេងៗទៀតដូចជាប្រជាជនធម្មតា ។ ដោយសារត្រូវបង្ខំឲ្យធ្វើការងារខ្លះដែលខុសនឹងវិន័យសង្ឃ ព្រះសង្ឃមួយចំនួនបានសឹកដោយព្រះអង្គឯង ។ ព្រះសង្ឃខ្លះទៀតត្រូវខ្មែរក្រហមបង្ខំឲ្យសឹក ខ្លះទៀតត្រូវសម្លាប់ចោល ។ ព្រះតេជគុណ អ៊ឹក មុត បានសឹកដោយព្រះអង្គឯង ប៉ុន្តែលោកនៅតែរក្សាវត្តពន្ធនៅនឹងចង្កេះ លួចសូត្រធម៌ និងថ្វាយបង្គំព្រះដោយលាក់កំបាំង ។ ព្រះតេជគុណបានបន្ថែមថា មានពេលខ្លះប្រជាជនបានលបលួចមកនិមន្តលោកទៅសូត្រធម៌ក្នុងពិធីបញ្ចុះសព ឬសូត្រផ្លុំព្យាបាលជំងឺដោយមិនឲ្យខ្មែរក្រហមដឹងឡើយ ។ នៅក្នុងរបបខ្មែរក្រហម ព្រះតេជគុណ អ៊ឹក មុត តែងតែបន់ស្រន់ឲ្យរបបនេះបញ្ចប់ឆាប់ៗ ដើម្បីឲ្យប្រជាជនខ្មែររួចចាកផុតអំពីទុក្ខវេទនា និងដើម្បីឲ្យការគោរពព្រះពុទ្ធសាសនាត្រូវបានបើកចំហឡើងវិញ ។ ក្រោយពេលដែលរបបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩ ព្រះតេជគុណ អ៊ឹក មុត បានបួសជាថ្មីម្តងទៀតនៅវត្តគួលខេត្តបាត់ដំបង ។


ព្រះតេជគុណ អ៊ឹក មុត

ព្រះតេជគុណ ហាត់ សារ៉ាយ ព្រះជន្ម៩៧វស្សា ជាទីប្រឹក្សាព្រះចៅអធិការវត្តសង្កែខេត្តបាត់ដំបង បានឲ្យដឹងថា÷ នៅក្នុងរបបខ្មែរក្រហម ដោយដឹងខ្លួនមានឋានៈដូចគ្រហស្ថហើយ ព្រះសង្ឃមួយចំនួនបានបង្ខំចិត្តសឹកដោយព្រះអង្គឯង ប៉ុន្តែព្រះសង្ឃមួយចំនួនទៀតដាច់ខាតមិនព្រមសឹក ហើយនៅតែបន្តគ្រងស្បង់ចីវរនិងអត់ចង្ហាន់ល្ងាចដដែល ។ មើលឃើញយ៉ាងដូច្នោះ ខ្មែរក្រហមបានចេញប្រកាសមួយដាក់កំហិតឲ្យព្រះសង្ឃទាំងអស់លាចាកសិក្ខាបទត្រឹមខែមិថុនាឆ្នាំ១៩៧៦ ។ ទោះបីជាព្រះតេជគុណ ហាត់ សារ៉ាយ លាចាកសិក្ខាបទហើយក្តី ក៏លោកនៅតែត្រូវបានអញ្ជើញដោយស្ងាត់ៗដោយឪពុកម្តាយឬសាច់

ញាតិរបស់កូនកម្លោះកូនក្រមុំដែលរៀបចំឡើងដោយអង្គការ ដើម្បីប្រោះព្រំដល់គូស្វាមីភរិយាឲ្យរស់នៅជាមួយគ្នាដោយសេចក្ដីសុខ ។ ព្រះតេជគុណលួចធ្វើរបៀបនេះបានប្រមាណជាងដប់ដង ។ នៅដើមឆ្នាំ១៩៧៩ ខ្មែរក្រហមបានចុះឈ្មោះព្រះតេជគុណ ហាត់ សារ៉ាយ ទៅក្នុងបញ្ជីមនុស្សដែលត្រូវយកទៅកម្ទេច ប៉ុន្តែសំណាងល្អ របបខ្មែរក្រហមបានដួលរលំ ជាហេតុធ្វើឲ្យព្រះតេជគុណរួចផុតពីសេចក្ដីស្លាប់ ហើយបានចូលមកបួសក្នុងព្រះពុទ្ធសាសនាវិញ ដោយនៅតែប្រើវត្តពន្ធដែលខ្មោចមាតារបស់លោករក្សាទុកឲ្យពីរបបប៉ុលពតដដែល ។

ព្រះតេជគុណ ធីម ប៉ក់ បានត្រូវខ្មែរក្រហមបង្ខំឲ្យលាចាកសិក្ខាបទ ប៉ុន្តែលោកនៅតែក្រវាត់វត្តពន្ធជាប់រហូត ។ នៅពេលយប់ ព្រះតេជគុណតែងតែលួចសូត្រធម៌ជានិច្ច ហើយនៅពេលបំពេញការងាររស្វាត់កំបាំងពីភ្នែកអ្នកដទៃ ព្រះតេជគុណតែងតែលួចថ្វាយបង្គំព្រះនៅតាមដើមឈើឬក៏គុម្ពោតព្រៃដោយអុជក្រឡាតដូងជំនួសធូប ។ ក្រោយពេលដែលរបបខ្មែរក្រហមត្រូវដួលរំលំ ព្រះតេជគុណត្រូវបានបំបួសជាថ្មីឡើងវិញដោយអាចារ្យរួមនៅវត្តពោធិវង្ស ហើយក្រោយមកបានក្លាយជាមេគណខេត្តបាត់ដំបង ។ ព្រះអង្គបានសុគតនៅឆ្នាំ១៩៨៧ ។

មុនទសវត្សរ៍ឆ្នាំ១៩៧០ ព្រះសង្ឃទូទាំងប្រទេសមានចំនួនប្រមាណជាង៦ម៉ឺនអង្គ ។ យោងតាមស្ថិតិរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជាដែលធ្វើនៅក្នុងឆ្នាំ១៩៨៣បានឲ្យដឹងថាក្នុងអំឡុងពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៨ ខ្មែរក្រហមបានសម្លាប់ព្រះសង្ឃអស់ចំនួន ២៥.១៦៨អង្គ ។ បន្ទាប់ពីរបបខ្មែរក្រហមត្រូវបញ្ចប់ ក្នុងចំណោមអតីតសង្ឃមួយចំនួនដែលនៅមានព្រះជន្ម បានបួសសាជាថ្មី ហើយយុវជនជំនាន់ក្រោយក៏បានបួសជាបន្តបន្ទាប់ទៀត ។ បច្ចុប្បន្ននេះចំនួនព្រះសង្ឃនៅទូទាំងប្រទេសកម្ពុជាបានកើនដល់ ៥៩.៤៧០អង្គ វិញហើយ ។

ខ្មែរក្រហមបានខិតខំព្យាយាមប្រើប្រាស់គ្រប់មធ្យោបាយដើម្បីបំបាត់ព្រះពុទ្ធសាសនា ប៉ុន្តែគោលបំណងនេះមិនបានសម្រេចឡើយ ព្រោះព្រះពុទ្ធសាសនានៅតែរស់ជានិច្ចក្នុងសន្តានចិត្តប្រជាជនកម្ពុជាគ្រប់រូប និងមិនសាបសូន្យជារៀងរហូត ។

**ព្រុំ ផល្លា**



ព្រះវិហារមួយដែលត្រូវខ្មែរក្រហមកម្ទេចសល់តែឆ្អឹង

# បរាជ័យដោយការធ្វេសប្រហែសៈ នយោបាយរបស់ខ្មែរក្រហមចំពោះស្ត្រី

**(តពីលេខមុន)**

នៅក្នុងសៀវភៅរបស់ ជូឌីស ស្តេស៊ី ដែលមានចំណងជើងថា "បដិវត្តន៍បិតាធិបតេយ្យនិងសង្គមនិយមនៅក្នុងប្រទេសចិន" បានលើកឡើងអំពី "ការវិភាគបែបសម្ភារៈនិយម ផ្អែកតាមប្រវត្តិសាស្ត្រអំពីបដិវត្តន៍បិតាធិបតេយ្យនិងសង្គមនិយមនៅក្នុងប្រទេសចិន" ។ សង្គមវិទូរូបនេះបានសង្កេតឃើញស្រដៀងគ្នាទៅនឹង ចនសុន ដែរ ប៉ុន្តែពុំសូវផ្តោតការរិះគន់ជាចំហទៅលើបក្សកុម្មុយនិស្តចិនទេ ។ ស្តេស៊ី បានសរសេរថា គ្រួសារមានតួនាទីយ៉ាងសំខាន់ក្នុងការកំណត់រូបរាងនៃដំណើរការបដិវត្តន៍ និងមិនគួរត្រូវបានមើលឃើញថាដើរតាមបញ្ជារបស់បក្សកុម្មុយនិស្តដោយប្រយោលនោះទេ ។ តាមការពិត ស្តេស៊ី បានទាញហេតុផលថា បដិវត្តន៍គ្រួសារពិតជាបានកើតឡើងនៅក្នុងប្រទេសចិនមែន ប៉ុន្តែមិនមែនតាមរបៀបដែលពួកស្ត្រីនិយមបានគិតទុកនោះទេ ។ ផ្ទុយទៅវិញ ស្តេស៊ី បានបកស្រាយអំពីសហការគ្នាជាក់ស្តែងរវាងបក្សនិងកសិករក្នុងអំឡុងពេលនៃដំណើរការបដិវត្តន៍ ដែលក្នុងសហការនេះ បក្សកុម្មុយនិស្តចិនបានធានាឲ្យមានការបែងចែកដោយយុត្តិធម៌នូវអត្ថប្រយោជន៍ទាំងឡាយដែលនឹងលេចចេញពីការអនុវត្តន៍បិតាធិបតេយ្យទៅឲ្យប្រជាកសិករបុរសរបស់ចិន ជាថ្នូរនឹងការគាំទ្ររបស់កសិករចំពោះការប្រយុទ្ធប្រឆាំងរបស់បក្សទល់នឹងពួកជប៉ុន និងបក្សក្កុកមីងតាង ។ ដូច្នេះប្រជាកសិករបានតស៊ូប្រយុទ្ធដើម្បីការស្តារឡើងវិញនូវការអនុវត្តន៍បិតាធិបតេយ្យដែលមានតាំងពីបុរាណកាលមកក្នុងប្រទេសចិន ។ ដោយមានការកែប្រែខ្លះដោយបក្សកុម្មុយនិស្តចិន សង្គមវិទូ ស្តេស៊ី បានដាក់ឈ្មោះឲ្យសង្គមបិតាធិបតេយ្យថ្មី ថាជាសង្គម "បិតាធិបតេយ្យបែបប្រជាធិបតេយ្យ" ។ ស្ត្រីត្រូវបាន "ប្រគល់ទៅឲ្យ" បុរសវិញ ហើយគ្រួសារនៅតែស្ថិតជាធាតុសំខាន់នៃសង្គមចិនដដែល ។ ស្តេស៊ី បានគិតថា កម្មវិធីសហករណ៍ភាវូបនីយកម្មរបស់បក្សកុម្មុយនិស្តចិនដែលដាក់ឲ្យអនុវត្តបន្ទាប់ពីបានផ្តួលរំលំបក្សក្កុកមីងតាង ជាការសង្កត់ធ្ងន់ទៅលើបិតាធិបតេយ្យបែបប្រជាធិបតេយ្យ ពីព្រោះអំណាចត្រូវបានបែងចែកសាឡើងវិញទៅឲ្យកសិករបុរសនៅក្នុងដំណាក់កាលមួយដែលគាត់ហៅថា"បិតាធិបតេយ្យសង្គមនិយម" ។ ឥទ្ធិពលទៅលើស្ត្រីដោយសារសម្ព័ន្ធភាពរវាងបក្សកុម្មុយនិស្តចិននិងបិតាធិបតេយ្យនិយម ស្តេស៊ី បានសន្និដ្ឋានថាមានលក្ខណៈចម្រុះ គឺ "បិតាធិបតេយ្យបែបប្រជាធិបតេយ្យនិងបិតាធិបតេយ្យបែបសង្គមនិយមថ្មីនេះ បានធានាដល់ស្ត្រីជាកសិករភាគច្រើននូវការកើនឡើងយ៉ាងខ្ពស់ត្រដែតនូវឋានៈរបស់ស្ត្រីទាំងនោះនៅក្នុងសង្គមលើសពីសម័យមុនរបបកុម្មុយនិស្ត ក៏ប៉ុន្តែស្ត្រីក្នុងដំណាក់កាលនេះពុំទាន់មានឋានៈស្មើនឹងបុរសនៅឡើយទេ" ។

គំនិតរបស់នរវិទូ ម៉ាហ្គ៊ីរី វុស ទៅលើគោលនយោបាយរបស់បក្សកុម្មុយនិស្តចិនចំពោះស្ត្រី មានលក្ខណៈប្រហាក់ប្រហែលគ្នានឹងគំនិតរបស់ ស្តេស៊ី ដែរ លើកលែងតែមួយចំណុចសំខាន់ចេញគឺ ស្តេស៊ី មានជំនឿថា បក្សកុម្មុយនិស្តចិនបានព្យាយាមដោយចេតនាដើម្បីរក្សានូវរចនាសម្ព័ន្ធបិតាធិបតេយ្យរបស់ចិនឲ្យឋិតថេរ ចំណែក វុស បានសរសេរថាមិនមែនដូច្នោះទេ ។ ផ្ទុយទៅវិញ ភាពឋិតថេរនៃបិតាធិបតេយ្យនៅតាមជនបទគឺជាលទ្ធផលនៃ "បរាជ័យជាបន្តបន្ទាប់របស់មេដឹកនាំដែលជាបុរសរបស់បក្សកុម្មុយនិស្តចិនក្នុងការកត់សម្គាល់អំពីការគិតគូរបែបភេទនិយមរបស់បក្ស" ។

នរវិទូជំនាញផ្នែកវប្បធម៌ចិនឈ្មោះ វីបេខ ហិមមែល និង ពៀរ ស៊ីនចឹក ហាក់បីដូចជាមិនទុកចិត្តទៅលើលទ្ធភាពរបស់ជនកុម្មុយនិស្តចិនក្នុងការរំដោះស្ត្រី ។ នៅក្នុងសៀវភៅ "ស្ត្រីជនបទចិនដែលនិយាយរៀបរាប់អំពីគោលនយោបាយទៅលើ

ស្ត្រីមុននិងក្រោយបដិវត្តន៍វប្បធម៌» នរវិទូពីររូបនេះបានរិះគន់ទៅលើកន្ទុះសមត្ថភាពរបស់ «សហព័ន្ធស្ត្រីប្រជាធិបតេយ្យចិន» ក្នុងការសម្រេចឲ្យបាននូវគោលដៅទាំងឡាយដែលលើកឡើងនៅក្នុងវិធីសាស្ត្ររបស់ អែងដែល ទោះបីជាសហព័ន្ធនេះបានទទួលយកនូវផែនការរបស់ អែងដែល ក៏ដោយ ។ នរវិទូទាំងពីររូបនេះបានសន្និដ្ឋានថា ស្ត្រីនៅតែមិនត្រូវបានរំដោះរហូតដល់ពេលដែលសហព័ន្ធនេះបញ្ឈប់ការលើកតម្កើងនិងគាំទ្រនយោបាយ «ការងារទ្វេ» ដែលចែងថាស្ត្រីត្រូវបានទាមទារឲ្យចូលរួមក្នុងការងារផលិតកម្មសហករណ៍ផង ត្រូវបំពេញកាតព្វកិច្ចនៅក្នុងផ្ទះផង ។ អ្នកនិពន្ធទាំងពីររូបបានទាញហេតុផលថា «ការងារទ្វេ» នេះគឺមិនយុត្តិធម៌ទេចំពោះស្ត្រី ពីព្រោះថាស្ត្រីត្រូវបានផ្តល់នូវសំណងតិចជាងការងារដែលខ្លួនបានធ្វើ ពីព្រោះការងារនៅក្នុងផ្ទះមិនដែលត្រូវបានផ្តល់ការទូទាត់ទេ ។ ទោះជាយ៉ាងណាក៏ដោយ ភាពចំបាច់នៃការងារផ្ទះមានន័យថា «គ្រួសារជារនាំងនៃការរំដោះស្ត្រី» ។ ការស្រាវជ្រាវរបស់នរវិទូពីររូបនេះមានសារសំខាន់ដល់ការបង្ហាញឲ្យឃើញនូវចំណុចខ្សោយរបស់ចលនាស្ត្រីចិនដែលមេដឹកនាំខ្មែរក្រហមអាចមើលឃើញដោយផ្ទាល់ភ្នែក ។ តាមពិត សេចក្តីសន្និដ្ឋានរបស់បញ្ញាជនទាំងពីររូបនេះទាក់ទិនទៅនឹងភាពមិនគួរជាទីពេញចិត្តនៃ «ការងារទ្វេ» អាចជាអ្វីដែលមេដឹកនាំខ្មែរក្រហមបានជួបប្រទះ ។

ប្រទេសវៀតណាមមានប្រវត្តិសាស្ត្រជាយូរយារមកហើយទាក់ទិនទៅនឹងវីរភាពរបស់នារីបដិវត្តន៍ ។ សុភាសិតបុរាណមួយរបស់វៀតណាមបានចែងថា «ពេលមានសង្គ្រាម សូម្បីតែស្ត្រីក៏ត្រូវប្រយុទ្ធដែរ» ហើយនៅសតវត្សរ៍ទី២០ ក្នុងការតស៊ូដ៏ជូរចត់របស់ប្រទេសវៀតណាមប្រឆាំងនឹងអាណានិគមបារាំងនិងកងទ័ពអាមេរិក សុភាសិតនេះពិតជាត្រឹមត្រូវមែន ។ សំណេរប្រវត្តិសាស្ត្រទាក់ទងទៅស្ត្រីនិងបដិវត្តន៍វៀតណាមពុំសូវបានពឹងផ្អែកទៅលើទ្រឹស្តីប្រវត្តិសាស្ត្រដូចករណីស្ត្រីនិងបដិវត្តន៍ចិននោះទេ ហើយក៏មិនសូវទូលំទូលាយដែរ ។ លើសពីនេះមានរឿងជាច្រើនដែលគេដឹងអំពីការចូលរួមក្នុងបដិវត្តន៍របស់ស្ត្រីវៀតណាមច្រើនជាងស្ត្រីកម្ពុជា ។ សំណេរថ្មីៗនេះមួយក៏ដូចជាសំណេរពីរផ្សេងទៀតដែលបានសរសេរឡើងនៅក្នុងសម័យសង្គ្រាមវៀតណាម បានផ្តល់នូវការពន្យល់យ៉ាងក្បោះក្បាយអំពីតួនាទីរបស់ស្ត្រីនៅក្នុងប្រទេសវៀតណាមកុម្មុយនិស្ត ។

នៅក្នុងការវិភាគមួយនៅឆ្នាំ១៩៦៦ទៅលើពួកវៀតកុង ដកក្លាស ផាយ បានពិភាក្សាទៅលើតួនាទីដ៏សំខាន់របស់ស្ត្រីក្នុងសង្គ្រាមនៅវៀតណាម ។ ផាយ ជាមន្ត្រីបរិចារកិច្ចបរទេសរបស់សហរដ្ឋអាមេរិកដ៏មានបទពិសោធន៍ ហើយជាបញ្ញាជននាំមុខលើចំណេះដឹងអំពីប្រទេសវៀតណាម ។ គាត់បានសរសេរអំពីការបង្កើតឡើងនូវ «សមាគមរំដោះស្ត្រី» នៅឆ្នាំ១៩៦១ ហើយបានឆ្លុះបញ្ចាំងអំពីប្រសិទ្ធភាពការងាររបស់សមាគមនេះនៅក្នុងចលនាឃោសនានយោបាយឲ្យមានការចុះចូលរបស់សត្រូវ ។ ផាយ បានសរសេរថាការឃោសនានេះបានសង្កត់ធ្ងន់ទៅលើសីលធម៌រស់នៅដោយអំពាវនាវឲ្យស្ត្រីទាំងអស់បង្កើនសីលធម៌រស់នៅរបស់ប្រជាជនវៀតណាម ។ សមាគមនេះបានលើកអំពីទង្វើអសីលធម៌របស់កងទ័ពវៀតណាមខាងត្បូងនិងអាមេរិកាំង ។ គណបក្សកុម្មុយនិស្តនៅវៀតណាមខាងត្បូងបានផ្តោតការយកចិត្តទុកដាក់ទៅលើស្ត្រីដោយសន្យាថា នឹងធ្វើឲ្យមានសមភាពរវាងបុរសនិងស្ត្រី ។ ផាយ ពន្យល់ថា បក្សកុម្មុយនិស្តវៀតណាមបានយល់ពីសារប្រយោជន៍នៃការធ្វើដូច្នេះ ។ សមាគមរំដោះស្ត្រីក៏បានប្រឹងប្រែងយ៉ាងមោះមុតក្នុងការអប់រំឲ្យមានការយល់ដឹងអំពីវណ្ណៈសង្គមក្នុងចំណោមកសិករស្ត្រី ។

ប្រវត្តិសាស្ត្រនៃការចូលរួមរបស់ស្ត្រីវៀតណាមនៅក្នុងសង្គ្រាម ត្រូវបានកត់ត្រាទុកដោយអ្នកវិទ្យាសាស្ត្រនយោបាយម្នាក់ឈ្មោះ វីល្លៀម ឌឺលី ។ នៅក្នុងអត្ថបទដែលមានចំណងជើងថា «ស្ត្រីនៅក្នុងបដិវត្តន៍កុម្មុយនិស្តនៅប្រទេសវៀតណាម» គាត់សរសេរថា នៅក្នុងដំណាក់កាលនៃការតស៊ូប្រឆាំងនឹងអាណានិគមនិយមបារាំង បក្សកុម្មុយនិស្តពិតជាបានមានការចាប់អារម្មណ៍ទៅលើការរំដោះស្ត្រី ហើយក្នុងពេលជាមួយគ្នានោះដែរ បក្សនេះបានកត់សម្គាល់អំពីសារសំខាន់របស់កងទ័ពស្ត្រីចំពោះចលនារំដោះជាតិ ។ ឌឺលី បានចង្អុលបង្ហាញអំពីភាពជាប់ទាក់ទងគ្នារវាងចលាចលសង្គមដែលកកើតឡើងដោយសារសង្គ្រាមទៅនឹងការផ្លាស់ប្តូរតួនាទីរបស់ស្ត្រីនៅប្រទេសវៀតណាម

ដោយលើកឡើងថា «តម្រូវការរបស់សង្គ្រាមបានជំរុញឲ្យស្ត្រីធ្វើការងាររបស់បុរស ហើយបន្ទាបតម្លៃគ្រួសារនិងបង្កើនតម្លៃរបស់បក្សនៅក្នុងសង្គម» ។ ជារួម ថឺលី យល់ថា បក្សកុម្មុយនិស្តបានចាត់ទុកសង្គ្រាមវៀតណាមជាឱកាសដ៏ល្អមួយក្នុងការទម្លាយរនាំងបិទជិតរបស់គ្រួសារបែបប្រពៃណី ។

សាន់ជ្រា ថាយល័រ បានសរសេរនៅក្នុងសៀវភៅរបស់គាត់ដែលមានចំណងជើងថា «ស្ត្រីវៀតណាមចូលរួមសង្គ្រាមៈ ប្រយុទ្ធដើម្បីហូជីមិញនិងបដិវត្តន៍» អំពីវិធីសាស្ត្រនិងមូលហេតុដែលស្ត្រីបានជួយជនកុម្មុយនិស្តវៀតណាមឲ្យឈ្នះសង្គ្រាម ។ ផ្អែកទៅលើបទសម្ភាសន៍របស់គាត់ របាយការណ៍នៃការស៊ើបការណ៍សម្ងាត់របស់សហរដ្ឋអាមេរិក និងឯកសារជាភាសាវៀតណាម ប្រវត្តិវិទូរូបនេះបានពិពណ៌នាអំពីចលនាតស៊ូរបស់ស្ត្រីដែលមានថ្នាក់ដឹកនាំត្រឹមត្រូវដែលទទួលនូវកម្លាំងចិត្តពីភាពជា «សន្តបុគ្គល» (អ្នកដែលគួរយកជាគំរូ) របស់ហូជីមិញ ក៏ដូចជាទស្សនៈរបស់ហូជីមិញទាក់ទិនទៅនឹងសមភាពភេទ ។ សមាគមរំដោះស្ត្រីគឺជាអង្គភាពបែបកុម្មុយនិស្តមួយដ៏សំខាន់នៅវៀតណាមខាងត្បូង ហើយត្រូវបានផ្តល់នូវគោលដៅបីឲ្យសម្រេចបាននៅក្នុងដំណើរការប្រយុទ្ធដើម្បីឯករាជ្យគឺៈ «ការងារស៊ើបការណ៍និងយោធា ការតស៊ូដោយផ្ទាល់និងការធ្វើបាតុកម្មប្រឆាំងកងទ័ពប្រឆាំង រួមទាំងការបង្អាក់ប្រតិបត្តិការសត្រូវ និងការចែកខិតប័ណ្ណឃោសនាឲ្យសត្រូវចុះចូល» ។ ថាយល័រ សរសេរថា ការងារទាំងនេះ«មានភាពចាំបាច់»សម្រាប់បុព្វហេតុប្រយុទ្ធប្រឆាំងរបស់ជនកុម្មុយនិស្ត ។ បក្សកុម្មុយនិស្តបានកត់សម្គាល់ពីសារសំខាន់នៃការបញ្ចូលមនោគមវិជ្ជាទៅឲ្យប្រជាជននៅគ្រប់ស្រទាប់នៃសង្គម ដោយចេញក្រឹត្យមួយដែលមានអត្ថន័យថា សូម្បីតែកសិករអវិជ្ជាទាំងក្មេងចាស់ប្រុសស្រី ក៏គួរតែត្រូវផ្តល់នូវការអប់រំអំពីគោលបំណងរបស់វណ្ណៈកសិករនិងឲ្យដឹងអំពីការកេងប្រវ័ញ្ចដែរ ។ ដើម្បីទាក់ទាញកសិករស្ត្រី ការឃោសនារបស់សហគមន៍បានឆ្លុះបញ្ចាំងអំពីសារជាតិអសីលធម៌នៃរបបដឹកនាំដែលគាំទ្រដោយសហរដ្ឋអាមេរិករបស់ យៀម (ប្រធានាធិបតីវៀតណាមខាងត្បូង ង៉ូ ឌិញយៀម) ទាហានរបស់របបនេះ និងជនជាតិអាមេរិកាំងដែរ ។ សមាគមនេះបានចង្អុលបង្ហាញអំពីវិសមភាពនៃសិទ្ធិរបស់ស្ត្រីនៅវៀតណាមខាងត្បូង ហើយសន្យាថានឹងធានាឲ្យបាននូវសមភាពភេទនៅគ្រប់ស្រទាប់វណ្ណៈនៃសង្គមវៀតណាមនៅពេលដែលដណ្តើមបានឯករាជ្យ ។ ការស្រាវជ្រាវរបស់ ថាយល័រ បានលាតត្រដាងយ៉ាងច្បាស់ក្រឡែតនូវតួនាទីដ៏សំខាន់របស់ស្ត្រីនៅក្នុងបដិវត្តន៍ ហើយជាការងារប្រវត្តិសាស្ត្រផ្ទាល់មាត់ដ៏គួរឲ្យចាប់អារម្មណ៍ ។ ទោះជាយ៉ាងណាក៏ដោយ វានៅតែមានការជជែកគ្នាមិនចេះចប់អំពីអត្ថន័យពិតប្រាកដនៃលទ្ធផលចុងក្រោយរបស់បដិវត្តន៍ចំពោះស្ត្រីវៀតណាម ។

សំណេរប្រវត្តិសាស្ត្រនេះបង្ហាញថាតួនាទីពិតប្រាកដរបស់ស្ត្រីនៅក្នុងបដិវត្តន៍កម្ពុជាមិនទាន់ត្រូវបានសិក្សាឲ្យបានលម្អិតនៅឡើយទេ ពិសេសនៅក្នុងអំឡុងសង្គ្រាមស៊ីវិល ។ យើងគ្រាន់តែដឹងថាគ្រួសារត្រូវបានបំបែកបំបាក់ដោយចេតនាដោយពួកខ្មែរក្រហម ដែលជាមូលហេតុនាំឲ្យមានភាពមិនពេញចិត្តឬទុក្ខព្រួយដល់ស្ត្រីកម្ពុជាយ៉ាងខ្លាំង ។ ការរីកធំធាត់និងសារជាតិរបស់បដិវត្តន៍ធ្លាប់ត្រូវបានសិក្សាយ៉ាងយកចិត្តទុកដាក់នៅក្នុងសៀវភៅប្រវត្តិសាស្ត្រ ដោយមានភស្តុតាងយ៉ាងច្បាស់ក្រឡែតថា បដិវត្តន៍ខ្មែរក្រហមមានឫសគល់ចេញពីលទ្ធិម៉ាក្សលេនីនមួយផ្នែក និងទ្រឹស្តីរបស់ម៉ៅសេទុងនិងស្តាលីនមួយផ្នែក ។ ការសិក្សាស្រាវជ្រាវបានបង្ហាញឲ្យឃើញថា បដិវត្តន៍កម្ពុជាទទួលបានការគាំទ្រដ៏ស្តួចស្តើងប៉ុណ្ណោះពីប្រជាកសិករដែលចូលរួមបម្រើបដិវត្តន៍ក្នុងគោលបំណងអភិរក្សនូវអ្វីដែលមានពីមុន (របបសង្គមរាស្ត្រនិយម) មិនមែនគោលបំណងបដិវត្តន៍នោះទេ ។ ការសិក្សាអំពីស្ត្រីនៅក្នុងបដិវត្តន៍ចិននិងវៀតណាមមានលក្ខណៈទូលំទូលាយជាងនៅប្រទេសកម្ពុជា ។ ការសិក្សានេះបានចង្អុលបង្ហាញថា ស្ត្រីមានតួនាទីយ៉ាងសំខាន់នៅក្នុងបដិវត្តន៍នៅក្នុងប្រទេសនីមួយៗ ហើយស្ត្រីជាផ្នែកមួយនៃចលនាដែលមានថ្នាក់ដឹកនាំត្រឹមត្រូវ ។ ប៉ុន្តែការសិក្សានេះក៏បានបង្ហាញដែរថា សមភាពភេទនៅតែមិនសម្រេចបានទាំងស្រុងបន្ទាប់ពីជ័យជម្នះបដិវត្តន៍ត្រូវដណ្តើមយកបាននៅក្នុងប្រទេសនីមួយៗ ។

ដើម្បីគូសវាសនូវតថភាពនៃជីវិតរបស់ស្ត្រីនៅក្រោមរបប

ខ្មែរក្រហម ខ្ញុំនឹងផ្សារភ្ជាប់នូវប្រធានបទទាំងឡាយដែលត្រូវបានលើកយកមកពិភាក្សានៅក្នុងជំពូកនេះ រួមមាន គោលនយោបាយរបស់ខ្មែរក្រហមទៅលើស្ត្រីនិងគ្រួសារ មនោគមវិជ្ជារបស់បដិវត្តន៍កម្ពុជា និងការគាំទ្ររបស់កសិករចំពោះបដិវត្តន៍ ។ រួចហើយខ្ញុំនឹងប្រៀបធៀបបដិវត្តន៍របស់ប្រទេសកម្ពុជាទៅនឹងបដិវត្តន៍របស់ប្រទេសចិន វៀតណាម និង កូរ៉េខាងជើង បន្ទាប់មកខ្ញុំនឹងបង្ហាញអំពីអ្វីដែលខ្មែរក្រហមបានរៀនសូត្រពីប្រទេសទាំងបីនេះ និងបង្ហាញពីចំណុចទាំងឡាយដែលខ្មែរក្រហមមិនបានរៀនសូត្រ ។

## ជំពូកទីពីរ
## «បុព្វហេតុរបស់យើងគឺខុសគ្នា»: ទស្សនៈប្រៀបធៀបចំពោះគោលនយោបាយទៅលើស្ត្រីរបស់ជនកុម្មុយនិស្តអាស៊ី

«យើងមិនដោះស្រាយបញ្ហាដូចប្រទេសផ្សេងទេ ។ យើងមានលក្ខណៈខុសពីគេ ។ គោលនយោបាយរបស់យើងខុសពីគេ ។ ទស្សនៈគោលរបស់យើងខុសពីគេ ។ គោលជំហររបស់យើងខុសពីគេ ។ ដូច្នេះការដោះស្រាយបញ្ហាក៏ត្រូវប្រើប្រាស់វិធីសាស្ត្រខុសគេដែរ» ។ ទ្រឹស្តីរបស់បក្សកុម្មុយនិស្តកម្ពុជាដកស្រង់ចេញពីឯកសារផែនការ៤ឆ្នាំ បោះពុម្ពឆ្នាំ១៩៧៦ ។

កម្ពុជាប្រជាធិបតេយ្យបានបង្កឲ្យមានការផ្លាស់ប្តូរយ៉ាងគំហុកទៅលើស្ត្រីនិងគ្រួសារកម្ពុជា ។ ទោះជារបបកុម្មុយនិស្តនៅក្នុងប្រទេសជាច្រើននៅអាស៊ីលុបបំបាត់ចោលនូវទំនៀមទម្លាប់រស់នៅជាគ្រួសារមិនបានសម្រេចក៏ដោយក៏ខ្មែរក្រហមបានបំផ្លាញនូវការរស់នៅជាគ្រួសារនេះទាំងស្រុង ហើយកសាងជំនួសវិញនូវសង្គមមួយដែលពឹងផ្អែកទៅលើការរស់នៅហូបចុករួមគ្នា ។ ហ្វ្រេឌ្រិក អ៊ែងដែល បានបកស្រាយដោយត្រួសៗពីសង្គមបែបនេះនៅក្នុងសៀវភៅរបស់គាត់ដែលមានចំណងជើងថា «ប្រភពនៃគ្រួសារ ទ្រព្យសម្បត្តិឯកជន និង រដ្ឋ» ។ ការវាយប្រហាររបស់ខ្មែរក្រហមទៅលើគ្រួសារបានចាប់ផ្តើមក្នុងអំឡុងសង្គ្រាមស៊ីវិលនៅកម្ពុជាពីឆ្នាំ១៩៧០ដល់១៩៧៥ នៅពេលដែលប្រជាកសិកររួមទាំងស្ត្រីជំទង់ត្រូវបានបង្ខំឲ្យចាកចេញពីភូមិដោយពួកកុម្មុយនិស្តដើម្បីចូលបម្រើបដិវត្តន៍ ។ ស្ត្រីបានចូលបម្រើបដិវត្តន៍ចិនវៀតណាម ហើយប្រហែលជាកូរ៉េខាងជើងដែរ ប៉ុន្តែបដិវត្តន៍នៅក្នុងប្រទេសទាំងនេះមិនបានព្យាយាមបង្កើតឲ្យមានការប្រែប្រួលដ៏ធំធេងដូចដែលខ្មែរក្រហមបានធ្វើ និងដូចអ្វីដែល អ៊ែងដែល បានសរសេរនោះទេ ។ តាមការពិត គ្រាន់តែក្រឡេកមើលមួយភ្លែតទៅលើប្រទេសអាស៊ីទាំងបីនេះ ក៏អាចឃើញដែរថា គម្រោងរបស់ អ៊ែងដែល មិនត្រូវបានអនុវត្តយ៉ាងពេញលេញទេ មានតែកម្ពុជាប្រជាធិបតេយ្យមួយប៉ុណ្ណោះ ដែលបានធ្វើស្រដៀងនឹងគម្រោងនេះច្រើនជាងគេ ។

អ្វីដែលធ្វើឲ្យរបបនេះទាំងនេះមានសារប្រយោជន៍សម្រាប់ការសិក្សានៅក្នុងនេះ គឺការមិនបានអនុវត្តតាមចក្ខុវិស័យអំពីគ្រួសាររបស់ អ៊ែងដែល នេះហើយ ។ «កង្វះខាត»ទាំងនេះអាចត្រូវបានកត់សម្គាល់ដោយខ្មែរក្រហមដែលយល់ថា ដើម្បីបង្កើតសង្គមកុម្មុយនិស្តមួយដ៏ល្អ ចាំបាច់ត្រូវតែបង្កើតឲ្យមានការផ្លាស់ប្តូរយ៉ាងគំហុកមួយ ។ តាមការពិតខ្មែរក្រហមពុំបានរៀនសូត្រពីការបរាជ័យរបស់ប្រទេសទាំងបីនេះទេ ពីព្រោះខ្មែរក្រហមតែងតែលើកឡើងម្តងហើយម្តងទៀតថាបដិវត្តន៍របស់ខ្លួនមានលក្ខណៈពិសេសមិនធ្លាប់មានមិនពឹងពាក់អ្នកដទៃនិងរីកលូត-លាស់ឆាប់រហ័ស ។

អ្វីដែលធ្វើឲ្យប្រទេសចិននិងវៀតណាមក្លាយជាគំរូដែលគួរឲ្យរៀនសូត្រតាម គឺប្រសិទ្ធភាពនៃការជ្រើសរើសនិងការបញ្ចូលមនោគមវិជ្ជាទៅឲ្យស្ត្រីរបស់ប្រទេសទាំងនេះ និងតួនាទីដ៏សំខាន់ដែលស្ត្រីមាននៅក្នុងបដិវត្តន៍ ។ ផ្ទុយទៅវិញ បដិវត្តន៍ខ្មែរក្រហមទំនងជាផ្តល់នូវការយកចិត្តទុកដាក់តិចតួចប៉ុណ្ណោះទៅលើស្ត្រី ហើយការពុំសូវយកចិត្តទុកដាក់នេះត្រូវបានឆ្លុះបញ្ចាំងឲ្យឃើញតាមរយៈការគាំទ្រដែលស្ត្រីទទួលបាន ។

នៅក្នុងសៀវភៅ «ប្រភពនៃគ្រួសារ ទ្រព្យសម្បត្តិឯកជន និង រដ្ឋ» អ៊ែងដែល បានចង្អុលបង្ហាញអំពីតួនាទីរបស់ស្ត្រីសង្គមនិយម និងមាគ៌ាឆ្ពោះទៅរកការរំដោះស្ត្រីចេញពីវិសមភាព ។ គាត់សរសេរថា ការរំដោះស្ត្រីឲ្យរួចចាកផុតពីការគាបសង្កត់អាចកើតឡើងក្នុងករណីដែលស្ត្រីទាំងអស់ត្រូវបានដឹកនាំឲ្យចូលរួមនៅក្នុងផលិតកម្មឧស្សាហកម្ម ហើយគ្រួសារលែងជាកត្តាចម្បង

នៃផលិតកម្មសេដ្ឋកិច្ចតទៅទៀត ។ គ្រួសារប្រភេទនេះបង្កើតឲ្យមាន“ទាសភាព”ដល់ស្ត្រី ដែលក្នុងនោះ បុរសតែងតែជាអ្នកស្វែងរកប្រាក់ មានអំណាចជាងគេនៅក្នុងគ្រួសារ ហើយការងារផ្ទះរបស់ស្ត្រីត្រូវបានចាត់ទុកថា ជាការងារបន្ទាប់បន្សំដែលមិនត្រូវបានឲ្យតម្លៃ ។ ផ្ទុយទៅវិញ បែបផែនផលិតកម្មជាលក្ខណៈសហករណ៍នឹងលុបបំបាត់ចោលនូវគ្រួសារឯកជន ដែលនាំឲ្យការចិញ្ចឹមបីបាច់ថែរក្សាកូនចៅក្លាយទៅជាការងាររួម នាំឲ្យស្ត្រីរួចចាកផុតពីការងារផ្ទះ អនុញ្ញាតឲ្យស្ត្រីចូលរួមនៅក្នុងសកម្មភាពផលិតកម្មយ៉ាងពេញលេញ និងផ្តល់ដល់ស្ត្រីនូវសិទ្ធិស្មើគ្នាជាមួយបុរស ។

ជនបដិវត្តន៍ពីររូបដ៏ល្បីល្បាញនៅក្នុងសតវត្សរ៍ទី២០ បានចម្លងតាមគំនិតរបស់ អ៊ែងហ្គែល ។ លេនីន ដូច អ៊ែងហ្គែល ដែរ បានចាត់ទុក “ការងារផ្ទះជាការងារដែលបង្អាប់ រឹតត្បិត និងគាបសង្កត់ស្ត្រី” ហើយ“ធ្វើឲ្យកម្លាំងពលកម្មស្ត្រីគ្មានប្រយោជន៍សម្រាប់ជាតិ” ។ លេនីន មានជំនឿថា ចលនារំដោះស្ត្រីគួរតែជាការងារទីពីររបស់បដិវត្តន៍ទាំងមូល ពីព្រោះការចាប់អារម្មណ៍តែមួយគត់ទៅលើបញ្ហាស្ត្រី ជាការបង្អាក់សកម្មភាពចលនាតស៊ូ និងមានលក្ខណៈអនុធន ។ ដូច្នេះការរំដោះស្ត្រីអាចប្រព្រឹត្តទៅបានតែតាមរយៈសកម្មភាពរបស់បដិវត្តន៍ទេ ។ គំនិតនេះក៏ត្រូវបានពោលអះអាងជាថ្មីពីបក្សកុម្មុយនិស្តចិន ។ បក្សនេះបានប្រកាសអំពីការគាំទ្រស្ត្រីជាបន្តបន្ទាប់ ប៉ុន្តែបានរិះគន់ថា “ស្ត្រីនិយម”ជានយោបាយរបស់ពួកអនុធន ។ ម៉ៅ សេទុង បានគាំទ្រចំពោះការផ្តល់សិទ្ធិដល់ស្ត្រីបន្តិចម្តងៗ ពីព្រោះមេដឹកនាំរូបនេះយល់ថា ប្រសិនបើកំណែទម្រង់ត្រូវបានយកមកអនុវត្តលឿនពេក ប្រតិកម្មប្រឆាំងនឹងបដិវត្តន៍អាចកើតមាន ។ គាត់ក៏ចាត់ទុកដែរថា ការរំដោះស្ត្រីជាភារកិច្ចដែលមានសារសំខាន់ចំពោះចលនាបដិវត្តន៍ទាំងមូល ដោយថ្លែងថា ការលុបបំបាត់ចោលនូវវិសមភាពរវាងបុរសនិងស្ត្រី“នឹងកើតមានឡើងដោយឯកឯងបន្ទាប់ពីការតស៊ូទទួលបានជោគជ័យ” ។

ទស្សនៈរបស់ជនកុម្មុយនិស្តចិនទៅលើស្ត្រីនិងគ្រួសារគឺមានសារសំខាន់សម្រាប់ការសិក្សាអំពីស្ត្រីនៅក្រោមរបបខ្មែរក្រហមតាមហេតុផលពីរ ។ ទីមួយ បក្សកុម្មុយនិស្តចិនគឺជាអ្នកគាំទ្ររបបខ្មែរក្រហមដ៏ធំផុតសម្រាប់ការរស់រានមានជីវិតរបស់ខ្មែរក្រហម ហើយមេដឹកនាំកុម្មុយនិស្តខ្មែរ (រួមទាំងប៉ុលពតដែលពុំសូវធ្វើដំណើរច្រើន) បានចេញទៅប្រទេសចិនជាញឹកញាប់ ។ ដូច្នេះបទពិសោធន៍កុម្មុយនិស្តនិយមនៅប្រទេសចិនអាចមានឥទ្ធិពលយ៉ាងខ្លាំងទៅលើមេដឹកនាំខ្មែរក្រហម ។ ទោះជាជនកុម្មុយនិស្តវៀតណាមមានទំនាក់ទំនងដោយផ្ទាល់ជាមួយកម្ពុជាដែលប្រទេសនេះបានហ្វឹកហ្វឺនកម្មាភិបាលនិងទាហានកម្ពុជាក៏ដោយ ក៏ទំនាក់ទំនងរវាងកម្ពុជានិងវៀតណាម គឺពោរពេញទៅដោយការមិនទុកចិត្តគ្នានិងការប្រកាន់ពូជសាសន៍ដែលធ្លាប់មានជាយូរណាស់មកហើយក្នុងប្រវត្តិសាស្ត្រ ។ ទីពីរ ចំណុចដែលកំណត់ព្រឹត្តិការណ៍សេដ្ឋកិច្ចសង្គមនិងមនោគមវិជ្ជា ដែលគាត់តែងពីលក្ខណៈដឹកនាំរបស់បក្សកុម្មុយនិស្តចិន មានដូចជាមហាលោតផ្លោះមហាអស្ចារ្យ បដិវត្តន៍វប្បធម៌ និងការប្រកួតប្រជែងដើម្បីគ្រួតត្រាបក្សបន្ទាប់ពីមរណភាពរបស់ ម៉ៅ សេទុង មានលក្ខណៈស្រដៀងគ្នានឹងបដិវត្តន៍របស់កម្ពុជាប្រជាធិបតេយ្យ ដែលកើតមានក្នុងពេលដែលខ្មែរក្រហមបានព្យាយាមប្រយុទ្ធដើម្បីឡើងកាន់អំណាចនិងការពារអំណាច ។ នៅក្នុងសម័យកាលយុគនេះ តួនាទីរបស់ស្ត្រីនៅក្នុងប្រទេសចិនគឺជាបញ្ហាដ៏សំខាន់មួយ ។

នៅក្នុងសម័យមុនពេលមានចលាចលនៅក្នុងសតវត្សរ៍ទី២០ ស្ត្រីចិនមានតួនាទីបន្ទាប់បន្សំនៅក្នុងសង្គម ដែលស្របទៅតាមទ្រឹស្តីរបស់ទស្សនវិទូចិនឈ្មោះ ខុងជឺ ។ គ្រួសារជាប្រពៃណីចិនមានលក្ខណៈប្តីជាមេគ្រួសារនិងមានអំណាចក្នុងគ្រួសារ កូនយកតំណខាងឪពុក និងកូនក្រមុំទៅនៅផ្ទះកូនកំលោះបន្ទាប់ពីរៀបអាពាហ៍ពិពាហ៍ ។ សង្គមនេះបានផ្តល់ដល់ស្ត្រីនូវសិទ្ធិនិងអំណាចបន្តិចបន្តួចប៉ុណ្ណោះ ។ តម្លៃនៅក្នុងលទ្ធិខុងជឺ ដែលរួមទាំងចំណុចទាំងឡាយដែលគាត់តែងនូវតួនាទីរបស់ស្ត្រីនៅក្នុងសង្គម ត្រូវបានទទួលរងការរិះគន់នៅក្នុងអំឡុងប៉ុន្មានឆ្នាំចុងក្រោយនៃរាជវង្សឆេង (១៦៤៤-១៩១១) និងនៅក្នុង “ចលនា៤ឧសភា១៩១៩” ។ នៅក្នុងសមាជបក្សលើកទីពីរប្រព្រឹត្តទៅនៅក្នុងឆ្នាំ១៩២២ បក្សកុម្មុយនិស្តចិនបានបង្កើតនូវ “មន្ទីរកិច្ចការនារី” ដោយចេញសេចក្តីប្រកាសមួយដែលផ្តល់ដល់

ស្ត្រីនូវសិទ្ធិបោះឆ្នោតនិងសិទ្ធិធ្វើការងារ ហើយបានប្រកាសលុបបំបាត់ចោលរាល់នីតិបញ្ញត្តិទាំងឡាយដែលគាបសង្កត់ទៅលើស្ត្រី ។

គោលនយោបាយដែលដាក់ចេញជាផ្លូវការរបស់បក្សកុម្មុយនិស្តចិនអំពីស្ត្រី មានការប្រែប្រួលទៅតាមតំបន់និងកាលៈទេសៈ ប៉ុន្តែបក្សកុម្មុយនិស្តចិននៅតែមានទំនោរទៅរកការគាំទ្រនូវបិតាធិបតេយ្យដដែល ទោះបីជាបានអនុម័តច្បាប់និងបាននិយាយគាំទ្រស្ត្រីក៏ដោយ ។ ក្រឹត្យរៀបអាពាហ៍ពិពាហ៍របស់បក្សនេះ (ដែលផ្តល់ឲ្យស្ត្រីនូវសេរីភាពក្នុងការជ្រើសរើសស្វាមីនិងសិទ្ធិលែងលះ) ជាចំណុចមិនដាច់ស្រេច ពិសេសនៅក្នុងចំណោមកសិករអភិរក្សនិយម ។ នៅក្នុងសម័យកាលតស៊ូបដិវត្តន៍ពីឆ្នាំ១៩៣០ដល់អំឡុងឆ្នាំ១៩៤០ បក្សកុម្មុយនិស្តបានបន្ថយនូវការអនុវត្តន៍ច្បាប់នេះរបស់ខ្លួនដើម្បីការពារកុំឲ្យប៉ះពាល់ដល់ការគាំទ្របក្សកុម្មុយនិស្តនៅតាមជនបទ ។ នៅទីបញ្ចប់បក្សកុម្មុយនិស្តទទួលយកនូវទ្រឹស្តីមួយជំហានម្តងៗរបស់ ម៉ៅសេទុង ក្នុងកំណែទម្រង់សង្គម នោះគឺ “ការរំដោះស្ត្រីត្រូវឋិតនៅជាការងារបន្ទាប់បន្សំរបស់បដិវត្តន៍ ហើយនឹងត្រូវសម្រេចឲ្យបានក្រោយជ័យជំនះ” ។

ទោះជាយ៉ាងណាក៏ដោយ បក្សកុម្មុយនិស្តចិនបានកេណ្ឌកសិករស្ត្រីជាទ្រង់ទ្រាយធំដើម្បីមកគាំទ្របដិវត្តន៍របស់ខ្លួនបានយ៉ាងជោគជ័យ ។ បក្សកុម្មុយនិស្តបានកត់សម្គាល់នូវសារប្រយោជន៍នៃការកេណ្ឌគ្រួសារទាំងមូល ។ ដើម្បីសម្រេចបានយ៉ាងដូច្នេះ ការពន្យល់ឲ្យស្ត្រីយល់អំពីតម្លៃនៃបដិវត្តន៍ មានប្រយោជន៍ក្នុងការបង្កើនការគាំទ្រពីប្តីនិងកូនប្រុសរបស់ស្ត្រីនោះ ។ ដើម្បីទទួលបាននូវការទុកចិត្តពីកសិករស្ត្រី សមាគមស្ត្រីរបស់បក្សបានចូលរួមនៅក្នុងសកម្មភាពដែលបានជួយដល់ស្ត្រីដោយផ្ទាល់ ។ សមាគមនេះត្រូវបានចាត់ឲ្យប្រមែប្រមូលស្ត្រីនិងជម្រុញឲ្យស្ត្រីចូលរួមនៅក្នុងផលិតកម្មកសិកម្ម ដើម្បីជាជំនួយដល់ការធ្វើសង្គ្រាម និងរក្សាឲ្យបាននូវស្ថិរភាពបរិមាណផលិតកម្មនៅពេលដែលបុរសចេញទៅធ្វើសង្គ្រាមនៅសមរភូមិ ។ បក្សកុម្មុយនិស្តចិនយល់ថា សកម្មភាពបែបនេះ នឹងបង្កើននូវចំណាប់អារម្មណ៍របស់ស្ត្រី បង្កើនឋានៈសង្គមនិងសេដ្ឋកិច្ចរបស់ស្ត្រី ហើយបន្តិចម្តងៗនឹងកំណត់សាជាថ្មីនូវតួនាទីរបស់ស្ត្រីដែលពីមុនមកនៅក្នុងតំបន់ខ្លះ (ពិសេសប៉ែកពាយ័ព្យនៃប្រទេសចិន) មានការចូលរួមពីស្ត្រីយ៉ាងតិចតួចបំផុតនៅក្នុងសកម្មភាពផលិតកម្ម ។

ស្ត្រីបានសម្តែងនូវតួនាទីដោយផ្ទាល់នៅក្នុងការតស៊ូអាវុធប្រឆាំងនឹងជប៉ុន និងបក្សកួកមីងតាង តាមរយៈការចូលបម្រើការងារនៅក្នុងក្រុមស៊ើបការណ៍សម្ងាត់ រាយមីន ព្យាបាលអ្នកជំងឺ ជញ្ជូនសម្ភារ និងការពារភូមិ ។ ច្បាប់របស់បក្សកុម្មុយនិស្តដែលបានផ្តល់ដល់ស្ត្រីនូវសិទ្ធិកាន់កាប់ដីធ្លីនិងរៀបអាពាហ៍ពិពាហ៍បានទាក់ទាញឲ្យស្ត្រីជំទង់ចូលរួមនៅក្នុងចលនាតស៊ូ ទោះបីជាស្ត្រីទាំងនេះមានការខឹងសម្បានឹងការអនុវត្តន៍ជាក់ស្តែងរបស់ច្បាប់ទាំងនេះដែលប្រែប្រួលជាញឹកញយដោយសារបក្សកុម្មុយនិស្តចិនព្យាយាមថែរក្សានូវគោលនយោបាយបត់បែនតាមកាលៈទេសៈឆ្ពោះទៅកាន់ការរំដោះស្ត្រីក៏ដោយ ។ ប្រសិនបើបក្សកុម្មុយនិស្តចិនដឹងថាច្បាប់ដែលបក្សបង្កើតធ្វើឲ្យមានភាពមិនស្ងប់ចិត្តចំពោះប្រជាកសិករ ឬមួយដឹងថា ប្រជាជនកំពុងតែត្រូវរំខាននៅក្នុងកិច្ចការយោធាបក្សកុម្មុយនិស្តចិននឹងពន្យារពេលធ្វើកំណែទម្រង់ ហើយរិះគន់សង្គមរបស់ស្ត្រីអំពីការងាកចេញពីចលនាបដិវត្តន៍ទូទៅ ។

ទោះបីជាមានគម្លាតរវាងច្បាប់និងការអនុវត្តន៍ជាក់ស្តែងរបស់បក្សកុម្មុយនិស្តចិនក៏ដោយ ក៏បក្សអាចធ្វើឲ្យស្ត្រីជឿទុកចិត្តថា ការចូលរួមបម្រើបដិវត្តន៍នឹងធ្វើឲ្យកម្រិតជីវភាពរបស់ស្ត្រីកាន់តែប្រសើរឡើង ។ បក្សបានប្រើប្រាស់យ៉ាងមានប្រសិទ្ធភាពនូវការឃោសនាអំពីផលប្រយោជន៍នៃការរំដោះស្ត្រី ដើម្បីពង្រីកនូវការគាំទ្រទៅលើបក្សពីមូលដ្ឋាន ។ ផ្ទុយទៅវិញ នៅក្នុងប្រទេសកម្ពុជាមានភស្តុតាងតិចតួចប៉ុណ្ណោះដែលបង្ហាញអំពីការឃោសនារបស់ខ្មែរក្រហមសំដៅទៅលើស្ត្រី ។ នារីជំទង់ត្រូវបានប្រាប់ថា ស្ត្រីមានសិទ្ធិស្មើបុរស ប៉ុន្តែខ្មែរក្រហមពុំបានប្រែក្លាយសម្តីនេះឲ្យទៅជាច្បាប់ទេ ។

ជាការពិតណាស់ ស្ត្រីនៅតាមស្រុកស្រែចម្ការរបស់ប្រទេសចិនត្រូវបានតម្រូវឲ្យទទួលបាននូវកំណើនសេដ្ឋកិច្ចសង្គមនិង នយោបាយដ៏ជាក់លាក់មួយ នេះប្រហែលជាដោយសារ

តម្រូវការចាំបាច់របស់សង្គ្រាម ជាជាងការខំប្រឹងប្រែងដាក់ស្តែងផ្តោះទៅកាន់គោលបំណងមិនប្រកាន់ភេទរបស់បក្សកុម្មុយនិស្ត ។ បក្សកុម្មុយនិស្តចិនបានបដិសេធមិនព្រមលុបបំបាត់ចោលនូវសង្គមបិតាធិបតេយ្យ ប៉ុន្តែកែសម្រួលវិញ ដោយជឿជាក់យ៉ាងមុតមាំថា ការផ្លាស់ប្តូរដាក់ស្តែងនឹងកើតមានបន្ទាប់ពីទទួលបានជ័យជម្នះ ។ កាយអាន ចនសុន បានសរសេរថា ម៉ៅបានមើលស្រាលភាពស៊ិតស្វាញមិនព្រមប្រែប្រួលនៃប្រពៃណីទំនៀមទម្លាប់ចិន ហើយពុំបានទទួលស្គាល់អភិរក្សភាពរបស់ប្រជាកសិករដែល“ភាគច្រើនបានតស៊ូប្រយុទ្ធដើម្បីស្តារឡើងវិញនូវជីវិតជាប្រពៃណីរបស់ខ្លួន គឺជីវិតដែលបែកបាក់ដោយសារសង្គ្រាម ហើយមិនមែនសម្រាប់បម្លាស់ប្តូរសង្គមទេ” ។ ដូច្នេះនៅពេលដែលបក្សកុម្មុយនិស្តចិនបានព្យាយាមអនុវត្តកំណែទម្រង់នៅអំឡុងដើមទសវត្សរ៍ឆ្នាំ១៩៥០ ដែលផ្តល់ដល់ស្ត្រីនូវសិទ្ធិកាន់កាប់ដីធ្លីនិងរៀបអាពាហ៍ពិពាហ៍បក្សកុម្មុយនិស្តបានបង្កឲ្យមានប្រទូសរ៉ាយនៅក្នុងសង្គមកសិករ ហើយបានបញ្ឈប់ការអនុវត្តភ្លាមៗដែរ ។ ដូច្នេះបិតាធិបតេយ្យចិនបានបង្ហាញនូវភាពរឹងមាំដ៏គួរឲ្យញញើត ។ សមភាពភេទតាមរយៈបដិវត្តន៍ដែល អ៊ែងដែល, លេនីន និង ម៉ៅ សេទុង បានទស្សន៍ទាយទុក ពុំបានកើតមាននៅក្នុងប្រទេសចិនទេ ។ ភាពស៊ិតស្វាញនៃបិតាធិបតេយ្យនៅក្នុងប្រទេសចិនអាចជាសញ្ញាមួយប្រាប់ខ្មែរក្រហមថាមានតែបំផ្លាញចោលយ៉ាងឆាប់រហ័សនូវទំនៀមទម្លាប់ ទើបអាចកែប្រែគ្រួសារនិងរំដោះស្ត្រីនៅក្នុងប្រទេសកម្ពុជាយ៉ាងពិតប្រាកដ ។

នៅក្នុងអំឡុងពេលនៃការអនុវត្តនយោបាយមហាលោតផ្លោះមហាអស្ចារ្យពីឆ្នាំ១៩៥៨ដល់១៩៦០ ជាថ្មីម្តងទៀតបក្សកុម្មុយនិស្តចិនបានសាកល្បងអនុវត្តនូវចក្ខុវិស័យរបស់ អ៊ែងដែល ទាក់ទងទៅនឹងការរំដោះស្ត្រីតាមរយៈការធ្វើផលិតកម្មរួមគ្នា ។ ឯកសារមួយរបស់បក្សកុម្មុយនិស្តចិនបានលើកឡើងថា “ដោយឃើញថា ឥឡូវនេះស្ត្រីអាចធ្វើការដោយស្មើដៃគ្នាជាមួយបុរស ស្ត្រីមានឋានៈកាន់តែខ្ពស់នៅក្នុងផ្ទះនិងនៅក្នុងសង្គម” ។ ជាមួយគ្នានោះដែរ “បញ្ហាដ៏យូរអង្វែងទាក់ទងទៅនឹងការចម្អិនម្ហូបនិងថែទាំកូនចៅ” ត្រូវបានដោះស្រាយដោយសហករណ៍ ។ តាមការពិត រដ្ឋាភិបាលកុម្មុយនិស្តបានប្រឹងប្រែងសាងសង់មន្ទីរកុមារនិងបរិក្ខារសហករណ៍ ដើម្បីលុបបំបាត់ចោលនូវបន្ទុកការងារផ្ទះរបស់ស្ត្រី ហើយរដ្ឋាភិបាលនេះបានជំរុញឲ្យស្ត្រីរក្សានូវតុល្យភាពរវាងការងារនិងគ្រួសារ ។ បែកចេញឆ្ងាយពីគំនិតរបស់ អ៊ែងដែល បក្សកុម្មុយនិស្តចិនបានថ្លែងថា “ការរស់នៅជាគ្រួសារតាមប្រពៃណីចាស់មិនអាចកើតមានវិញទេ ប៉ុន្តែរស់នៅក្នុងគ្រួសារដ៏ធំមួយ” តាមរយៈការបង្កើតសហករណ៍ ។ ប៉ុន្តែ ក្រោយពីការបរាជ័យដ៏ធ្ងន់ធ្ងរនៃកម្មវិធីមហាលោតផ្លោះមហាអស្ចារ្យ ការកសាងគ្រឿងប្រដាប់និងអគារសម្រាប់សហករណ៍មានការថយចុះ ហើយតួនាទីក្នុងផ្ទះរបស់ស្ត្រីត្រូវបានលើកឡើងយកមកអនុវត្តវិញ ។

ក្រោយមក ជាពិសេសក្នុងដំណាក់កាលបដិវត្តន៍វប្បធម៌ (១៩៦៦-១៩៧០) ស្ត្រីត្រូវបានបង្ខំឲ្យចូលរួមនៅក្នុងសកម្មភាពផលិតកម្មក៏ដូចជាកិច្ចការនយោបាយជាថ្មីម្តងទៀត ហើយឲ្យយកចិត្តទុកដាក់តិចតួចទៅលើគ្រួសារ និងកាន់តែច្រើនទៅលើសហករណ៍ ។ ទោះជាយ៉ាងណាក៏ដោយ គ្រឿងបរិក្ខារចាំបាច់របស់សហករណ៍នៅតែមិនគ្រប់គ្រាន់ដដែល ។ ដូចនៅក្នុងសម័យមហាលោតផ្លោះមហាអស្ចារ្យ ស្ត្រីត្រូវបានដាក់បន្ទុកឲ្យអនុវត្ត “ការងារទ្វេ៖ ធ្វើការងារក្នុងគេហដ្ឋានផង ការងារសហករណ៍ផង” ។ បក្សកុម្មុយនិស្តចិនបានកត់សម្គាល់នូវស្ថានការណ៍ ហើយបានដាក់“ការងារទ្វេ”ជាគុណធម៌សង្គមនិយមមួយ ។ ទោះជាបានបង្កើតច្បាប់និងបញ្ចេញគំនិតគាំទ្រស្ត្រីក៏ដោយ ក៏បក្សកុម្មុយនិស្តចិនត្រូវបរាជ័យក្នុង“ការរំដោះ”កសិករស្ត្រីដែរ ។ នៅក្នុងប្រទេសចិន ចក្ខុវិស័យរបស់ អ៊ែងដែល ចំពោះស្ត្រីនិងគ្រួសារនៅតែជាការស្រមើស្រមៃ ។

បក្សកុម្មុយនិស្តកម្ពុជាប្រាកដជាបានយល់ដឹងអំពីភាពចលាចលនៅក្នុងសង្គមនិងសមរភូមិមនោគមវិជ្ជាដែលប្រទេសចិនបានឆ្លងកាត់ ។ ដោយបក្សកុម្មុយនិស្តកម្ពុជាបានខ្ចីបទពិសោធន៍ពីចិន ឧទាហរណ៍ពាក្យស្លោក មហាលោតផ្លោះមហាអស្ចារ្យ (ជាឃ្លាដែលនិយមប្រើក្នុងសម័យខ្មែរក្រហម) ប្រទេសកម្ពុជាប្រហែលជាបានកត់ត្រានូវបរាជ័យសង្គមនិយមរបស់ប្រទេសចិនហើយ ។ ចំពោះស្ត្រីនិងគ្រួសារ បម្រែបម្រួលនៃគោលនយោបាយរបស់ប្រទេសចិនពុំបានរំដោះស្ត្រី ឬលុបបំបាត់

ចោលនូវបិតាធិបតេយ្យដែលអនុវត្តយ៉ាងពេញលេញនៅតាមជនបទទេ ។ ក្នុងអំឡុងសម័យបដិវត្តន៍វប្បធម៌ និងការឈានចូលមកដល់នូវបនទាំងបួន(១៩៧៣-១៩៧៦) បក្សកុម្មុយនិស្តចិនខ្លួនឯងបានបង្ហាញនូវការសោកស្តាយ ហើយបានប្រកាសលុបបំបាត់ចោលនូវការប្រើប្រាស់ទ្រឹស្តីរបស់ទស្សនៈវិទូ ខុងជឺដោយរួមទាំងទស្សនៈដែលបង្កឲ្យមានការជិះជាន់ស្ត្រីផង ។

ភាពអន់ថយនៃប្រទេសចិនក៏ដូចជាកូរ៉េកុម្មុយនិស្តត្រូវបានលើកយកមកពិភាក្សានៅក្នុងការបង្កើត"ផែនការ៤ឆ្នាំ" របស់បក្សកុម្មុយនិស្តកម្ពុជាដែលបានសរសេរនៅក្នុងឆ្នាំ១៩៧៦ ។ នៅក្នុងប្រទេសនីមួយៗ គោលនយោបាយនេះបានព្រមានថា "ពួកមូលធននិងពួកបុគ្គលនិយមកំពុងតែស្ថិតនៅក្នុងដំណើរការនៃការពង្រឹងនិងពង្រីកជាប្រចាំនូវមូលដ្ឋានរបស់វាគ្រប់ទិសទី ។ ឲ្យតែពួកវានៅរស់ ពួកវានឹងពង្រឹងខ្លួនឯងនិងពង្រីកដើម្បីឲ្យក្លាយជាឧបសគ្គរាំងស្ទះដំណើរការបដិវត្តន៍សង្គមនិយម" ។ ផ្ទុយទៅវិញ បក្សកុម្មុយនិស្តកម្ពុជាបានធ្វើដំណើរទៅមុខនៅលើវិថីសង្គមនិយមមួយដ៏ងាយស្រួលបំផុតៈ "ចំពោះយើង យើងបង្កើតឲ្យមានការហូបចុករួមគ្នាទាំងស្រុង... ។ ជារួមការបង្កើននូវកម្រិតជីវភាពរបស់ជនរួមជាតិយើងមានន័យថាការធ្វើការងារនេះតាមរយៈសហករណ៍.... ។ ប្រជាជនយើងមានការសប្បាយចិត្តនឹងរស់នៅក្នុងការដឹកនាំបែបនេះ" ។

គួរឲ្យចាប់អារម្មណ៍ខ្លាំងណាស់ ដំណាក់កាលនៃបនទាំងបួនគឺជាពេលវេលាដែលមានទំនាក់ទំនងរវាងជនកុម្មុយនិស្តកម្ពុជានិងចិនកើនឡើង ។ ពេលដែលបក្សកុម្មុយនិស្តចិនកំពុងឋិតនៅក្នុងដំណាក់កាលរិះគន់ ការរៀបចំទុកដាក់គ្រួសារតាមបែបប្រពៃណីទំនៀមទម្លាប់ ខ្មែរក្រហមបានចាប់ផ្តើមដំណើរការបំផ្លាញការរស់នៅជាគ្រួសារ ដោយថ្លែងថា ខ្លួន"រំដោះ"ស្ត្រីដើម្បីបម្រើបដិវត្តន៍ ទោះជាចង់ឬមិនចង់ក៏ដោយ ។ ការពិតជាក់ស្តែងដែលថាបដិវត្តន៍របស់បក្សកុម្មុយនិស្តចិនកើតឡើងនៅ


ក្រុមសិល្បៈនារី

ក្នុងពេលជាមួយគ្នានឹងការរីកចម្រើនរបស់បក្សកុម្មុយនិស្តកម្ពុជា បានជំរុញឲ្យបក្សកុម្មុយនិស្តកម្ពុជាដើរតាមផ្លូវជ្រុលនិយម ។ តាមការពិត សម្តេចព្រះ នរោត្តម សីហនុ បានរៀបរាប់អំពីការមិនពេញចិត្តរបស់សមាជិកពីររូបនៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនិស្តកម្ពុជា (ខៀវ សំផន និង អៀង ធីរិទ្ធ) ចំពោះការផ្តល់ឱវាទពីនាយករដ្ឋមន្ត្រីចិន ជូ អេន ឡាយ ។ នៅក្នុងឆ្នាំ ១៩៧៥ នៅទីក្រុងប៉េកាំង ជូ បានផ្តល់យោបល់ឲ្យសមាជិកទាំងពីរនេះអនុវត្តការធ្វើដំណើរទៅរកលទ្ធិកុម្មុយនិស្តនិយមដោយល្បឿនយឺតៗ ហើយត្រូវចៀសវាងការអនុវត្តន៍នយោបាយ “មហាលោតផ្លោះមហាអស្ចារ្យ” ។ ជូ បានថ្លែងថា កំណែទម្រង់មួយជំហានម្តងៗច្បាស់ជានាំទៅរក“ការរីកចម្រើនសន្តិភាព និងសុភមង្គល” សម្រាប់ប្រទេសកម្ពុជា ។ សម្តេច សីហនុ បានសរសេរថា “ឆ្លើយតបទៅនឹងដំបូន្មានដ៏មានអត្ថន័យខ្លឹមសារនេះ ខៀវ សំផន និង អៀង ធីរិទ្ធ បានញញឹមដោយក្តីពេញចិត្តបំផុត” ។ តាមការពិតបក្សកុម្មុយនិស្តកម្ពុជាបានបដិសេធចោលទាំងស្រុងនូវឱវាទរបស់ ជូ អេនឡាយ ហើយបានព្យាយាមធ្វើកំណែទម្រង់ទៅលើប្រទេសកម្ពុជាទាំងមូលនិងទាំងស្រុងដោយគំហុកបំផុតជាងអ្វីៗដែល ម៉ៅ សេទុង ធ្លាប់បានព្យាយាមធ្វើនៅក្នុងប្រទេសចិនទៅទៀត ។ ប៉ុល ពត បានសម្រេចថា បក្សកុម្មុយនិស្តកម្ពុជានឹងអនុវត្តគោលនយោបាយ “មហាលោតផ្លោះ មហាអស្ចារ្យ” ពិសេសឆ្ពោះទៅកាន់សង្គមនិយម ។ គម្រោងនេះរួមមានការព្យាយាមកម្ទេចចោលនូវសម្ព័ន្ធភាពស្និតល្មួតនៅក្នុងគ្រួសារ និងបង្កើតឡើងនូវឈ្មោះ“អង្គការ” ដែលតំណាងឲ្យអាជ្ញាធរតែមួយគត់របស់បក្ស ។ បិតាធិបតេយ្យជាប្រពៃណីនឹងត្រូវលុបបំបាត់ចោលទាំងស្រុង ។

ដូចនៅក្នុងប្រទេសចិន គ្រួសារនៅក្នុងប្រទេសវៀតណាមគឺមានលក្ខណៈបិតាធិបតេយ្យនិងផ្តាច់ការ ទោះបីជានៅប្រទេសវៀតណាមស្ត្រីមានឋានៈខ្ពស់ជាងនៅចិនបន្តិចក៏ដោយ ។ សម្រាប់វៀតណាម គ្រួសារគឺជាឯកតាសេដ្ឋកិច្ចតូចបំផុតនៅក្នុងសង្គម ។ អាណានិគមនិយមបារាំងបានទម្លាក់ឋានៈរបស់ស្ត្រីវៀតណាមដោយចាត់ទុកស្ត្រីគឺជា“ទាសករនៃទាសករ” បានសេចក្តីថាស្ត្រីជាទ្រព្យសម្បត្តិរបស់បុរស ហើយបុរសជាទ្រព្យសម្បត្តិរបស់ពួកចៅហ្វាយនាយចក្រពត្តិបារាំង ។

ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងការតស៊ូបដិវត្តន៍នៅអំឡុងទសវត្សឆ្នាំ១៩៣០ ស្ត្រីមានតួនាទីដ៏សំខាន់ ។ ស្ត្រីជាអ្នកលីសែងសម្ភារឲ្យកងទ័ព ។ ស្ត្រីបានចូលរួមបម្រើនៅក្នុងសម្ព័ន្ធមិត្តវៀតណាមឈ្មោះ វៀតមិញ ដែលត្រូវបានបង្កើតឡើងដោយ ហូជីមិញ នៅឆ្នាំ១៩៤១ ដើម្បីប្រយុទ្ធប្រឆាំងនឹងការត្រួតត្រារបស់ជប៉ុន ។ ដើម្បីលើកទឹកចិត្តស្ត្រី វៀតមិញបានផ្តល់ឲ្យស្ត្រីនូវដីធ្លីនិងសិទ្ធិបោះឆ្នោត ហើយបានប្រកាសជាផ្លូវការនូវសមភាពផ្នែកសេដ្ឋកិច្ចនិងនយោបាយរវាងបុរសនិងស្ត្រី ។ ហូជីមិញខ្លួនឯងជាប្រភពនៃការលើកទឹកចិត្តមិនអាចកាត់ថ្លៃបានសម្រាប់ប្រជាជនវៀតណាម រួមទាំងស្ត្រីផង ។ គាត់គឺជានិមិត្តរូបនៃភាពក្លាហានមោះមុតនិងការរួបរួមជាតិសម្រាប់ប្រជាជនវៀតណាម ហើយជាអ្នកជាតិនិយមដ៏ប្តូរផ្តាច់ម្នាក់ ។ វត្តមានរបស់គាត់នៅក្នុងថ្នាក់ដឹកនាំចលនាបដិវត្តន៍វៀតណាម គឺជាអ្វីដែលខ្មែរក្រហមពុំមាននៅក្នុងបដិវត្តន៍របស់ខ្លួន លើកលែងតែនៅក្នុងដំណាក់កាលដែលពួកខ្មែរក្រហមបានចងសម្ព័ន្ធភាពជាមួយសម្តេច សីហនុ ដែលព្រះអង្គត្រូវបានលើកតម្កើងយ៉ាងខ្ពង់ខ្ពស់ក្នុងឋានៈជាមេដឹកនាំរណសិរ្សរួបរួមជាតិ ។ រណសិរ្សនេះបានចាប់ផ្តើមបាត់បង់ប្រជាប្រិយភាពនៅពេលដែលសម្តេច សីហនុ ត្រូវបានរុញច្រានចេញពីជួរដឹកនាំ ហើយកម្មាភិបាលខ្មែរក្រហមបានឡើងមកជំនួសព្រះអង្គនៅផ្នែកខាងមុខនៃចលនាវិញ ។

នៅក្នុងដំណាក់កាលប្រយុទ្ធប្រឆាំងនឹងបារាំង ស្ត្រីវៀតណាមបានបំពេញតួនាទីជាអ្នកដឹកជញ្ជូនសម្ភារគ្រាប់រំសេវសម្រាប់ការប្រយុទ្ធនៅក្នុងសមរភូមិឌៀនបៀនភូ នៅឆ្នាំ១៩៥៤ ។ លើសពីនេះ ស្ត្រីវៀតណាមបានចូលរួមនៅក្នុងការវាយឆ្មក់ស៊ើបការណ៍យកពត៌មានសម្ងាត់ ហើយឃោសនាសុំការគាំទ្រពីប្រជាជនក្នុងតំបន់ ។ ជាពិសេស ស្ត្រីខំប្រឹងរក្សានូវផលិតកម្មកសិកម្មតាមមូលដ្ឋានមិនឲ្យធ្លាក់ចុះនៅតាមមូលដ្ឋាននៅពេលដែលបុរសទៅប្រយុទ្ធនៅសមរភូមិមុខ ។ បដិវត្តន៍បានធ្វើឲ្យកសិករស្ត្រីមានឱកាសទទួលបាននូវគំនិតស្ត្រីនិយមដែលចាប់ផ្តើមបន្ធូរចំណងបិតាធិបតេយ្យជាប្រពៃណីដែលរារាំងមិនឲ្យស្ត្រី

ធ្វើការងារផ្សេងៗក្រៅអំពីការងារផ្ទះ ។

បន្ទាប់ពីទទួលបានឯករាជ្យ សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាមបានបន្តប្រឆាំងនឹងបិតាធិបតេយ្យនិយមតាមរយៈការអនុម័តច្បាប់មួយស្តីអំពីការរៀបអាពាហ៍ពិពាហ៍និងគ្រួសារនៅឆ្នាំ១៩៥៩ ។ ច្បាប់នេះបានហាមប្រាមចំពោះការបង្ខំឲ្យរៀបអាពាហ៍ពិពាហ៍ ហើយផ្តល់ឲ្យស្ត្រីនូវសិទ្ធិកាន់កាប់ដីធ្លី ។ ច្បាប់នេះត្រូវបានបង្កើតឡើងដើម្បីបន្ថយតម្លៃរបស់គ្រួសារ ហើយពង្រឹងតួនាទីរបស់រដ្ឋនៅក្នុងជីវិតរបស់ប្រជាកសិករ ។ ប៉ុន្តែគោលបំណងមួយទៀតរបស់ច្បាប់ដដែលនេះគឺ “កសាងគ្រួសារដែលមានសុភមង្គល មានលក្ខណៈប្រជាធិបតេយ្យ ហើយប្តីនិងប្រពន្ធមានសិទ្ធិស្មើគ្នា” ។ ដូច្នេះសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាមពុំមានបំណងនឹងលុបបំបាត់ចោលការរស់នៅជាគ្រួសារទាំងស្រុងនោះទេ ។ ដូចនៅប្រទេសចិនដែរ ទំនៀមទម្លាប់ប្រពៃណីចាស់របស់កសិករនៅតែមានទម្ងន់ខ្លាំងក្លា ហើយការយកច្បាប់ទៅអនុវត្តជាក់ស្តែងនៅតែប្រែប្រួលដដែល ។ វីល្លៀម ឌីលី បានចង្អុលបង្ហាញថា តួនាទីរបស់ស្ត្រីដែលកំពុងតែប្រែប្រួលនៅក្នុងប្រទេសវៀតណាម គឺមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងសង្គ្រាម ។ ពួកអភិរក្សនិយមនៅក្នុងបក្សត្រូវបានជំរុញឲ្យផ្លាស់ប្តូរទស្សនៈរបស់ពួកគេចំពោះស្ត្រី នៅពេលដែលសង្គ្រាមវៀតណាមបានបង្កើនតម្លៃស្ត្រីក្នុងផលិតកម្មកសិកម្មនិងឧស្សាហកម្ម ។ បក្សកុម្មុយនិស្តក៏បានកត់សម្គាល់ដែរថា ភាពចលាចលនៅក្នុងសម័យសង្គ្រាមផ្តល់ឱកាសមួយសម្រាប់ “បំពេញតម្រូវការឲ្យគ្រួសារ”និងធ្វើឲ្យការរស់នៅជាគ្រួសាររង្គោះរង្គើតាមរយៈការឃោសនារបស់បក្ស ។

នៅក្នុងសង្គ្រាម ស្ត្រីនៅប៉ែកខាងជើងត្រូវបានផ្តល់ឲ្យមានការទទួលខុសត្រូវបីយ៉ាងៈ ទីមួយ ត្រូវធ្វើការងារផ្ទះនៅពេលដែលប្តីមិននៅ ។ ទីពីរ ត្រូវរក្សាឲ្យបាននូវផលិតកម្មដើម្បីយកទៅផ្គត់ផ្គង់ឲ្យទាហាននៅក្នុងសមរភូមិ ។ ទីបី ត្រូវប្រយុទ្ធនៅពេលដែលប្តីមិននៅ ។ គ្រួសារត្រូវបិតនៅដដែលទោះជាក្នុងទម្រង់មួយដែលត្រូវបានកែប្រែពីទ្រឹស្តីរបស់ ខុងជឺ ក៏ដោយ ។

នៅវៀតណាមខាងត្បូង សង្គ្រាមក៏មានន័យថាជាការផ្លាស់ប្តូរដ៏ធំធេងសម្រាបកសិករស្ត្រី នៅពេលដែលខ្លួនចូលរួមកាន់តែជ្រៅជាមួយ“រណសិរ្សរំដោះជាតិ” ។ រណសិរ្សរំដោះជាតិជាចលនាតស៊ូកុម្មុយនិស្តនិយម មានគោលបំណងផ្តួលរំលំរដ្ឋាភិបាលវៀតណាមខាងត្បូងដែលគាំទ្រដោយសហរដ្ឋអាមេរិក ។ នៅក្នុងឆ្នាំ១៩៦១ រណសិរ្សរំដោះជាតិបានបង្កើត“សមាគមរំដោះស្ត្រី”ដែលមានតួនាទីសំខាន់ក្នុងការឃោសនាសម្រាប់បដិវត្តន៍ ។ សមាគមនេះបានបោះពុម្ពខិតប័ណ្ណ លិខិតប្រកាស និងលិខិតផ្សេងទៀតសម្រាប់ការចែកចាយនៅក្នុងនិងក្រៅប្រទេស ។ ការងារឃោសនានេះជាការងារស្នូលរបស់ចលនា “បិញវ៉ាន” ដែលមានបំណងចង់ឲ្យកងទ័ពសត្រូវកែប្រែគោលជំហរមកបម្រើបដិវត្តន៍វិញ ។ ដើម្បីទាក់ទាញស្ត្រី សមាគមបានខំប្រឹងលាតត្រដាងអំពីភាពអសីលធម៌របស់សត្រូវ ហើយបានរិះគន់ពួកសក្តិភូមិដែលដាក់បន្ទុកធ្ងន់ធ្ងរមកលើគ្រួសារ និងគាបសង្កត់ស្ត្រីនៅវៀតណាមខាងត្បូង ។ សមាគមបានសរសើរអំពីជំនឿអរូបិយនិងការប៉ិនប្រសប់របស់ស្ត្រីនៅក្នុងការរៀបចំទុកដាក់ប្រាក់កាស និងបានលើកឡើងអំពីកំណែទម្រង់ប្រជាធិបតេយ្យដែលបានបង្កើនរួចជាស្រេចនូវកម្រិតជីវភាពរបស់ស្ត្រីនៅវៀតណាមខាងជើង ។ សមាគមបានព្យាយាមបណ្តុះកំហឹងវណ្ណៈនៅក្នុងចិត្តរបស់កសិករស្ត្រីនៅវៀតណាមខាងត្បូង ហើយគោលដៅមួយរបស់សមាគមនេះគឺបង្រៀនដល់ប្រជាកសិករនូវទ្រឹស្តី ម៉ាក្ស-លេនីន និង ហូជីមិញ ដើម្បីឲ្យពលរដ្ឋគ្រប់រូប រួមទាំងជនអវិជ្ជា យល់ថាជនកុម្មុយនិស្តជាមនុស្សប្រភេទណា ។ សាន់ដ្រា ថាយល័រ បានទាញហេតុផលថា សមាគមរំដោះស្ត្រីបានអនុញ្ញាតឲ្យស្ត្រីមួយចំនួនចូលរួមនៅក្នុងចលនាបដិវត្តន៍នៅពេលដែលបុរសចាកចេញទៅសមរភូមិ ។

ស្ត្រីនៅភាគខាងត្បូងក៏មានការងារជាច្រើនមុខព្រួញដែរ ដែលរួមទាំងការរួមចំណែកនៅក្នុងចលនា បិញវ៉ាន់ ផង ។ មុខព្រួញផ្សេងទៀតគឺការចូលរួមនៅក្នុងចលនាតស៊ូអាវុធតាមមធ្យោបាយមួយចំនួនដូចជា ស៊ើបការណ៍សម្ងាត់ ព្យាបាលទាហានរបួស ផ្តល់ដល់ពលទាហាននូវម្ហូបអាហារនិងសម្លៀកបំពាក់ បង្អាក់ដំណើរការសត្រូវតាមរយៈការធ្វើបាតុកម្មធ្វើឲ្យប៉ះពាល់ដល់ការធ្វើដំណើររបស់ពួកទាហាន និងបញ្ចុះបញ្ចូលមន្ត្រីរបស់រដ្ឋាភិបាល ។

ម៉ារីអាន់ តេត្រូល មានជំនឿថា ដូចនៅក្នុងប្រទេសចិន

ដែរ នៅក្នុងប្រទេសវៀតណាម បិតាធិបតេយ្យមានជ័យជម្នះលើទ្រឹស្តីបដិវត្តន៍បន្ទាប់ពីជនកុម្មុយនិស្តទទួលបានជ័យជម្នះ ។ មេដឹកនាំធំៗរបស់វៀតណាមមិនមានការចាប់អារម្មណ៍ក្នុងការបន្តធ្វើចលនារំដោះស្ត្រីដែលអាចធ្វើឲ្យប៉ះពាល់ដល់តំណែងរបស់ខ្លួនឡើយ ។ មេដឹកនាំទាំងនោះបានបណ្តោយឲ្យបិតាធិបតេយ្យវិលត្រឡប់មកវិញ ដើម្បីធានាឲ្យបាននូវការគាំទ្រពីកសិករ ប៉ុន្តែ គេត្រូវ បានកត់សម្គាល់អំពីការកើនឡើងនៃចំនួនរបស់ស្ត្រីនៅក្នុងទីផ្សារការងារនិងការអប់រំ ។

ជាថ្មីម្តងទៀត បរាជ័យនេះអាចត្រូវបានកត់ត្រាទុកដោយមេដឹកនាំខ្មែរក្រហមនៅក្នុងពេលដែលមេដឹកនាំខ្មែរក្រហមទៅទស្សនាទីក្រុងហាណូយ ហើយមេដឹកនាំទាំងនេះប្រហែលជាបានបដិសេធដោយក្រអឺតក្រទមនូវដំបូន្មានរបស់វៀតណាមទាក់ទិននៅនឹងគោលនយោបាយអំពីស្ត្រីនិងគ្រួសារ ។ ក្រៅអំពីការប៉ុន់ស្មាននេះ សមាគមរំដោះស្ត្រីដែលមានការដឹកនាំយ៉ាងត្រឹមត្រូវនិងធ្វើសកម្មភាពនិងឃោសនាជ្រើសរើសយ៉ាងមានប្រសិទ្ធភាព មានលក្ខណៈផ្ទុយទៅនឹងគោលនយោបាយចំពោះស្ត្រីរបស់ជនបដិវត្តន៍កម្ពុជា ។ បើប្រៀបធៀបទៅនឹងស្ត្រីវៀតណាម ស្ត្រីខ្មែរបានទទួលនូវហេតុផលមនោគមវិជ្ជា សេដ្ឋកិច្ចឬសង្គមតិចតួចណាស់ក្នុងការគាំទ្រខ្មែរក្រហម នៅពេលដែលការបញ្ចូលមនោគមវិជ្ជាម៉ាក្សលេនីនមិនមានភាពច្បាស់លាស់ ។

ដូចគ្នាដែរ គោលនយោបាយចំពោះស្ត្រីនៃ"សាធារណរដ្ឋប្រជាមានិតកូរ៉េ"ត្រូវបានដឹងឮតិចតួចណាស់ ។ ទំនាក់ទំនងរវាងប្រទេសនេះនិងកម្ពុជាប្រជាធិបតេយ្យក៏មិនសូវដឹងច្បាស់ដែរ បើទោះជាប្រទេសទាំងពីរនេះជាសម្ព័ន្ធមិត្តនឹងគ្នាក៏ដោយ ។ ប៉ុលពតបានទៅធ្វើទស្សនកិច្ចនៅប្រទេសកូរ៉េខាងជើងនៅឆ្នាំ១៩៧៧ ហើយកូរ៉េខាងជើងត្រូវបានដឹងថា ធ្លាប់បានផ្តល់ជំនួយឲ្យប្រទេសកម្ពុជា ។ ភាពស្រដៀងគ្នារវាងរបបគ្រប់គ្រងទាំងពីរ ពិសេសត្រង់ចំណុចរក្សាការណ៍សម្ងាត់និងទ្រឹស្តីខ្លួនទីពឹងខ្លួន បញ្ជាក់អំពីតម្រូវការនៃការបន្តការសិក្សាអំពីទំនាក់ទំនងរបស់ប្រទេសទាំងពីរ ។

មានកង្វះខាតពត៌មានជាក់ស្តែងខ្លះៗអំពីកងទាហានស្ត្រីនៅក្នុងការតស៊ូដើម្បីឯករាជ្យភាពប្រឆាំងនឹងការគ្រប់គ្រងរបស់ជប៉ុននៅក្នុងអំឡុងពេលមុននិងក្នុងសង្គ្រាមលោកលើកទីពីរ ទោះបីជា គីម អ៊ីលស៊ុង ដែលជាប្រធានាធិបតីបិតាជាតិ និងជា"មេដឹកនាំដ៏អស្ចារ្យ"មួយរូបរបស់កូរ៉េ លើកតម្កើងការចូលរួមរបស់ស្ត្រីក្នុងកងទ័ពក៏ដោយ ។ មេដឹកនាំរូបនេះបានថ្លែងថា ស្ត្រីបានប្រយុទ្ធកាន់ដៃគ្នានៅក្នុងសមរភូមិជាមួយបុរស ។ ភរិយារបស់លោកឈ្មោះ គីម ជុងស៊ុក ត្រូវបានគោរពលើកតម្កើងជាវីរនារីបដិវត្តន៍សម្រាប់ការប៉ិនប្រសប់ធ្វើសង្គ្រាមរបស់អ្នកស្រី ។ នៅក្នុងអំឡុងឆ្នាំ១៩១០ដល់១៩៤៥ មានភស្តុតាងបញ្ជាក់ពីអង្គភាពស្ត្រីស្នេហាជាតិនៅប្រទេសកូរ៉េ ដែលគាំទ្រនិងបណ្តុះឲ្យមានការស្រលាញ់ស្នេហាជាតិនិងការស្អប់ខ្ពើមពួកជប៉ុន ។ អង្គភាពស្ត្រីកូរ៉េនៅក្នុងដំណាក់កាលនេះបានលើកតម្កើងដល់ការរំដោះស្ត្រី ។

សង្គមកូរ៉េបែបប្រពៃណីបានមានជំនឿទៅលើលទ្ធិខុងជឺនិយមបែបថ្មីដែលបន្ទាបស្ត្រីឲ្យទាបជាងបុរស ។ ដូចនៅក្នុងប្រទេសវៀតណាមនិងចិន នៅក្នុងសម័យនោះជនកុម្មុយនិស្តត្រូវតែដោះស្រាយជាមួយបញ្ហាបិតាធិបតេយ្យនិយមដែលចាក់ឫសយ៉ាងរឹងមាំនៅក្នុងសង្គម ហើយជនកុម្មុយនិស្តកូរ៉េក៏បានអនុម័តច្បាប់នេះដែរនៅក្នុងឆ្នាំ១៩៤៦ ដោយផ្តល់ឲ្យស្ត្រីនូវសិទ្ធិកាន់កាប់ ដីធ្លីនិងរៀបអាពាហ៍ពិពាហ៍ក្នុងកម្រិតជាក់លាក់មួយ ហើយបានឲ្យតម្លៃទៅលើសមភាពរវាងបុរសនិងស្ត្រី ។ ទោះជាយ៉ាងណាក៏ដោយ គោលនយោបាយនេះត្រូវបានដាក់ចេញពី "ខាងលើ" ដោយសារស្ត្រីមិនមានយោបល់ច្រើនចំពោះបញ្ហានេះ ។ អាស្រ័យលើអ្នកសង្កេតការណ៍មួយរូបគោលនយោបាយស្ត្រីរបស់កូរ៉េខាងជើងមានគោលដៅបីយ៉ាងគឺ រំដោះស្ត្រីឲ្យរួចចាកផុតពីសង្គមគ្រួសារបិតាធិបតេយ្យ រំដោះតាមរយៈពលកម្មសង្គម និងបង្កើតស្ត្រីសង្គមនិយមមួយរូបដ៏ឆ្នើម ។

នៅពេលដែលសហករណ៍ភាវូបនីយកម្មត្រូវបានធ្វើឲ្យសម្រេចនៅក្នុងអំឡុងប៉ុន្មានឆ្នាំក្រោយសង្គ្រាមវៀតណាម គ្រួសារដែលមានតែប្តី ប្រពន្ធ និងកូន នៅក្នុងផ្ទះជាមួយគ្នានៅតែជាការពេញចិត្តរបស់ប្រជាជនកូរ៉េខាងជើង ។ ប្រធានាធិបតីគីម ជុងអ៊ីល បានថ្លែងថា គ្រួសារប្រភេទនេះ គឺជា "កោសិកាសង្គម"ហើយត្រូវបានការពារដោយរដ្ឋ ។ ចំណុចនេះត្រូវបាន

បញ្ជាក់ជាថ្មីម្តងទៀតដោយគណៈប្រតិភូស្ត្រី ជាន់ខ្ពស់មួយក្រុម នៅក្នុងដំណើរទស្សនកិច្ចទៅកាន់ប្រទេសកូរ៉េខាងជើង ។ គណប្រតិភូនេះក៏បានចាត់ទុកថា ការងារចម្បងមួយរបស់ស្ត្រីជាកាតព្វកិច្ច "ពីធម្មជាតិ"និង"ជាទំនៀមទម្លាប់ប្រពៃណី" ។ ដូច្នេះ គំរូរបស់អ៊ែងដែល ត្រូវបានបដិសេធដោយរដ្ឋកុម្មុយនិស្តនៅអាស៊ីជាថ្មីម្តងទៀតហើយ ។ តាមការពិត អាស្រ័យទៅលើមនោគមវិជ្ជា "ជូឆេ" (មនោគមវិជ្ជាមូលដ្ឋានរបស់កូរ៉េខាងជើងជឿជាក់ទៅលើទ្រឹស្តីខ្លួនទីពឹងខ្លួន) តម្លៃឬគំនិតបរទេសត្រូវតែទទួលយកហើយកែប្រែសម្រាប់ប្រើប្រាស់នៅក្នុងស្ថានភាពជាក់ស្តែងនៅក្នុងប្រទេសកូរ៉េមិនមែនយកមកអនុវត្តទាំងងងឹតងងល់ទេ ។ កូរ៉េខាងជើងបានបំពេញតាមទ្រឹស្តីនោះទាក់ទងទៅនឹងគោលនយោបាយចំពោះស្ត្រីនិងគ្រួសារ ។

ប្រធានាធិបតី គីម ជុងអ៊ីល បានសន្យាថានឹងផ្តល់សេវាកម្មដ៏ទូលំទូលាយដើម្បីរំដោះស្ត្រីចេញពីការងារផ្ទះ ហើយអនុញ្ញាតឲ្យស្ត្រីចូលរួមយ៉ាងពេញទំហឹងនៅក្នុងការងារផលិតកម្ម ប៉ុន្តែនៅទីបំផុត គោលនយោបាយ"ការងារទ្វេ"បានលេចឡើង ។ រដ្ឋាភិបាលបានកសាងមន្ទីរកុមាររាប់ពាន់ដោយមូលហេតុថា ប្រធានាធិបតី គីម ជុងអ៊ីល បានចេញក្រឹត្យថា ស្ត្រីមានតួនាទីសំខាន់នៅក្នុងការងារអប់រំកូនចៅ ។ នៅក្នុងឆ្នាំ១៩៦១ គីម ជុងអ៊ីល បានពោលថា "សម្រាប់ពេលបច្ចុប្បន្ន មាតាត្រូវបានតម្រូវឲ្យមានតួនាទីសំខាន់ក្នុងការចិញ្ចឹមបីបាច់កូនចៅឲ្យក្លាយទៅជាជនកុម្មុយនិស្តដ៏វិសេសវិសាលបំផុត ។ មាតាទាំងអស់ត្រូវយល់ឲ្យច្បាស់អំពីទម្ងន់នៃកាតព្វកិច្ចនេះនិងកិត្តិយសនៃការអប់រំអនាគតមេដឹកនាំសង្គមកុម្មុយនិស្ត" ។ ចំណុចនេះមានលក្ខណៈផ្ទុយទាំងស្រុងទៅនឹងបដិវត្តន៍នៅក្នុងប្រទេសកម្ពុជា ។ អ៊ឹម ចាន់ (កម្មាភិបាលស្ត្រីមួយរូបដែលបានផ្តល់បទសម្ភាសន៍) បាននិយាយថា គាត់ត្រូវបានហាមប្រាមមិនឲ្យទៅជួបឪពុកម្តាយ ពីព្រោះប្រធានកងរបស់គាត់បានប្រាប់គាត់ថា ប្រសិនបើគាត់ត្រឡប់ទៅផ្ទះវិញ គាត់នឹងរៀបចំសកម្មភាពក្បត់ ។ តាមពិតខ្មែរក្រហមបានពង្រត់កុមារចេញពីផ្ទះដើម្បីបញ្ចូលមនោគមវិជ្ជានៅក្នុងអំឡុងពេលមុននិងក្រោយសង្គ្រាមស៊ីវិល (១៩៧០-១៩៧៥) ហើយមិនឲ្យកុមារទាំងនោះមកជួបជុំជាមួយឪពុកម្តាយវិញទេ ។ ប្រាកដណាស់ របបខ្មែរក្រហមដែលពោរពេញទៅដោយភាពមិនទុកចិត្តគ្នានិងអសន្តិសុខ នឹងមិនបណ្តោយឲ្យគ្រួសារបណ្តុះបណ្តាលមនោគមវិជ្ជាដល់កុមារឡើយ ។ ខ្មែរក្រហមបានជឿជាក់តាំងពីដើមទីថាគ្រួសារជាអ្នកប្រកួតប្រជែងជាមួយអង្គការក្នុងការដណ្តើមយកភក្តីភាពពីកសិករ ។

ដូចនៅប្រទេសចិននិងវៀតណាមដែរ នយោបាយរបស់កូរ៉េខាងជើងចំពោះស្ត្រីនិងគ្រួសារ មិនបានដើរតាមមាក៏ម៉ាក្សលេនីននោះទេ ទោះបីជារបបនោះមើលទៅហាក់បីដូចជាបានបង្កើតនូវប្រព័ន្ធសហករណ៍ខ្លះៗដើម្បីជួយសម្រាលបន្ទុកការងារផ្ទះរបស់ស្ត្រីក៏ដោយ ។ សហករណ៍ភាវូបនីយកម្មរបស់បក្សកុម្មុយនិស្តកម្ពុជាគឺមានលក្ខណៈពេញលេញជាង ទោះជាខ្មែរក្រហមប្រហែលជាបានខ្ចីគំនិតខ្លះៗពីកម្មវិធីគ្រួសាររបស់កូរ៉េខាងជើងក៏ដោយ ។ ដោយសារទំនាក់ទំនងរវាងកូរ៉េខាងជើងនិងបក្សកុម្មុយនិស្តកម្ពុជាមិនឋិតថេរ វាមានការពិបាកក្នុងការកំណត់ឲ្យច្បាស់អំពីកម្រិតនៃសហប្រតិបត្តិការឬការស្ញប់ស្ញែងរវាងប្រទេសទាំងពីរ ។ ប៉ុន្តែ ការផ្តោតការយកចិត្តទុកដាក់ខ្ពស់ចំពោះនយោបាយខ្លួនទីពឹងខ្លួននិងឯករាជ្យម្ចាស់ការរបស់ប្រទេសទាំងពីរបង្ហាញថា គំនិតរបស់កូរ៉េខាងជើងប្រហែលជាមានឥទ្ធិពលទៅលើខ្មែរក្រហម ហើយអាចជំរុញឲ្យមេដឹកនាំខ្មែរក្រហមដែលមានជំនឿយ៉ាងមុតមាំអំពីភាពត្រឹមត្រូវឥតខ្ចោះនិងជោគជ័យរបស់បដិវត្តន៍និងលទ្ធភាពរបស់បដិវត្តន៍ក្នុងការធ្វើអ្វីៗដោយមិនចាំបាច់ពឹងពាក់ប្រទេសដទៃ ។

ការស្ទាបស្ទង់នេះចង្អុលបង្ហាញថា របបកុម្មុយនិស្តនិយមរបស់ប្រទេសចិន វៀតណាម និងកូរ៉េខាងជើង បានបរាជ័យក្នុងការរំដោះស្ត្រីទៅតាមគម្រោងរបស់ អ៊ែងដែល ដែលសរសេរនៅក្នុងសៀវភៅ "ប្រភពនៃគ្រួសារ ទ្រព្យសម្បត្តិឯកជន និង រដ្ឋ" របស់គាត់ ។ ផ្ទុយទៅវិញ នៅក្នុងអំឡុងពេលនៃការតស៊ូបដិវត្តន៍ ជនកុម្មុយនិស្តបានប្រើប្រាស់ទ្រឹស្តីរបស់អ៊ែងដែល ដើម្បីទាក់ទាញស្ត្រីឲ្យគាំទ្រខ្លួន ហើយបានបោះបង់ចោលនូវគំនិតនេះវិញនៅពេលដែលជ័យជម្នះត្រូវបានទទួល ហើយអំណាចត្រូវបានពង្រឹង ។ គំនិតរបស់ ថឺលី ដែលថានៅប្រទេសវៀតណាម ស្ត្រីមានតួនាទីថ្មីដោយសារសង្គ្រាមគឺ

ត្រឹមត្រូវនៅក្នុងប្រទេសផ្សេងទៀតរួមទាំងប្រទេសកម្ពុជាផង ។ នៅកម្ពុជា តម្រូវការចាំបាច់នៅក្នុងសង្គ្រាមស៊ីវិលទាមទារឲ្យស្ត្រីចូលរួមដោយសកម្មនិងសស្រាក់សស្រាំនៅក្នុងចលនាបដិវត្តន៍ ហើយស្ត្រីត្រូវធ្វើការងារសំខាន់ៗ (យ៉ាងហោចណាស់នៅប្រទេសចិននិងវៀតណាម) ដូចជាធ្វើជាទាហាន អ្នកជញ្ជូនគ្រាប់ គិលានុបដ្ឋាយិកា កងការពារ អ្នកឃោសនានយោបាយ កសិករ និងការងារផ្សេងទៀត ។ គេគ្រូល បានកត់សម្គាល់ថា ទោះជាយ៉ាងណា«អ្នកបដិវត្តន៍យកចិត្តទុកដាក់ខ្លាំងទៅលើចំណុចថាតើនរណាជាអ្នកដឹកនាំប្រទេសបន្ទាប់ពីការប្រយុទ្ធគ្នាត្រូវបានបញ្ចប់» ដោយសារថា វាតែងតែមានការបន្តភ្ជាប់រវាងសង្គមនិងវប្បធម៌មុននិងក្រោយបដិវត្តន៍ ។ នៅក្នុងសម័យសន្តិភាព របបទាំងឡាយដែលបានលើកឡើងនៅក្នុងនិក្ខេបបទនេះបានចាប់អារម្មណ៍លើការរស់រានមានជីវិតរបស់រដ្ឋាភិបាលខ្លួនជាជាងការអនុវត្តកំណែទម្រង់សម្រាប់ក្រុមមនុស្សដែលចាត់ទុកថាមិនសូវសំខាន់ដូចជាស្ត្រី ។ ជាលទ្ធផល ប្រទេសទាំងនេះមិនមានឆន្ទៈគ្រប់គ្រាន់ដើម្បីអនុវត្តការវាយប្រហារឲ្យពេញទំហឹង និងដោយប្រថុយប្រថានទល់នឹងបិតាធិបតេយ្យនិយមដែលបានចាក់ឫសយ៉ាងរឹងមាំនៅក្នុងសង្គមផ្អែកទៅលើគំនិតរបស់ទស្សនៈវិទូខុងជឺទេ ដំណោះស្រាយគឺបិតាធិបតេយ្យត្រូវបានកែប្រែបន្តិច ដើម្បីអនុញ្ញាតឲ្យស្ត្រីចូលរួមនៅក្នុងសកម្មភាពផលិតកម្ម ហើយជំរុញឲ្យស្ត្រីបំពេញកាតព្វកិច្ចនៅក្នុងផ្ទះថែមទៀត ។ «ការងារទ្វេ»ត្រូវបានលើកតម្កើងក្នុងពេលដែលកំណែទម្រង់ត្រូវបានរារាំង ។

នៅក្នុងប្រទេសកម្ពុជា ទាំងក្នុងដំណាក់កាលមុននិងក្រោយសង្គ្រាមស៊ីវិល ខ្មែរក្រហមបានអនុវត្តសហករណ៍ភាវូបនីយកម្ម ដោយបានដាក់បុរស ស្ត្រី និង កុមារ ឲ្យធ្វើការនៅក្នុងកសិដ្ឋាន និងរោងចក្រ ដែលធ្វើឲ្យមានការប៉ះពាល់ដល់ជីវិតគ្រួសារ និងបង្កើននូវប្រជាប្រិយភាពរបស់របបដឹកនាំ ។ តាមរយៈទង្វើបែបនេះ បក្សកុម្មុយនិស្តកម្ពុជាបានអះអាងថាខ្លួនបានរំដោះស្ត្រីហើយ ។ តាមការពិត បក្សកុម្មុយនិស្តកម្ពុជាហាក់ដូចជាបានអនុវត្តនូវគោលគំនិតរបស់ អ៊ែងដែល នៅក្នុងទម្រង់ដ៏បរិសុទ្ធរបស់វាគឺថា ស្ត្រីផលិត ដូច្នេះស្ត្រីត្រូវបានរំដោះរួចហើយ ។ នៅពេលដែលបានកាន់កាប់អំណាច ជនកុម្មុយនិស្តខ្មែរមិនបានជួបប្រទះនឹងការបះបោរប្រឆាំងទល់នឹងគោលនយោបាយគ្រួសារដូចនៅប្រទេសផ្សេងទេ ។ ខ្មែរក្រហមបានលុបបំបាត់គ្រួសារចោលទាំងស្រុង ។ ខ្មែរក្រហមបានធ្វើឲ្យសម្រេចនូវគម្រោងបង្កើតសហករណ៍លឿនហើយពេញលេញជាងនៅប្រទេសចិន វៀតណាម ឬកូរ៉េខាងជើងទៅទៀត ។

ខ្មែរក្រហមមានឱកាសរៀនសូត្រតាមបទពិសោធន៍បដិវត្តន៍របស់ចិន វៀតណាម និងកូរ៉េខាងជើង ដោយរួមទាំងការប្រើប្រាស់ស្ត្រីរបស់ប្រទេសនីមួយៗ ហើយនិងគោលនយោបាយរបស់ប្រទេសទាំងនេះចំពោះគ្រួសារផង ។ ផ្ទុយទៅវិញ ខ្មែរក្រហមបានជ្រើសរើសការមិនរៀនសូត្រតាម ។ ប៉ុល ពត បានថ្លែងថា «យើងមិនពឹងពាក់បរទេសទេ» ។ «ឯករាជ្យម្ចាស់ការខ្លួនទីពឹងខ្លួន» ជាមូលដ្ឋានគ្រឹះនៃគោលនយោបាយរបស់ខ្មែរក្រហមមានរៀបរាប់នៅក្នុងផែនការ៤ឆ្នាំរបស់បក្សដែលសរសេរថា«យើងមិនដោះស្រាយបញ្ហាដូចប្រទេសផ្សេងទេ ។ យើងមានលក្ខណៈខុសពីគេ ។ គោលនយោបាយរបស់យើងខុសពីគេ ។ ទស្សនៈគោលជំហររបស់យើងខុសពីគេ ។ គោលជំហររបស់យើងខុសពីគេ ។ ដូច្នេះការដោះស្រាយបញ្ហាក៏ត្រូវប្រើប្រាស់វិធីសាស្ត្រខុសពីគេដែរ» ។ ខ្មែរក្រហមយល់ថាបដិវត្តន៍របស់ខ្លួនជាបដិវត្តន៍ដ៏ឧត្តុង្គឧត្តម និងមិនធ្លាប់មាននៅក្នុងប្រទេសផ្សេងនៅលើពិភពលោក៖«ចលនាបដិវត្តន៍របស់យើងគឺជាបដិវត្តន៍ថ្មីហើយសំខាន់មួយ នៅក្នុងពិភពលោកទាំងមូល ពីព្រោះយើងមិនធ្វើដូចប្រទេសផ្សេងទេ...។ ប្រជាជនកំពុងតែតាមដានមើលយើង» ។ ខ្មែរក្រហមបានប្តេជ្ញានឹងអភិវឌ្ឍប្រទេសកម្ពុជាដោយមិនចាំបាច់ពឹងពាក់ប្រទេសដទៃ «ពីព្រោះយើងបានក្លាយជាទាសករអស់រយៈពេលជាយូរមកហើយ» ។ តាមការពិត ឯករាជ្យភាពត្រូវបានមើលឃើញថា មានសារសំខាន់ចំពោះជ័យជម្នះរបស់បដិវត្តន៍ ។ ចំពោះប្រព័ន្ធបញ្ចូលទឹក កសិកម្ម និងឧស្សាហកម្ម បក្សកុម្មុយនិស្តកម្ពុជាបានថ្លែងថា «មានការរីកចម្រើនខ្ពស់ដោយសារយើងមានឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួន ទៅខ្ពស់បំផុត ។ នៅក្នុងមហាចលនាតស៊ូដែលជាជំហានទីមួយយើងមើលឃើញនូវអនាគតដ៏

គ្រប់គ្រងមួយនៃការកសាងសង្គមនិយមនៅក្នុងប្រទេសកម្ពុជា» ។ ខ្មែរក្រហមបានដាក់ខ្លួនឲ្យឆ្ងាយពីបដិវត្តន៍កុម្មុយនិស្តរបស់ប្រទេសដទៃ ។ ផែនការបួនឆ្នាំបានរៀបរាប់ថា ប្រទេសចិន វៀតណាម និងកូរ៉េខាងជើង បានចំណាយអស់រយៈពេលជាច្រើនឆ្នាំដើម្បីកសាងសង្គមនិយមឲ្យបានពេញលេញ ។ «សម្រាប់ប្រទេសយើង យើងមានលក្ខណៈប្លែកពីប្រទេសទាំងបីនេះ ។ យើងមានការអភិវឌ្ឍន៍លឿនជាងប្រទេសផ្សេង ។ ប្រសិនមើលទៅលក្ខណៈសហករណ៍របស់យើង យើងបានដើរទៅមុខបួនដប់ឆ្នាំមុនប្រទេសដទៃ...គ្មានអ្វីត្រូវប្រឡំទេ» ។ ផែនការបួនឆ្នាំបានថែងថា ប្រទេសកម្ពុជាបានរីកចម្រើនខ្ពស់ពីព្រោះ«យើងបានលោតពីបដិវត្តន៍ប្រជាធិបតេយ្យមកសង្គមនិយមតែម្តង» ។

ចំណុចសំខាន់មួយដែលបែងចែកបដិវត្តន៍កម្ពុជាឲ្យដាច់ពីប្រទេសកុម្មុយនិស្តផ្សេងនៅអាស៊ី គឺជាការរីកចម្រើនយ៉ាងឆាប់រហ័សមិនគួរឲ្យជឿ ។ ខ្មែរក្រហមបានប្រយុទ្ធអស់រយៈពេលតែប្រាំឆ្នាំប៉ុណ្ណោះជាមួយពួក «សត្រូវចក្រពត្តិ» ។ ជនកុម្មុយនិស្តចិន វៀតណាម និងកូរ៉េខាងជើង សុទ្ធតែបានធ្វើសង្គ្រាមអស់រយៈពេលដ៏យូរមុនពេលសម្រេចបានជ័យជម្នះពេញលេញ ហើយមានពេលវេលាច្រើនជាងខ្មែរក្រហមច្រើនណាស់ដើម្បីសម្រួចគោលនយោបាយរបស់ខ្លួនប្រើប្រាស់ធនធានកំណត់របស់ខ្លួន ហើយស្វែងរកមធ្យោបាយល្អបំផុតក្នុងការរក្សាអំណាច ។ ការឡើងកាន់អំណាចដ៏លឿនរបស់ខ្មែរក្រហមនៅក្នុងប្រទេសកម្ពុជាមានលក្ខណៈដូចគ្នាទៅនឹងល្បឿនដែលខ្មែរក្រហមដំណើរការកំណែទម្រង់ទាំងស្រុងរបស់ខ្លួនដែរ ។ លទ្ធផលគឺចលនារបស់ខ្មែរក្រហមខ្វះភាពបត់បែននិងភាពជឿនលឿនដែលប្រទេសចិន វៀតណាម និងកូរ៉េខាងជើងមាន ។ ខ្មែរក្រហមយល់ឃើញផ្សេង ។ សម្រាប់មេដឹកនាំខ្មែរក្រហម ល្បឿនគឺមានសារសំខាន់សម្រាប់ការកសាងបដិវត្តន៍ៈ «យើងចង់កសាងសង្គមនិយម ផ្លាស់ប្តូរមុខមាត់ប្រទេសរបស់យើងនិងធ្វើឲ្យប្រជាជនយើងទទួលបាននូវភាពរុងរឿងឲ្យបានឆាប់រហ័ស» ។ តាមការពិតជាក់ស្តែងអាស្រ័យទៅលើផែនការ៤ឆ្នាំ នៅក្នុងឆ្នាំ១៩៧៦ ប្រទេសកម្ពុជាបានក្លាយទៅជាប្រទេសសង្គមនិយមរួចទៅហើយ ។

ទស្សនៈប្រៀបធៀបដែលបានលើកឡើងនៅក្នុងជំពូកនេះត្រូវចាំបាច់កំណត់ដោយភាពខុសគ្នាជាក់ស្តែងនៅក្នុងឋានៈរបស់ស្ត្រីពីបុរាណមកនៅក្នុងប្រទេសកម្ពុជា ចិន វៀតណាម និងកូរ៉េខាងជើង ។ ស្ត្រីកម្ពុជាទទួលបានសិទ្ធិសេរីភាពនិងអំណាចច្រើនជាងស្ត្រីនៅប្រទេសទាំងបីផ្សេងទៀតនៅអាស៊ី ។ ប្រជាជនកម្ពុជារស់នៅតាមជនបទភាគច្រើនគឺជាអ្នកកាន់ព្រះពុទ្ធសាសនា ហើយសង្គមកម្ពុជាពុំសូវមានគំនិតបិតាធិបតេយ្យរឹងមាំដូចនៅប្រទេសផ្សេងទេ ។ ស្ត្រីមានសិទ្ធិកាន់កាប់ដីធ្លី ។

ទោះជាយ៉ាងណាក៏ដោយ ការប្រៀបធៀបនៅតែមានសារសំខាន់ពីព្រោះវាច្បាស់ណាស់ថា ខ្មែរក្រហមបានកត់ត្រាទុកនូវភាពខុសគ្នាផ្នែកវប្បធម៌និងរចនាសម្ព័ន្ធដឹកនាំនៅក្នុងសង្គមផ្សេងទៀត ហើយកែប្រែគោលនយោបាយរបស់ខ្លួនទៅតាមនោះដែរ ។ ប៉ុន្តែខ្មែរក្រហមមិនបានក្តាប់ឲ្យជាប់នូវភាពខុសគ្នាស៊ីជម្រៅទេ ។ ឧទាហរណ៍ ការវិភាគទៅលើលក្ខខណ្ឌសេដ្ឋកិច្ចជនបទនៅក្នុងប្រទេសកម្ពុជាត្រូវបានចម្លងចេញពីទ្រឹស្តីរបស់ម៉ៅសេទុងនិងជនកុម្មុយនិស្តវៀតណាម ប៉ុន្តែការវិភាគបែបនេះមិនស័ក្តិសមទាល់តែសោះទៅនឹងស្ថានភាពរបស់ប្រទេសកម្ពុជា ។ ដូចបក្សកុម្មុយនិស្តចិននិងវៀតណាមខាងជើង ជនកុម្មុយនិស្តកម្ពុជាបានប្រកាសសង្គ្រាមជាមួយពួកម្ចាស់ដីដោយចោទថាអ្នកទាំងអស់នេះជាមូលហេតុនៃកំហឹងរបស់ប្រជាកសិករកម្ពុជា ទោះបីជាក់ស្តែងប្រជាកសិករភាគច្រើនមានដីធ្លីដោយខ្លួនឯងសម្រាប់ធ្វើស្រែចម្ការ ហើយគឺបំណុលទេដែលជាកត្តាបង្កជាបន្ទុកសេដ្ឋកិច្ចដ៏ធ្ងន់ធ្ងរដល់កសិករក៏ដោយ ។ ស្រដៀងគ្នានេះដែរ ខ្មែរក្រហមអាចថតចម្លងនូវការគាបសង្កត់របស់បិតាធិបតេយ្យនៅក្នុងប្រទេសចិន វៀតណាម និងកូរ៉េខាងជើងមកដាក់លើស្ត្រីកម្ពុជា ហើយបានប្រើប្រាស់នូវដំណោះស្រាយដែល អ៊ែងដែល បានលើកឡើងមកព្យាបាលជំងឺសង្គមដែលប្រជាកសិករខ្មែរពុំបានទទួលរង ។ ***(នៅមានត)***

**ហ្សាល់ ភាគារីយ៉ា**



ជនរងគ្រោះនៅមន្ទីរស-២១

# សន្តិភាព និង ច្បាប់សង្គ្រាមៈ

## តួនាទីនៃនីតិមនុស្សធម៌អន្តរជាតិនៅក្នុងបរិយាកាសក្រោយពេលមានជម្លោះ

នីតិមនុស្សធម៌បានបង្កើតតាំងពីយូរណាស់មកហើយនូវការសិក្សាស្រាវជ្រាវស៊ីជម្រៅទៅលើបញ្ហាច្បាប់សារវិជ្ជមានជាពិសេសទាក់ទងនឹងស្ថានភាពនៅពេលប្រយុទ្ធលើសមរភូមិនិងការកាន់កាប់ដោយយោធា ។ មានការផ្តោតយកចិត្តទុកដាក់តិចតួចណាស់ (ហើយទើបតែមាននៅពេលថ្មីនេះទៀត) ទៅលើតួនាទីរបស់នីតិមនុស្សធម៌ក្នុងសម័យក្រោយពេលមានជម្លោះ ។ អ្វីដែលមានការចាប់អារម្មណ៍នោះគឺការផ្តោតទៅលើករណីយុត្តិសាស្ត្រពីទីក្រុងនូរិមប៊ឺក ទីក្រុងតូក្យូ ដែលសង្កត់ធ្ងន់ទៅលើ "យុត្តិធម៌ជាការទទួលខុសត្រូវ" ជាមួយនឹងព្រឹត្តិការណ៍មួយចំនួនដូចជា ករណីជំនុំជម្រះក្តីទៅលើជនជាប់ចោទ អេច្ចម៉ាន់ ដែលដើរតួជាកាតាលីករជម្រុញឲ្យមានការពិភាក្សាកាន់តែទូលំទូលាយថែមទៀត ។

មូលហេតុគឺថាៈ មានការពិភាក្សាតិចតួចអំពីតួនាទីរបស់នីតិមនុស្សធម៌នៅក្នុងស្ថានការណ៍ក្រោយជម្លោះ ពីព្រោះថាវាហាក់ដូចជាគ្មានរឿងច្រើនត្រូវពិភាក្សា (បើទោះជាប្រការនេះទទួចសួរសំណួរទាក់ទងនឹងបញ្ហាថាតើច្បាប់នោះប្រហែលជាមានតួនាទីកាន់តែធំប្រសិនបើមានការពិភាក្សាដេញដោលកាន់តែទូលំទូលាយទៅលើការចូលរួមវិភាគទានដែលអាចធ្វើទៅបានរបស់ច្បាប់នេះបានលេចឡើងតាំងពីមុនក៏ដោយ) ។ នៅពេលដែលការជំនុំជម្រះក្តីនៅតូក្យូនិងនូរិមប៊ឺក និងច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ១០ បានបញ្ចប់ទៅ ហេដ្ឋារចនាសម្ព័ន្ធដែលមានសុពលភាពជាអន្តរជាតិនេះក៏បានបញ្ចប់ដែរ ។ អវត្តមាននៃអង្គតុលាការពិសេសដែលមានលក្ខណៈប្រហាក់ប្រហែលគ្នានេះ អសុឆន្ទៈរបស់សហគមន៍អន្តរជាតិក្នុងការបង្កើតឡើងនូវអង្គតុលាការអចិន្ត្រៃយ៍មួយដែលមានសមត្ថកិច្ចជំនុំជម្រះបទល្មើសព្រហ្មទណ្ឌនៅលើផ្នែកនេះ ព្រមជាមួយនឹងការយកនីតិមនុស្សធម៌អន្តរជាតិមកប្រើតិចតួចពីសំណាក់តុលាការព្រហ្មទណ្ឌជាតិនៅក្នុងស្ថានការណ៍ក្រោយពេលមានជម្លោះ ទោះជាមានយុត្តាធិការសកលទៅលើការរំលោភធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវទាំងបួនចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ ស្តីអំពីការគាំពារជនរងគ្រោះដោយសង្គ្រាម ទាំងអស់នេះសុទ្ធតែរួមចំណែកធ្វើឲ្យមានស្ថានការណ៍មួយដែលក្នុងនោះ នីតិមនុស្សធម៌អន្តរជាតិហាក់ដូចជាកំពុងតែដើរតួនាទីយ៉ាងតិចតួចបំផុតនៅក្នុងស្ថានការណ៍ក្រោយពេលសង្គ្រាម ដោយបង្កើតឡើងតែផលប្រយោជន៍ខាងការស្រាវជ្រាវមិនសូវទាក់ទងប៉ុណ្ណោះ ។ ការលាយបញ្ហានានាបញ្ចូលគ្នាគឺជាទិន្នាការរបស់អ្នកច្បាប់មួយចំនួនចំពោះការបែងចែកជាផ្នែកៗ ដែលជាលទ្ធផលបណ្តាលឲ្យយល់ឃើញថានីតិមនុស្សធម៌អន្តរជាតិរវាកចេញពីចំណុចសំខាន់នៃការពិភាក្សាតាមផ្លូវច្បាប់ ។

រូបភាពសព្វថ្ងៃនេះបានផ្លាស់ប្តូរស្ទើរតែមិនអាចចំណាំបានទៅហើយ ។ មិនមែនតែតួនាទីរបស់នីតិមនុស្សធម៌អន្តរជាតិនៅក្នុងស្ថានភាពក្រោយជម្លោះក្លាយជាចំណុចមួយស្ថិតក្រោមការផ្តោតសំខាន់ចេះតែកើនឡើងខាងការស្រាវជ្រាវប៉ុណ្ណោះទេ ប៉ុន្តែក៏នៅមានការបន្ថយភាពឯកោនៅក្នុងវិស័យច្បាប់នេះ ដែលជាលទ្ធផលឃើញថា ទំនាក់ទំនងរវាងនីតិមនុស្សធម៌និងផ្នែកផ្សេងៗទៀតនៃនីតិសាធារណៈអន្តរជាតិកាន់តែមានលក្ខណៈជាក់ស្តែងហើយ ។

មានកត្តាបីយ៉ាងដែលរួមចំណែកយ៉ាងទូលំទូលាយដល់ការវិវឌ្ឍន៍បែបនេះ ។ ទីមួយគឺការប្រសព្វគ្នារវាងនីតិមនុស្សធម៌អន្តរជាតិនិងនីតិសិទ្ធិមនុស្សអន្តរជាតិ ជាក់ស្តែងបំផុតគឺការអនុម័តនូវបទបញ្ញត្តិនានាចែងអំពីការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ដែលចែងនៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយឆ្នាំ១៩៦៦ នៅក្នុងពិធីសារពីរនៅឆ្នាំ១៩៧៧ ដែលបន្ថែមទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ។ ការ

ប្រសព្វគ្នានេះក៏បានបង្ហាញជាក់ស្តែងនៅក្នុងការគាក់តែងក្រមចរិយានិងសេចក្តីប្រកាសនានាដែលមានបំណងធ្វើជាស្ពានភ្ជាប់រវាងនីតិសិទ្ធិមនុស្សជាមួយនឹងនីតិមនុស្សធម៌អន្តរជាតិ ទាក់ទងនឹងស្ថានភាពពេលមានវិបត្តិដែលមានលក្ខណៈផ្សេងៗគ្នា ។

កត្តាទីពីរទាក់ទងនឹងវិវឌ្ឍន៍ពីរដែលមានទំនាក់ទំនងគ្នាទៅវិញទៅមក ។ វិវឌ្ឍន៍ទីមួយគឺការលេចឡើងក្នុងប៉ុន្មានឆ្នាំថ្មីៗនេះនូវទំនោរទៅរកដំណើរការសន្តិភាពដែលមានការរៀបចំត្រឹមត្រូវពាក់ព័ន្ធនឹងជម្លោះហិង្សាតឹងតែងឬមិនអាចដោះស្រាយចេញ (ឧទាហរណ៍ដូចជា អែលសាល់វ៉ាឌ័រ អតីតយូហ្គោស្លាវី ប៉ាឡេស្ទីនអ៊ីស្រាអែល អាហ្វ្រិកខាងត្បូង និង អៀរឡង់ខាងជើង) ។ ដោយសារមានតុល្យភាពកម្លាំង ឬស្ថានភាពដែលភាគីម្ខាងមិនអាចយកជ័យជម្នះលើភាគីម្ខាងទៀត ហើយបង្ខំឲ្យភាគីម្ខាងទៀតទទួលយកអ្វីដែលជាគំនិតរបស់ខ្លួននោះ ដំណើរការចរចាគឺត្រូវប៉ុនប៉ងផ្សះផ្សាបង្រួបបង្រួមដើម្បីបម្រើផលប្រយោជន៍របស់ភាគីទាំងសងខាង ។ ជាញឹកញយ ប្រការនេះតម្រូវឲ្យមានការដោះស្រាយបញ្ហានៃការរំលោភច្បាប់សិទ្ធិមនុស្សនិងច្បាប់មនុស្សធម៌អន្តរជាតិ ។ ទីពីរ វិវឌ្ឍន៍ដែលមានទំនាក់ទំនងគ្នាគឺដំណើរការផ្ទេរការគ្រប់គ្រងអំណាចពីរបបយោធាមកស៊ីវិលវិញជាក់ស្តែងនៅក្នុងទសវត្សរ៍ថ្មីៗនេះ នៅក្នុងទ្វីបអាមេរិកឡាទីន (ដូចជាប្រទេសឈីលីនិងប្រេស៊ីល) ។ វិធីទាំងនេះបង្កើតឲ្យមាន “យុត្តិធម៌សម័យអន្តរកាល” ដែលជាការនិយាយដល់ដំណាក់កាលអន្តរកាលក្រោយរបបគ្រប់គ្រងកុម្មុយនិស្តនៅអឺរ៉ុបខាងកើត ។ ប្រការសំខាន់នៅត្រង់ចំណុចនេះគឺបញ្ហាថាតើរដ្ឋាភិបាលស្នងអំណាចតាមលក្ខណៈប្រជាធិបតេយ្យគួរតែដោះស្រាយចំពោះការរំលោភយ៉ាងធ្ងន់ធ្ងរដែលប្រព្រឹត្តដោយរបបមុនៗយ៉ាងដូចម្តេច ដោយនិយាយយោងជាពិសេសដល់យន្តការស្របច្បាប់សម្រាប់ចាត់ការអំពីបញ្ហានេះ ។ ដូចនេះ គោលរឿងនៃបញ្ហានេះប្រទាក់ក្រឡាគ្នាយ៉ាងមាំជាមួយគោលរឿងទាំងឡាយដែលបានលេចឡើងនៅក្នុងដំណាក់កាលចរចាសន្តិភាពនាពេលថ្មីៗនេះ ។ តាមពិត មិនអាចយកបញ្ហាច្បាប់ច្រើនដែលទាក់ទងនឹងគោលរឿងទាំងឡាយដែលបានលេចឡើងនៅក្នុងដំណាក់កាលចរចាសន្តិភាព ដាក់ឲ្យស្ថិតនៅក្រោមដំបូល “យុត្តិធម៌សម័យអន្តរកាល” ជាទូទៅបានឡើយ ។

កត្តាទីបីដែលទាក់ទងដោយផ្ទាល់ជាមួយនឹងបញ្ហាចរចាគឺការធ្វើឲ្យរស់ឡើងវិញនូវគំរូតុលាការព្រហ្មទណ្ឌអន្តរជាតិដំបូងឡើងតាមរយៈការប្រើប្រាស់ប្រកបដោយភាពច្នៃប្រឌិតនូវជំពូក VII នៃធម្មនុញ្ញអង្គការសហប្រជាជាតិក្នុងការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីរួចហើយដោយយកតាមគំរូនេះជាមួយនឹងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា ហើយចុងក្រោយយកគំរូបង្កើតដោយលក្ខន្តិកៈទីក្រុងរ៉ូម ។ ការបង្កើតនិងដំណើរការតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីនិងប្រទេសរ៉្វាន់ដា បានចូលរួមចំណែកផ្តល់ជាលក្ខណៈទូទៅមួយ មិនត្រឹមតែតាមរយៈឥទ្ធិពលរបស់តុលាការទាំងពីរនេះទៅលើវិវឌ្ឍន៍នៃច្បាប់សារវិជ្ជមាននោះទេ ប៉ុន្តែតាមរយៈការបង្កាត់ឲ្យមានកំហឹងក្នុងការជជែកវែកញែកយ៉ាងក្តៅគគុកអំពីបញ្ហា“ការទទួលខុសត្រូវនិងសន្តិភាព” ។ គោលរឿងនេះដែលនិយាយចេញយ៉ាងស្រួចស្រាល់បំផុតនៅអំឡុងឆ្នាំ១៩៦៦-១៩៩៧ និងការផ្លាស់ប្តូរគ្នារវាងស្មេរអនាមិកនិងប្រព័ន្ធផ្សព្វផ្សាយ ***Felice Gae*** នៅក្នុងទំព័រនិយាយអំពីសិទ្ធិមនុស្សប្រចាំត្រីមាសនោះ បានភ្ជាប់វិវឌ្ឍន៍ជាច្រើនដែលបានលើកឡើងជាគម្រោងខាងដើម ពោលគឺថាតើការបង្កើតឲ្យមានសន្តិភាពតម្រូវការឲ្យមានការទទួលខុសត្រូវទន្ទឹមគ្នាចំពោះការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើនីតិមនុស្សធម៌អន្តរជាតិ ឬថាតើការទាមទារឲ្យមានសន្តិភាពផងនិងការទទួលខុសត្រូវផង អាចសម្រេចបានទាំងពីរដែរឬទេ?

គោលបំណងនៃការសរសេរអត្ថបទនេះគឺមិនមែនចង់ស្វែងរកនូវចម្លើយច្បាស់លាស់ចំពោះសំណួរនេះទេ ប៉ុន្តែវាគឺជាកិច្ចការកាន់តែលម្អិតក្នុងការពិនិត្យមើល និងការវិភាគរិះគន់ទៅលើតួនាទីដែលការជជែកវែកញែកនានាបានណែនាំឲ្យផ្តោតទៅលើនីតិមនុស្សធម៌អន្តរជាតិ (ទាំងច្បាប់សារវិជ្ជមាននិងនីតិវិធី) ។ ការផ្តោតការយកចិត្តទុកដាក់ពិសេសទៅលើការរួមចំណែករបស់ច្បាប់ក្នុងការធ្វើឲ្យមានភាពនឹងនក្នុងបរិយាកាសក្រោយសង្គ្រាម តាមរយៈការរួមចំណែកក្នុងដំណើរការផ្សះផ្សាបង្រួបបង្រួម ។ ដូចនេះ ចំណុចសំខាន់គឺឥទ្ធិពលតាមផ្លូវច្បាប់

ជាអ្វីដែលប្រហែលជាអាចវាយតម្លៃដ៏ប្រសើរបំផុតក្នុងន័យជាយន្តការតាមផ្លូវច្បាប់ដែលគេប្រើជាញឹកញយបំផុតក្នុងការយកច្បាប់មកអនុវត្តជាក់ស្តែង ពោលគឺការជំនុំជម្រះករណីព្រហ្មទណ្ឌ និងគណៈកម្មការស្វែងរកការពិត ។

គេអាចគិតដល់យ៉ាងហោចណាស់បីចំណុចដែលនីតិមនុស្សធម៌អន្តរជាតិអាចដើរតួនាទីសំខាន់ក្នុងបរិយាកាសក្រោយពេលមានជម្លោះ ។ ចំណុចទីមួយគឺនិយាយដល់ដំណាក់កាល"បន្សុទ្ធកម្ម" ពោលគឺសម្រិតសម្រាំងយក"សមាសភាពមិនល្អ"ចេញពីកម្លាំងសន្តិសុខពីសំណាក់រដ្ឋាភិបាលស្នងអំណាច ។ ចំណុចទីពីរគឺទាក់ទងនឹងសំណងប៉ះប៉ូវដល់ជនរងគ្រោះនៃការរំលោភពីអតីតកាល ។ ចំណុចទីបីគឺការរួមចំណែកកាន់តែមានលក្ខណៈទូលំទូលាយ ដែលការចែកចាយបទដ្ឋាននិងគោលការណ៍នីតិមនុស្សធម៌អាចធ្វើឡើងដើម្បីកសាងនូវវប្បធម៌គោរពសិទ្ធិមនុស្សនិងការទទួលខុសត្រូវក្នុងស្ថានភាពក្រោយជម្លោះ ។ បញ្ហាទាំងនេះវាហួសពីបញ្ហាចោទនាពេលបច្ចុប្បន្ន ។ បញ្ហាទាំងនេះនឹងត្រូវចាត់ទុកថាជាជំនួយក្នុងការបំពងសំឡេងបន្ថែមទៀតអំពីបញ្ហាផ្សេងៗដែលជាការផ្តោតយកចិត្តទុកដាក់របស់អត្ថបទនេះ ។

## ការជំនុំជម្រះក្តី សន្តិភាព និង នីតិមនុស្សធម៌អន្តរជាតិ

ការពិភាក្សាអំពី "សន្តិភាពនិងការទទួលខុសត្រូវ" ពិតជាមានបញ្ហានៅក្នុងច្បាប់មនុស្សធម៌អន្តរជាតិ ។ ការលើកឡើងថាការមិនកាត់សេចក្តីគឺជាជម្រើសនយោបាយស្របច្បាប់ ("សន្តិភាពសំខាន់ជាងការទទួលខុសត្រូវ") វាមានលក្ខណៈផ្ទុយគ្នានឹងអនុសញ្ញាទីក្រុងហ្សឺណែវដើម្បីបង្ក្រាបការរំលោភធ្ងន់ធ្ងរនានា ។ ហេតុដូចនេះ ការលើកលែងដល់ការរំលោភធ្ងន់ធ្ងរអាចមានភាពមិនស្របច្បាប់ ប៉ុន្តែវាបង្ហាញថាវាជាផ្នែកមួយមានលក្ខណៈចាំបាច់ចេញពីកញ្ចប់សន្តិភាពទូទៅ ។ ទស្សនីករណ៍ដូចៗគ្នាមួយចំនួនក៏មានដែរ ទាក់ទងនឹងការរំលោភយ៉ាងធ្ងន់ធ្ងរដល់ច្បាប់សិទ្ធិមនុស្សអន្តរជាតិ ។

នីតិមនុស្សធម៌អន្តរជាតិពិតជាបានចែងអំពីការលើកលែងទោសទាក់ទងនឹងជម្លោះមិនមែនប្រដាប់អាវុធអន្តរជាតិដែលមានកម្រិតខ្ពស់ ពោលគឺពិធីសារ II ឆ្នាំ១៩៧៧ បន្ថែមទៅលើអនុសញ្ញាទីក្រុងហ្សឺណែវចែងថា នៅពេលចប់ជម្លោះ អាជ្ញាធរត្រូវ"ខិតខំផ្តល់នូវការលើកលែងទោសឲ្យបានទូលំទូលាយតាមតែអាចធ្វើទៅបាន" ។ ចំណែកឯបទបញ្ញត្តិទាក់ទងនឹងបញ្ហានេះត្រូវបានយកមកនិយាយយោងជាទូទៅត្រឹមតែបទល្មើសដែលការលើកលែងទោសអាចធ្វើទៅរួច ហើយមិននិយាយដល់ការរំលោភធ្ងន់ធ្ងររបស់ច្បាប់នេះឡើយ ។ ដូចនេះ ប្រភេទជនដែលមានប្រយោជន៍អាចមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធជាមួយនឹងជនដែល "រួចទោសពីការប្រយុទ្ធ" នៅក្នុងជម្លោះប្រដាប់អាវុធជាលក្ខណៈអន្តរជាតិ ហើយអ្នកដែលមានភាពរួចទោសនេះអាចទទួលបាននូវសិទ្ធិក្នុងការដោះលែងក្រោយពេលជម្លោះផុតរលត់ទៅ ។

ក៏ប៉ុន្តែ រវាងជម្រើសដាច់ណាត់នៃការលើកលែងទោសជាផ្លូវការចំពោះបទឧក្រិដ្ឋទាំងអស់ ជាមួយនឹងការតាំងចិត្តដាក់លាក់ក្នុងការកាត់សេចក្តីតាមផ្លូវតុលាការនោះ មានស្រមោលស្រអាប់រាប់មិនអស់គ្រាន់តែភាពមិនស្របច្បាប់មានកម្រិតតិចឬច្រើនប៉ុណ្ណោះ ។ បើមិននិយាយអំពីការលើកលែងទោសជាក់លាក់ប្រហែលជាមិនអាចអនុវត្តជាក់ស្តែងបានឡើយ ។ ប្រការនេះប្រហែលជាកើតចេញពីការព្រមព្រៀងគ្នាដោយគ្មានសរសេរជាលាយលក្ខណ៍អក្សរ ដែលថា គ្មានអ្វីនឹងត្រូវធ្វើឡើងដើម្បីជំរុញឲ្យមានការកាត់សេចក្តីតាមផ្លូវតុលាការនៅក្នុងកម្រិតជាតិឬអន្តរជាតិ ឬក៏អ្វីដែលមានលក្ខណៈស្រពេចស្រពិលមិនច្បាស់លាស់គឺ"ការយោគយល់"ទាក់ទិននឹងបញ្ហានេះ ។ លទ្ធភាពមួយទៀតដែលអាចកើតឡើងដែរគឺថា ការខកខាននេះប្រហែលជាយោងទៅតាមសេចក្តីសម្រេចខាងនយោបាយជាឯកតោភាគី ឬការខកខាននេះប្រហែលជាឆ្លុះបញ្ចាំងឲ្យឃើញអំពីកង្វះខាតភ័ស្តុតាងជាក់ស្តែងដែលអាចកើតចេញពីការលំបាកជាក់ស្តែងក្នុងការប្រមែប្រមូលចងក្រង ឬកង្វះខាតសុឆន្ទៈក្នុងការស៊ើបអង្កេត ។ ទាក់ទិននឹងជម្លោះប្រដាប់អាវុធមិនមែនជាលក្ខណៈអន្តរជាតិ ដែលនាពេលបច្ចុប្បន្ននេះត្រូវបានទទួលស្គាល់ថាការរំលោភធ្ងន់ធ្ងរដល់នីតិមនុស្សធម៌អន្តរជាតិដែលកំពុងអនុវត្តសព្វថ្ងៃជាបទល្មើសអន្តរជាតិនោះ ទាំងមាត្រា៣នៃអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ទាំងពិធីសារបន្ថែម II សុទ្ធតែគ្មានចែងអំពីបទបញ្ញត្តិមានតម្លៃប្រហាក់ប្រហែលនឹងបទបញ្ញត្តិចែង

នៅក្នុងអនុសញ្ញានានាដែលបង្កើតបានដោយយុត្តាធិការសកលទៅលើការរំលោភធ្ងន់ធ្ងរ ។

សម្រាប់អ្នកដែលចង់ឲ្យមានការគោរពនីតិមនុស្សធម៌អន្តរជាតិតាមតែអាចធ្វើទៅបាននោះ ជាការសំខាន់ណាស់ថា ទង្វើករណ៍នានាដែលកំពុងស្ថិតនៅក្នុងក្រសែភ្នែកសាធារណជននាពេលបច្ចុប្បន្ន ស្ដីអំពីការប្រើប្រាស់ឬស្ដីអំពីការជំនុំជម្រះក្ដីទាក់ទងនឹងការប្រើនីតិមនុស្សធម៌ ត្រូវតែលើកយកមកពិចារណា និងយកចិត្តទុកដាក់ ប្រសិនបើត្រឹមតែចង់ធានាថាភាពអាចកើតឡើងនៃការគោរពនីតិមនុស្សធម៌អន្តរជាតិត្រូវបានលើកកម្ពស់ ។ ប្រការនេះតម្រូវឲ្យមានការពិនិត្យពិច័យហ្មត់ចត់ទៅលើកិច្ចព្រមព្រៀងនានា ទោះទន់ទៅរកច្បាប់ដើម្បីអះអាងបញ្ជាក់ថា ការទាមទារឲ្យមានការប្រើច្បាប់នៅក្នុងកាលៈទេសៈបែបនេះ គឺមិនត្រូវផ្អែកលើការអះអាងដ៏សន្ធឹកសន្ធាប់នោះទេ ប៉ុន្តែត្រូវផ្អែកលើហេតុផលមាំទាំទើបបាន ។

## ការប្រើប្រាស់ការជំនុំជម្រះក្ដី

ទង្វើករណ៍គាំទ្រឲ្យមានការប្រើប្រាស់ការជំនុំជម្រះក្ដីនៅក្នុងស្ថានភាពក្រោយជម្លោះកើតឡើង ចែកចេញជាបីផ្នែកសំខាន់ៗៈ ទីមួយ ការជំនុំជម្រះដើម្បីឲ្យរាងចាល ទីពីរ ការជំនុំជម្រះដើម្បីយុត្តិធម៌ និងទីបី ការជំនុំជម្រះក្ដីដើម្បីឲ្យមានផ្លូវទៅរកការពិត ។ ជួនកាល ការធ្វើទង្វើករណ៍ប្រព្រឹត្តទៅដោយការនិយាយសរុបដោយផ្ទាល់ឃ្លាតចាកពីការពិភាក្សារកយុត្តិធម៌តាមបទដ្ឋានឧក្រិដ្ឋវិទ្យានិងយុត្តិធម៌តាមលក្ខណៈព្រហ្មទណ្ឌ ។ ការនិយាយដល់ទ្រឹស្ដីនៃការធ្វើឲ្យរាងចាល ផ្ដល់នូវឧទាហរណ៍ជាក់ស្ដែង ។ គ្រាន់តែអានមួយត្រួសវាអាចមានបញ្ហាពីរជាស្រេចទៅហើយ ។ បញ្ហាទីមួយគឺដោយសារថា របៀបរបបតាមផ្លូវច្បាប់អន្តរជាតិមានលក្ខណៈខុសប្លែកគ្នាពីរបៀបរបបតាមផ្លូវច្បាប់ជាតិ ដែលជាកត្តាអាចប៉ះទង្គិចយ៉ាងខ្លាំងជាមួយនឹងការប្រតិបត្តិរបស់តុលាការអន្តរជាតិ ។ បញ្ហាទីពីរគឺដោយសារថា ដូចដែល ខូហេន បានគូសបញ្ជាក់រួចហើយ ឧក្រិដ្ឋវិទ្យាដែលត្រួតត្រាដោយលោកខាងលិច យកអត្ថិភាពនៃលទ្ធិប្រជាធិបតេយ្យស្ថិតស្ថេរមួយជាចំណុចចាប់ផ្ដើមរបស់ខ្លួន ដែលជាការសន្មតក្រោមផ្លូវច្បាប់សម្រាប់ស្ថានការណ៍ក្រោយពេលជម្លោះ ។ ប្រការនេះមិនមែនចង់សំដៅថា ទង្វើករណ៍នេះគ្មានសុពលភាពទេ ប៉ុន្តែគ្រាន់តែថា ទង្វើករណ៍ទាំងនេះចាំបាច់ត្រូវស្នើឡើងដោយមានការប្រុងប្រយ័ត្នខ្ពស់ ។ ប្រការនេះក៏បញ្ជាក់ឲ្យមានភាពចាំបាច់សម្រាប់ឲ្យមានការកំណត់កាន់តែច្បាស់លាស់អំពីបន្ទាត់ព្រំសីមាក្នុងស្រុកនិងអន្តរជាតិទាក់ទងនឹងការជំនុំជម្រះក្ដី ពីព្រោះគេអាចទាញហេតុផលថា ព្រំដែនទឹកនៅតំបន់នេះបានក្លាយជាភក់អស់ទៅហើយ ។ យ៉ាងហោចណាស់ ចំណុចនេះគឺដោយសារការខកខានមិនបានកំណត់ឲ្យបានច្បាស់ដូចដែលបានលើកឡើងរួចមកហើយទេ ។

តាមការពិត គេចាំបាច់ត្រូវយកការជំនុំជម្រះក្ដីបួនមកពិចារណា ។ ទីមួយ គឺការជំនុំជម្រះក្ដីដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ (ដែលអាចដំណើរការបានដោយឈរលើមូលដ្ឋាននៃការរំលោភច្បាប់អន្តរជាតិ) ។ ទីពីរ តុលាការនៅក្នុងស្រុកនៃប្រទេសទីបីដោយឈរលើមូលដ្ឋាននៃការរំលោភលើច្បាប់ព្រហ្មទណ្ឌអន្តរជាតិឬរំលោភច្បាប់ក្នុងស្រុក តែជាកាតព្វកិច្ចតាមផ្លូវច្បាប់របស់អន្តរជាតិ (ជាជម្រើសមួយដែលករណីលោក ពីណូឆេត្រូវបានបង្ហាញឲ្យក្លាយទៅជាពត៌មានសុសសាយជាសាធារណៈ) ។ ទីបី តុលាការក្នុងស្រុកសម្រាប់រដ្ឋដែលមានបញ្ហារំលោភច្បាប់ព្រហ្មទណ្ឌអន្តរជាតិ និងទីបួន ការជំនុំជម្រះក្ដីនៅក្នុងតុលាការក្នុងស្រុកសម្រាប់រដ្ឋនោះដោយឈរលើមូលដ្ឋាននៃការចោទប្រកាន់ធ្វើឡើងជាលក្ខណៈច្បាប់ក្នុងស្រុកដែលក៏អាចធ្វើឡើងជាលក្ខណៈបទល្មើសច្បាប់អន្តរជាតិដែរ (ឧទាហរណ៍ ការសម្លាប់មនុស្សម្នាក់ប្រហែលជាអាចត្រូវចោទប្រកាន់ថាជាឃាតកម្មជាជាងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ) ។ គឺដោយសារតែវាមានការពាក់ព័ន្ធនឹងលទ្ធភាពផ្សេងៗគ្នាយ៉ាងដូចនេះហើយ បានជាសុពលភាពនៃទង្វើករណ៍និងទង្វើករណ៍ជំទាស់ជុំវិញបញ្ហាទំនាក់ទំនងរវាងការធ្វើឲ្យរាងចាល យុត្តិធម៌ និង ការពិត ចាំបាច់ត្រូវតែវិនិច្ឆ័យឲ្យដឹងស-ខ្មៅ ជាជាងធ្វើឡើងក្នុងលក្ខណៈជា “ការជំនុំជម្រះក្ដីមានលក្ខណៈអរូបិយ” ។

## ការជនុំជម្រះ និង ការធ្វើឲ្យរាងចាល

ទ្រឹស្ដីធ្វើឲ្យរាងចាលនៅក្នុងបរិបទនៃការរំលោភធ្ងន់ធ្ងរដល់នីតិមនុស្សធម៌អន្តរជាតិមិនទាន់បង្ហាញចេញនៅឡើយទេ ។

ស្នាដៃសិក្សាស្រាវជ្រាវជាលក្ខណៈខគ្រិដ្ឋវិទ្យាលើកឡើងនូវការធ្វើឲ្យរាងចាលជាពីរបែប ។ ទីមួយ ការធ្វើឲ្យរាងចាល“ដោយឡែក” តាមរយៈការកាត់សេចក្តីជនទាំងឡាយដែលជាប់ទាក់ទិននៅក្នុងបទល្មើសព្រហ្មទណ្ឌ ។ ទីពីរ ការធ្វើឲ្យរាងចាល“ទូទៅ” ទៅលើការប្រព្រឹត្តិបទល្មើសព្រហ្មទណ្ឌធ្ងន់ធ្ងរនៅក្នុងសង្គមទូទៅ ។ ក្រោយពេលយកបទពិសោធន៍នៅប៊ូស្នៀហឺស៊ីហ្គោវីណានិងកូសូវ៉ូ មកផ្ទុំគ្នា គេត្រឹមតែអាចនិយាយបានថា ការធ្វើឲ្យរាងចាលនៅក្នុងស្ថានភាពជាក់ស្តែងទាំងនោះជាមន្ទិលសង្ស័យដ៏ធំទាក់ទងនឹងតម្លៃនៃតុលាការអន្តរជាតិ ។ នេះជាការសន្និដ្ឋានដែល ខូហេន បានលើកឡើងតាំងពីមុនពេលលោកចាត់ទុកទ្រឹស្តីនេះថា“មានការពាក់ព័ន្ធប្រកបដោយមន្ទិលសង្ស័យ” មកម្ល៉េះ ។

លទ្ធភាពនៃការកាត់សេចក្តីលើការរំលោភលើច្បាប់មនុស្សធម៌មុនពេលតុលាការអាចត្រូវចាត់ទុកថាមានតម្លៃធ្វើឲ្យរាងចាលខ្លាំងជាងតុលាការក្នុងស្រុក ដោយសារតែភាពធ្ងន់ធ្ងរដែលតុលាការអន្តរជាតិឲ្យតម្លៃ ។ ប្រការនេះមិនមែនជាករណីជាក់ស្តែងទេ ។ យ៉ាងហោចណាស់ផ្នែកមួយនៃបញ្ហាប្រហែលជាអ្វីដែល ហ្វារ័រ លើកឡើង “ភាពប្រាកដប្រជាឈ្នះភាពតឹងរ៉ឹង” នៅក្នុងប្រយោជន៍នៃការធ្វើឲ្យរាងចាល ។ ដូចនេះ ដោយសារចំនួនមនុស្សសម្រាប់ចូលរួមក្នុងដំណើរកាត់សេចក្តីនៅក្នុងតុលាការអន្តរជាតិមានកម្រិតតិចដោយឈរលើមូលដ្ឋានភ័ស្តុតាង អ្នកប្រព្រឹត្តបទល្មើសជាបុគ្គលនឹងដឹងថាឱកាសដែលខ្លួនត្រូវផ្តន្ទាទោសស្ថិតនៅឆ្ងាយ ហើយតម្លៃនៃការធ្វើឲ្យរាងចាលក៏ទាបដែរ ។ រូបភាពនេះប្រហែលជាមានលក្ខណៈខុសគ្នាប្រសិនបើការជំនុំជម្រះក្តីមានទ្រង់ទ្រាយធំ មានលក្ខណៈប្រព័ន្ធ និងជាការជំនុំជម្រះក្តីក្នុងស្រុក ហើយគ្មានភាពលម្អៀងទៅលើការរំលោភបែបនេះត្រូវបានបង្កើតឡើងនៅក្នុងកម្រិតជាតិ ប៉ុន្តែទម្រាំតែមានភ័ស្តុតាងគ្រប់គ្រាន់ ទ្រឹស្តីនៃការធ្វើឲ្យរាងចាល“ដោយឡែក” នឹងនៅតែមិនអាចស្តែងចេញនូវតម្លៃធ្វើឲ្យរាងចាលដដែលនៅក្នុងបរិបទដែលកំពុងតែសិក្សានេះ ។

សន្មតថា តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីបានសម្រេចនូវសមិទ្ធផលតិចតួចក្រោមប្រធានបទ “ដោយឡែក” តាំងពីមុនពេលមានករណីនៅកូសូវ៉ូ “ប៉ាយ៉ាម អាហាវ៉ាន” ដែលធ្វើជាទីប្រឹក្សាច្បាប់តុលាការនេះផ្ទាល់ យល់ឃើញថា វាជាការចូលរួមចំណែកយ៉ាងសំខាន់ដល់ការធ្វើឲ្យរាងចាលជាទូទៅ ក្នុងន័យថា ដំណើរការនេះជួយបង្កើតបានជា “ការធ្វើឲ្យមានក្តីសង្ឃឹមជាលក្ខណៈអន្តរជាតិជាបណ្តើរៗអំពីការទទួលខុសត្រូវជាលក្ខណៈបុគ្គល និងការកើតឡើងនូវការសម្របជាទម្លាប់ទៅតាមគោលការណ៍មនុស្សធម៌បឋម” ។ ស្តែងចេញពីទស្សនវិស័យនេះ ការជំនុំជម្រះក្តីក្លាយទៅជារឿងប្រហាក់ប្រហែលគ្នាទៅនឹងឧបករណ៍វិស្វកម្មសង្គមៈ “ការទប់ស្កាត់បទឧក្រិដ្ឋនាពេលអនាគត គឺជាដំណើរការវែងឆ្ងាយក្នុងការផ្លាស់ប្តូរសង្គមនិងនយោបាយ ដែលនាំឲ្យមានអន្តរជាតូបនីយកម្មទៅលើគំរូនានាក្នុងបរិបទជាក់លាក់ ឬ“ក្លាយជាការពិត” ឬការជ្រៀតចូលជាបណ្តើរៗនូវគោលការណ៍ទាំងនេះទៅក្នុង“អំណាចពិតប្រាកដ”ដែលគេចង់បាន ។ ការផ្តោតលើបញ្ហានេះមានភាពប្រទាក់ក្រឡាជាមួយនឹងការពិភាក្សាកាន់តែទូលំទូលាយមួយដែលលើកឡើងពីខាងដើម ស្តីអំពីការកសាងតួនាទី“កសាងវប្បធម៌” នៃច្បាប់មនុស្សធម៌អន្តរជាតិជាទូទៅ ។ ចំណែកឯការសង្កត់ធ្ងន់អន្តរជាតូបនីយកម្មស្របគ្នាជាមួយទស្សនៈរបស់ ខេវ៉ាន ស្តីអំពីការជំនុំជម្រះក្តី ជាវិថីឆ្ពោះទៅរកការពិត ហើយចំណុចនេះនឹងត្រូវពិភាក្សានៅខាងក្រោម ។

## យុត្តិធម៌ ការទទួលខុសត្រូវ និង នីតិរដ្ឋ

ការទាមទារយុត្តិធម៌ជាក់លាក់ដែលមានលក្ខណៈផ្សេងគ្នាពីទ្រឹស្តីនៃការធ្វើឲ្យរាងចាល លេចចេញនៅក្នុងការពិភាក្សាអំពីតុលាការក្នុងបែបដែនពីរយ៉ាងៈ ទីមួយ យុត្តិធម៌ជាភាពត្រឹមត្រូវ (ពិភាក្សាសំខាន់នៅក្នុងបរិបទនៃទំនាក់ទំនងរវាងការពិតនិងនីតិវិធីតាមផ្លូវច្បាប់) ។ ទីពីរ បណ្តុំនៃទទ្បីករណ៍ជុំវិញផ្ទៃរឿង “យុត្តិធម៌ជាការទទួលខុសត្រូវ” ដែលផ្តោតសំខាន់ទៅលើកាតព្វកិច្ចសីលធម៌របស់រដ្ឋដែលប្រឈម មុខនឹងការរំលោភក្នុងទ្រង់ទ្រាយធំនិងផ្តោតលើភាពចាំបាច់ក្នុងការលើកកម្ពស់ធម្មាធិបតេយ្យ (នីតិរដ្ឋ) ។ ដូចដែល ហ៊ូសេ និង ខូហេន កត់សម្គាល់ដែរ របបដែលទទួលខុសត្រូវចំពោះការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរនិងជាប្រព័ន្ធ ត្រូវបានចាត់ទុកថាមានភាពអន់ថយ

ខាងសីលធម៌ ដោយបណ្តោយឲ្យមានជនរងគ្រោះនៃអំពើទារុណកម្ម ឃាតកម្ម និងការរំលោភទូទៅរាប់មិនអស់ ។ គេអះអាងថា ការឈឺចាប់របស់ជនរងគ្រោះសងមកវិញនូវសីលធម៌ដែលមិនអាចទទួលបានថា ចារីប្រព្រឹត្តបទល្មើសគួរតែរួចផុតពីការផ្តន្ទាទោស ហើយដោយសារសីលធម៌ក៏ទាមទារថាជនជាប់ចោទពីការរំលោភត្រូវតែទទួលការប្រព្រឹត្តិដោយត្រឹមត្រូវដែរនោះ ផ្លូវសមស្របមួយក្នុងការផ្តន្ទាទោសគឺតាមរយៈការជំនុំជម្រះក្តីដែលគោរពនីតិវិធីនិងត្រឹមត្រូវតាមច្បាប់ ។ ក្នុងករណីដែលគ្មានចំណាត់ការ ឬចំណាត់ការមិនគ្រប់គ្រាន់នៅត្រឹមថ្នាក់ជាតិ (ដូចជាករណីអតីតយូហ្គោស្លាវីនិងរ៉ូវ៉ាន់ដា) កាតព្វកិច្ចត្រូវធ្លាក់ទៅលើសហគមន៍អន្តរជាតិ ។ ទស្សនៈបែបនេះស៊ីគ្នាយ៉ាងខ្លាំងជាមួយនឹងការទាមទារដែលគ្មានការគាំទ្រទាក់ទងនឹងធម្មាធិបតេយ្យ ។ ដោយសារការរក្សាធម្មាធិបតេយ្យជាការល្អ កាតព្វកិច្ចពាក់កណ្តាលសីលធម៌ក្នុងការលើកកម្ពស់ចំណុចល្អនេះធ្លាក់ទៅលើរដ្ឋនោះមុនគេ រួចមកធ្លាក់មកលើសហគមន៍អន្តរជាតិ ។

ជួនកាល ការទាមទារដែលផ្អែកលើសីលធម៌ចង់បានយុត្តិធម៌ត្រូវបានបង្ហាញចេញក្នុងទម្រង់ជាហេតុផលដាក់ទោសស្រដៀងៗគ្នាចេញពីការពិភាក្សាអំពីយុត្តិធម៌ព្រហ្មទណ្ឌជាលក្ខណៈជាតិ ពោលគឺការចាំបាច់ឲ្យមានទំនាក់ទំនងរវាងការឈឺចាប់របស់ជនរងគ្រោះ និងអ្វីដែលត្រូវបន្ទុំទៅលើចារីប្រព្រឹត្តបទល្មើស ។ អ្នកអត្ថាធិប្បាយ (បើមានក៏មានតិចដែរ) ដែលបានលូកមាត់នៅក្នុងការពិភាក្សាថ្នាក់ជាតិ បានទាញហេតុផលថា ការផ្តន្ទាទោសអាចនាំដល់ការស្តារនីតិសម្បទាដល់អ្នករំលោភច្បាប់ (ទោះជាបញ្ហាដូចគ្នាមួយចំនួនកើតមានឡើងនៅក្នុងការពិភាក្សាវែកញែកដែលលើកមកនិយាយនៅខាងក្រោម អំពី“ការដាក់បញ្ចូលនូវភាពអាម៉ាស់” ទាក់ទងនឹងគណៈកម្មការស្វែងរកការពិតក៏ដោយ) ។

ដោយមូលហេតុដូចបានជម្រាបជូនមកខាងលើនេះហើយ បានជាបញ្ហានៃធម្មានុរូបនៃការអានត្រួសៗទៅលើការពិភាក្សាវែកញែកចាប់ពីយុត្តិធម៌ព្រហ្មទណ្ឌក្នុងស្រុកទៅដល់បរិយាកាសក្រោយពេលមានជម្លោះ គឺជាបញ្ហាទុកចំហចោល ។ លក្ខណៈពិសេសនៃទិដ្ឋភាពអន្តរកាលបរិយាកាសក្រោយពេលជម្លោះគឺជាការបោះជំហានពីស្ថានការណ៍ដែលក្នុងនោះធម្មាធិបតេយ្យអវត្តមានឬត្រូវបានបន្ទាបយ៉ាងខ្លាំងស្ថានភាពមួយដែលធម្មា-ធិបតេយ្យត្រូវបានបង្កើតឡើង ។ ហេតុដូចនេះ គ្មានលទ្ធភាពឯណាក្នុងការរក្សាធម្មាធិបតេយ្យនោះទេ (យ៉ាងតិចនៅថ្នាក់ជាតិ) យ៉ាងច្រើនគឺអាចបង្កើតសាជាថ្មី ។

ទាក់ទងនឹងទស្សនៈដែលផ្អែកលើសីលធម៌ ជាការច្បាស់ណាស់ថា ប្រជាជនច្រើនណាស់មានការស្អប់ខ្ពើមយ៉ាងខ្លាំងចំពោះការដែលអ្នកបណ្តោយឲ្យជនរងគ្រោះឈឺចាប់យ៉ាងខ្លាំង ហើយបែរជាគេមិនឲ្យទទួលខុសត្រូវចំពោះមុខច្បាប់ ។ ការជំនុំជម្រះក្តីព្រហ្មទណ្ឌមកលើបុគ្គល ជាការផ្តល់នូវគំរូនៃការទទួលខុសត្រូវ ។ ដោយនីតិមនុស្សធម៌អន្តរជាតិផ្តល់នូវការទទួលស្គាល់គោលការណ៍ទទួលខុសត្រូវជាបុគ្គលខ្លាំងជាងច្បាប់សិទ្ធិមនុស្ស ដាក់ឲ្យនៅក្រោមច្បាប់នូវការរំលោភធ្ងន់ធ្ងរជាពិសេសការប្រព្រឹត្តិឡើងនៅក្នុងស្ថានភាពមានជម្លោះ ហើយជាពិសេសចាប់តាំងពីការអនុម័តពិធីសារបន្ថែមចំនួនពីរនៅឆ្នាំ១៩៧៧ និងការផ្តល់នូវការធានានីតិវិធីត្រឹមត្រូវតាមច្បាប់ទូលំទូលាយនោះ គឺច្បាប់នេះបម្រើតែគោលបំណងនេះឯង ។ ការកំណត់ការប្រព្រឹត្តិបទល្មើសណាមួយជាការរំលោភលើច្បាប់សង្គ្រាម ទោះជាការកំណត់នេះធ្វើឡើងដោយតុលាការអន្តរជាតិឬតុលាការក្នុងស្រុក គឺជាការសង្កត់ធ្ងន់ទៅលើភាពធ្ងន់ធ្ងរនៃបទល្មើស នៅក្នុងទម្រង់មួយដែលការជំនុំជម្រះក្តីដែលមានបទចោទប្រកាន់ក្នុងស្រុកធម្មតាមិនអាចធ្វើទៅបាន សូម្បីតែបទចោទប្រកាន់ដែលធ្វើឡើងនោះមានធាតុផ្សំដូចជាធាតុផ្សំនៅក្នុងច្បាប់មនុស្សធម៌អន្តរជាតិក៏ដោយ ។ ដូចនេះការប្រើច្បាប់មនុស្សធម៌អន្តរជាតិមានតួនាទីជានិមិត្តសញ្ញាសំខាន់ដែលអាចរួមចំណែកយ៉ាងប្រសើរដល់ការបំពេញទៅតាមការស្រេកឃ្លានយុត្តិធម៌តាមផ្លូវច្បាប់ពីសំណាក់ជនរងគ្រោះ ។

ទស្សនៈផ្ទុយពីនេះមានឫសគល់ចេញមកពីការពិភាក្សាវែកញែកអំពី “សន្តិភាពនិងការទទួលខុសត្រូវ”ៈ ដូចដែល ខូហេន បានកត់សម្គាល់ថា “មតិផ្ទុយគឺជាវិធានការនៃនិរទណ្ឌភាពប្រហែលជាវិធីប្រសើរបំផុតក្នុងការបង្កើតលក្ខខណ្ឌនយោបាយដែលតាមរយៈវិធីនេះគេអាចសម្រេចបាននីតិរដ្ឋ” ។ កាន់តែសាមញ្ញជាង

នេះក្នុងបម្លាស់ប្តូរគំនិតខាងលើ “ជនអនាមិក” បានអះអាងដោយចោទប្រកាន់ថា ការទាមទារឲ្យមានការផ្តន្ទាទោសដែលធ្វើឡើងនៅអំឡុងពេលនៃការចរចាសន្តិភាពមានន័យថា “ប្រជាជនរាប់ពាន់នាក់ដែលមិនគួរស្លាប់ បានស្លាប់បាត់បង់ជីវិត ពីព្រោះអ្នកសីលធម៌និយមកាលនោះចង់បាននូវសន្តិភាពមួយដែលឥតខ្ចោះ” ។ ភាពផ្សេងៗគ្នានៃទឡ្ហីករណ៍នេះមានទិសដៅតែមួយៈ ការទទូចឲ្យមានការកាត់សេចក្តីអ្នករំលោភសិទ្ធិមនុស្សកាលពីអតីតកាលនៅក្នុងដំណាក់កាលអន្តរកាល ក្រោយពេលមានជម្លោះកើតឡើងអាចមានការខូចប្រយោជន៍ ពីព្រោះវាអាចរារាំងដល់ការចរចារកដំណោះស្រាយ (ប្រជាជនទួរគីមិនបោះឆ្នោតឲ្យមានបុណ្យខួបកំណើតព្រះយេស៊ូ) ឬអាចបំផ្លាញលទ្ធិប្រជាធិបតេយ្យដែលទើបតែបិចពន្លកក្រោយពេលជម្លោះត្រូវបញ្ចប់ ដូចជាបណ្តាលឲ្យមានរដ្ឋប្រហារយោធាជាដើម ។ ផ្ទុយទៅនឹងការបំពេញតាមបំណងចង់បានយុត្តិធម៌ លទ្ធផលចុងក្រោយអាចមានការរំលោភសិទ្ធិមនុស្សកាន់តែច្រើន ហើយការកាត់ទោសអាចនាំដល់វិទ្ធង្សនាជាជាងស្តារឡើងវិញនូវធម្មាធិបតេយ្យ ។

ខណៈដែលគ្មានការបដិសេធកម្លាំងដែលផ្អែកលើហេតុការណ៍របស់ទឡ្ហីករណ៍ទាំងនេះ វាមិនច្បាស់ទេថា ទឡ្ហីករណ៍ទាំងនេះអនុវត្តស្មើៗគ្នាចំពោះលទ្ធភាពទាំងបួនយ៉ាងឲ្យមានការជំនុំជម្រះក្តីដែលកំណត់ច្បាស់ខាងលើ ។ គេក៏អាចអះអាងថាការផ្ទោកមកផ្តោតលើការលៃលកពេលវេលានៃការជំនុំជម្រះក្តីច្រើនស្មើនឹងការផ្តួចផ្តើមរបស់ខ្លួនដែរ ហើយថា ក្នុងករណីខ្លះអាចមានព្រឹត្តិការណ៍មករំខាន ។ ចំណែកឯការជំនុំជម្រះក្តីនៅក្នុងថ្នាក់ជាតិ ទោះជាធ្វើការចោទប្រកាន់តាមបទដ្ឋានច្បាប់ក្នុងស្រុកនិងច្បាប់អន្តរជាតិក្តី គឺអាស្រ័យទៅលើតុល្យភាពនៃកម្លាំងនៅក្នុងក្របខណ្ឌរដ្ឋដែលមានបញ្ហា ។ ការជំនុំជម្រះក្តីនៅក្នុងស្ថានភាពក្រោយជម្លោះនៅចំពោះមុខតុលាការអន្តរជាតិឬចំពោះមុខតុលាការក្នុងស្រុកនៅក្នុងប្រទេស ទីបីគឺមិនគិតអំពីការពិចារណាបែបនេះទេ ទោះជានឹងមានការគិតគូរជាចម្បងទៅលើចុងចោទនិងសាក្សីព្រមទាំងភស្តុតាងយ៉ាងណាក៏ដោយ ។ មិនចង់សំដៅថា ការជំនុំជម្រះបែបនេះអាចមិនបំផ្លាញដល់ការដោះស្រាយតាមរយៈសន្តិភាពនោះទេ ប៉ុន្តែវាបង្ហាញថាលទ្ធភាពនេះអាចមិនកើតឡើង ពោលគឺ តើធ្វើរដ្ឋប្រហារដើម្បីអ្វីទៅបើរដ្ឋប្រហារនេះរារាំងដល់ការជំនុំជម្រះក្តីភ្លាមៗទាំងរារាំងមិនឲ្យមានការជំនុំជម្រះក្តីនាពេលអនាគតទៀតនោះ? ស្រដៀងគ្នានេះដែរ ទឡ្ហីករណ៍របស់“ជនអនាមិក”សន្មតជាមុននូវជម្រើសគោលនយោបាយមួយទាក់ទងនឹងតុលាការអន្តរជាតិពិសេសដោយស្ថិតនៅក្នុងគន្លងការចរចាសន្តិភាព ។

ទោះបីជាទស្សនៈនេះត្រូវបានយល់ឃើញបែបណាក៏ដោយ (ទទួលការរិះគន់យ៉ាងខ្លាំង) ការយកគំនិតនេះទៅអនុវត្តជាក់ស្តែងភាគច្រើនមិនបានការ នៅក្នុងស្ថានភាពដែលមានតុលាការអន្តរជាតិស្រាប់ ដោយមានយុត្តាធិការផង ដែលតុលាការនេះបង្កើតឡើងដោយលក្ខន្តិកៈហើយរដ្ឋនោះជាភាគី ។ ប្រការនេះមិនចង់សំដៅថា ការផ្តួចផ្តើមបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិនឹងផ្តល់ឱសថកែរោគគ្រប់មុខ ហើយបញ្ចប់ការពិភាក្សាអំពី “សន្តិភាពនិងការទទួលខុសត្រូវ” នោះទេ ។ សូម្បីតែអត្រានៃការផ្តល់សច្ចាប័នមានកម្រិតខ្ពស់ក៏ដោយ ក៏នឹងត្រូវការកិច្ចខិតខំប្រឹងប្រែងខ្លាំងក្លាទាក់ទងនឹងការធ្វើការចោទប្រកាន់ (ទោះជាចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិនិងតុលាការក្នុងស្រុកក្តី) ហើយម្យ៉ាងវិញទៀត ភស្តុភារមានកម្រិតនៅក្នុងករណីដែលមានកិច្ចការដែលត្រូវដោះស្រាយមានទំហំធំធេង ។ មិនតែប៉ុណ្ណោះសោត តុលាការក្នុងស្រុកផ្តល់នូវផលប្រយោជន៍នៃ“ភាពឆាប់រហ័ស”ក្នុងការទទួលសារដែលគេបញ្ជូន ព្រមទាំងសិទ្ធិចូលរួមរបស់សាក្សីដែលតុលាការអន្តរជាតិមិនអាចធ្វើបានដូច ។ ប៉ុន្តែវាបានចង្អុលបង្ហាញអំពីការពិភាក្សាវែកញែកជាក់ស្តែងដែលកាន់តែមានលក្ខណៈចង្អៀតទៅៗៈ ការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិនឹងបង្កើតជាចំណុចរឹងមួយចំនួន ដោយកំណត់យ៉ាងហោចណាស់នូវព្រំដែននៃការពិភាក្សាវែកញែកអំពីការទទួលខុសត្រូវតាមផ្លូវច្បាប់ ។

ការបង្កើតសណ្ឋានដែលអាចទៅរួចទាក់ទងនឹងការផ្គួកផ្គងតាមផ្លូវច្បាប់បែបនេះ នៅតែមិនទាន់មានចម្លើយនៅឡើយ ទាក់ទងនឹងទំនាក់ទំនងជាក់ច្បាស់រវាងការទទួលខុសត្រូវនិងការផ្សះផ្សាដែលមានលក្ខណៈខុសគ្នាបន្តិចបន្តួចប៉ុណ្ណោះពីការគណនាអំពីផលប៉ះពាល់នៃការកាត់សេចក្តី ។ ដំណោះស្រាយបញ្ហា


រូបថត ម៉ោង ៩:៣០ នាទីព្រឹក ១៧ មេសា ១៩៧៥



ដ៏ធំនេះតម្រូវឲ្យមានការប្រើប្រាស់ទ្រឹស្តីនៃទំនាក់ទំនងរវាងការទទួលខុសត្រូវនិងការពិត ទាំងក្នុងន័យការជំនុំជម្រះក្តីព្រហ្មទណ្ឌនិងការប្រព្រឹត្តិទៅរបស់គណៈកម្មការស្វែងរកការពិត ។

**ការជំនុំជម្រះក្តី និង ការពិតៈ សារសំខាន់នៃនីតិវិធីកំណត់ដោយច្បាប់**

ដោយហេតុថា ស្នាដៃសិក្សាស្រាវជ្រាវជាច្រើនអំពីយុត្តិធម៌សម័យអន្តរកាលមើលឃើញដំណាក់កាលពីរតាមលំដាប់ថ្នាក់ពោលគឺដំណាក់កាល «ការពិត» និង «ដំណាក់កាលយុត្តិធម៌» (ការស្វែងរកការពិតក្រោយពីមានការជំនុំជម្រះក្តី) ថ្មីៗនេះ ស្មេរដូចជា អាខាវ៉ាន ជាដើម បានគាំទ្រគួនាទីចម្រាញ់យកការពិតពីដំណាក់កាលជំនុំជម្រះក្តី ជាគំនិតដែលទទួលបានការគាំទ្រ ។ ខ្លឹមសារនៃទឡ្ហីករណ៍នេះគឺថា តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីនឹងនិយាយអំពី«ការពិតនៃបុព្វហេតុនិងផលវិបាកកើតចេញពីសោកនាដកម្មលើប្រជាជនយូហ្គោស្លាវី» តាមរយៈការប្រើឆន្ទានុសិទ្ធិរបស់រដ្ឋអាជ្ញា ។ ប្រការនេះនឹងបង្កើតការពិត«ដ៏ប្រសើរ»ដែល«បង្ហាញថា បុគ្គលជាពិសេសមេដឹកនាំ មានការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋ ហើយថា គ្មានយុត្តិកម្មយករួចខ្លួនចំពោះការចូលរួមប្រព្រឹត្តកំហុសមកលើក្រុមជាតិពន្ធទាំងអស់ឡើយ ។ ការពិតនៅក្នុងបរិបទនេះគឺថា ត្រូវ«ចែករំលែកគ្នា»រវាងក្រុមជាតិពន្ធទាំងឡាយក៏ដូចជាតម្លៃដែលចែកចាយតាមរយៈការធ្វើឲ្យរាងចាលជាទូទៅយ៉ាងដូច្នេះដែរ ដែលត្រូវ«ធ្វើឲ្យមានលក្ខណៈអន្តរជាតិ»ដូចដែលកត់សម្គាល់ពីខាងដើម ដូចជាការផ្តល់នូវ«ដំណើររឿងពាក់ព័ន្ធនឹងសីលធម៌និងការបកស្រាយ...ដែលអំពាវនាវឲ្យមានចំណងរួមរវាងមនុស្សជាតិទូទៅដែលពុះពារជម្នះការបែងចែកជាតិពន្ធនេះ» ។

ការផ្សះផ្សាគឺជាលទ្ធផលដែលគេចង់បានចុងក្រោយបង្អស់ ដោយសារថា ក្រុមជាតិពន្ធនីមួយៗចាប់ផ្តើមដឹងថាមិនមែនជាក្រុមប្រឆាំងទេដែលទទួលខុសត្រូវចំពោះអំពើឃោរឃៅ ប៉ុន្តែគឺមេដឹកនាំនៃភាគីទាំងសងខាងឯណោះទេដែលជាអ្នកទទួលខុសត្រូវ ។ នីតិមនុស្សធម៌អន្តរជាតិដែលទទួចដល់ការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គលនោះ ហាក់ដូចជាមានលក្ខណៈគ្រប់គ្រាន់ក្នុងការបង្ហាញចំណុចនេះឲ្យបានច្បាស់លាស់ ប៉ុន្តែ

មុនពេលគេអនុម័តយកគួនាទីថ្មីនេះ ក៏ត្រូវរកឲ្យឃើញនូវចំណុចខ្សោយនានាដែលអាចកើតមាននៅក្នុងទស្សនៈនៃ «ការជំនុំជម្រះក្តីដើម្បីការពិត»ជាមុនសិនដែរ ។

ចំណុចខ្សោយលេចធ្លោបំផុតគឺថាវាអាស្រ័យទៅលើសុពលភាពនៃទ្រឹស្តីណាមួយដែលអាចអនុវត្តទៅមានផលវិជ្ជមានឬអវិជ្ជមានតែប៉ុណ្ណោះ ឬទ្រឹស្តីមួយចង្អោមអំពីជម្លោះជាតិពន្ធុដែល អាខាវ៉ាន ឲ្យឈ្មោះថា «ឧបករណ៍និយម» (លទ្ធិទស្សនវិជ្ជាដែលនិយមថាប្រាជ្ញានិងទ្រឹស្តីទាំងឡាយជាឧបករណ៍សម្រាប់ប្រព្រឹត្តទៅ) ។ ចំណុចនេះចង់និយាយថា ជម្លោះជាតិពន្ធុកើតឡើងពីឧបាយបញ្ឆោតរបស់ក្រុមអ្នកមានអំណាចមួយចំនួនតូចដែលគិតតែពីផលប្រយោជន៍ផ្ទាល់ខ្លួន ជាការពិតដែលត្រូវតែបង្ហាញចេញតាមរយៈការកាត់សេចក្តីមេដឹកនាំជាន់ខ្ពស់ ពោលគឺ «ត្រីធំ» ។ ផ្ទុយមកវិញ ទ្រឹស្តីដទៃទៀតផ្តោតលើបុព្វហេតុដែលមានការរៀបចំត្រឹមត្រូវ និងដើមហេតុជាលក្ខណៈប្រវត្តិសាស្ត្រនៃជម្លោះជាតិពន្ធុ ហើយរកផ្លូវដោះស្រាយបញ្ហាទាំងនេះឆ្ពោះទៅរកការផ្សះផ្សា ឬយ៉ាងហោចណាស់ឆ្ពោះទៅរកការរួមរស់ជាមួយគ្នាក្រោមមនោមវិជ្ជាផ្សេងគ្នា ។ ចំណុចខ្សោយប្រហាក់ប្រហែលគ្នាដែលអាចកើតឡើង គឺភាពស្រុះស្រួលគ្នារវាងយុទ្ធសាស្ត្រដែលស្នើឡើងដោយ អាខាវ៉ាន ជាមួយនឹងទស្សនៈអនុលោមតាមនីតិវិធីត្រឹមត្រូវ ។ ខណៈដែលផ្តោតការយកចិត្តទុកដាក់ទៅលើមេដឹកនាំជាន់ខ្ពស់ត្រូវការប្រើប្រាស់ធនធានច្រើនគ្រោះថ្នាក់ស្ថិតនៅត្រង់ថា អ្វីដែលគួរឲ្យសរសើរខាងសីលធម៌អាចគេចាត់ទុកថាមានការប្រឡូកប្រឡាក់ប្រសិនបើវាបង្កើតជាគំនិតថា យុទ្ធសាស្ត្រនៃការកាត់សេចក្តីកំពុងត្រូវបានកេងយកប្រយោជន៍ដើម្បីបង្ហាញនូវទ្រឹស្តីណាមួយអំពីជម្លោះជាតិពន្ធុថាត្រឹមត្រូវ ។

ក៏អាចមានបញ្ហាដែរជាមួយនឹងសញ្ញាណការពិត ឬសញ្ញាណនៃការពិតនោះ នៅខណៈដែល ខូហេន បានចាត់ទុកថាជា «រន្ធខ្មៅពីក្រោយគំនិតទំនើប» ។ ប្រការនេះលើកឡើងជាបញ្ហានានាដែលមិនត្រឹមតែជះឥទ្ធិពលទៅលើទស្សនៈរបស់ អាខាវ៉ាន ប៉ុណ្ណោះទេ តែជះឥទ្ធិពលទៅលើរាល់ការប៉ុនប៉ងទាំងឡាយដើម្បីទាញយកការពិតចេញពីដំណើរការជំនុំជម្រះក្តី ហើយកាន់តែមានលក្ខណៈខ្លាំងក្លាទៀត នោះគឺឥទ្ធិពលទៅលើគម្រោងការនៃគណៈកម្មការស្វែងរកការពិត ។ ប្រសិនបើសន្មតថាការស្វែងរកការពិតណាមួយជាយន្តការពេញច្បាប់ តើការជំនុំជម្រះក្តីព្រហ្មទណ្ឌផ្តល់នូវយន្តការដ៏ប្រសើរបំផុតឬល្អដើម្បីកំណត់អំពីការជំនុំជម្រះនេះដែរឬទេ?

ដំណោះស្រាយរបស់ អាខាវ៉ាន បែកចេញជាពីរ ដោយផ្អែកលើនីតិវិធីដែលមានច្បាប់ចែងដើម្បីផ្តល់នូវបំណែកនៃការយល់ច្បាស់ការពិតដែលគ្រាន់តែឲ្យល្អមើល និងការយល់ឃើញតាមទ្រឹស្តីដែលកាច់ជ្រុលពេកនោះដើម្បីប្រចាប់ជាគោលការណ៍មួយក្នុងការផ្គុំបំណែកទាំងនេះឲ្យចេញជារូបរាងឡើង ។ ហេតុដូចនេះ ដូចដែលលោក ម៉ៃឃើល អ៊ីកណាទីហ្វ បានលើកឡើងដែរនីតិវិធីភស្តុតាងផ្លូវការសម្រាប់តុលាការ ដូចជាតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី នឹងត្រូវចាត់ទុកថា«ប្រគល់ភាពពេញច្បាប់ដល់ការពិតដែលអាចប្រកែកបាន» ។ ចេញពីការប្រមូលអង្គហេតុបែបនេះ ការពិត«ប្រសើរបំផុត» ពោលគឺការទទួលខុសត្រូវរបស់ត្រីធំនឹងត្រូវពិចារណាទាញសេចក្តីសន្និដ្ឋានឬចងក្រងឡើង ។

មិនមែនមនុស្សគ្រប់រូបសុទ្ធតែមានសុទិដ្ឋិនិយមទៅលើការប្រើប្រាស់ដំណើរការជំនុំជម្រះក្តី ដូចជាមានសុទិដ្ឋិនិយមទៅលើយន្តការស្វែងរកការពិតនោះទេ សូម្បីតែក្នុងចំណោមអ្នកដែលចាត់ទុកទង្វើជាក់ស្តែងថាមានតម្លៃខ្លាំងក៏ដោយ ។ អ្នកច្បាប់មិនមែនជាអ្នកប្រវត្តិសាស្ត្រទេ ហើយមានការចាប់អារម្មណ៍មិនមែនទៅលើអង្គហេតុអរូបទេ ប៉ុន្តែចាប់អារម្មណ៍ទៅលើទំនាក់ទំនងរវាងការពិតនិងច្បាប់ដែលអង្គហេតុជាវិធាននៃពិភពច្បាប់ដែលត្រូវជំរុញឲ្យមានការចូលរួមជាមួយគ្នា ។ ហេតុដូចនេះហើយបានជា ខូហេន ចោទសួរថា តើ«ក្បួនភស្តុតាងធម្មតា»នៃច្បាប់ព្រហ្មទណ្ឌផ្តល់នូវវិធីមានប្រសិទ្ធភាពក្នុងការទទួលនូវការដឹងព្ទ ហើយ (ដោយនិយាយយោងដល់ការកាត់សេចក្តី ក្លូសបាប៊ី) លើកឡើងនូវលទ្ធភាព (គ្មានអ្វីហួសពីហ្នឹងទេ) ថា យុទ្ធសាស្ត្រកាត់សេចក្តីអាចបង្វែងដានឬបំភ្លៃជាជាងបម្រើបុព្វហេតុនិយាយការពិត ។

ជាការពិតណាស់ គ្មានចម្លើយងាយៗឆ្លើយតបនឹងសំណួរ

នេះទេ ហើយអាចផ្ទុយមកវិញថា ចំណុចខ្សោយនៃដំណើរការជំនុំជម្រះទាក់ទងនឹងបញ្ហានេះក៏ជាចំណុចខ្លាំងរបស់វាដែរ ។ ឈរលើទស្សនៈសុទិដ្ឋិនិយម ការជំនុំជម្រះក្តីអាចកំណត់បានយ៉ាងប្រាកដនូវការពិតមួយដែលមានកម្រិតតិច ពីព្រោះការពិតដែលត្រូវសម្រេចត្រូវបានកម្រិតដោយច្បាប់សារវិជ្ជមានផងនិងនីតិវិធីផង ដូចជាថា តាមវិធាននៃភ័ស្តុតាងដែលមិនគិតបញ្ចូលការពិចារណាដល់អង្គហេតុមួយចំនួនណានោះដែរ ហើយអង្គហេតុដែលទាក់ទងគឺជាអង្គហេតុដែលទាក់ទងនឹងបទល្មើសព្រហ្មទណ្ឌច្បាស់លាស់ណាមួយ ដែលប្រការនេះជាការប្រថុយប្រថាននឹងការបំភ្លៃពីរត្រួត ។ ប៉ុន្តែប្រការនេះផ្តល់នូវផលប្រយោជន៍ពីរៈ ភាពតឹងរ៉ឹងខ្លាំងនៃវិធាននីតិវិធីអាចផលិតនូវការរកឃើញអង្គហេតុពិតដែល“ជាប់គ្នា” ពីព្រោះការជំនុំជម្រះក្តីប្រដិប្រដូចគ្នាជាមួយនឹងសញ្ញាណយុត្តិធម៌រួមដែលមានលក្ខណៈបញ្ជាក់ថាពិតខាងប្រវត្តិសាស្ត្រ ពោលគឺ“យុត្តិធម៌ជាភាពត្រឹមត្រូវ” ។ ការចាត់ជាចំណាត់ថ្នាក់នូវអង្គហេតុបែបនេះថាជាបង្កើតជាបទល្មើសជាក់លាក់ណាមួយ ជាពិសេសបទល្មើសដែលមានស្នាមទុយ៌សធ្ងន់ធ្ងរ (ដូចជាឧក្រិដ្ឋសង្គ្រាម) អាចដើរទន្ទឹមគ្នាឆ្ពោះទៅរកការដោះស្រាយការឈឺចាប់របស់ជនរងគ្រោះប្រយុទ្ធប្រឆាំងនឹងយុទ្ធសាស្ត្រក្នុងការបដិសេធការឈឺចាប់ ហើយមកដល់កម្រិតនេះយ៉ាងហោចណាស់គឺឈានដល់ការបង្កើតបាននូវការពិតមួយ ។ យុទ្ធសាស្ត្របដិសេធបែបនេះមានជាច្រើនប្រភេទ ចាប់ពីការបដិសេធដ៏គ្រោតគ្រាតនូវអង្គហេតុពីសំណាក់អ្នកបដិសេធថាមិនមានហាយនភាព រហូតដល់ការភ្លាំងភ្លាត់គំនិតកាន់តែច្រើនឡើង ។

វិធីម្យ៉ាងក្នុងការស្រាយគំរូការពិត ការជំនុំជម្រះក្តី ផ្សះផ្សា អាចស្ថិតនៅក្នុងសញ្ញាណនៃ “ការទទួលស្គាល់” ដែលលើកឡើងដោយទស្សនវិទូទីក្រុងញូវយ៉ក ថូម៉ាស ណេដែល ។ ប្រសិនបើផ្នត់គំនិតនេះត្រូវបានស្រាយចេញ គេអាចចាត់ទុកថាវាមានធាតុផ្សំទាំងការទទួលយកនិងការវាយតម្លៃ ។ សំខាន់គឺការសរសើរថាទង្វើដូចដែលបានលើកឡើងនេះជាកំហុសឆ្គង ។ មានការទទួលស្គាល់ឬទទួលយកជាលក្ខណៈអត្តនោម័តិនូវអង្គហេតុពីសំណាក់អ្នកប្រព្រឹត្តខុស ពីសំណាក់អ្នកដែលចូលរួមប្រព្រឹត្ត ឬពីសំណាក់សង្គមទូទៅ ហើយការវាយតម្លៃទៅលើអង្គហេតុទាំងនេះដោយការយោងទៅតាមបទដ្ឋានសត្យានុម័តដែលជាការកំណត់នូវទង្វើខុស ។ ឧទាហរណ៍ ការទទួលស្គាល់មិនត្រឹមតែថាអង្គភាពយោធាបានធ្វើការកាប់សម្លាប់នោះទេ ប៉ុន្តែការកាប់សម្លាប់នោះគឺជាឃាតកម្ម ។ ការពិតដែលកំពុងត្រូវបានទទួលស្គាល់ ត្រូវបានចងក្រងឡើងមិនមែនក្នុងន័យ“អង្គហេតុនៅក្នុងភាពអរូប”នោះទេ ប៉ុន្តែក្នុងន័យ “អង្គហេតុជា” ដែលពាក្យថា“ជា”នេះ គឺក្តោបទាំងការទទួលខុសត្រូវទាំងតាមផ្លូវច្បាប់និងតាមផ្លូវសីលធម៌ ។

នៅក្នុងបរិបទទូទៅនេះ នីតិមនុស្សធម៌អន្តរជាតិអាចផ្តល់នូវចំណុចយោងមួយចំនួនដើម្បីបង្កើតបានពាក្យធាតុផ្សំ “ជា” ទោះជាតាមរយៈការនិយាយត្រង់ៗរបស់ច្បាប់ដែលមានចែងហើយក្តី ឬកាន់តែចំៗជាងនេះទៀត ទោះជាតាមរយៈការបកស្រាយតាមគំនិតច្នៃប្រឌិតក៏ដោយចុះ ។ មានអ្នកខ្លះអាចចោទសួរថា តើការបង្កើតរូបមន្តតាមផ្លូវច្បាប់អាចក្រសោបគ្រប់គ្រាន់នូវសេចក្តីរន្ធត់នៃអំពើឃោរឃៅក្នុងទ្រង់ទ្រាយធំបានដែរឬទេ ហើយអ្នកផ្សេងទៀតឆ្ងល់ថាតើការបង្កើតច្បាប់វាស្របទៅនឹងគោលការណ៍នីត្យានុកូលភាពរបស់លោកខាងលិចដែរឬទេ ។

ជាការស្នើជាយោបល់ ដូចដែល អាខាវ៉ាន ទំនងជាធ្វើដូចនេះដែរគឺថា ការដែលថាដំណើរការជំនុំជម្រះក្តីនឹងផ្តល់នូវការបង្កើតឬទទួលស្គាល់ការពិតដែលនឹងផ្តល់ការផ្សះផ្សាប្រហែលជាបំផ្លើសករណីនេះហើយ ។ ទង្វឹករណ៍ដែលមានលក្ខណៈគួរឲ្យស្វាគមន៍ជាង ប្រហែលពាក់ព័ន្ធនឹងការចាត់ទុកការពាក់ព័ន្ធនឹងបញ្ហាជនរងគ្រោះជាបុព្វលក្ខខណ្ឌ ឬយ៉ាងហោចណាស់ទំនងជាប្រផ្នូលនៃការផ្សះផ្សា ហើយចុងបញ្ចប់រួមចំណែកយ៉ាងសំខាន់ដល់ស្ថិរភាពបរិយាកាសក្រោយជម្លោះ ព្រមទាំងចាត់ទុកការជំនុំជម្រះក្តីជាផ្លូវទៅកាន់ការចូលរួមបែបនេះ ។ វាអាចបំពេញមុខងារនេះបានតាមរយៈការផ្តន្ទាទោសអ្នកធ្វើខុស (ដែលជាការបំពេញទៅតាមការទាមទារឲ្យមានការទួលខុសត្រូវ) និង/ឬ ដោយបំពេញមុខងារចម្រាញ់យកការពិតមិនសូវលើសលប់ដែលអាចទទួលស្គាល់ដែលមិនទាន់ជួយបាននៅឡើយទេ ដើម្បីឈានទៅទទួលស្គាល់ទំហំនៃការឈឺចាប់របស់ជនរងគ្រោះ

នៃអំពើឃោរឃៅនោះ ។ ទោះជាដំណើរការជំនុំជម្រះក្តីព្រហ្មទណ្ឌ ដែលយកច្បាប់មនុស្សធម៌អន្តរជាតិមកប្រើ ឬអង្គច្បាប់ដទៃទៀតមានសមត្ថភាពរួមចំណែកកាន់តែផ្ទាល់ដល់ការបង្រួបបង្រួមផ្សះផ្សា ជាពិសេសតាមរយៈការផ្សះផ្សាខ្លួនឯងក្តី គឺត្រូវដាក់ឲ្យមានការទទួលខុសត្រូវចូលក្នុងដំណើរការបែបនេះដែលគេទំនងជាមិនដែលបំពេញនោះ ។

## បំពេញបេសកម្មស្វែងរកការពិត

សូម្បីតែអ្នកគាំទ្រម៉ឺងម៉ាត់ចំពោះជម្រើសនៃការកាត់សេចក្តីជាផ្លូវទៅរកការពិតទទួលស្គាល់ថា ការជំនុំជម្រះក្តីមិនមែនគ្មានការកំណត់នៅក្នុងបញ្ហានេះទេ ។ ហេតុនេះហើយបានជា អាខាវ៉ាន យល់ថា "...ការឃ្លាតឆ្ងាយរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីពីតំបន់នេះមានន័យថាវាមិនអាចជំនួសជាមួយនឹងគំនិតផ្តួចផ្តើមពីក្នុងស្រុក (ក្នុងនោះរួមមានគណៈកម្មការស្វែងរកការពិតដែលផ្អែកលើការចូលរួមរបស់ប្រជាជន ឬឥរិយាបថរបស់សាធារណជនចំពោះការលាងទោសរបស់មេដឹកនាំ)" ។ នៅក្នុងទិដ្ឋភាពជាច្រើននៃទម្រង់របស់គណៈកម្មការស្វែងរកការពិតមានលក្ខណៈដូចគ្នាទៅនឹងទម្រង់ដែលទាក់ទងនឹងការកាត់សេចក្តីដែរ ។ ដប់ឃីន និង រ៉ូតអារៀហ្សា វិភាគទៅលើគោលដៅដែលគណៈកម្មការនានាត្រូវសម្រេចទាក់ទងនឹង"ការបង្កើតបញ្ជី-ឯកសារ ដែលអាចជឿទុកចិត្តបាននូវអ្វីដែលបានកើតឡើង ការផ្តល់នូវវេទិកាសម្រាប់ជនរងគ្រោះសេចក្តីស្នើនានាដើម្បីចៀសវាងកុំឲ្យមានការរំលោភទៅថ្ងៃអនាគតនិងការកំណត់ថាអ្នកណាជាអ្នកទទួលខុសត្រូវចំពោះមុខច្បាប់ព្រមទាំងផ្តល់នូវវិធានការនៃការដាក់ឲ្យចារីប្រព្រឹត្តបទល្មើសទទួលខុសត្រូវតាមផ្លូវច្បាប់" ។ ជាក់ស្តែងដូចដែល ហេន័រ លើកឡើងដែរថា នៅក្នុងសម័យអន្តរកាលនយោបាយ ការជំរុញឲ្យមានការផ្តួចផ្តើមគំនិតគឺស្ថិតនៅត្រង់បំណងប្រាថ្នាក្នុងការសម្គាល់ "នូវការបញ្ចប់ការចងក្រងឯកសារស្តីអំពីការរំលោភសិទ្ធិមនុស្សពីអតីតកាល ជំរុញការផ្សះផ្សាជាតិ និង/ឬ ជំរុញឲ្យមានចីរភាពដល់ភាពស្របច្បាប់ខាងនយោបាយ ។

## ការពិតជាអ្វី?

"បញ្ជី-ឯកសារដែលអាចជឿទុកចិត្តបាន" ដែល ដប់ឃីន និង រ៉ូតអារៀហ្សា បានលើកឡើង ត្រូវបានយល់ឃើញខុសៗគ្នាទាក់ទងនឹងទំនោរទូទៅនៃការរំលោភបំពាន ។ ហេតុដូចនេះហើយបានជា ហេន័រ និយាយថា គោលបំណងគឺចង់"គូសចេញជារូបភាពរួមមួយនៃការរំលោភសិទ្ធិមនុស្ស ឬការរំលោភច្បាប់មនុស្សធម៌អន្តរជាតិ មួយរយៈកន្លងមក" ជាវិធីមួយដែលតម្រូវឲ្យមានជម្រើសជាយុទ្ធសាស្ត្រទាក់ទងនឹងការផ្តោតសំខាន់លើការស៊ើបអង្កេត ។ ប៉ុន្តែមិនដូចជាការទទូចរបស់ អាខាវ៉ាន ទៅលើការប្រើឆន្ទានុសិទ្ធិនៃរដ្ឋអាជ្ញានៅក្នុងដំណើរការជំនុំជម្រះក្តីដើម្បីរកការពិត"ប្រសើរបំផុត"នោះទេ ការព្រួយបារម្ភរបស់គណៈកម្មការស្វែងរកការពិតត្រូវបានផ្តួចផ្តើមឡើងជាទូទៅមិនមែនទៅលើភាពត្រឹមត្រូវនៃទ្រឹស្តីជាក់លាក់នៃជម្លោះជាតិពន្ធុនោះទេ ប៉ុន្តែវាទាក់ទងទៅនឹងការអនុវត្តតាមលក្ខណៈបច្ចេកទេសក្នុងការជ្រើសរើសគំរូជាតំណាងដើម្បីធ្វើការពិនិត្យ ។

ជាការពិតណាស់ថា រាល់ការជ្រើសរើសគឺសុទ្ធតែប្រថុយនឹងការខុសពីគោលបំណងដើម ប៉ុន្តែក្នុងករណីគណៈកម្មការស្វែងរកការពិត គ្រោះថ្នាក់នៃការខុសពីគោលបំណងដើមដែលចង់បានការពិតដែល ខូហេន លើកឡើងថា វាអាចអាស្រ័យទៅនឹងដំណើរការជំនុំជម្រះក្តី នោះគួរតែមិនមានភាពជាក់ស្តែងពីព្រោះថា ជម្រើសយុទ្ធសាស្ត្រទៅលើរូបរឿងក្តីដែលត្រូវស៊ើបអង្កេតមិនកំណត់ទៅលើករណីទាំងឡាយដែលចារីណាម្នាក់អាចត្រូវបានរកឃើញ ហើយដែលជនសង្ស័យអាចបង្ហាញខ្លួននៅចំពោះមុខតុលាការនោះទេ ។ ដូចគ្នានេះដែរ ពត៌មានដែលត្រូវទទួលបានមិនកំណត់ដោយតម្រូវការភស្តុតាងនៃនីតិវិធីព្រហ្មទណ្ឌ ។

នីតិមនុស្សធម៌អន្តរជាតិផ្តល់នូវចំណុចទាក់ទងសំខាន់នៅក្នុងបរិបទនេះដោយហេតុផលពីរយ៉ាង ។ ហេតុផលទី១គឺថា ច្បាប់នេះកំណត់គំរូបទដ្ឋានដែលតាមរយៈបទដ្ឋាននេះមិនមែនមានតែឥរិយាបថរបស់កម្លាំងសន្តិសុខរបស់រដ្ឋមួយត្រូវបានប៉ាន់ប្រមាណនោះ តែសូម្បីតែតួអង្គមិនមែនរដ្ឋក៏អាចប៉ាន់ប្រមាណបានដែរ ។ ហេតុផលទី២គឺថា ការវាយតម្លៃនេះត្រូវបានបញ្ចេញបញ្ចូលជាមួយនឹងបរិបទច្បាស់លាស់ដែលជារឿយៗមានការឈានមុខក្នុងការដោះសាយករួចខ្លួនពីសំណាក់អ្នកដែលទទួលខុសត្រូវចំពោះការរំលោភ ជាពិសេសការកើតឡើងនូវ

សង្គ្រាមឬជម្លោះប្រដាប់អាវុធ ។

## តួអង្គរដ្ឋ និង តួអង្គមិនមែនរដ្ឋ

ប៉ុន្មានឆ្នាំថ្មីៗនេះ នីតិមនុស្សធម៌អន្តរជាតិបាននិងកំពុងតែផ្តោតការយកចិត្តទុកដាក់កាន់តែខ្លាំងមកលើផលវិបាកតាមផ្លូវច្បាប់ទាក់ទងនឹងឥរិយាបថរបស់តួអង្គមិនមែនរដ្ឋ ។ នីតិមនុស្សធម៌អន្តរជាតិបញ្ចេញនូវគោលការណ៍ទទួលខុសត្រូវជាលក្ខណៈបុគ្គលដែលបានចាក់ឫសកាន់តែជ្រៅ ។ សូមត្រឡប់មកនិយាយអំពីការវិភាគរបស់ ហេន័រ មកលើតួនាទីរបស់គណៈកម្មការស្វែងរកការពិត ។ ទំនងជាថា មុខងារតួនាទីដែលធ្វើឡើងដើម្បីបំពេញច្បាប់ដែលអ្នកស្រីប្រមើលឃើញនោះ អាចសម្រេចទៅបានតែនៅពេលដែលគណៈកម្មការខ្លួនឯងសម្រេចបាននូវភាពស្របច្បាប់ពីសំណាក់ប្រជាជន ។ ដើម្បីសម្រេចបាននូវភាពស្របច្បាប់ពីសំណាក់ប្រជាជននេះ វាតម្រូវឲ្យគណៈកម្មការស្វែងរកការពិតនៅក្នុងស្ថានភាពក្រោយជម្លោះនោះ ចៀសវាងការពាក់ព័ន្ធផ្នែកនយោបាយ ហើយកុំឲ្យគណៈកម្មការនេះធ្វើប្រតិបត្តិការជាលក្ខណៈដូចជាការសម្រាំងយកការពិតដែលសមមូលទៅនឹងយុត្តិធម៌សម្រាប់អ្នកឈ្នះ ។ យ៉ាងហោចណាស់ផ្នែកមួយនៃចម្លើយអាចស្ថិតនៅត្រង់ឆន្ទៈក្នុងការពិនិត្យទៅលើការរំលោភបំពាននានាជាទូទៅឲ្យបានទូលំទូលាយ ។ ដូចជាគណៈកម្មការ រ៉េធីក នៅប្រទេសឈីលី គណៈកម្មាធិការស្វែងរកការពិតរបស់ប្រទេសអែលសាល់វ៉ាឌ័រ និងគណៈកម្មការស្វែងរកការពិតនិងផ្សះផ្សាជាតិរបស់អាហ្វ្រិកខាងត្បូង គណៈកម្មការទាំងនេះសុទ្ធតែធ្វើការស៊ើបអង្កេតលើបទរំលោភបំពាននានាមិនត្រឹមតែការរំលោភរបស់កម្លាំងសន្តិសុខរដ្ឋទេ ប៉ុន្តែការរំលោភបំពានរបស់ក្រុមប្រឆាំងប្រដាប់អាវុធទៀតផង ។ ជាពិសេសគណៈកម្មការស្វែងរកការពិតរបស់អែលសាល់វ៉ាឌ័រនិងគណៈកម្មការស្វែងរកការពិតនិងផ្សះផ្សាជាតិរបស់អាហ្វ្រិកខាងត្បូងបានយកនីតិមនុស្សធម៌អន្តរជាតិមកវាយតម្លៃទៅលើឥរិយាបថរបស់អង្គភាពមិនមែនជារដ្ឋ ។

ការប្រើនីតិមនុស្សធម៌អន្តរជាតិគឺដើម្បីទប់ទល់ជាមួយនឹងការដោះសាយករួចខ្លួនដែលជាទូទៅធ្វើឡើង ដោយមានល្បិចខ្ពស់ (ឬទទួលយកដោយស្ងៀមស្ងាត់) ពីសំណាក់រដ្ឋនិងតួអង្គមិនមែនរដ្ឋៈ "យើងបានធ្វើនូវអ្វីដែលយើងបានធ្វើ ពីព្រោះយើងកំពុងតែធ្វើសង្គ្រាមប្រឆាំងនឹងភេរវកម្មសង្គ្រាមស៊ីវិលសង្គ្រាមរំដោះជាតិ" ។ ដោយសារនីតិមនុស្សធម៌អន្តរជាតិចាត់ទុកអត្ថិភាពនៃជម្លោះប្រដាប់អាវុធជាចំណុចចាប់ផ្តើមរបស់ខ្លួន ទោះជាមានលក្ខណៈមិនមែនជាអន្តរជាតិឬជាអន្តរជាតិ (រួមទាំងសង្គ្រាមរំដោះជាតិក្តី) នីតិមនុស្សធម៌អន្តរជាតិបានផ្តល់បង្អែកខាងវោហារសាស្ត្រដល់អ្នកដែលចូលរួមនៅក្នុងជម្លោះ ។ ដូចនេះ ផ្លូវសម្រាប់ចៀសវាងដ៏ច្បាស់លាស់ ពោលគឺធ្វើសង្គ្រាមជាលក្ខណៈដោះសានោះ អាចក្លាយជាច្រកមួយឆ្ពោះទៅរកការទទួលខុសត្រូវ ។

សូម្បីតែជម្លោះប្រដាប់អាវុធនៅក្នុងន័យបច្ចេកទេសប្រហែលជាអាចស្ថិតនៅក្នុងភាពមន្ទិលសង្ស័យក្តី ក៏គំនិតចេះតែកើតមានកាន់តែច្រើនថាគំរូបទដ្ឋាន និងគោលការណ៍នានាដែលចែង និងកំណត់យ៉ាងច្បាស់បំផុតនៅក្នុងនីតិមនុស្សធម៌អន្តរជាតិនោះ រក្សាបាននូវសុពលភាពក្នុងគ្រប់ស្ថានការណ៍មានជម្លោះ ដោយទាំងមិនគិតពីថាតើចំណុចចាប់ផ្តើមតាមផ្លូវច្បាប់ (ជម្លោះប្រដាប់អាវុធ) ត្រូវបានឈានដល់ហើយឬនៅនោះទេ ។ ចំពោះបញ្ហានេះ គេប្រហែលជាអាចជួយបំពេញចន្លោះប្រហោងដែលបន្សល់ទុកដោយនីតិសិទ្ធិមនុស្សអន្តរជាតិដែលមានបំណងដោះស្រាយស្ថានការណ៍ក្រោយជម្លោះតាមរយៈយន្តការដែលគេរិះគន់យ៉ាងខ្លាំង ។

ឧទាហរណ៍ដ៏ច្បាស់បំផុតនៃសំណើនេះគឺការបង្កើតឡើងក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ នូវក្រមចរិយាធម៌និងបណ្តុំគោលការណ៍ដែលផ្អែកលើគំរូបទដ្ឋានមនុស្សធម៌ ប៉ុន្តែក៏ផ្អែកលើនីតិសិទ្ធិមនុស្សដែរ ។ មានយុទ្ធសាស្ត្រពីរដែលអាចបែងចែកច្បាស់ ។ យុទ្ធសាស្ត្រទីមួយមានគោលបំណងបង្កើតឡើងនូវក្រមមួយរៀបចំឡើងជាពិសេសដើម្បីអនុវត្តនៅក្នុងបរិយាកាសមានជម្លោះពាក់កណ្តាលប្រដាប់អាវុធ ពោលគឺស្ថានការណ៍ "ចលាចល និងភាពតានតឹងផ្ទៃក្នុង" ។ យុទ្ធសាស្ត្រទីពីរមានគោលបំណងចងក្រងជាច្បាប់នូវគំរូបទដ្ឋានជាក់លាក់សម្រាប់អនុវត្តនៅក្នុងជម្លោះដែលមិននឹកស្មានដល់ ។ ការអនុវត្តយុទ្ធសាស្ត្រទីពីរនេះអាចយកគំរូតាម "សេចក្តីប្រកាសទីក្រុងអូស្លូ ស្តីអំពីបទដ្ឋាននិងនីតិវិធី

សម្រាប់អនុវត្តក្នុងពេលមានគ្រោះអាសន្ន សាធារណៈ ឬអំពើហោរហៅផ្ទៃក្នុង (១៩៨៧) និងសេចក្តីប្រកាសស្តីអំពីគំរូបទដ្ឋានអប្បបរមានៅ ធើគូ/អាបូ (១៩៩០) ដែលពេលខ្លះហៅថា សេចក្តីប្រកាសធើគូ/អាបូ ។ នៅឆ្នាំ១៩៩៤ អត្ថបទវិសោធនកម្មត្រូវបានអនុម័ត ដែលទទួលបាននូវការបញ្ជាក់ត្រឹមត្រូវទាំងពីសំណាក់អង្គការសហប្រជាជាតិ និងអង្គការដើម្បីសន្តិសុខនិងសហប្រតិបត្តិការនៅអឺរ៉ុប ។

ដោយការជំនុំជម្រះដើម្បីដាក់ទណ្ឌកម្មត្រូវអនុវត្តច្បាប់រឹង (ទៅតាមនិយមន័យ) គណៈកម្មការស្វែងរកការពិតអាចមានកម្រិតខ្លាំងជាងភាពទន់ភ្លន់នៅក្នុងគំរូបទដ្ឋានដែលគេប្រើ ជាក់ស្តែងគឺដោយសារគោលបំណងចម្បងរបស់គំរូបទដ្ឋានទន់ភ្លន់ទាំងនេះមិនមែនដាក់ទណ្ឌកម្មឡើយ ។ ដូចនេះ គណៈកម្មការស្វែងរកការពិតអាចផ្តល់ជាផ្លូវមួយ (ដែលដំណើរការជំនុំជម្រះក្តីមិនអាចធ្វើតាម) ឆ្ពោះទៅរកការអនុវត្តជាក់ស្តែងនូវគោលការណ៍មនុស្សធម៌ដែលមានរៀបរៀងជាក្រុមដើម្បីជំរុញគោលការណ៍ទាំងនេះឲ្យអនុវត្តក្នុងស្ថានការណ៍ក្រោយជម្លោះ ។

មានប្រយោជន៍ជាច្រើនដែលត្រូវទទួលពីការអនុវត្តនីតិមនុស្សធម៌អន្តរជាតិនិងគំរូបទដ្ឋាននានា ចំពោះទាំងសកម្មភាពរបស់រដ្ឋនិងអង្គភាពមិនមែនរដ្ឋ ហើយប្រយោជន៍នេះក៏មិនមែនមានន័យថាគ្មានគ្រោះថ្នាក់ដែលមិនអាចនឹកដល់នោះទេ ។ ការលើកកម្ពស់ភាពស្របច្បាប់របស់គណៈកម្មការស្វែងរកការពិតតាមរយៈការបង់សំណាញ់ឲ្យធំគឺជារឿងមួយ ប៉ុន្តែការទទួលបាននូវត្រីទៅតាមវង្វង់សំណាញ់ដែលបង់ទៅគឺជារឿងមួយផ្សេង ។ ដូចដែល ខូហេន សរសេរទាក់ទងនឹងរឿងប្រហាក់ប្រហែលនេះដែរ ដែលនិយាយអំពីការលើកលែងទោសតាមការយោគយល់នោះ ការប្រព្រឹត្តិមកលើរដ្ឋនិងមិនមែនរដ្ឋតាមវិធីនេះ ផ្តល់“នូវភាពស៊ីមេទ្រីក្នុងការលាក់កំបាំងភាពពិតក្នុងសង្គម” ។ នៅក្នុងចរន្តស្របគ្នានេះដែរ ផមឃីន និង រ៉ូតអារៀហ្សា ប្រាប់ឲ្យដឹងជាមុននូវគ្រោះថ្នាក់ក្នុងការចាត់ទុកអំពើហោរហៅរបស់រដ្ឋនិងមិនមែនរដ្ឋ ថា“មានមុខងារសមមូលគ្នា” ដោយបង្កើតបានជា“ការបំភ្លៃឯកសារប្រវត្តិសាស្ត្រ” ។ ជាពិសេស អ្នកទាំងពីរផ្តល់ជាសញ្ញាណបង្ការទុកជាមុនថា ឥទ្ធិពលនៃការអប់រំដល់ប្រជាជនទូទៅអាចបាត់បង់នៅក្នុងការគិតឃើញថា “រឿងរ៉ាវអាក្រក់ៗកើតឡើងនៅគ្រប់សង្គ្រាមទាំងអស់ ហើយត្រូវបានប្រព្រឹត្តឡើងដោយភាគីទាំងអស់” ។

ច្បាស់ណាស់ថា គ្មានចម្លើយងាយស្រួលចំពោះសំណួរកើតចេញពីបញ្ហាទាំងនេះឡើយ ។ អ្វីដែលអាចនិយាយបានប្រហែលជាថា ខណៈដែលការប្រើនីតិមនុស្សធម៌អន្តរជាតិក្នុងការវាយតម្លៃទៅលើឥរិយាបថរបស់ក្រុមប្រឆាំងប្រដាប់អាវុធអាចបង្កើនភាពត្រឹមត្រូវ រួចហើយជំរុញដល់ភាពស្របច្បាប់របស់គណៈកម្មការស្វែងរកការពិត ។ ប្រការនេះមិនគួរធ្វើឡើងដោយឃ្លាតចាកពីការផ្តោតសំខាន់ទៅលើការទទួលខុសត្រូវរបស់រដ្ឋក្នុងនាមជានីតិបុគ្គលដែលមានការទទួលខុសត្រូវចម្បងក្នុងការលើកកម្ពស់ច្បាប់អន្តរជាតិឡើយ ។ ចំណុចស្នូលនៃបញ្ហានេះគឺការកំណត់នូវជម្រើសជាយុទ្ធសាស្ត្រសម្រាប់ធ្វើឡើងនៅដើមដំបូង ទាក់ទងនឹងវិសាលភាពតាមផ្លូវច្បាប់និងអង្គហេតុក្នុងការស៊ើបអង្កេតរបស់គណៈកម្មការស្វែងរកការពិត ។ ស្ថានការណ៍ក្នុងក្របខណ្ឌអង្គហេតុពិតដែលត្រូវបានស៊ើបអង្កេតគួរតែជាស្ថានការណ៍ទាំងឡាយដែលធ្វើឡើងដើម្បីសម្រេចឲ្យបាននូវគោលបំណងខាងការអប់រំដូចដែល ផប់ឃីន និង រ៉ូតអារៀហ្សា បានគូសបញ្ជាក់ ។ វាត្រូវការជាចាំបាច់ក្នុងការបញ្ជាក់ឲ្យបានច្បាស់ថា ខណៈដែលក្រុមប្រឆាំងប្រដាប់អាវុធអាចដាក់ឲ្យទទួលខុសត្រូវថាបានប្រព្រឹត្តការរំលោភលើច្បាប់មនុស្សធម៌អន្តរជាតិនោះ ការយកចិត្តទុកដាក់គួរតែធ្វើឡើងទៅលើការរិះគន់របស់ មីរ៉ា ដែលថា ដោយកំណត់នូវលក្ខណៈនៃទង្វើរបស់តួអង្គមិនមែនរដ្ឋថាជាការរំលោភសិទ្ធិមនុស្សគណៈកម្មការ រ៉េទីក បានបំផ្លាញតួនាទីអប់រំនៅក្នុងរបាយការណ៍របស់ខ្លួន ។

### ការពិត និង ការផ្សះផ្សា

បញ្ហាដែលកាន់តែសំខាន់គឺការស្វែងរកការពិតមិនមែននៅត្រង់ឥរិយាបថរបស់រដ្ឋឬមិនមែនរដ្ឋនោះទេ ។ ហេន័រ ដែលលើកឡើងនូវគន្លងមួយដែលស្របគ្នាទៅនឹងការដាក់ទណ្ឌកម្មបានទាញហេតុផលថា “...សារសំខាន់នៃគណៈកម្មការស្វែងរកការពិតប្រហែលជាអាចពិពណ៌នាកាន់តែសុក្រឹតថែមទៀតថាជា

ការទទួលស្គាល់នូវការពិតជាដាច់ស្វែងរកការពិត...ការទទួលស្គាល់ជាផ្លូវការនូវអង្គហេតុដែលលើកឡើងនៅក្នុងរបាយការណ៍គណៈកម្មការស្វែងរកការពិត ពីសំណាក់រដ្ឋាភិបាលឬកម្លាំងប្រឆាំង អាចដើរតួនាទីយ៉ាងសំខាន់ខាងចិត្តសាស្ត្រក្នុងការទទួលស្គាល់“ការពិត”ដែលត្រូវបានបដិសេធជាយូរមកហើយ ។

ដូចជាក្នុងករណីការកាត់សេចក្តីដែរ នីតិមនុស្សធម៌អន្តរជាតិអាចដើរតួនាទីសំខាន់ក្នុងការកំណត់ពាក្យថា “ជា” នៅក្នុងដំណាក់កាលទទួលស្គាល់នេះ ។ ការរកឃើញថា ឥរិយាបថរបស់តួអង្គនានានៅក្នុងជម្លោះគួរតែចាត់ទុកជាការរំលោភលើនីតិមនុស្សធម៌អន្តរជាតិឬគំរូបទដ្ឋាននានា បានឆ្លុះបញ្ចាំងជាគោលនូវភាពធ្ងន់ធ្ងរនៃការរំលោភនោះ ហើយអាចជួយដោះស្រាយអារម្មណ៍ឈឺចាប់របស់ជនរងគ្រោះបាន ។

ជាថ្មីម្តងទៀត ប្រការនេះលើកជាបញ្ហានៃផ្លូវឆ្ពោះទៅរកការផ្សះផ្សាដែលអាចកើតមានឡើង ។ វាត្រូវបានលើកឡើងពីខាងដើមហើយថា ដើម្បីចាត់ទុកការកាត់សេចក្តីជាការផ្តល់នូវការផ្សះផ្សានោះ ប្រហែលជាត្រូវតែដាក់ការទទួលខុសត្រូវនេះទៅក្នុងតួនាទីកាត់សេចក្តីដែលទំនងជាមិនអាចបំពេញបាន ហើយថាវាប្រហែលជាមានភាពជាក់លាក់អាចសម្រេចទៅបានទៀតផងក្នុងការចាត់ទុកការចូលរួមដោះស្រាយការព្រួយបារម្ភរបស់ជនរងគ្រោះ (តាមរយៈការកាត់សេចក្តី) ជាការត្រួសត្រាយផ្លូវឆ្ពោះទៅរកការផ្សះផ្សា ទោះជាប្រការនេះមិនអាចចៀសរួចថាវានាំដល់ការនាំឲ្យមានផលប៉ះពាល់ខូចប្រយោជន៍ដល់ការកាត់សេចក្តីក៏ដោយ ។ ការយកច្បាប់មនុស្សធម៌អន្តរជាតិមកប្រើនៅក្នុងការស្វែងរកការពិតរបស់គណៈកម្មការស្វែងរកការពិត ហាក់ដូចជាផ្តល់នូវសញ្ញាប្រាប់អំពីភាពធ្ងន់ធ្ងរនៃអ្វីដែលបានកើតឡើង ខណៈដែលកំពុងតែចៀសវាងពីផលប៉ះពាល់ខូចប្រយោជន៍ដល់ការកាត់សេចក្តី ហើយវាជាការផ្តល់នូវផ្លូវផ្សេងមួយទៀតឆ្ពោះទៅរកការផ្សះផ្សា ។

ប្រការនេះនៅតែមិនទាន់ឆ្លើយតបទៅបញ្ហាជាចំហនៃទំនាក់ទំនងរវាងការរកឃើញរបស់គណៈកម្មការស្វែងរកការពិត និងដំណើរការក្តីជាបន្តបន្ទាប់ដែលអាចកើតឡើងដដែល ទោះជាក្នុងករណីព្រហ្មទណ្ឌឬករណីផ្សេងទៀតក៏ដោយ ។ លទ្ធភាពអាចស្ថិតនៅត្រង់ការរការចងភ្ជាប់ដំណើរការនេះជាមួយ (ឬបង្កើតសាជាថ្មីជា) យន្តការបន្ទុកម្មដែលធ្វើឡើងដើម្បីរារាំងអ្នករំលោភកុំឲ្យដើរតាមរបៀបរបបចាស់ ដោយឲ្យអនុវត្តតាមរបៀបរបបថ្មីក្នុងសេវាសាធារណៈ ហើយប្រហែលជាពាក់ព័ន្ធនឹងបញ្ហាសំណង ។ ជម្រើសមួយទៀតអាចជាការយកតាមគំរូខគ្រិស្តវិទ្យារបស់ ប្រេដរើតធី ដែលនិយាយអំពី “ការបញ្ចូលភាពអាម៉ាស់” ដែល ខូហេន បានប្រមើល ប្រហែលជាអាចនាំដល់ “ភាពអាម៉ាស់ជាសាធារណៈ និងការបកអាក្រាតដែលអាចឆ្លើយតបទៅនឹងការទាមទារឲ្យមានការទទួលស្គាល់” ។

ជម្រើសមួយទៀតគឺគំរូរបស់អាហ្វ្រិកខាងត្បូង ដែលការនិយាយចេញពីមាត់ចារីប្រព្រឹត្តបទល្មើសនៅចំពោះមុខគណៈកម្មការស្វែងរកការពិត អាចនាំដល់ការលើកលែងទោស ប៉ុន្តែប្រការនេះវាផ្តល់មកវិញនូវបញ្ហាមួយចំនួនអំពីភាពពេញច្បាប់នៃការលើកលែងទោសដែលយើងបានដោះស្រាយរួចហើយនៅខាងដើមនៃអត្ថបទនេះ ។ ជម្រើសមួយទៀតគឺយកបញ្ហាកាត់សេចក្តីនេះជាបញ្ហាចំហពេញទី ប៉ុន្តែវាប្រហែលជាធ្វើឲ្យតួនាទីសម្រាំងការពិតរបស់គណៈកម្មការស្វែងរកការពិតមានលក្ខណៈកាន់តែលំបាក ដោយសារថានឹងគ្មានការលើកទឹកចិត្តដល់ចារីប្រព្រឹត្តបទល្មើសឲ្យចូលរួមនៅក្នុងដំណើរការនេះ ។ ប៉ុន្តែទោះជាដើរតាមផ្លូវណាមួយក៏ដោយ វាជាការច្បាស់ណាស់ថា នីតិមនុស្សធម៌អន្តរជាតិនិងគំរូបទដ្ឋាននានាមានតួនាទីក្នុងការកំណត់ម៉ែត្រសម្រាប់វាស់តុលាការព្រហ្មទណ្ឌឬគណៈកម្មការស្វែងរកការពិត ។ ដូចនេះ សូម្បីតែមានទស្សនៈមួយថាការសម្រេចចិត្តដោយសំអាងទៅលើហេតុការណ៍ថាតើត្រូវដំណើរការដោយមានការជំនុំជម្រះក្តីឬដោយដើរតាមផ្លូវគណៈកម្មការស្វែងរកការពិតយ៉ាងណានោះ វាចាំបាច់មិនត្រូវឲ្យសមមូលគ្នាជាមួយនឹងការសម្រេចទាក់ទងនឹងថាតើនីតិមនុស្សធម៌អន្តរជាតិត្រូវយកមកប្រើឬអត់នោះទេ ប៉ុន្តែត្រូវនិយាយអំពីគំរូដែលយកអង្គច្បាប់នេះជាមូលដ្ឋាន ។

### សេចក្តីសន្និដ្ឋាន

អ្វីជាការស្រាវស្រង់សង្ខេបដែលបង្ហាញជូននេះគឺថា នីតិមនុស្សធម៌អន្តរជាតិអាចរួមចំណែកទូលំទូលាយនៅក្នុងបរិយាកាស

ក្រោយពេលមានជម្លោះ ជាងក្នុងវិធីជាប្រពៃណីដែលបានលើកឡើង ។ អត្ថបទនេះពិនិត្យទៅលើការប្រើច្បាប់មនុស្សធម៌អន្តរជាតិនៅក្នុងដំណើរការជំនុំជម្រះក្តី និងការប្រើប្រាស់ច្បាប់មនុស្សធម៌អន្តរជាតិនៅក្នុងគណៈកម្មការស្វែងរកការពិតដែលជាការបែងចែកច្បាស់នូវការរួមចំណែកដែលអាចធ្វើទៅបានក្នុងដំណើរការបន្សុទ្ធកម្មនិងដែលពាក់ព័ន្ធទៅនឹងសំណង ។

មិនមែនទឡ្ហីករណ៍ទាំងអស់ដែលស្ថិតនៅក្នុងក្រសែភ្នែកសាធារណជនសម្រាប់ឲ្យមានការប្រើប្រាស់ច្បាប់មនុស្សធម៌អន្តរជាតិនៅក្នុងដំណើរការជំនុំជម្រះក្តីសុទ្ធតែមានការបង្ខំឲ្យកើតឡើងស្មើៗគ្នានោះទេ ។ ខណៈដែលវិធាននៃច្បាប់នេះផ្តល់នូវផ្លូវសមស្របបំផុតនាំដល់ការទទួលខុសត្រូវជាលក្ខណៈបុគ្គលនោះ តម្លៃនៃការធ្វើឲ្យរាងចាលចេញពីតុលាការដែលប្រើច្បាប់មនុស្សធម៌អន្តរជាតិមិនអាចបង្ហាញបានទេ ហើយទំនងជានៅតែមានលក្ខណៈដូចនេះដដែល វៀរលែងតែនិងរហូតទាល់តែអ្នករំលោភច្បាប់សំខាន់ៗប្រឈមមុខនឹងលទ្ធភាពកាត់ទោសខ្ពស់ ទោះជាកាត់ទោសក្នុងលក្ខណៈជាតិឬលក្ខណៈអន្តរជាតិក៏ដោយ ។ ប្រការនេះចងភ្ជាប់ជាមួយនឹងគម្រោងការមួយកាន់តែទូលំទូលាយ នាំដល់ការរក្សាបានជាទូទៅនូវគំរូបទដ្ឋានមនុស្សធម៌ដែលជាគោលដៅគួរតែជាស្នូលនៃយុទ្ធសាស្ត្រសម្រាប់ផ្សព្វផ្សាយច្បាប់មនុស្សធម៌ ។

ទាក់ទងនឹងបញ្ហាជំនុំជម្រះក្តីជាផ្លូវទៅរកការពិតនោះ ជាការច្បាស់មិនអាចប្រកែកបានថា នីតិវិធីតឹងតែងនៃការជំនុំជម្រះក្តីព្រហ្មទណ្ឌកម្រិតដល់ការពិតដែលអាចសម្រេចចេញយ៉ាងហោចណាស់ធ្វើឲ្យខូចខាតដល់ការពិតដែលលេចជារូបរាងឡើង ។ នីតិមនុស្សធម៌អន្តរជាតិអាចចូលរួមយ៉ាងសំខាន់ទាក់ទងនឹងការទទួលស្គាល់នូវភាពធ្ងន់ធ្ងរនៃការរំលោភបំពាននានា ។ ការរកឃើញមួយដែលថាអំពើមួយជាការរំលោភទៅលើច្បាប់សង្គ្រាម បានបញ្ជាក់ច្បាស់អំពីវិសាលភាពនៃបទល្មើសមានប្រសិទ្ធភាពជាងការរកឃើញដែលថាច្បាប់ក្នុងស្រុកត្រូវបានរំលោភហើយ ។

ជានិច្ចកាល ការទាញហេតុផលឲ្យប្រើច្បាប់មនុស្សធម៌នៅក្នុងដំណើរការជំនុំជម្រះក្តីមានលក្ខណៈប្រទាំងប្រទើសគ្នាជាមួយនឹងទស្សនៈ “សន្តិភាព និង ការទទួលខុសត្រូវ” ។ ប៉ុន្តែខណៈដែលប្រការនេះជាញឹកញយតែងតែបានបង្ហាញជូនជាលក្ខណៈជាជម្រើស “មួយ” ពោលគឺ “ជំនុំជម្រះក្តី ឬ សន្តិភាព” បើពិនិត្យឲ្យកាន់តែជិតដិតបំផុតឃើញថា បញ្ហានេះអាចទាក់ទងច្រើនជាមួយពេលវេលានិងគំរូនៃការជំនុំជម្រះក្តីដូចគ្នានឹងការជំនុំជម្រះក្តីក្នុងលក្ខណៈអរូបដែរ ។ ចំពោះបញ្ហានេះគឺមានភាពខុសគ្នារវាងការជំនុំជម្រះក្តីក្នុងស្រុកដែលមានលក្ខខណ្ឌធ្ងន់ទៅលើតុល្យភាពនៃកម្លាំងនៅក្នុងស្ថានភាពមានជម្លោះនិងការជំនុំជម្រះក្តីនៅក្នុងប្រទេសទីបី និងចំពោះមុខយន្តការអន្តរជាតិដែលមានស្រាប់ (ដូចជាតុលាការព្រហ្មទណ្ឌអន្តរជាតិជាដើម) ។ ដោយពេលវេលាចេះតែរំកិលទៅមុខ ប្រសិនបើការរំពឹងទុកមានកាន់តែខ្លាំងទៅលើការទទួលខុសត្រូវចំពោះការរំលោភយ៉ាងធ្ងន់ធ្ងរ វាទំនងជាថាការរំពឹងទុកបែបនេះនឹងបាត់បង់កម្លាំងមួយចំនួន ។

ទោះបីជានៅក្នុងស្ថានការណ៍ដែលគេមិនប្រើច្បាប់មនុស្សធម៌អន្តរជាតិនៅក្នុងការជំនុំជម្រះក្តីព្រហ្មទណ្ឌ នៅក្នុងបរិយាកាសក្រោយជម្លោះក្តី ក៏ច្បាប់នេះនៅតែអាចដើរតួនាទីសំខាន់នៅក្នុងការទទួលស្គាល់ការពិតអំពីជម្លោះដែលកើតឡើងនោះ នៅពេលដែលគណៈកម្មការស្វែងរកការពិតពឹងផ្អែកលើច្បាប់នេះ ។ នីតិមនុស្សធម៌ផ្តល់នូវផលប្រយោជន៍ជាក់លាក់នៅក្នុងបញ្ហានេះ ក្នុងន័យថាវាបានពង្រីកខ្លួនខ្លាំងទៅដល់តួអង្គមិនមែនរដ្ឋជាងនីតិសិទ្ធិមនុស្សអន្តរជាតិ ។ ដោយសារគណៈកម្មការស្វែងរកការពិតមិនចាំបាច់ភ្ជាប់ខ្លួនខ្លាំងណាស់ណាទៅនឹងច្បាប់ដែលបានចែង វានៅតែមានលទ្ធភាពថា គំរូបទដ្ឋានដែលបានចងក្រងឡើងហើយកំពុងតែត្រូវបានអភិវឌ្ឍនៅក្នុងការទំនាក់ទំនងរវាងនីតិសិទ្ធិមនុស្សនិងនីតិមនុស្សធម៌អន្តរជាតិ អាចត្រូវបានយកជាមូលដ្ឋានសម្រាប់គណៈកម្មការស្វែងរកការពិតនៅក្នុងវិធីដែលមិនអាចមានលទ្ធភាពនៅក្នុងការជំនុំជម្រះក្តីព្រហ្មទណ្ឌ ។ និយាយរួម រូបភាពដែលលេចឡើងគឺជារូបភាពដែលនីតិអន្តរជាតិសាធារណៈអាចដើរតួនាទីសំខាន់នៅក្នុងបរិយាកាសក្រោយជម្លោះ ជាងតួនាទីចេញពីរូបមន្ត “សន្តិភាព និង ការទទួលខុសត្រូវ” ។

**ខុម ខែម ប៉ែល**

# តុលាការប្រជាជននៅប្រទេសរ៉ាន់ដា

***(តពីលេខមុន)***

### ***ច) យុត្តិធម៌សម្រាប់អ្នកណា?***

*ឡាសបឹក មានការភ្ញាក់ផ្អើលជាខ្លាំងនៅខណៈពេលដែលគាត់ចុះទៅពិនិត្យស្ថានភាពអ្នកទោសនៅមន្ទីរឃុំឃាំងនៅគីបូយេ ហើយក្តាប់បានពីស្ថានភាពលំបាករបស់អ្នកទោស ជាពិសេសនៅពេលដែលត្រូវអ្នកទោសម្នាក់ចោទសួរថា "យុត្តិធម៌សម្រាប់អ្នកណា?" ។ អាណាគាសេ និង សេរូមបា ត្រូវតុលាការកាត់ទោសឲ្យជាប់គុកអស់មួយជីវិតពីបទប្រើរថយន្តឈូសបំផ្លាញវិហារកាតូលិកមួយនៅយ៉ាងហ្កេ និងពីបទសម្លាប់ជនជាតិទុតស៊ីអស់ពីរពាន់នាក់ ។ អាណាគាសេ គិតថា ការកាត់ក្តីរបស់តុលាការគឺអយុត្តិធម៌ ដោយសារគាត់ត្រូវជាប់ឃុំឃាំង ចំណែកឯ សេរូមបា ដែលជាបព្វជិតសាសនា និងជាអ្នកផ្តើមគំនិត បានរត់គេចខ្លួនទៅប្រទេសអ៊ីតាលី ហើយត្រូវបានការពារដោយក្រុមបព្វជិតនៃបុរីវ៉ាទីកង់ ។ អ្នកទោសម្នាក់ផ្សេងទៀតបានរអ៊ូរទាំថា "ដំណើរការកាត់ទោសស្វែងរកយុត្តិធម៌របស់តុលាការមានការយឺតយ៉ាវជាខ្លាំង ។ ពួកយើងជាប់ឃុំឃាំងអស់រយៈពេល៧ឆ្នាំដោយគ្មានការជំនុំជម្រះក្តី ។ ពេលយើងឮដំណឹងអំពីតុលាការដែលប្រជាជនហៅថា កាឆាឆា យើងសប្បាយចិត្តហើយចង់ឲ្យតុលាការប្រជាជននេះកើតឡើងឆាប់ៗដើម្បីជួយរកយុត្តិធម៌ឲ្យពួកយើង" ។*

*ឡាម ប៊ូន យល់ឃើញថា មូលហេតុសំខាន់ដែលប្រជាជនរ៉ាន់ដាមិនពេញចិត្តហើយរិះគន់តុលាការព្រហ្មទណ្ឌអន្តរជាតិ គឺដោយសារតុលាការនេះគិតតែដោះស្រាយបញ្ហាយុត្តិធម៌បញ្ហាឧក្រិដ្ឋជន ហើយព្រងើយកន្តើយមិនយកចិត្តទុកដាក់ចំពោះជនរងគ្រោះដែលក្រីក្រខ្វះខាត ។ ឡាម ប៊ូន បញ្ជាក់បន្ថែមថា យុត្តិធម៌គឺជាធាតុសំខាន់ធ្វើឲ្យជនរងគ្រោះបានធូរស្បើយអារម្មណ៍ ប៉ុន្តែជនរងគ្រោះក៏ត្រូវការជំនួយបន្ថែមពីលើយុត្តិធម៌នេះដែរ ។ ជនរងគ្រោះត្រូវតែទទួលបាននូវអ្វីដែលគាត់ត្រូវការបន្ថែមពីលើយុត្តិធម៌នេះទៀត ដើម្បីឲ្យពួកគាត់អាចបំភ្លេចអតីតកាល ហើយកសាងអនាគតថ្មីឡើងវិញ ។*

### ***៩) ប្រព័ន្ធតុលាការប្រជាជន ហៅ កាឆាឆា***

*ដូចដែលបានបង្ហាញអំពីចំណុចខ្សោយរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ដូចជាការយឺតយ៉ាវនិងស្ថានភាពលំបាករបស់អ្នកទោសនៅក្នុងមន្ទីរឃុំឃាំង ដែលបណ្តាលឲ្យការគាំទ្ររបស់ប្រជាជនចំពោះតួនាទីតុលាការក្នុងដំណើរការផ្សះផ្សាបង្រួបបង្រួមជាតិនៅប្រទេសរ៉ាន់ដាថយចុះ ។ នៅពាក់កណ្តាលឆ្នាំ២០០២ រដ្ឋាភិបាលរ៉ាន់ដាបានចាប់ផ្តើមដាក់ចេញនូវផែនការថ្មីដើម្បីជំរុញដំណើរការផ្សះផ្សាបង្រួបបង្រួមឲ្យបានខ្លាំងក្លា ។ គម្រោងថ្មីនោះហៅថា ប្រព័ន្ធតុលាការប្រជាជន ឬហៅថា កាឆាឆា ដែលជាវិធីដោះស្រាយជម្លោះកាលពីសម័យបុរាណនៅប្រទេសរ៉ាន់ដា ។*

*ក) អ្វីទៅជាតុលាការប្រជាជន?*

*តុលាការប្រជាជន (កាឆាឆា) គឺជាប្រភេទតុលាការដែលប្រជាជនរ៉ាន់ដាសម័យបុរាណបានប្រើប្រាស់សម្រាប់ដោះស្រាយទំនាស់កើតឡើង ។ "កាឆាឆា" មានន័យថា ការជួបជុំគ្នាអង្គុយលើវាលស្មៅដើម្បីពិភាក្សាដោះស្រាយទំនាស់ដែលកើតឡើង ។ កាលពីសម័យបុរាណ មនុស្សចាស់ជាមេកន្ទ្រាញឬមេភូមិបានកោះហៅភាគីជម្លោះឬភាគីមានទំនាស់នឹងគ្នាមកជួបជុំអង្គុយលើវាលស្មៅក្រោមដើមឈើដើម្បីដោះស្រាយទំនាស់ ហើយបង្រួបបង្រួមភាគីជម្លោះឲ្យត្រូវរ៉ូវគ្នាឡើងវិញ ។ ឧទាហរណ៍នៅពេលដែលសត្វគោឬក្របីរបស់អ្នកភូមិណាម្នាក់ចូលទៅស៊ីស្រូវនៅក្នុងស្រែរបស់អ្នកភូមិម្នាក់ទៀត ។ បញ្ហាឬជម្លោះបែបនេះមេកន្ទ្រាញឬមេភូមិតែងប្រើប្រាស់តុលាការប្រជាជនដើម្បីដោះស្រាយ ។ វិធីសាស្ត្រនេះតម្រូវឲ្យម្ចាស់ក្របីមកអង្គុយជុំជាមួយម្ចាស់ស្រូវ ហើយរៀបរាប់អំពីហេតុការណ៍ដែលបានកើតឡើងឲ្យមេកន្ទ្រាញឬមេភូមិបានដឹង ។ បន្ទាប់មក មេកន្ទ្រាញឬមេភូមិដោះស្រាយបញ្ហានិងផ្សះផ្សាគូទំនាស់ទាំងពីរឲ្យយល់*

ព្រមអធ្យាស្រ័យគ្នានិងឈានដល់ការត្រូវរ៉ូវគ្នាឡើងវិញ ។ តុលាការប្រជាជនដែលរដ្ឋាភិបាលរ៉ាន់ដាកំណត់ដាក់ចេញដើម្បីប្រើប្រាស់ដោះស្រាយទំនាស់នៅពេលនេះ ទាមទារមនុស្សចាស់ទុំក្នុងភូមិដែលមានលក្ខណៈសម្បត្តិល្អ ចូលរួមដោះស្រាយជម្លោះឬបណ្តឹងរបស់ប្រជាជន ។ ប៉ុន្តែទំនាស់នៅពេលនេះ មិនមែនជាទំនាស់រឿងស្រូវឬគោក្របីឡើយ ពោលគឺជាទំនាស់កើតឡើងពីការកាប់សម្លាប់ប្រល័យពូជសាសន៍នៅប្រទេសរ៉ាន់ដាក្នុងឆ្នាំ១៩៩៤ ។

នៅដើមឆ្នាំ១៩៩៩ សេចក្តីព្រាងច្បាប់តុលាការប្រជាជនត្រូវបានផ្សព្វផ្សាយ ហើយការងារពាក់ព័ន្ធក៏បានចាប់ផ្តើមដំណើរការជាបន្តបន្ទាប់ដែរ ។ ឧទាហរណ៍ការប្រជុំសិក្សាអំពីច្បាប់ដែលចូលរួមដោយអង្គការក្រៅរដ្ឋាភិបាល និងសហគមន៍អន្តរជាតិផ្តល់ជំនួយ ។ ព្រឹត្តិការណ៍ផ្សេងទៀតរួមមាន នៅថ្ងៃទី១ ខែមករា ឆ្នាំ២០០៣ ប្រធានាធិបតីរ៉ាន់ដាបានចេញអនុក្រឹត្យប្រកាសដោះលែងអ្នកទោសចំនួនបួនម៉ឺនប្រាំបួនពាន់បីរយចិតសិបប្រាំមួយនាក់ ។ អ្នកទោសដែលត្រូវដោះលែងនោះរួមមានអ្នកទោសដែលត្រូវចាប់ខ្លួនដោយគ្មានភស្តុតាងមនុស្សចាស់ជរា និងអ្នកដែលជាប់ចោទពីបទចូលរួមឬជំរុញឲ្យមានអំពើសម្លាប់ ហើយត្រូវបានចាប់ខ្លួនឃុំឃាំងជាច្រើនឆ្នាំរហូតអាចលើសពីទោសកំហុសរបស់ខ្លួនប្រសិនបើតុលាការបើកសវនាការជំនុំជម្រះក្តី ។ ការជ្រើសរើសចៅក្រមចំនួន២៦ម៉ឺននាក់ដោយបោះឆ្នោត ។ បេក្ខជនគឺបុរសនិងស្ត្រីដែលគ្មានជាប់ពាក់ព័ន្ធនឹងអំពើកាប់សម្លាប់ ។ ការបណ្តុះបណ្តាលជំនាញច្បាប់បន្ថែមពីសំណាក់គ្រូចំនួន៧រយនាក់ដែលបានទទួលការបណ្តុះបណ្តាលរួចហើយ អំពីច្បាប់ក៏ដូចជាការងារជាចៅក្រមក្នុងតុលាការប្រជាជនជូនដល់ចៅក្រមដែលត្រូវបានជ្រើសរើស ។ តាមផែនការរបស់រដ្ឋាភិបាលរ៉ាន់ដា តុលាការប្រជាជននឹងចាប់ដំណើរការនៅខែមិថុនាឆ្នាំ២០០៣ ហើយនឹងបញ្ចប់នៅចុងឆ្នាំ២០០៨ ។

១) អំពីប្រព័ន្ធតុលាការប្រជាជន

តុលាការប្រជាជននឹងត្រូវបង្កើតឡើងនៅទូទាំងប្រទេស ហើយមានការជ្រើសតាំងចៅក្រមដោយប្រជាជនដែលរស់នៅក្នុងភូមិឃុំស្រុកនិងខេត្ត ។ អ្នកទោសទាំងអស់លើកលែងតែប្រភេទអ្នកទោសដែលជាប់ចោទពីបទឧក្រិដ្ឋប្រភេទទីមួយ (មេដឹកនាំខ្ពស់បំផុត) នឹងត្រូវបញ្ជូនខ្លួនពីពន្ធនាគារទៅចូលរួមក្នុងពិធីសវនាការរបស់តុលាការប្រជាជនដែលមានទីតាំងនៅកន្លែងដែលឧក្រិដ្ឋជនបានប្រព្រឹត្តអំពើឧក្រិដ្ឋកម្ម ។ ប្រជាជនចំនួន១៩រូបដែលគ្មានជាប់ពាក់ព័ន្ធនឹងអំពើឧក្រិដ្ឋ និងមិនមែនជាសាច់ញាតិរបស់អ្នកទោស នឹងត្រូវបានជ្រើសរើសចេញពីក្នុងចំណោមប្រជាជនក្នុងសហគមន៍ដែលចូលរួមក្នុងសវនាការដើម្បីធ្វើជាគណៈកម្មាធិការសម្រាប់សវនាការ ។ ដំណើរការរបស់តុលាការគឺប្រជាជនក្នុងសហគមន៍ទាំងអស់អាចចូលរួមក្នុងសវនាការ (អង្គសភា) ដើម្បីពិភាក្សា ផ្តល់ពត៌មាន និងប្តឹងផ្តល់ចំពោះករណីរបស់ជនជាប់ចោទម្នាក់ៗ ហើយចៅក្រមជាអ្នកសម្រេចក្តី ។

តុលាការប្រជាជនចែកចេញជាបួនថ្នាក់ ។ ទីមួយ តុលាការប្រជាជនថ្នាក់ភូមិ ទីពីរថ្នាក់ឃុំ ទីបីថ្នាក់ស្រុក និងទីបួនថ្នាក់ខេត្ត ។ តុលាការប្រជាជនគ្រប់ថ្នាក់មានភារកិច្ចសម្រេចដោគវាសនារបស់អ្នកទោស ។ តុលាការប្រជាជនថ្នាក់ភូមិមានភារកិច្ចជំនុំជម្រះក្តីរបស់អ្នកទោសប្រភេទទីបួន ដែលជាប់ចោទពីបទលួចរបស់របរ និងបំផ្លិចបំផ្លាញសម្ភារអ្នកដទៃ ។ ប្រសិនបើរកឃើញថា អ្នកទោសពិតជាបានប្រព្រឹត្តអំពើដូចពោលខាងលើ អ្នកទោសត្រូវចេញសងថ្លៃខូចខាតដល់ជនរងគ្រោះ ។ ករណីនេះ តាមច្បាប់របស់តុលាការប្រជាជន គឺអ្នកទោសគ្មានសិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍ឡើយ ។ តុលាការថ្នាក់បន្ទាប់គឺតុលាការប្រជាជនថ្នាក់ឃុំ ។ តុលាការនេះមានភារកិច្ចជំនុំជម្រះក្តីបទឧក្រិដ្ឋប្រភេទទីបីដែលអ្នកទោសជាប់ចោទពីបទបង្ករបួសស្នាមដោយគ្មានចេតនាបំផ្លាញអាយុជីវិតជនរងគ្រោះ ។ តុលាការថ្នាក់ស្រុកមានភារកិច្ចជំនុំជម្រះក្តីបទឧក្រិដ្ឋប្រភេទទីពីរដែលអ្នកទោសជាប់ចោទពីបទសម្លាប់មនុស្សហើយអាចត្រូវកាត់ទោសឲ្យជាប់ឃុំឃាំងមួយរយៈឬអស់មួយជីវិត ។ តុលាការប្រភេទចុងក្រោយគឺតុលាការប្រជាជនថ្នាក់ខេត្ត ។ តុលាការនេះមានភារកិច្ចតែមួយ គឺទទួលបណ្តឹងឧទ្ធរណ៍របស់អ្នកទោសថ្នាក់ស្រុក ។

នៅក្នុងប្រព័ន្ធតុលាការប្រជាជន ជនជាប់ចោទគ្មានមេធាវី

ការពារទេ ។ ច្បាប់របស់តុលាការប្រជាជនកំណត់ឲ្យប្រជាជនដើរតួជាដើមចោទនិងជាចៅក្រម ។ អ្នកទោសប្រភេទទីមួយដែលជាប់ចោទពីបទមេគំនិតដឹកនាំឲ្យមានអំពើប្រល័យពូជសាសន៍រួមនឹងអំពើរំលោភលើផ្លូវភេទ ហើយដែលអាចត្រូវកាត់ទោសដោយការប្រហារជីវិត ត្រូវជំនុំជម្រះនៅក្នុងតុលាការដែលមានមេធាវីនិងចៅក្រម ។

ច្បាប់សំខាន់មួយនៅក្នុងច្បាប់របស់តុលាការប្រជាជនគឺការសារភាពកំហុសរបស់ឧក្រិដ្ឋជន ។ ច្បាប់នេះចែងថា អ្នកទោសដែលសារភាពកំហុសហើយសុំការលើកលែងទោស នឹងទទួលបានការសម្រាលទោស ។ ការសម្រាលទោសមានលក្ខណៈធំបើអ្នកទោសយល់ព្រមសារភាពកំហុសរបស់ខ្លួនក្នុងរយៈពេលជាប់ឃុំឃាំង ឬនៅមុនពេលតុលាការប្រជាជនបើកសវនាការជំនុំជម្រះ ។ ការសម្រាលទោសមានលក្ខណៈតូចបើអ្នកទោសព្រមសារភាពកំហុសក្នុងអំឡុងពេលជំនុំជម្រះក្តី ហើយអ្នកទោសនឹងមិនទទួលបានការសម្រាលទោសទាល់តែសោះប្រសិនបើមិនព្រមឆ្លើយសារភាពហើយត្រូវតុលាការរកឃើញថាមានកំហុស ។ ការដាក់ទោសរបស់តុលាការប្រជាជនគឺកំណត់ឲ្យអ្នកទោសទៅចូលរួមបម្រើសកម្មភាពសង្គម ដូចជាសង់ផ្ទះឲ្យប្រជាជន ស្ពានផ្លូវនិងសាលារៀន ជាដើម ។

ចំណុចសំខាន់មួយទៀតរបស់តុលាការប្រជាជនគឺសំណងសម្រាប់ជនរងគ្រោះ ។ នៅក្នុងផ្នែកមួយនៃដំណើរការរបស់តុលាការប្រជាជនគឺតុលាការផ្តល់ឱកាសឲ្យជនរងគ្រោះធ្វើការរៀបរាប់បញ្ជាក់អំពីការខូចខាតបាត់បង់ទ្រព្យសម្បត្តិនិងសាច់ញាតិរបស់ខ្លួនជូនតុលាការ ។ នៅពេលបញ្ចប់សវនាការជំនុំជម្រះ ជនរងគ្រោះទទួលបានលិខិតទទួលស្គាល់ការខូចខាតជាផ្លូវការពីតុលាការ ហើយជនរងគ្រោះអាចប្រើប្រាស់លិខិតនេះដើម្បីបើកប្រាក់សំណងអំពីមូលនិធិសាធារណៈ ។

គ) ចំណុចខ្លាំងនិងចំណុចខ្សោយ

បំណងរបស់រដ្ឋាភិបាលរ៉្វាន់ដាដែលសម្រេចយកប្រព័ន្ធយុត្តិធម៌សម័យបុរាណ ហៅថា តុលាការប្រជាជន ឬ កាឆាឆា មកប្រើប្រាស់សម្រាប់ដោះស្រាយជម្លោះនាបច្ចុប្បន្ននេះមានដូចខាងក្រោម ÷

១) ដើម្បីស្វែងរកការពិតអំពីអ្វីដែលបានកើតឡើងក្នុងរបបប្រល័យពូជសាសន៍នៅប្រទេសរ៉្វាន់ដា ។

២) ដើម្បីជំរុញដំណើរការជំនុំជម្រះក្តីរបស់ជនជាប់ចោទឲ្យលឿនទៅមុខ ។

៣) ដើម្បីលុបបំបាត់វប្បធម៌លើកលែងទោស ។

៤) ផ្សះផ្សាបង្រួបបង្រួមប្រជាជនរ៉្វាន់ដាឲ្យជានានឹងគ្នាឡើងវិញ ។

៥) ក្រើនរំឭកប្រជាជនអំពីវប្បធម៌ និងយុត្តិធម៌នៅសម័យបុរាណរបស់ប្រទេសរ៉្វាន់ដា ។

៦) ដើម្បីជាការបញ្ជាក់ថា ប្រជាជនមានសមត្ថភាពដើម្បីដោះស្រាយជម្លោះដោយខ្លួនឯង ។

តុលាការប្រជាជនមានលទ្ធភាពសម្រេចតាមបំណងខាងលើនិងជួយឲ្យមានការផ្សះផ្សាបង្រួបបង្រួមនៅប្រទេសរ៉្វាន់ដាជាជាងតុលាការព្រហ្មទណ្ឌអន្តរជាតិ ។ តុលាការប្រជាជនមានចំនួនមួយម៉ឺន ហើយស្ថិតនៅគ្រប់ទីកន្លែងទូទាំងប្រទេស ដូច្នេះតុលាការនេះអាចជំនុំជម្រះក្តីបានលឿន ។ តុលាការប្រជាជនបានកើតតាំងពីសម័យបុរាណ ដូច្នេះប្រជាជនយល់ដឹងនិងគាំទ្រតុលាការនេះ ។ ការចូលរួមរបស់ប្រជាជនអាចធ្វើឲ្យមានការពិភាក្សា ធ្វើឲ្យប្រជាជនមានអារម្មណ៍ធូរស្បើយ យល់ព្រមអធ្យាស្រ័យឲ្យគ្នាទៅវិញទៅមក ។ ការនាំជនជាប់ចោទវិលត្រឡប់ទៅជំនុំជម្រះក្តីនៅទីកន្លែងដែលឧក្រិដ្ឋជនបានប្រព្រឹត្តអំពើឧក្រិដ្ឋកម្ម គឺជាការលើកតម្កើងសិទ្ធិនិងទឹកចិត្តដល់ជនរងគ្រោះ ។ ដំណើរការរបស់តុលាការប្រជាជន ទាំងការសារភាពនិងការដាក់ទោស អាចជួយឲ្យមានការអភិវឌ្ឍន៍ភូមិស្រុក និងបង្ហាញអ្នកភូមិអំពីអ្វីដែលបានកើតឡើង ។ អ្នកទោសដែលប្រព្រឹត្តខុសហើយយល់ព្រមសារភាពកំហុស នឹងត្រូវបានដោះលែងឲ្យមានសេរីភាពវិលត្រឡប់ទៅជួបជុំគ្រួសារវិញ ។

ព្យែរ៉េត មុកាមូរិនហ្គូ មានទឹកចិត្តរីករាយចំពោះតុលាការប្រជាជន ។ មុកាមូរិនហ្គូ ត្រូវអ្នកជិតខាងចោទប្រកាន់ថាបានចូលរួមប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ដូច្នេះនាងត្រូវបានចាប់ខ្លួននិងឃុំឃាំងអស់រយៈពេល៦ឆ្នាំ ។ កាលនោះនាងមានអាយុ១៦ឆ្នាំ ។ នាងរៀបរាប់ឲ្យដឹងថា «ខ្ញុំមិនបានប្រព្រឹត្តអំពើ

ខក្រិដ្ឋទេ ។ ខ្ញុំពិតជាមិនដឹងថាត្រូវសារភាពរឿងអ្វីឡើយ ។ ខ្ញុំជាមនុស្សស្អាតស្អំ ។ បាតដៃខ្ញុំអត់មានប្រឡាក់ឈាមអ្នកណាទេ ។ រដ្ឋាភិបាលក៏ដឹងហើយទទួលស្គាល់រឿងនេះដែរ ។ មិនមែនអ្នកជាប់ឃុំឃាំងទាំងអស់សុទ្ធតែបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍នោះទេ» ។ មុកាមូរិនហ្គូ បង្ហាញមុខក្នុងពេលជំនុំជម្រះរបស់តុលាការប្រជាជនក្នុងជំហានសាកល្បង ។ អ្នកភូមិជឿនាងហើយបានយល់ព្រមដោះលែងនាងឲ្យមានសេរីភាព ។ ករណីខាងលើនេះក៏បានកើតឡើងនៅក្នុងសវនាការរបស់តុលាការប្រជាជននៅ ហ្គិសេវ៉ូ ដែរ ។ នៅទីនោះ អ្នកភូមិជាជនជាតិទុតស៊ី បានជួយការពារនិងយល់ព្រមឲ្យតុលាការដោះលែងជនជាប់ចោទហ៊ូទូ ។

ទោះបីជាយ៉ាងណាក៏ដោយ ប្រជាជនរ៉ាន់ដាមួយចំនួនមិនសប្បាយចិត្តចំពោះប្រព័ន្ធតុលាការប្រជាជនឡើយ ។ ដេនវៀ បូនីហ្វ៊ីម៉ាណា សព្វថ្ងៃជាអ្នកបើករថយន្តតាក់ស៊ី បានបាត់បង់ឪពុកម្តាយ បងប្អូន៣នាក់ និងប្អូនស្រីម្នាក់ ។ បូនីហ្វ៊ីម៉ាណា បានថ្លែងថា តុលាការប្រជាជនបង្កើតឡើងគឺសម្រាប់ជួយខក្រិដ្ឋជនប្រល័យពូជសាសន៍ឲ្យគេចផុតពីមន្ទីរឃុំឃាំង ។ មនុស្សចាស់សម័យបុរាណប្រើប្រាស់តុលាការប្រជាជនដើម្បីជំនុំជម្រះក្តីតូចតាច ដូចជាករណីលួចគោក្របីជាដើម ។ ការយកតុលាការប្រជាជនមកអនុវត្តចំពោះបទខក្រិដ្ឋប្រល័យពូជសាសន៍គឺពិតជាមិនត្រឹមត្រូវឡើយ ។ បូណាវិនធើ នីទីប៊ីហ្វ៊ី យល់ស្របជាមួយបូនីហ្វ៊ីម៉ាណា ដែរ ។ ចំពោះ នីទីប៊ីហ្វ៊ី តុលាការប្រជាជនគឺជាឆាកល្ខោនដែលរៀបចំសម្តែងដោយប្រជាជនសញ្ជាតិហ៊ូទូដើម្បី «ដោះលែងប្រជាជនសញ្ជាតិហ៊ូទូដែលមានកំហុសឲ្យគេចផុតពីមន្ទីរឃុំឃាំង» ។

ប្រជាជនមួយចំនួនទៀតមិនគាំទ្រតុលាការប្រជាជន ដោយពន្យល់ថា តុលាការនេះអាចបង្កឲ្យមានភាពស្មុគស្មាញនៅក្នុងភូមិ ។ ឧទាហរណ៍ ស្ត្រីមេម៉ាយចាស់ជរាដែលគេចផុតពីការសម្លាប់ នឹងមានការភិតភ័យម្តងទៀតដោយសារតែតុលាការដោះលែងខក្រិដ្ឋជនឲ្យវិលត្រឡប់ទៅរស់នៅក្នុងភូមិស្រុកជាមួយគាត់វិញ ។ អាល់ហ្វុសិន វីម៉ាណា ជាស្ត្រីមេម៉ាយដែលបាត់បង់ប្តីនិងកូននៅក្នុងរបបប្រល័យពូជសាសន៍បានរៀបរាប់ដូចខាងក្រោម ÷

«មានរឿងច្រើនដែលខ្ញុំមិនអាចបំភ្លេចបាន ។ ខ្ញុំបានដឹងរឿងជាច្រើនដូចជាការរំលោភលើរូបរាងកាយស្ត្រីទាំងចាស់ទាំងក្មេង ។ ប្រសិនបើរឿងនេះវាកើតឡើងលើរូបអ្នកវិញ ហើយឥឡូវអ្នកធ្វើបាបយើងវិលត្រឡប់មករស់នៅក្នុងភូមិស្រុកជាមួយយើងវិញ ចុះបើថ្ងៃណាមួយមនុស្សម្នាក់នោះផឹកស្រាហើយស្រវឹង រួចដើរនិយាយប្រាប់គេឯងពេញភូមិថា គាត់បានរំលោភអ្នកឯង តើអ្នកគិតយ៉ាងម៉េច? គេថាតុលាការប្រជាជនអាចជួយប្រជាជន តើវាជួយអ្វីកើតទៅ?»

អ្នកជំនាញការបរទេសនិងក្រុមឃ្លាំមើលអំពីសិទ្ធិមនុស្សបានរិះគន់ភាពលម្អៀងរបស់តុលាការប្រជាជន ។ ជនរងគ្រោះខ្លះមិនចាប់អារម្មណ៍ និងមិនជឿថាតុលាការប្រជាជនអាចធ្វើឲ្យខ្លួនលាតត្រដាងនូវការពិតហើយអាចផ្សះផ្សាបង្រួបបង្រួមរវាងជនរងគ្រោះនិងជនដៃដល់បានឡើយ ។ ប្រជាជនបារម្ភថាការពិតនៅតែមិនអាចដឹង ដោយសារចៅក្រមមិនអព្យាក្រឹតហើយគ្មានចំណេះដឹងផ្នែកច្បាប់ច្បាស់លាស់ ។ ជនរងគ្រោះឈ្មោះ ថឺរេសា វិនហ្គាប៊ីយេ បាត់បង់កូនប្រុសចំនួន៣នាក់និងកូនស្រីម្នាក់បានរៀបរាប់ឲ្យដឹងថា «ខ្ញុំមិនជឿថាចៅក្រមអព្យាក្រឹតទេ ។ បើខក្រិដ្ឋជនជាសាច់ញាតិរបស់ចៅក្រមនោះ ចៅក្រមពិតជាមិនអាចរកយុត្តិធម៌រកសខ្មៅឃើញឡើយ» ។ មូកាសេរូក៏គ្មានជំនឿលើតុលាការប្រជាជននិងចៅក្រមដែរ ។ មូកាសេរូលើកឡើងអំពីករណីក្នុងគ្រួសារក្មួយរបស់នាងថា សមាជិកគ្រួសារនោះស្លាប់ទាំងអស់នៅសល់តែក្មួយប្រុសរបស់នាងម្នាក់អាយុ១៣ឆ្នាំប៉ុណ្ណោះ ។ នាងបារម្ភទីមួយខ្លាចក្មួយប្រុសរបស់នាងមិនហ៊ាននិយាយរៀបរាប់រឿងដែលកើតឡើងប្រាប់តុលាការ ។ ទីពីរនាងខ្លាចតុលាការនិងចៅក្រមមិនជឿក្មួយរបស់នាង ។ «ចុះបើមានករណីបែបនេះ បើយើងនៅសល់តែក្មេងម្នាក់ជាសាក្សី អ្នកដទៃទៀតគឺជាសាច់ញាតិរបស់ឃាតករ ហើយអះអាងថាឃាតករគ្មានកំហុស តើរឿងហ្នឹងវាទៅជាយ៉ាងណា?» ។

ការមិនទុកចិត្តនិងក្តីបារម្ភរបស់ប្រជាជនអំពីភាពមិនលម្អៀងរបស់ចៅក្រម ការពិតច្បាប់របស់តុលាការប្រជាជនបានកំណត់និងចែងដើម្បីទប់ទល់យ៉ាងច្បាស់ ។ អាន់តូនី រូប៊ូរីកា តំណាង

ក្រសួងយុត្តិធម៌ បានពន្យល់អំពីវិធានការចំពោះភាពលម្អៀងថា ÷

“ជនរងគ្រោះគិតថា គាត់នឹងត្រូវតុលាការសួរនាំសព្វគ្រប់អំពីអ្វីដែលបានកើតឡើង ។ ការពិតយើងដឹងថាគាត់មិនដឹងរឿងទាំងអស់ច្បាស់លាស់ទេ ព្រោះគាត់រត់គេចខ្លួនពីការសម្លាប់ ។ អ្វីដែលយើងត្រូវការពីគាត់គឺព័ត៌មានដែលគាត់ដឹងតែប៉ុណ្ណោះ មិនមែនរឿងតាំងពីដើមដល់ចប់ឡើយ ។ ពេលបានដឹងព័ត៌មាន យើងនិងសួរឧក្រិដ្ឋជនឲ្យឆ្លើយសារភាព ។”

វិធានការផ្សេងទៀតរបស់រដ្ឋាភិបាលរួមមាន ទីមួយ ការបង្ហាត់បង្រៀនអំពីក្រមសីលធម៌ដល់ចៅក្រមទាំងពីរម៉ឺនប្រាំមួយពាន់នាក់បន្ទាប់ពីត្រូវបានជ្រើសរើស ។ ទីពីរ គឺមាត្រាទី៤២ នៃច្បាប់របស់តុលាការប្រជាជន បើកផ្លូវបណ្តឹងឧទ្ធរណ៍ថ្នាក់ខេត្តបន្តទៀតក្នុងករណីមានការសង្ស័យឬមិនពេញចិត្តចំពោះការជំនុំជម្រះ ។ ជាមួយគ្នានេះ មាត្រាទី១៦និង៥០នៃច្បាប់ក៏បានចែងទប់ស្កាត់ភាពមិនអព្យាក្រឹតរបស់ចៅក្រមដែរ ។ ឧទាហរណ៍ មាត្រាទី១៦កំណត់ថា ករណីចៅក្រមនិងឧក្រិដ្ឋជនគឺជាសាច់ញាតិនឹងគ្នា ការជំនុំជម្រះក្តីត្រូវផ្ទេរទៅធ្វើនៅកន្លែងដែលមានភាពអព្យាក្រឹត ។ ជាពិសេស មាត្រាទី៥០បានចែងច្បាស់ថា ក្នុងករណីមានភាពមិនប្រក្រតីកើតឡើង ក្រុមជំនួយការច្បាប់នឹងពិនិត្យនិងសម្រេចលើសំណុំរឿងនោះ ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ចេនឌី ដៀមួយូ បន្ថែមថា “គ្រប់ករណីដែលមិនពេញចិត្ត ប្រជាជនអាចប្តឹងឧទ្ធរណ៍បាន” ។

អត្ថបទសិក្សាអំពីការផ្សះផ្សាបង្រួបបង្រួមជាច្រើនបានសរសេរថា ការផ្សះផ្សាបង្រួបបង្រួមមិនមែនជាលទ្ធផលដែលងាយមើលឃើញឡើយ ។ ការផ្សះផ្សាបង្រួបបង្រួមគឺជាការស្វែងរកដែលទាមទារការប្តេជ្ញាចិត្តនិងកិច្ចសហការ ។ ប៉ុន្តែ ដៀមួយូ ហាក់ដូចជាពេញចិត្តយ៉ាងខ្លាំងចំពោះដំណើរការរបស់តុលាការប្រជាជន ។ ដោយសារទីមួយតុលាការនេះអាចជួយដោះស្រាយបញ្ហាជនជាប់សង្ស័យដែលកំពុងជាប់ឃុំឃាំង និងទីពីរអាចនាំឲ្យប្រទេសរ៉្វាន់ដាមានសន្តិភាពក្នុងរយៈពេលពី៣ទៅ៥ឆ្នាំខាងមុខ ។

បទពិសោធន៍និងមេរៀនដែលកើតឡើងនៅប្រទេសរ៉្វាន់ដា បញ្ជាក់ច្បាស់ថា យុត្តិធម៌តាមផ្លូវតុលាការតែមួយមិនគ្រប់គ្រាន់សម្រាប់នាំមកនូវការផ្សះផ្សាបង្រួបបង្រួមឡើយ ។ តាមការបង្ហាញនិងឧទាហរណ៍ខាងលើ គឺការស្វែងរកយុត្តិធម៌មានភាពស្មុគស្មាញ ហើយតែងតែមានផលប៉ះពាល់លើធាតុផ្សេងៗទៀត ។ សន្តិភាពនិងការបង្រួបបង្រួមជាតិពិតប្រាកដសម្រាប់ប្រទេសរ៉្វាន់ដាត្រូវការជាចាំបាច់នូវការព្យាបាលរបួសផ្លូវចិត្ត និងការជឿទុកចិត្តគ្នាឡើងវិញ ។ ជនជាតិទុតស៊ីដែលនៅរស់ត្រូវតែមានជំនឿចិត្តលើជនជាតិហ៊ូទូដែលវិលត្រឡប់មករស់នៅក្នុងភូមិស្រុកជាមួយពួកគាត់ម្តងទៀត ។ ចំណែកជនជាតិហ៊ូទូត្រូវផ្តាច់ខ្លួនឲ្យផុតពីភាពដែលកំណត់ខ្លួនឯងថាជាផ្នែកមួយនៃអំពើប្រល័យពូជសាសន៍ ហើយជឿថាជនជាតិទុតស៊ីពិតជាមិនធ្វើការសងសឹកមកលើខ្លួននិងក្រុមគ្រួសារឡើយ ។ តុលាការប្រជាជនហាក់ដូចជាមានតួនាទីសំខាន់ក្នុងការកសាងទំនុកចិត្តរបស់ប្រជាជនឡើងវិញ ។ បច្ចុប្បន្ននេះតុលាការប្រជាជនកំពុងដំណើរការ ដូច្នេះក្តីសង្ឃឹមថាប្រជាជននិងប្រទេសជាតិពិតជាអាចឆ្លងផុត និងធ្វើដំណើរទៅរកភាពសុខដុមរមនានាពេលអនាគតខាងមុខ គឺអាស្រ័យទាំងស្រុងលើការជឿនិងចូលរួមរបស់ប្រជាជននៅក្នុងដំណើរការនេះ ។

**អៀ ម៉េងទ្រី**

# សេចក្តីជូនដំណឹង

សមាគមអ្នកនិពន្ធខ្មែរសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងសូមជម្រាបជូនដំណឹងដល់ម្ចាស់អត្ថបទដែលបានផ្ញើអត្ថបទមកសមាគមអ្នកនិពន្ធខ្មែរដើម្បីចូលរួមក្នុង “វេទិកាថែរក្សាប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ” ឲ្យបានជ្រាបថា គណៈកម្មការកំណែកំពុងតែពិនិត្យនិងវាយតម្លៃស្នាដៃនីមួយៗ ។ ចំពោះលទ្ធផលសម្រេច សមាគមអ្នកនិពន្ធខ្មែរនឹងជូនដំណឹងនៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៣ ។ សូមអរគុណ ។

**យូ ប៊ូ**

**ប្រធានសមាគមអ្នកនិពន្ធខ្មែរ**

# ខ្ញុំមិនចង់ជួប

ខ្ញុំជាកូនច្បងនៅក្នុងគ្រួសារមួយដែលសមាជិក៦នាក់ៈ លោកយាយរបស់ខ្ញុំ ម៉ាក់របស់ខ្ញុំ ខ្លួនខ្ញុំ និងប្អូនស្រីប្រុសរបស់ខ្ញុំ៣នាក់ (ប៉ារបស់ខ្ញុំស្លាប់នៅឆ្នាំ១៩៨៩) ។ ម៉ាក់របស់ខ្ញុំជាអាជីវករ ។ ប្អូនៗរបស់ខ្ញុំនៅរៀននៅឡើយ ។ ក្នុងជីវភាពដ៏សមរម្យ យើងទាំងអស់គ្នារស់នៅប្រកបដោយសុភមង្គលនិងឯករាជ្យភាព ។ លោកយាយនិងម៉ាក់ស្រលាញ់ថ្នាក់ថ្នមនិងមានព្រហ្មវិហារធម៌ចំពោះកូនចៅជានិច្ច ។ តាំងពីតូចរហូតដល់ពេលនេះដែលខ្ញុំមានអាយុ២៣ឆ្នាំ ខ្ញុំមិនដែលស្គាល់ការលំបាកវេទនាឬភាពអត់ឃ្លានសោះឡើយ ។ ផ្ទុយពីខ្ញុំ, ម៉ាក់ ប៉ា អ៊ំ ពូ មីង និងលោកយាយលោកតារបស់ខ្ញុំ សុទ្ធតែធ្លាប់ឆ្លងកាត់របបខ្មែរក្រហម ធ្លាប់ជួបប្រទះនឹងការងារធ្ងន់ធ្ងរហួសប្រមាណ ភាពអត់ឃ្លាន ជំងឺដ៏កាចសាហាវ ការបង្ខិតបង្ខំបំបិទសិទ្ធិសេរីភាព និងភាពរន្ធត់តក់ស្លុតចំពោះការយកមនុស្សទៅសម្លាប់ដោយគ្មានកំហុស ។

មុនឆ្នាំ១៩៧៥ក្រុមគ្រួសាររបស់ម៉ាក់រស់នៅភូមិព្រែកក្តាម ឃុំកំពង់ហ្លួង ស្រុកពញាឮ ខេត្តកណ្តាល ។ ម៉ាក់មានបងប្អូនប្រាំនាក់ ក្នុងនោះមានស្រី៤នាក់និងប្រុសម្នាក់ ។ ប្អូនប្រុសរបស់ម៉ាក់ឈ្មោះ គីយ៉ា បានស្លាប់នៅ១៩៧៣ នៅពេលដែលគាត់ចូលធ្វើពេទ្យទាហាន ។ នៅឆ្នាំ១៩៧២ក្រុមគ្រួសាររបស់ម៉ាក់បានភៀសខ្លួនមករស់នៅគីឡូម៉ែត្រលេខ៦ ។ ម៉ាក់បានធ្វើការនៅក្នុងរោងចក្រតម្បាញមួយឈ្មោះ រោងចក្រត្រាំងអ៊ិច ។ ម៉ាក់ធ្វើការនិងស្នាក់នៅក្នុងរោងចក្រនោះរហូត ។ ម៉ាក់បាននិយាយប្រាប់ខ្ញុំថា នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ក្នុងពេលដែលខ្មែរក្រហមវាយដណ្តើមកាន់កាប់បានទីក្រុងភ្នំពេញ ម៉ាក់កំពុងតែធ្វើការនៅក្នុងរោងចក្រនៅឡើយ ។ កងទ័ពខ្មែរក្រហមជាច្រើននាក់ដែលមានសម្លៀកបំពាក់ពណ៌ខ្មៅនិងកាន់កាំភ្លើងគ្រប់ដៃបានសម្រុកចូលក្នុងរោងចក្រ ហើយស្រែកបង្ខំឲ្យអ្នកធ្វើការនៅក្នុងរោងចក្រចាកចេញជាបន្ទាន់ ។ ស្របពេលជាមួយគ្នានោះ ខ្មែរក្រហមកំពុងតែជម្លៀសប្រជាជនឲ្យចេញពីទីក្រុងភ្នំពេញដែរ ដោយមិនអនុញ្ញាតឲ្យសួរនាំតវ៉ាឬមានប្រតិកម្មអ្វីទាំងអស់ បើពុំនោះសោតនឹងត្រូវវាយធ្វើបាបឬសម្លាប់ចោលនៅនឹងកន្លែង ។ អ្នកខ្លះភ័យខ្លាចខ្លាំងពេកទៅជាភាន់ភាំងគ្មានបានយកអ្វីទៅជាមួយទាល់តែសោះ ។ មនុស្សទាំងអស់ត្រូវបង្ខំឲ្យទៅរស់នៅទីជនបទដាច់ស្រយាល ។

ម៉ាក់និងក្រុមគ្រួសារបានធ្វើដំណើរទៅស្រុកកំណើតនៅភូមិព្រែកក្តាម ឃុំកំពង់ហ្លួង ស្រុកពញាឮ ខេត្តកណ្តាល ។ ចំណែកប្អូនស្រីរបស់គាត់ឈ្មោះ អៃសាស់ ដែលមានប្តីជាទាហានកុម្មុយនិស្ត បានទៅតាមគ្រួសាររបស់ប្តីឆ្ពោះទៅខេត្តកំពង់ចាម ។ ម៉ាក់និងក្រុមគ្រួសារស្នាក់នៅស្រុកកំណើតបានតែ៣ថ្ងៃប៉ុណ្ណោះក៏ត្រូវខ្មែរក្រហមជម្លៀសទៅវត្តស្ពឺស្ថិតក្នុងខេត្តកំពង់ចាម ហើយនៅបានតែ១ថ្ងៃ ខ្មែរក្រហមបានជម្លៀសទៅវត្តឫស្សីកែវ ស្ថិតក្នុងខេត្តក្រចេះបន្តទៀត ។ នៅទីនោះបាន៣ថ្ងៃ បងស្រីរបស់ម៉ាក់ឈ្មោះ រីយ៉ា ប្រសូត្របានកូនប្រុសម្នាក់ ។ ពីរថ្ងៃក្រោយមកម៉ាក់និងក្រុមគ្រួសារត្រូវបង្ខំឲ្យធ្វើដំណើរបន្តទៅទៀត លើកលែងតែបងស្រីរបស់ម៉ាក់និងកូនដែលទើបប្រសូត្រព្រមទាំងគ្រួសាររបស់គាត់ប៉ុណ្ណោះ ដែលទទួលការអនុញ្ញាតឲ្យស្នាក់នៅទីនោះសិន ។ បងស្រីរបស់ម៉ាក់បានផ្ញើកូនច្បងរបស់គាត់ពីរនាក់(ស្រី១ ប្រុស១)ទៅ ជាមួយម៉ាក់ដែរ ។

ម៉ាក់ត្រូវបានជម្លៀសតាមរទេះគោទៅឃុំសោប ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ ។ នៅតាមផ្លូវ អ្នកបររទេះឈ្មោះ តាហេ (ជាប្រជាជនមូលដ្ឋាន) បានលួចខ្សឹបប្រាប់ម៉ាក់ឲ្យប្រយ័ត្នពាក្យសម្តី ព្រោះខ្មែរក្រហមបញ្ជូនគាត់ឲ្យមកស៊ើបអំពីក្រុមគ្រួសាររបស់ម៉ាក់ ជាពិសេសគឺម៉ាក់តែម្តង ។ គាត់ប្រាប់ទៀតថា បើអង្គការឲ្យធ្វើអ្វីត្រូវតែធ្វើតាមកុំប្រកែកឲ្យសោះ ។ ម៉ាក់និងក្រុមគ្រួសារភិតភ័យខ្លាំងណាស់ក្រោយពីបានឮរឿងនេះ ។ ទៅដល់ខេត្តក្រចេះភ្លាម ខ្មែរក្រហមបានឲ្យក្រុមគ្រួសាររបស់ម៉ាក់ព្រមទាំងក្រុមគ្រួសារដទៃប្រមាណ១០គ្រួសារទៀតទៅរស់នៅក្នុង

រោងបាយចាស់មួយដែលត្រូវបោះបង់ចោល ។ បន្ទាប់មក គាត់ទាំងអស់គ្នាត្រូវខ្មែរក្រហមបង្ខំឲ្យទៅធ្វើស្រែចម្ការ ។ កន្លងបានជិត១ខែ ខ្មែរក្រហមបានហៅប្រជាជនទៅប្រជុំ ហើយក៏លើកនិយាយពីរឿងសាសនា ។ តាំងពីពេលនោះមកការប្រតិបត្តិសាសនាត្រូវហាមឃាត់ មិនអនុញ្ញាតឲ្យជនជាតិចាមសំយ៉ាង (ថ្វាយបង្គំ) បួស ព្រមទាំងបំផ្លាញចោលអស់នូវគម្ពីរគីតាបគូរ៉ាន និងបង្ខំឲ្យស្ត្រីកាត់សក់ខ្លី ហើយឲ្យជនជាតិចាមដូរឈ្មោះ ។ ម៉ាក់ឈ្មោះ ហាលីម៉ាស់ ត្រូវដូរទៅជា លី វិញ ។ ដោយសារតែការភ័យខ្លាចព្រមទាំងនឹកទៅដល់សម្តីរបស់ តាហេ (អ្នកបរទេះ) ម៉ាក់និងក្រុមគ្រួសារបង្ខំចិត្តធ្វើតាមអង្គការវិន័យ ។ ម៉ាក់ចង់លួចសំយ៉ាងនិងបួសខ្លាំងណាស់ ប៉ុន្តែខ្លាចខ្មែរក្រហមដឹង ។ អ្វីដែលម៉ាក់មិនអាចបំភ្លេចបាននោះគឺខ្មែរក្រហមបង្ខំឲ្យគាត់និងបងប្អូនចាមដទៃទៀតទទួលទានសាច់ជ្រូក ។ ពេលនោះដើម្បីរក្សាជីវិតឲ្យរស់ គាត់ទាំងអស់គ្នាសុខចិត្តទទួលទានសាច់ជ្រូក ។ ប្រមាណ១ខែក្រោយមក បងស្រីរបស់ម៉ាក់ដែលឆ្លងទន្លេនៅវត្តឫស្សីកែវ បានធ្វើដំណើរមកជួបជុំជាមួយម៉ាក់និងក្រុមគ្រួសារវិញ ។ ជារៀងរាល់ថ្ងៃ ខ្មែរក្រហមបានចែករបបអង្ករឲ្យកន្ទះកំប៉ុងសម្រាប់មនុស្សម្នាក់ ជួនកាលមានលាយគ្រាប់ពោតផង ។ សុខភាពរបស់ម៉ាក់ចាប់ផ្តើមចុះខ្សោយ រាងកាយរបស់ម៉ាក់ស្គមទៅៗជាលំដាប់ ។


ឪពុកម្តាយរបស់ ហ៊ុវីណា ក្នុងឆ្នាំ១៩៨២

រស់នៅឃុំសោបបានរយៈពេលប្រហែល១ឆ្នាំខ្មែរក្រហមចាប់ផ្តើមរើសកងចល័ត ។ សមាជិកកងចល័តត្រូវតែជាអ្នកពេញវ័យនិងនៅលីវ (ទាំងស្រីទាំងប្រុស) ។ ម៉ាក់ក៏ត្រូវបានជ្រើសរើសចូលក្នុងកងចល័តហើយត្រូវបំបែកចេញពីក្រុមគ្រួសារ ។ កងចល័តត្រូវទៅធ្វើការនៅជិតព្រៃស្រោងចម្ងាយប្រមាណ១៥គីឡូម៉ែត្រពីភូមិ ។ ការងាររបស់ម៉ាក់គឺជីកស្ទូងវែកដី និងលើកទំនប់ដែលធំបំផុតទូទាំងស្រុកព្រែកប្រសព្វ ឈ្មោះទំនប់អាលំញ៉ោដោយខ្មែរក្រហមបានប្រមូលកងចល័តពីគ្រប់ភូមិឃុំ មកលើកទំនប់នេះ ។

ម៉ាក់ត្រូវធ្វើការទាំងយប់ទាំងថ្ងៃគ្មានពេលសម្រាកឡើយ លើកលែងតែពេលហូបបាយ ។ របបអាហារមាន២ពេល គឺម៉ោង១១ថ្ងៃត្រង់និងម៉ោង៥ល្ងាច ។ អាហារមានតែបបររាវ ជួនកាលមានបាយម្តងម្កាលដែរ (ពេលណាដែលមេកងសប្បាយចិត្ត) ។ នៅក្នុងកងរបស់ម៉ាក់ អ្នកដែលត្រូវរកឃើញថាជាអតីតមន្ត្រីនៃរបបចាស់ សិស្សនិស្សិត បញ្ញវន្ត ឬមានជាប់ពាក់ព័ន្ធនឹងនិន្នាការរបបមុន ត្រូវយកទៅសម្លាប់ចោលនៅជើងទំនប់ទាំងអស់ ។

នៅឆ្នាំ១៩៧៧ (លើកទំនប់មិនទាន់ចប់) អង្គការបានដកកងចល័តរបស់ម៉ាក់ទៅធ្វើការនៅស្រុកអាទេះ (ជាប់ព្រំប្រទល់ខេត្តកំពង់ធំ) វិញ ។ ទៅទីនោះមានសភាពស្ងាត់ជ្រងំ មានតែផ្ទះប៉ុន្តែគ្មានមនុស្សរស់នៅ ។ ក្រៅពីអ្នកដាំបាយ៥នាក់ដែលបន្តរស់នៅក្នុងភូមិប្រជាជនដទៃទៀត បានផ្លាស់ប្តូរទីលំនៅទៅកន្លែងផ្សេង គ្មានសល់ដោយសារទីនោះជាតំបន់ចាញ់ខ្លាំង ។ ក្នុងកងចល័តនីមួយៗប្រជាជនចាស់ត្រូវដកចេញលើកលែងតែមេកង ។ ការងារលំបាកជាងនៅការដ្ឋានទំនប់អាលំញ៉ោ ហើយរបបអាហារក៏កាន់តែតិចទៅៗ ។ ម៉ាក់និងអ្នកនៅក្នុងកងចល័តស្ទើរតែពាក់កណ្តាលចាប់ផ្តើមមានជំងឺគ្រុនចាញ់ ។ អ្នកជំងឺទាំងអស់ត្រូវបានបញ្ជូនមកមន្ទីរពេទ្យដែលមានចម្ងាយប្រមាណ៥គីឡូម៉ែត្រពីការដ្ឋាន ។ ជារៀងរាល់ថ្ងៃ អ្នកជំងឺត្រូវបញ្ជូនទៅមន្ទីរពេទ្យជាបន្តបន្ទាប់ ។ សម្រាកនៅមន្ទីរពេទ្យបានប្រហែល

កន្លះខែ ម៉ាក់ក៏ជាសះស្បើយ ហើយវិលត្រឡប់ទៅការដ្ឋានវិញ ។ ម៉ាក់បន្តជីវិតដ៏សែនលំបាកវេទនានៅការដ្ឋាន ស្រុកអាទេះ ។ នៅពេលយប់ព្រៃមានសភាពស្ងាត់ជ្រងំ ឮតែសំឡេងលលកខ្មោច ទីទុយ មៀម យំគួរឲ្យព្រឺខ្លាច ។ រៀងរាល់យប់ថ្ងៃ ម៉ាក់បន់ស្រន់ឲ្យរបបនេះបញ្ចប់ឆាប់ៗ ។ ជាង១ខែក្រោយមក ម៉ាក់បានទទួលការអនុញ្ញាតិឲ្យវិលត្រឡប់មកភូមិវិញ ។ ពេលមកដល់ភូមិអ្នកភូមិប្រាប់ថា ម៉ាក់មានសំណាងណាស់ដែលនៅរស់រានមានជីវិត ព្រោះកន្លែងដែលម៉ាក់ទៅធ្វើការគឺជាកន្លែងលត់ដំដ៏ក្តៅគគុក ។

ក្រោយមកខ្មែរក្រហមបានបញ្ជូនម៉ាក់ទៅលើកទំនប់សង្កាត់នៅភូមិព្រៃករកា ឃុំសោប ស្រុកព្រៃកប្រសព្វ ។ នៅកន្លែងនោះរបបអាហារគ្រាន់បើជាងនៅកន្លែងលត់ដំ ហើយការងារក៏មិនលំបាកវេទនាដូចនៅកន្លែងលត់ដំដែរ ។ លើកទំនប់នៅភូមិព្រៃករកាមិនបានយូរប៉ុន្មានផង អង្គការក៏បញ្ជូនម៉ាក់ទៅដកស្ទូងនៅភូមិបឹងព្រែង ហើយបានប្រហែល២ខែ ម៉ាក់ត្រូវចេញទៅលើកទំនប់ធំម្តងទៀត គឺទំនប់អាលំញោងដែល ។ ពេលនេះហើយដែលខ្មែរក្រហមបានយកមនុស្សទៅសម្លាប់ចោលកាន់តែច្រើនឡើង ។ ម៉ាក់ប្រាប់ថា ខ្មែរក្រហមបានយកមនុស្សទៅសម្លាប់ប្រមាណ ២០នាក់ក្នុងមួយលើក ហើយកប់នៅក្បែរៗទំនប់ ។ សាកសពខ្លះកប់មិនជិតលេចដៃជើងចេញមកក្រៅប្រឡាង ។ អ្នកដែលត្រូវយកទៅសម្លាប់គឺអ្នកដែលត្រូវស៊ើបដឹងថាជាបុគ្គលិកឬមន្ត្រីនៃរបបមុន និស្សិត ឬបញ្ញវ័ន្ត ។ មិត្តភក្តិស្រីម្នាក់របស់ម៉ាក់ឈ្មោះ វីសូនី បានមកយំសោកនៅចំពោះមុខម៉ាក់នៅពេលដែលបងប្រុស ២នាក់របស់គាត់ត្រូវខ្មែរក្រហមសម្លាប់នៅក្បែរដើមគគីរធំមួយជិតទំនប់ ។

នៅពាក់កណ្តាលឆ្នាំ១៩៧៧ ខ្មែរក្រហមបានស្នើឲ្យម៉ាក់រៀបការជាមួយបុរសម្នាក់នៅក្នុងកងចល័តជាមួយគ្នា ប៉ុន្តែម៉ាក់ប្រកែក ។ ក្រោយមក ខ្មែរក្រហមស្នើឲ្យម៉ាក់រៀបការម្តងទៀតជាមួយបុរសផ្សេង ។ ម៉ាក់នៅតែប្រកែក ។ ខ្មែរក្រហមបានគំរាមម៉ាក់ថា បើមិនជ្រើសរើសនរណាម្នាក់ក្នុងចំណោមបុរសទាំង២នោះទេ ម៉ាក់ត្រូវតែទទួលខុសត្រូវនៅពេលដែលមានអ្វីកើតឡើងចំពោះខ្លួនឯង ។ ម៉ាក់ក៏សម្រេចចិត្តជ្រើសរើសបុរសម្នាក់ក្នុងចំណោមបុរសទាំង២ នោះគឺប៉ា ។ ម្តងនេះខ្មែរក្រហមបែរជាបដិសេធមិនឲ្យម៉ាក់រៀបការជាមួយប៉ា (មិនដឹងមូលហេតុអ្វី) ប៉ុន្តែនៅទីបំផុតម៉ាក់ក៏បានរៀបការជាមួយប៉ានៅពាក់កណ្តាលឆ្នាំ១៩៧៨ ។

ប៉ាក៏ជាប្រជាជន១៧មេសាដែរ ។ មុនឆ្នាំ១៩៧៥ ប៉ារស់នៅទីក្រុងភ្នំពេញ ។ ក្នុងពេលដែលប្រជាជនត្រូវជម្លៀសចេញពីទីក្រុងភ្នំពេញ ខ្មែរក្រហមបានចាប់ប៉ាចងស្លាបសេកដោយចោទប៉ាថាជាមន្ត្រីនៃរបបលន់ណុល ។ ខ្មែរក្រហមបានបណ្តើរប៉ានិងប្រជាជនប្រមាណមួយរយនាក់ទៀតទៅដល់រោងចក្រកែវ (ភាគខាងលិចនៃទីក្រុងភ្នំពេញ) ។ ប៉ាបានព្យាយាមលួចស្រាយចំណងដោយខ្លួនឯង បន្ទាប់មកជួយស្រាយចំណងឲ្យអ្នកនៅក្បែរគាត់បាន៧-៨នាក់ ហើយនាំគ្នារត់គេចទៅដល់ស្រុកកញ្ជៀច ខេត្តព្រៃវែង ។ រស់នៅស្រុកកញ្ជៀចបាន៥ខែ ខ្មែរក្រហមបានជម្លៀសប៉ាទៅភូមិសោបលើ ស្រុកព្រៃកប្រសព្វ ខេត្តក្រចេះ ។ ប៉ារស់នៅលាក់ឈ្មោះលាក់ប្រវត្តិរហូតដល់ពាក់កណ្តាលឆ្នាំ១៩៧៨ទើបបានរៀបការជាមួយម៉ាក់ ។

បន្ទាប់ពីរៀបការ ប៉ានិងម៉ាក់បានទទួលការអនុញ្ញាតឲ្យរស់នៅក្នុងភូមិ ហើយ៤ខែក្រោយមករបបខ្មែរក្រហមក៏ត្រូវដួលរំលំ ។ ប៉ាម៉ាក់និងក្រុមគ្រួសារបានធ្វើដំណើរត្រឡប់មកស្រុកកំណើតវិញ ។ នៅតាមផ្លូវ ម៉ាក់បានជួបអ្នកភូមិកំពង់ហ្លួងដែលត្រូវជម្លៀសទៅជាមួយប្អូនស្រីម៉ាក់ (អែសាស់) បានប្រាប់ម៉ាក់ថា អែសាស់ និងក្រុមគ្រួសារខាងប្តី ត្រូវខ្មែរក្រហមសម្លាប់ចោលទាំងអស់បន្ទាប់ពីដឹងថាប្តីរបស់គាត់ជាអតីតទាហានកុម្មុំងជូ ។

បន្ទាប់ពីមរណភាពដោយជំងឺរបស់ប៉ាខ្ញុំនៅឆ្នាំ១៩៨៩ ម៉ាក់មិនរៀបការម្តងទៀតទេ ។ គាត់សុខចិត្តរ៉ាប់រងបន្ទុកដ៏ធ្ងន់ធ្ងរតែម្នាក់ឯងក្នុងការចិញ្ចឹមកូនតូចៗចំនួនបួននាក់ ។ ខ្ញុំពិតជាស្ងើចសរសើរម៉ាក់ណាស់ដែលខំក្រាញនៀលតស៊ូរស់ឆ្លងកាត់របបខ្មែរក្រហម និងជម្នះការលំបាកក្នុងភាពជាស្ត្រីមេម៉ាយដែលត្រូវចិញ្ចឹមកូនតែម្នាក់ឯង ។ ខ្ញុំសូមបន់ស្រន់កុំឲ្យរបបខ្មែរក្រហមកើតមានជាថ្មីម្តងទៀត ។ ខ្ញុំមិនចង់ជួបប្រទះនឹងរបបនេះទេ ហើយក៏មិនចង់ឲ្យកូនខ្មែរជំនាន់ក្រោយៗទៀតជួបប្រទះដែរ ។

**សូ ហ្វារីណា**

# ខ្ញុំជាមនុស្សដែលមានសំណាង

លោកនាយកជាទីគោរពនិងស្រលាញ់រាប់អានដ៏ស្មោះ

ខ្ញុំបានអានស្ទើរតែគ្រប់លេខនូវទស្សនាវដ្តីស្វែងរកការពិតរបស់មជ្ឈមណ្ឌលលោក គ្រប់អត្ថបទដែលបានចុះផ្សាយបានញ៉ាំងទឹកចិត្តរបស់ខ្ញុំឲ្យរំជួលក្តុកក្តួលនិងសង្វេគរកទីដម្រៅគ្មាន ។ និយាយឲ្យចំវាគឺជាទុក្ខសោកមួយនៃការក្រឡេកមើលទៅអតីតកាលនាយុគសម័យដ៏មហាប្រល័យ ដែលរបបមួយបានធ្វើទារុណកម្មយ៉ាងព្រៃផ្សៃមកលើប្រជាពលរដ្ឋខ្លួនឯងយ៉ាងមហាអមនុស្សធម៌ជាទីបំផុត ។ ក្នុងនាមខ្ញុំក៏ជាជនរងគ្រោះម្នាក់ក្រោមរបបកម្ពុជាប្រជាធិបតេយ្យ (ក្រុមគ្រួសាររបស់ខ្ញុំដែលមានសមាជិក៨នាក់ដែលក្នុងនោះឪពុករបស់ខ្ញុំជាគ្រូពេទ្យនៅមន្ទីរពេទ្យព្រះអង្គឌួង និងម្តាយរបស់ខ្ញុំជាគ្រូបង្រៀននៅសាលាពោធិ៍ និងប្អូនតូចៗរបស់ខ្ញុំចំនួន៥នាក់ទៀត ត្រូវបានរបបអង្គការនិយមប្រល័យគ្មានត្រាប្រណីទាំងអស់ នេះមិនទាន់គិតដល់មាមីងនិងបងប្អូនជីដូនមួយចំនួន៣៦នាក់ទៀតផងទេ) ក៏ជាមនុស្សម្នាក់ដែលមានសំណាងជាងគេបានរស់រានមានជីវិតរហូតមកដល់បច្ចុប្បន្ននេះ សូមសម្តែងនូវទឹកចិត្តកតញ្ញូចំពោះសកម្មភាពដែលមិនចេះនឿយណាយរបស់លោក ក្នុងការស្រាវជ្រាវឯកសារនានាពាក់ព័ន្ធនឹងអំពើមនុស្សឃាតដ៏សែនយង់ឃ្នង និងសូមគាំទ្រយ៉ាងពេញទំហឹងចំពោះការបង្កើតតុលាការយុត្តិធម៌មួយ ដើម្បីស្វែងរកយុត្តិធម៌ជូនដល់កូនចៅជនរងគ្រោះនិងមនុស្សជំនាន់ក្រោយឲ្យបានមើលឃើញថាលើលោកយើងនេះមានយុត្តិធម៌ប្រាកដមែន ។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំនិងមានជំនឿជាក់ថា ប្រសិនជាមានតុលាការអព្យាក្រឹតមួយមែននោះ យុត្តិធម៌សម្រាប់ប្រជាជនកម្ពុជាដែលបានស្លាប់និងអ្នកដែលសល់ពីស្លាប់ពិតជានឹងមានន័យត្រចះត្រចង់ជាក់ជាមិនខាន ហើយលើសពីនេះ ប្រជាជនកម្ពុជាទាំងអស់ប្រាកដជាបានដឹងថាតើនរណាជាមេឃាតករពិត? ហើយការប្រល័យពូជសាសន៍ខ្មែរនាសម័យនោះគឺដើម្បីបម្រើផលប្រយោជន៍អ្វី? ដើម្បីមនោគមវិជ្ជាកុម្មុយនិស្តទឹកដីបុរជាតិសាសន៍? ព្រមទាំងអាចស្វែងយល់បានច្បាស់អំពីរបបកុម្មុយនិស្តនិងលទ្ធិប្រជាធិបតេយ្យតើខុសគ្នាយ៉ាងណា?

ឆ្លៀតក្នុងឱកាសទិវាបុណ្យឯករាជ្យជាតិគំរប់៥០ឆ្នាំនេះ ខ្ញុំសូមគោរពជូនពរលោកនាយកព្រមទាំងសហការីរបស់លោកទាំងអស់ដែលបម្រើការក្នុងមជ្ឈមណ្ឌលស្រាវជ្រាវស្វែងរកការពិតកម្ពុជា មានសុខភាពល្អ កម្លាំងមាំមួន និងប្រាជ្ញាឈ្លាសវៃដើម្បីបន្តការងារជាប្រវត្តិសាស្ត្រនេះជាគុណប្រយោជន៍សម្រាប់ប្រជាពលរដ្ឋខ្មែរ ក៏ដូចជាគុណប្រយោជន៍សំរាប់មនុស្សជាតិទូទៅលើពិភពលោកនេះ ។ សូមលោកនាយកមេត្តាទទួលនូវការគោរពរាប់អានដ៏ស្មោះអំពីខ្ញុំបាទ ។

ធ្វើនៅកោះកុង ថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៣

**នាយកមជ្ឈមណ្ឌលភាសាអង់គ្លេសមុនីរ័ត្ន ស្រុកស្មាច់មានជ័យ ខេត្តកោះកុង**

**ម៉ម ផៃប៊ុន ហៅ មុនីរ័ត្ន**

# ស្វែងរកប្អូន

នាងខ្ញុំឈ្មោះ ម៉ាក ឡាយ អាយុ៥៨ឆ្នាំ ឪពុកឈ្មោះ ម៉ាក ម្តាយឈ្មោះ នៅ ។ នាងខ្ញុំមានស្រុកកំណើតនៅភូមិព្រែកបាល័ង្គឆឹង ឃុំត្រើយស្លា ស្រុកស្អាង ខេត្តកណ្តាល សព្វថ្ងៃរស់នៅភូមិឃុំដដែល ។ នាងខ្ញុំសូមសួររកប្អូនពីរនាក់ ទីមួយឈ្មោះ ស្តើង សុខា ភេទស្រី ទីពីរឈ្មោះ ស្តើង សុខន ។ អ្នកទាំងពីរបានបាត់ខ្លួននៅក្នុងរបបខ្មែរក្រហម តាំងពីពេលដែលអង្គការឲ្យទៅធ្វើការនៅរោងចក្រក្តារបន្ទះ ។ បើប្អូនទាំងពីរបានទទួលដំណឹងហើយ ឬអស់លោកណាបានស្គាល់ឈ្មោះទាំងពីរខាងលើនេះ សូមមេត្តាទាក់ទងមកនាងខ្ញុំនៅភូមិឃុំខាងលើ ឬទាក់ទងតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជា ប្រអប់សំបុត្រលេខ១១១០ ភ្នំពេញ ទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារលេខ (៨៥៥) ២៣ ២១០ ៣៥៨ ឬ Email: dccam@online.com.kh ដោយក្តីអនុគ្រោះ ។ សូមអរគុណ ។

ជនរងគ្រោះនៅមន្ទីរស-២១



ដើម្បីឧបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំនៅទូទាំងព្រះរាជាណាចក្រកម្ពុជា
ទស្សនាវដ្តីចំនួន១០០០ច្បាប់ ជារៀងរាល់លេខនឹងដាក់លក់តែនៅក្នុងរាជធានីភ្នំពេញប៉ុណ្ណោះ មួយច្បាប់តម្លៃ ៧០០០រៀល

មជ្ឈមណ្ឌលឯកសារកម្ពុជាអំពាវនាវដល់រដ្ឋាភិបាល មូលនិធិនានា និងសាធារណជនគ្រប់រូប សូមជួយឧបត្ថម្ភការបោះពុម្ពផ្សាយទស្សនាវដ្តីនេះទៅតាមលទ្ធភាពដែលអាចធ្វើបាន។ ព័ត៌មានបន្ថែមចំពោះការបោះពុម្ពផ្សាយទស្សនាវដ្តីស្វែងរកការពិត សូមមេត្តាទាក់ទងមកកាន់នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ!

The Documentation Center of Cambodia would like to appeal to governments, foundations and individuals for support of the publication, *Searching for the Truth*. To contribute, please phone (855) 23 211 875 or Email: dccam@online.com.kh. Thank you.

**A magazine of the Documentation Center of Cambodia: *Searching for the Truth*. Number 47, November 2003.**
**Funded by Norway, Sweden, Switzerland, the Netherlands, Canada and USA.**